# បទពិសោធន៍ពីសវនាការជំនុំជម្រះក្តី “ឌុច”

## របាយការណ៍លម្អិតស្តីពីសវនាការសំណុំរឿងក្តីទីមួយក្នុង
## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ដោយក្រុមឃ្លាំមើលដំណើរការសាលាក្តីខ្មែរក្រហម**

Michelle Staggs Kelsall, Mary Kristerie A. Baleva, Aviva Nababan, Rachel Guo, Caroline Ehlert, ជូ វិនាថ, ង៉ែត សុវណ្ណនិត និង ភ័ក្រ សាវន

**ខែធ្នូ ឆ្នាំ២០០៩**

**គម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិអាស៊ី**

Asian International Justice Initiative (AIJI)

# មាតិកា


**ផ្នែកទី១ ៖ សេចក្តីផ្តើម និង សេចក្តីសង្ខេបខ្លឹមសារ** ១

**ផ្នែកទី២ ៖ សេចក្តីសង្ខេបសក្ខីកម្ម** ៩

ក. សារតានៃការជំនុំជម្រះក្តី **ឌុច** ៩

ខ. ការបកស្រាយទ្រឹស្តីនៃការទទួលខុសត្រូវ ១០

គ. សេចក្តីសង្ខេបនៃការបង្ហាញភស្តុតាង ១២

ឃ. សេចក្តីសង្ខេបភស្តុតាងបង្ហាញតាមអង្គហេតុ ១៤

ង. សេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោល ២២

ច. បទពិសោធន៍ទទួលបានពីនីតិវិធីបង្ហាញភស្តុតាង ២៤

**ផ្នែកទី៣ ៖ បញ្ហាច្បាប់ និង នីតិវិធី** ២៦

ក. សិទ្ធិដឹងពីមូលហេតុនៃការចោទប្រកាន់ ៖ ការអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋរួម (JCE) ២៨

ខ. សិទ្ធិទទួលបានការជំនុំជម្រះក្នុងរយៈពេលសមរម្យ ៣០

គ. គោលការណ៍ សមភាពរវាងការការពារ និង ការចោទប្រកាន់ ៣៤

ឃ. ការអនុវត្ត និង ការបកស្រាយវិធានផ្ទៃក្នុង អ.វ.ត.ក ៣៥

ង. ការផ្តន្ទាទោស ៤០

ច. បទពិសោធន៍ទទួលបានពីបញ្ហាច្បាប់ និង នីតិវិធី ៤៣

**ផ្នែកទី៤ ៖ ការចូលរួម និងការគាំពារ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី** ៤៤

ក. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ៤៦

ខ. ការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ៖ វត្តមានអ្នកចូលរួម ៥០

គ. ការចូលរួមនៅក្នុងដំណើរការនីតិវិធី ៖ ការគាំទ្រការចោទប្រកាន់ និងការទាមទារសំណង ៥២

ឃ. ការចូលរួម ការការពារ និងការគាំពារសាក្សី ៥៨

ង. បទពិសោធន៍ទទួលបានពីការចូលរួម និងការគាំពារ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ៦២

**ផ្នែកទី៥ ៖ ការគ្រប់គ្រងសវនាការ** ៦៤

ក. ការគ្រប់គ្រងរបស់តុលាការ ៦៥

ខ. ការគ្រប់គ្រងលើបញ្ហាទូទៅ ៧០

គ. ការចូលរួមពីសាធារណៈជន ៧៤

ឃ. វត្តមាន និង សកម្មភាពរបស់ភាគី ៧៤

ង. បទពិសោធន៍ទទួលបានពីការគ្រប់គ្រងសវនាការ ៧៥

**សេចក្តីសន្និដ្ឋាន** ៧៧

## ផ្នែកទី ១ : សេចក្តីផ្តើម និង សេចក្តីសង្ខេបខ្លឹមសារ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចុះហត្ថលេខានៅ ខែមិថុនា ឆ្នាំ ២០០៣ ។ យុត្តាធិការនៃតុលាការនេះ គឺដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះបទឧក្រិដ្ឋ និងការរំលោភយ៉ាងធ្ងន់ធ្ងរនៅកម្ពុជា ក្នុងកំឡុង ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ (ដែលរបបនេះត្រូវបានហៅថា *"កម្ពុជាប្រជាធិបតេយ្យ"* ។ ជាពិសេស តុលាការនេះត្រូវបានបង្កើតឡើង ជាផ្នែកមួយនៃប្រព័ន្ធយុត្តិធម៌កម្ពុជា ព្រោះមានសមាសភាពចៅក្រមព្រះរាជអាជ្ញា និងបុគ្គលិកជាតិ និងអន្តរជាតិ ។ តុលាការនេះបានប្រើប្រាស់ទាំងច្បាប់ជាតិ និងអន្តរជាតិ ក្នុងកិច្ចនីតិវិធីចោទប្រកាន់ ស៊ើបសួរ និងកាត់ទោសជនប្រព្រឹត្តបទឧក្រិដ្ឋ ។

អំពើសាហាវឃោរឃៅប្រព្រឹត្តនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលដឹកនាំដោយខ្មែរក្រហមអស់រយៈកាលជាង ៣ ឆ្នាំ ត្រូវបានចងក្រងជាឯកសារជាច្រើន ។ ក្នុងពេលនោះប្រជាជនប្រមាណជា ១.៧ លាននាក់ត្រូវបានស្លាប់ដោយការធ្វើទារុណកម្ម ការសម្លាប់ ឬការបង្អត់អាហារ ។ ចំណែកប្រជាជនរាប់លាននាក់ផ្សេងទៀតរស់នៅក្នុងស្ថានភាពអមនុស្សធម៌ ដោយការបង្ខំឱ្យធ្វើការយ៉ាងលំបាកវេទនាទូទាំងផ្ទៃប្រទេស ។ ខ្មែរក្រហមបានបំផ្លាញចោលរាល់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសាធារណៈ ដូចជា សាលារៀន វត្តអារ៉ាម និងការជំលៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជនឱ្យទៅរស់នៅតាមជនបទ ជាអ្នកស្រែចំការក្នុងគោលបំណងកសាងអំណាចអង្គការតែមួយ ។

រហូតមកដល់បច្ចុប្បន្ននេះ អ.វ.ត.ក បានចាប់ខ្លួនជនសង្ស័យចំនួន ០៥រូប ហើយ រួមមាន លោក **នួន ជា** លោក **កាំង ហ្គេចអ៊ាវ** លោក **ខៀវ សំផន** លោក **អៀង សារី** និង អ្នកស្រី **អៀង ធីរិទ្ធ** ។ មនុស្សដំបូងដែលត្រូវចាប់ខ្លួន គឺលោក **កាំង ហ្គេចអ៊ាវ** ហៅ **ឌុច** (បន្ទាប់ពីនេះហៅថា "**ឌុច**" ឬ "ជនជាប់ចោទ") ។ **ឌុច** ត្រូវបានបញ្ជូនពីមន្ទីរឃុំឃាំងតុលាការយោធាទៅ អ.វ.ត.ក នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ហើយសំណុំរឿងក្តីនេះត្រូវបានបញ្ជូនទៅជំនុំជម្រះ នៅថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០៩ បន្ទាប់ពីសវនាការបឋម នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ("សំណុំរឿងក្តីលេខ ០០១") ។ សវនាការលើអង្គសេចក្តី ត្រូវបានបញ្ចប់នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ ២០០៩ ចំណែកឯសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលធ្វើឡើងនៅ ថ្ងៃទី២៣ ដល់ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០០៩ ។ កិច្ចដំណើរការនីតិវិធីជំនុំជម្រះលើសំណុំរឿងក្តីនេះ ចំណាយពេលសរុបចំនួនប្រមាណ ២២សប្តាហ៍ (៧៧ ថ្ងៃ) ហើយអង្គជំនុំជម្រះបានស្តាប់សក្ខីកម្មសាក្សីចំនួន ៤៧រូប (សាក្សីបំភ្លឺអង្គហេតុចំនួន ៣៨រូប និងសាក្សីជំនាញចំនួន ៩រូប) ព្រមទាំងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២២រូប ។ បច្ចុប្បន្ននេះ ជនសង្ស័យចំនួន ៤រូបផ្សេងទៀត ក្នុងសំណុំរឿងក្តីលេខ ០០២ ដែលឥឡូវកំពុងស្ថិតនៅដំណាក់កាលស៊ើបសួរ ហើយប្រហែលជាត្រូវបញ្ជូនទៅជំនុំជម្រះនៅដើមឆ្នាំ ២០១១ ។ ថ្មីៗនេះ ការិយាល័យសហព្រះរាជអាជ្ញាបានចេញដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួន ២

ទៀត ទៅការិយាល័យសហចៅក្រមស៊ើប រួមមានជនជាប់ចោទ ៥ រូប[១] ។

របាយការណ៍នេះ នឹងរៀបរាប់អំពីសេចក្តីសង្ខេបនៃដំណើរការនីតិវិធីទាំងមូលនៃសវនាការកាត់ទោស **ឌុច** និងលើកឡើងជាសង្ខេបនូវ *"ចំណេះដឹងល្អៗ"* ដែលទទួលបានពីសំណុំរឿងក្តីដំបូងនេះ ហើយក៏ជាគំរូមួយដល់សំណុំរឿងក្តីក្រោយៗទៀតរបស់តុលាការនេះ ព្រមទាំងតុលាការអន្តរជាតិផ្សេងទៀត[២] ។ ផ្អែកតាមក្រុមឃ្លាំមើលតុលាការជាតិបានឱ្យដឹងថា កិច្ចដំណើរការនីតិវិធីតាំងពីដំបូងរហូតដល់ចុងបញ្ចប់ ពួកគេយល់ឃើញថា របាយការណ៍នេះអាចជាចំណេះដឹងមួយសម្រាប់តុលាការថ្នាក់ជាតិអនុវត្តតាម ។ របាយការណ៍នេះក៏បានឆ្លុះបញ្ចាំងពីកំឡុងពេលនៃកិច្ចដំណើរការនីតិវិធី និងលទ្ធផលនាពេលអនាគត ជារឿងក្តីគំរូ សម្រាប់ឱ្យរឿងក្តីក្រោយពិចារណាតាម ។ របាយការណ៍នេះ ត្រូវបានរៀបចំឡើងដោយក្រុមឃ្លាំមើលតុលាការ និងអ្នកស្រាវជ្រាវមកពីសាកលវិទ្យាល័យកាលីហ្វូរនី និងវិទ្យាស្ថាន Berkeley War Crimes Studies Center ព្រមទាំងមជ្ឈមណ្ឌល East West Center នៅក្នុងកម្មវិធីមួយឈ្មោះថា Asian International Justice Initiative (AIJI) ហើយលោក-អ្នកអាចរកបាននូវរបាយការណ៍ប្រចាំសប្តាហ៍នៃការឃ្លាំមើលកិច្ចដំណើរការកាត់ទោស **ឌុច** តាមរយៈគេហទំព័រនៃស្ថាប័នទាំងនេះ ។ ចំពោះសមាសភាពចូលរួមធ្វើរបាយការណ៍នេះ រួមមាន មេធាវីជាតិ/អន្តរជាតិ អ្នកស្រាវជ្រាវផ្នែកច្បាប់នានា មកពី ប្រទេសកម្ពុជា ចិន អាល្លឺម៉ង់ ឥណ្ឌូនេស៊ី ហ្វីលីពីន សិង្ហបុរី ស្វីស និងសហរដ្ឋអាមេរិក ជាដើម ("ក្រុមឃ្លាំមើលតុលាការ")[៣] ។

នីតិវិធីនៃការរៀបចំរបាយការណ៍នេះ គឺការឃ្លាំមើល និងការចូលរួមតាមដានសវនាការដោយផ្ទាល់ជាប្រចាំ នៅកំឡុងកិច្ចដំណើរការនីតិវិធីសវនាការទាំងមូល ។ បន្ថែមលើនេះ ក្នុងរយៈពេលប្រហែលជាពីរ/បីសប្តាហ៍ ក្រុមឃ្លាំមើលតុលាការ បានធ្វើបទសម្ភាសន៍ដោយផ្ទាល់ជាមួយភាគីពាក់ពន្ធ័ជាច្រើន ដូចជា សហព្រះរាជអាជ្ញា មេធាវីការពារក្តី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណី ក្រុមប្រឹក្សាជំនុំជម្រះ អង្គភាព

---

[១] សូមមើលសេចក្តីប្រកាសព័តិមាន " សេចក្តីថ្លែងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី" ថ្ងៃទី ៨ កញ្ញា ២០០៩ ។ អាចរកបាននូវក្នុងគេហទំព័រ http://www.eccc.gov.kh/english/press_release.list.aspx. (Last accessed 1 December 2009) ។ បន្ថែមពីនេះ រាល់ឯកសារទាំងអស់ដែលពាក់ព័ន្ធនឹង អ.វ.ត.ក. អាចរកបាននៅក្នុងគេហទំព័ររបស់អ.វ.ត.ក www.eccc.gov.kh

[២] យើងប្រើពាក្យ "តុលាការអន្តរជាតិ" នៅក្នុងរបាយការណ៍នេះ គឺសំដៅទៅលើទាំងតុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និង ប្រទេសរូវ៉ាន់ដា ក៏ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិ ព្រមទាំង រដ្ឋបាល ឬ សន្និសញ្ញារបស់អង្គការសហប្រជាជាតិ ដែលមានទីតាំងតុលាការនៅទីក្រុង កូសូវ៉ូ ប្រទេស ទីម័រខាងកើត បូសនៀ សេរ៉ាលេអូន និង កម្ពុជា ។

[៣] សំណុំឯកសាររបស់ក្រុមឃ្លាំមើលតុលាការ ទាំងអតីត និងបច្ចុប្បន្ន អាចមើលនៅក្នុងគេហទំព័រ www.eastwestcenter.org/aiji ។ ក្រុមនេះ រួមមាន : អ្នកស្រី ជូ វិនាថ (ខ្មែរ) លោក ង៉ែត សុវណ្ណនិត (ខ្មែរ) លោក ភ័ក្រ សាវ៉ន (ខ្មែរ) កញ្ញា សេក សុវណ្ណា (ខ្មែរ) កញ្ញា Binxin Zhang (ចិន) កញ្ញា Guo Cai (ចិន) លោក Florian Hansen (អាល្លឺម៉ង់) កញ្ញា Aviva Nababan (ឥណ្ឌូនេស៊ី) កញ្ញា Mary Kristerie Baleva (ហ្វីលីពីន) កញ្ញា Yvette Anthony (សិង្ហបុរី) កញ្ញា Delphia Lim (សិង្ហបុរី) កញ្ញា Sibylle Dishler (ស្វីស) កញ្ញា Romana Weber (ស្វីស) កញ្ញា Caroline Ehlert (ស្វីស) លោក Jaspreet Dosanjh (អាមេរិក) កញ្ញា Deepika Sharma (អាមេរិក) ។ កញ្ញា Mariko Miyahira (ជប៉ុន) ក៏បានចូលរួម ក្នុងក្រុមការងារនេះដែរនៅពាក់កណ្តាលឆ្នាំ ២០០៩ ។

បកប្រែ អង្គភាពជនរងគ្រោះ និងផ្នែកកិច្ចការសាធារណៈនៃសាលាក្តីខ្មែរក្រហម ។ របាយការណ៍នេះ ត្រូវបានដាក់ឱ្យមន្ត្រីតុលាការផ្តល់មតិយោបល់ ការសង្កេតនានា និងត្រួតពិនិត្យទៅលើភាពត្រឹមត្រូវនៃរបាយការណ៍ ។ ចំពោះបទសម្ភាសន៍ដែលធ្វើឡើងដោយក្រុមឃ្លាំមើលតុលាការ ពុំមានទស្សនៈបន្ទុះបង្អាប់ទៅលើភាគីនីមួយៗទេ គឺគ្រាន់តែសាកសួរយកព័ត៌មាន និងធ្វើការពិភាក្សា ដើម្បីជាមធ្យោបាយពង្រីកការវិភាគលើរបាយការណ៍នេះប៉ុណ្ណោះ ។

ចំពោះផ្នែកផ្សេងនៃរបាយការណ៍ត្រូវបានបែងចែកជា ៤ ផ្នែកសំខាន់ៗផ្សេងទៀត ដូចជា ផ្នែកទី២ នឹងផ្តល់ដល់អ្នកអាននូវសេចក្តីសង្ខេបសក្ខីកម្មដែលបានធ្វើឡើងនៅក្នុងសវនាការ រាប់បញ្ចូលទាំងសក្ខីកម្មរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងសាក្សីដទៃទៀត ។ សេចក្តីសង្ខេបនេះក៏បានបែងចែកជា ៧ ចំណុចសំខាន់ៗ ដែលអង្គជំនុំជម្រះ និងគូភាគីបានធ្វើការសួរដេញដោលចំពោះសាក្សី ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងរយៈពេលជាង ២០សប្តាហ៍នេះ[៤] ។ ចំណុចសំខាន់ៗរួមមាន (១)បញ្ហាទាក់ទងនឹងមន្ទីរ ម-១៣ (២)ការបង្កើតមន្ទីរ ស-២១ និងគុកនៅ តាខ្មៅ (៣)ការអនុវត្តគោលនយោបាយរបស់បក្សកុំម្មុយនីស្តកម្ពុជានៅមន្ទីរ ស-២១ (៤)ជម្លោះប្រដាប់អាវុធ (ឬអត្ថិភាពនៃជម្លោះប្រដាប់អាវុធរវាងកម្ពុជា និងវៀតណាម) (៥)ការប្រព្រឹត្តទៅរបស់មន្ទីរ ស-២១ រាប់បញ្ចូលទាំងមន្ទីរជើងឯក (៦)ការបង្កើត និងការប្រព្រឹត្តិទៅនៃមន្ទីរ ស-២៤ និង (៧)លក្ខណៈអត្តចរិករបស់ជនជាប់ចោទ ។ ទោះបីជា អង្គជំនុំជម្រះបានចាត់ទុកបញ្ហាសំណង និងការផ្តន្ទាទោសជាផ្នែកចុងក្រោយនៃកិច្ចនីតិវិធី ក៏ក្រុមយើងនឹងបង្ហាញចំណុចនេះនូវផ្នែកមួយដាច់ដោយឡែក ដើម្បីមានភាពងាយស្រួលក្នុងការអាន ។ កន្លងមក ការរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងការធ្វើសេចក្តីសង្ខេបសក្ខីកម្ម គឺធ្វើឡើងដោយការវិភាគសក្ខីកម្ម ដែលទទួលកំឡុងកិច្ចនីតិវិធីសវនាការ ។

ផ្នែកទី ៣ នឹងធ្វើការពិនិត្យទៅលើបញ្ហាច្បាប់ និង នីតិវិធីសំខាន់ៗ ដែលកើតមានកំឡុងពេលកិច្ចដំណើរការនីតិវិធី ។ ផ្អែកលើការសង្កេត និងការវិភាគជាទូទៅរបស់ក្រុមឃ្លាំមើលតុលាការ បញ្ហាចំនួន ៦ ត្រូវបានវិភាគ និងកំណត់ថា ជាបញ្ហាសំខាន់ៗ ដែលកើតមានកំឡុងពេលសវនការកាត់ទោស **ឌុច** តួយ៉ាង : (១)ការអនុវត្តទ្រឹស្តីនៃសហកម្មឧក្រិដ្ឋរួម នៅក្នុងសំណុំរឿងក្តី **ឌុច** ទ្រឹស្តីនេះបានជះឥទ្ធិពលដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការដឹងពីមូលហេតុនៃការចោទប្រកាន់ខ្លួន មុនពេលសំណុំរឿងក្តីចាប់ផ្តើម ដូចមានចែងនៅក្នុងមាត្រា ៣៥ថ្មី នៃ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (បន្ទាប់ពីនេះហៅថា "**ច្បាប់អ.វ.ត.ក**")[៥] (២)នីត្យានុកូលភាពនៃការឃុំខ្លួនបណ្តោះ អាសន្ន

---

[៤] សំណុំរឿងក្តី **ឌុច** (សំណុំរឿងលេខ ០០១ /១៨-០៧-២០០៧ អ.វ.ត.ក./ អជសដ (ចាប់ពីពេលនេះហៅថា "**សំណុំរឿងក្តីលេខ ០០១**" ) សេចក្តីណែនាំអំពីកម្មវិធីជំនុំជម្រះក្តី ចុះថ្ងៃទី ២០ មិនា ២០០៩ កឋាខណ្ឌទី ៩-១ និង ៩-២ ( ចាប់ពីពេលនេះទៅហៅថា "**សេចក្តីណែនាំអំពីកម្មវិធី**)" ។ លោក-អ្នក អាចរកបាននៅក្នុងគេហទំព័រ :

www.eccc.gov.kh/english/court_doc.list.aspx?courtDocCat=case_doc, last accessed on 18 November 2009 ។ ចាប់ពីពេលនេះទៅ រាល់ឯកសារយោងទាំងឡាយ ពីសវនាការរបស់ **ឌុច** អាចរកបាននៅក្នុងគេហទំព័រនេះ ។

[៥] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាមួយនឹងការរាប់បញ្ចូលវិសោធនកម្មចុះថ្ងៃទី ២៧ តុលា ២០០៤ (នស/រកម/១០០៤/០០៦) មាត្រា ៣៥ (ថ្មី) ផ្នែក (ក) (ចាប់ពីពេលនេះទៅហៅថា "**ច្បាប់អ.វ.ត.ក.**") ។

**ឌុច** និងផលប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះ ក្នុងរយៈពេលសមស្រប ព្រមទាំងការកំណត់យកនូវវិធីសាស្ត្រកែតម្រូវ នៅពេលអង្គជំនុំជម្រះរកឃើញថា ការឃុំខ្លួនជនជាប់ចោទមិនត្រឹមត្រូវតាមនីតិវិធី (៣) អានុភាពនៃវិប្បដិសារីរបស់ជនជាប់ចោទ រយៈពេលនៃការជំនុំជម្រះ និងផលប៉ះពាល់ទៅលើការផ្តន្ទាទោស (៤) ដំណើរការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយឈរលើគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ (៥) ការបកស្រាយរបស់អង្គជំនុំជម្រះលើវិធាន ៨៧ នៃវិធានផ្ទៃក្នុង ទាក់ទងនឹងការដាក់ឯកសារ និងការបង្ហាញភស្តុតាង កំឡុងកិច្ចដំណើរការនីតិវិធី និង (៦) ការប្រើប្រាស់ភស្តុតាង ដែលទទួលបានដោយអំពើទារុណកម្ម ។

ផ្នែកទី ៤ នឹងពិនិត្យមើលជាពិសេសលើការគាំពារ និងគាំទ្រនូវការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ក្នុងកិច្ចដំណើរការនីតិវិធីសវនាការ ។ ផ្នែកនេះនឹងធ្វើការផ្តោតសំខាន់លើ *"ការអនុវត្ត"* ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ដែលតុលាការសម្រេចអនុម័តផ្លាស់ប្តូរផែនការ យោងទៅតាមកិច្ចប្រជុំពេញអង្គលើកទី៦របស់អង្គជំនុំជម្រះ កាលពីខែកញ្ញា ឆ្នាំ ២០០៩[៦] ដោយផ្តល់ជាសង្ខេបនៃបញ្ហាប្រឈមមុខសំខាន់ៗរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ខ្លួន នៅក្នុងសំណុំរឿងក្តីលេខ ០០១ រួមមាន (១) ការបង្កើតទំនាក់ទំនងរវាងការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងបទឧក្រិដ្ឋដែល **ឌុច** បានរងការចោទប្រកាន់ (២) បញ្ហាទាក់ទិននឹងវត្តមាន និងការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី និង (៣) បញ្ហាទាក់ទិននឹងការរៀបចំកូនក្តី និងកិច្ចសហការក្នុងការតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ ម្យ៉ាងទៀត ផ្នែកនេះក៏ផ្តល់នូវសេចក្តីសង្ខេបអំពីបញ្ហាមួយចំនួនទាក់ទិននឹងការគាំពារសាក្សីដែលបានកើតមាននៅក្នុងសំណុំរឿងក្តីលេខ ០០១ ។

ចុងបញ្ចប់ ផ្នែកទី ៥ នឹងពិនិត្យទៅលើបញ្ហានៃការគ្រប់គ្រងសវនាការ ដែលបានកើតមានក្នុងកំឡុងពេលសវនាការកាត់ទោស **ឌុច** ។ ផ្នែកនេះ នឹងរៀបរាប់អំពីយុត្តាធិការរបស់តុលាការក្នុងកិច្ចដំណើរការនីតិវិធី ក៏ដូចជាបញ្ហារដ្ឋបាលមួយចំនួន ដែលនាំឱ្យប៉ះពាល់ដល់ការចូលរួមសវនាការជាសាធារណៈ និងការស្វែងរកយុត្តិធម៌ទាំងមូល ។ ផ្នែកទី ៥ ក៏បានបែងចែកជាផ្នែកតូចៗ ៤ ដូចជា : (១) ការគ្រប់គ្រងតុលាការ (២) ការគ្រប់គ្រងទូទៅ (៣) ការចូលរួមរបស់សាធារណៈជន និង (៤) វត្តមាន និងការអនុវត្តតួនាទី ។

សរុបមក ក្រុមឃ្លាំមើលតុលាការបានធ្វើការសង្កេត និងវិភាគអំពីកិច្ចដំណើរការកាត់ទោស **ឌុច** ដោយយោងទៅតាមនិយាមតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ។ បើទោះជា ក្រុមឃ្លាំមើលតុលាការមានកង្វល់មួយចំនួនទាក់ទងនឹងការអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម (JCE) នៅក្នុងករណីសំណុំរឿងក្តី **ឌុច** ក៏ដោយ (ដូចមានរៀបរាប់លម្អិតនៅក្នុងផ្នែកទី ៣ នៃរបាយការណ៍នេះ) នៅពេលធ្វើការប៉ាន់ប្រមាណទៅលើកិច្ចដំណើរការនីតិវិធីទាំងមូលបានបញ្ជាក់កាន់តែច្បាស់ថា ដំណើរការនីតិវិធីនេះ គឺជាខ្នាតគំរូ (benchmark) បើធៀបទៅតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ដែលបង្កើតនៅប្រទេស **រ្វ៉ាន់ដា** និង **អតីតប្រទេសយូហ្គោស្លាវី** (ICTR, ICTY ឬ "តុលាការអាដ

[៦] អ.វ.ត.ក សេចក្តីប្រកាសព័ត៌មាន "ការសន្និដ្ឋានកិច្ចប្រជុំពេញអង្គលើកទី ៦ របស់អ.វ.ត.ក" ចុះថ្ងៃទី ១១ កញ្ញា ២០០៩ កឋាខណ្ឌទី ២ និង ៣ ។

ហុក") និងតុលាការអន្តរជាតិផ្សេងៗទៀត យើងបានសង្កេតឃើញថា សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ត្រូវបានលើកកម្ពស់ ។

ដំណើរការកាត់ទោស **ឌុច** អាចធ្វើឱ្យសាលាក្តីនេះ មានឈ្មោះបោះសំឡេងនៅក្នុងប្រវត្តិសាស្ត្រ ក្នុងន័យថា មានតែតុលាការនេះប៉ុណ្ណោះ ដែលជនជាប់ចោទបានទទួលស្គាល់នូវអង្គហេតុចម្បងៗ ចំពោះការចោទប្រកាន់ប្រឆាំងនឹងខ្លួន ។ ថ្វីបើ ក្នុងខណៈពេលសវនាការនាសប្តាហ៍ចុងក្រោយ **ឌុច** បានស្នើឱ្យលើកលែងការចោទប្រកាន់ក៏ដោយ ក៏គាត់បានធ្វើការសហការយ៉ាងសកម្មជាមួយអង្គជំនុំជម្រះ តាំងពីដំណាក់កាលដំបូងរហូតដល់ការបង្ហាញនូវវិប្បដិសារី ការសោកស្តាយ និងការព្រមទទួលយកការផ្តន្ទាទោស ។ ជាលទ្ធផល សិទ្ធិមួយចំនួនត្រូវបានគោរពនៅក្នុងកិច្ចដំណើរការនីតិវិធី ដែលធានានូវគោលការណ៍សន្មតជាមុនថា *"គ្មានទោស"* (ឬការតវ៉ានឹងបន្ទុកភស្តុតាងពីសំណាក់សហព្រះរាជអាជ្ញា) ។ ផ្ទុយទៅវិញ មេធាវីការពារក្តីមិនតវ៉ាពីប្រភពដើមនៃភស្តុតាង ដែលដាក់បន្ទុកលើ **ឌុច** នោះទេ ។ បន្ថែមលើនេះ បញ្ហាដែលទាក់ទងទៅនឹងការបកប្រែភាសា ត្រូវបានដោះស្រាយយ៉ាងឆាប់រហ័ស ក្រៅពីនេះ កិច្ចខិតខំប្រឹងប្រែងដទៃទៀតក៏ជាតម្រូវការ ដើម្បីធ្វើឱ្យសវនាការកាន់តែប្រសើរឡើង ទាំងការបកប្រែផ្ទាល់មាត់ និងឯកសារនៅ អ.វ.ត.ក ។ ចំណែកឯជនជាប់ចោទ នៅក្នុងសំណុំរឿងក្តីលេខ ០០២ ឬ ០០៣ ហាក់មិនបង្ហាញនូវកិច្ចសហការជាមួយតុលាការនោះទេ ។

ផ្អែកតាមការវិភាគ ដែលបានផ្តល់ក្នុងរបាយការណ៍នេះ ក្រុមឃ្លាំមើលតុលាការបានរកឃើញនូវ "មេរៀនដកពិសោធន៍" (Lesson learned) មួយចំនួនដូចខាងក្រោម ៖

## (ក) អំពីការរៀបចំដំណើរការនីតិវិធីសវនាការ

អង្គជំនុំជម្រះ មានបំណងពិចារណាជ្រើសយកវិធីសាស្ត្រខុសៗគ្នា ក្នុងការរៀបចំបង្ហាញភស្តុតាងសម្រាប់សំណុំរឿងក្តីក្រោយៗនាពេលអនាគត ។ ការប្រើប្រាស់ចំណងជើងប្រធានបទ ដើម្បីរៀបចំធ្វើសក្ខីកម្មសាក្សី ក៏នៅតែជាក្តីកង្វល់ ព្រោះសក្ខីកម្មនៅតែមានភាពច្រំដែល ។ ម៉្យាងទៀត វាមានការលំបាកណាស់ ក្នុងការធានាឱ្យបានថា រាល់សំណួររបស់ភាគីស្ថិតក្នុងរង្វង់នៃប្រធានបទ ដែលកំពុងដេញដោលក្នុងសវនាការ នៅពេលសួរដេញដោលសាក្សីសំខាន់ៗ ជាពិសេសសាក្សីជំនាញ និងអតីតបុគ្គលិកមន្ទីរ ស-២១ ។ អង្គជំនុំជម្រះអាចនឹងពិចារណាជ្រើសរើសយករចនាសម្ព័ន្ធថ្មីតាមតុលាការអន្តរជាតិផ្សេងៗ ចំពោះការរៀបចំបង្ហាញភស្តុតាងទៅតាមប្រភេទសាក្សី និងទីកន្លែងដែលឧក្រិដ្ឋកម្មកើតឡើង ដើម្បីសម្រួលវិធីសាស្ត្រ សម្រិតសម្រាំងភស្តុតាងឱ្យកាន់តែល្អប្រសើរឡើងថែមទៀត សម្រាប់រឿងក្តីលេខ ០០២ ។

## (ខ) អំពីការអនុវត្តច្បាប់ និងនីតិវិធីសវនាការ

- សញ្ញាណច្បាប់ស៊ីវិលនៃ *iura novit curia* (តុលាការដឹងច្បាប់) គួរអនុវត្តដោយប្រុងប្រយ័ត្នចំពោះរឿងក្តីនៅក្នុង អ.វ.ត.ក ដោយពិចារណាអំពីការដាក់ទោសទណ្ឌ និងការជះឥទ្ធិពលដល់សិទ្ធិរបស់ជន

ជាប់ចោទ ដែលត្រូវបានកំណត់ចំពោះមុខសវនាការ ចាប់ពីដំបូងនៃការចោទប្រកាន់ និងជាពិសេសចំពោះសំណុំរឿងក្ដីឧក្រិដ្ឋកម្មដ៏ឃោរឃៅ ។ សំណុំរឿងក្ដីពិសេសនេះទាក់ទងទៅនឹងការអនុវត្តទ្រឹស្ដីសហកម្មឧក្រិដ្ឋកម្មរួម *JCE* ដែលជាទម្រង់មួយនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ និងជាយុត្តិសាស្ត្រថ្មីៗពាក់ព័ន្ធទៅនឹងតម្រូវការជាក់លាក់ ដែលអះអាងនូវទ្រឹស្ដីសហកម្មឧក្រិដ្ឋកម្មរួមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត ហើយក៏កម្រិតការអនុវត្តនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិនាពេលបច្ចុប្បន្ននេះ ។

- វិធីសាស្ត្រក្នុងការទទួលយកឯកសារ គឺជាការអនុវត្តមួយដ៏គួរឱ្យកោតសរសើរ អង្គជំនុំជម្រះ និងគូភាគីបានកំណត់នូវយុត្តិសាស្ត្រដ៏រឹងមាំនៅក្នុង អ.វ.ត.ក ពាក់ព័ន្ធនឹងចំណុចនេះ ហើយចំណុចនេះក៏គួរតែត្រូវបន្តអនុវត្តសម្រាប់សំណុំរឿងក្ដីលេខ ០០២ ទៀត ។
- យុត្តិសាស្ត្រសំខាន់ៗទាក់ទងទៅនឹងការឃុំខ្លួនបណ្ដោះអាសន្ន និងការប្រើប្រាស់ភស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម បានកើតមាននៅក្នុងសវនាការកាត់ទោស **ឌុច** ។ យុត្តិសាស្ត្រនេះ ក៏ជាមេរៀនមួយសម្រាប់មេធាវីនៅក្នុងព្រះរាជាណាចក្រកម្ពុជា យកមកធ្វើការពិចារណាការពារកូនក្ដីខ្លួននៅគ្រប់តុលាការនៅកម្ពុជា ។

## (គ) អំពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

- ចៅក្រមនៃ អ.វ.ត.ក គួរពិចារណាចេញសេចក្ដីណែនាំដោយផ្ទាល់មួយទាក់ទិនទៅនឹងការចូលរួមរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការសវនាការ ព្រោះថា នៅក្នុងសំណុំរឿងក្ដីលេខ ០០២ និងសំណុំរឿងក្ដីក្រោយៗទៀត ទាក់ទងនឹងការផ្លាស់ប្ដូរការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីហាក់ពុំមានឱកាសទេ ។ បញ្ហាចោទជាមូលដ្ឋាន រួមមានដូចជា តួនាទីរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលគួរតំណាងតែផលប្រយោជន៍កូនក្ដីរបស់ខ្លួន និងគាំទ្រដល់ការចោទប្រកាន់របស់សហព្រះរាជអាជ្ញា នៅតែជាចំណុចត្រូវបកស្រាយឱ្យបានច្បាស់លាស់ ។
- ការផ្ដល់នូវធនធានគ្រប់គ្រាន់ដល់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក៏ជាការធានាឱ្យមានភាពល្អប្រសើរនូវទំនាក់ទំនងជាមួយកូនក្ដី និងការយកចិត្តទុកដាក់ក្នុងការតំណាងផលប្រយោជន៍របស់កូនក្ដី ។ ទោះបីជាយ៉ាងណា កិច្ចសហការដ៏ល្អប្រសើររបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានបង្ហាញពីគុណប្រយោជន៍ដ៏ធំសម្រាប់កិច្ចដំណើរការជំនុំជម្រះទាំងមូល ។
- ការកំណត់ទៅលើសំណង ទាំងសំណងផ្លូវចិត្ត និងសំណងរួម គួរតែលើកឱ្យបានជាក់លាក់ ថាតើមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអាចដាក់ការទាមទាមសំណងជំនួសកូនក្ដីខ្លួន និងជនរងគ្រោះឬទេ ។

## (ឃ) អំពីការគ្រប់គ្រងសវនាការ

- អង្គជំនុំជម្រះ គួរចៀសវាងការចេញសេចក្ដីសម្រេចដោយពុំមានសំអាងហេតុច្បាស់លាស់ នៅក្នុងសំណុំរឿងក្ដីលេខ ០០២ ដែលករណីនេះអាចនឹងជួយពង្រឹងកិច្ចដំណើរការសវនាការ និងសមត្ថភាពរបស់

តុលាការក្នុងការដើរតួជាគំរូសម្រាប់តុលាការថ្នាក់ជាតិ ។ ក្រុមប្រឹក្សាអង្គជំនុំជម្រះគួរព្យាយាមបង្ហាញពីសំអាងហេតុរបស់ខ្លួនឱ្យបានច្បាស់លាស់រាល់សេចក្តីសម្រេចទាំងឡាយ ។

- វិធានការដែលចៅក្រមប្រកាន់យកក្នុងការបង្អាក់សំណួរគូភាគី ដែលប្រាសចាកពីប្រធានបទ គឺជាការគួរឱ្យកោតសរសើរ ។ ទោះបីជាបែបនេះក៏ដោយ ក្នុងកាលៈទេសៈខ្លះគេត្រូវពង្រឹងប្រសិទ្ធិភាពនៃការវាយតម្លៃទៅលើសំណួរទាំងនោះ ថាតើវាជាសំណួរច្រំដែលឬទេ ។ សរុបមក ការអនុវត្តបែបនេះបានបង្កើនប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី ហើយក៏សូមលើកទឹកចិត្តដល់អង្គជំនុំជម្រះ ក្នុងការបន្តសកម្មភាពនេះឱ្យកាន់តែសកម្មបន្ថែមទៀត ។
- កិច្ចសហប្រតិបត្តិការដ៏ល្អប្រសើររវាងតំណាងសហព្រះរាជអាជ្ញា និងការបញ្ជៀសនូវការចាកចេញជាច្រើនរបស់បុគ្គលិកក្នុងការិយាល័យសហព្រះរាជអាជ្ញា ក៏អាចផ្តល់គុណប្រយោជន៍ដ៏ប្រសើរដល់ដំណើរការរបស់ការិយាល័យនេះ ក្នុងការបំពេញការងារទៅតាមករណីនីមួយៗនៃសំណុំរឿងនៅតុលាការ ។
- មានព្រឹត្តិការណ៍ដ៏គួរឱ្យភ្ញាក់ផ្អើលជាច្រើន ក្នុងកំឡុងពេលសប្តាហ៍ចុងក្រោយនៃកិច្ចដំណើរការសវនាការ ខណៈដែលមេធាវីការពារក្តីជាតិ និងអន្តរជាតិ បានធ្វើសេចក្តីសន្និដ្ឋាន និងអំណះអំណាងផ្ទុយគ្នាការពារកូនក្តីខ្លួន (ដំបូងថា "មិនមានពិរុទ្ធភាព" តែចុងបញ្ចប់ថា "មានពិរុទ្ធភាព" ទៅវិញ) នៅក្នុងវិធានផ្ទៃក្នុងដែលបានធ្វើវិសោធនកម្មចុងក្រោយ បានធ្វើការធានាថា មេធាវីការពារក្តី ត្រូវកំណត់មេធាវីដឹកនាំឱ្យបានជាក់លាក់ ។
- ពុំមានសាក្សីណាម្នាក់ ត្រូវបានផ្តល់សក្ខីកម្មនៅក្នុងដំណាក់កាលសវនាការអសាធារណៈនោះទេ ។ ការអនុវត្តន៍ដ៏គួរឱ្យកោតសរសើររបស់អង្គជំនុំជម្រះ គឺការពារសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ ក្នុងការទទួលបាននូវសវនាការជាសាធារណៈ ។
- កិច្ចខិតខំប្រឹងប្រែងក្នុងការធានានូវការបកប្រែឯកសារ និងការបកប្រែប្រដេញផ្ទាល់មាត់ឱ្យត្រឹមត្រូវ ត្រូវបានយកចិត្តទុកដាក់ និងគួរបន្តជារៀងរហូតនៅក្នុងកិច្ចដំណើរការទាំងមូលរបស់ អ.វ.ត.ក ដើម្បីធានាថាសិទ្ធិរបស់ជនជាប់ចោទត្រូវបានលើកកម្ពស់ ។

## (ខ) អំពីការចូលរួមរបស់សាធារណៈជន និងការផ្សព្វផ្សាយព័ត៌មាន

- កិច្ចខិតខំប្រឹងប្រែងដែលបំពេញដោយផ្នែកកិច្ចការសាធារណៈ ក្នុងការបង្កើនចំនួនអ្នកចូលរួមជាផ្នែកមួយគួរឱ្យកោតសរសើរ និងគួរធ្វើបន្តទៀតសម្រាប់សំណុំរឿងក្រោយៗ ។ បន្ថែមលើនេះ ការបង្កើននូវផ្នែកបរិក្ខាសាធារណៈ ដើម្បីជួយសម្រួលដល់សាធារណៈជន គឺជាភាពចាំបាច់ ។
- កិច្ចខិតខំប្រឹងប្រែងនៅក្នុងការបង្កើនចំនួនដើមបណ្តឹងរដ្ឋប្បវេណីចូលរួមនៅក្នុងកិច្ចនីតិវិធី និងរៀបចំទុកជាមុននូវដើមបណ្តឹងរដ្ឋប្បវេណីចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី គួរតែត្រូវយកចិត្តទុកដាក់បន្ថែមទៀតសម្រាប់រឿងក្តីក្រោយៗ ។ ការចាត់វិធានការបន្ថែម ដើម្បីធានាដល់ដើមបណ្តឹងរដ្ឋប្បវេណី និង

ម្ចាស់បណ្ដឹង ព្រមទាំងជនរងគ្រោះដទៃទៀតត្រូវបន្តរក្សាការជូនដំណឹងឱ្យបានសមរម្យ អំពីកិច្ចដំណើរការនីតិវិធីសវនាការ ។ ដូចគ្នាផងដែរ ការបង្កើនសកម្មភាពមិនមែនផ្លូវច្បាប់ដល់ជនរងគ្រោះ គឺជាកេរ្តិ៍ដំណែលជាវិជ្ជមានមួយរបស់តុលាការនៅក្នុងបរិបទប្រទេសកម្ពុជា

# ផ្នែកទី ២ : សេចក្តីសង្ខេបសក្ខីកម្ម

## ក. សាវតានៃការជំនុំជម្រះក្តី **ឌុច**

ជនជាប់ចោទ **កាំង ហ្គេចអ៊ាវ** ហៅ "**ឌុច**" កើតនៅខេត្តកំពង់ធំ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ [៧]។ **ឌុច** មានអាជីព ជាគ្រូបង្រៀនមួយរូប និងបានចូលរួមចលនាកុម្មុយនីស្តនៅចុង ឆ្នាំ១៩៦០ ហើយត្រូវបានចូលជាសមាជិកគណបក្សកុម្មុយនីស្ត នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៦៧ ។ កំឡុងពេលគ្រប់គ្រងដោយ សម្តេចព្រះនរោត្តមសីហនុ **ឌុច** ត្រូវបានចាប់ខ្លួននៅ ខែមករា ឆ្នាំ១៩៦៨ និងត្រូវផ្តន្ទាទោសពីបទរំលោភសន្តិសុខប្រទេស ដោយដាក់គុករយៈពេល ២០ឆ្នាំ និងធ្វើការជាទំងន់ ។ **ឌុច** ក៏ដូចជាអ្នកទោសនយោបាយដទៃទៀតដែរ នៅខែមេសា ឆ្នាំ១៩៧០ រដ្ឋាភិបាល **លន់ ណុល** បានដោះលែងឱ្យមានសេរីភាព ។ ក្រោយមក គាត់បានទៅបំរើការជាប្រធានមន្ទីរ ម-១៣ ដែលជាមន្ទីរឃុំឃាំងមួយបង្កើតឡើងដោយបក្សកុម្មុយនីស្តនៅ ឆ្នាំ១៩៧១ ក្នុងគោលបំណងសួរចម្លើយ និងកម្ទេចសត្រូវរបស់បក្ស [៨] ។

ក្នុងកំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) **ឌុច** មានតួនាទីមួយចំនួននៅមន្ទីរ ស-២១ ដែលមានទីតាំងនៅទីក្រុងភ្នំពេញ ។ យោងតាមជនជាប់ចោទ អក្សរ "**ស**" មានន័យថាជា "**សន្តិបាល**" ដែលជាទម្រង់ថ្មីមួយនៃកម្លាំងសន្តិសុខ បង្កើតឡើងដោយខ្មែរក្រហម ដើម្បីការពារសន្តិភាព និងសន្តិសុខជាតិ ។ មន្ទីរ ស-២១ គឺជាគុកសន្តិសុខមួយ ដែលមានទំរង់ដូចមន្ទីរ ម-១៣ ដែរ ប៉ុន្តែមន្ទីរនេះត្រូវបានប្រើប្រាស់ដោយខ្មែរក្រហមថ្នាក់លើ ដើម្បីកម្ទេច ឬសម្លាប់សត្រូវ ដែលចាប់បាននៅក្នុងរបបនោះ ។ **ឌុច** បានទទួលស្គាល់ថា ខ្លួនជាប្រធានមន្ទីរ ស-២១ ចាប់ពីខែមិនា ឆ្នាំ១៩៧៦ រហូតដល់ ខែមករា ឆ្នាំ១៩៧៩ [៩] ។ បន្ថែមលើនេះ នៅចន្លោះឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ **ឌុច** បានសម្រេចផ្លាស់ប្តូរទីតាំងសម្លាប់មនុស្សពីមន្ទីរ ស-២១ ទៅកាន់មន្ទីរជើងឯកវិញ ដែលមានទីតាំងនៅចម្ងាយប្រមាណ ១៥ គ.ម ខាងត្បូងទីក្រុងភ្នំពេញ ស្ថិតក្នុងខេត្តកណ្តាល [១០] ។ ចំណែកឯទីតាំងមួយកន្លែងផ្សេងទៀតត្រូវបានគេស្គាល់ថា "ជាមន្ទីរ ស-២៤" មន្ទីរនេះក៏ជាផ្នែកមួយផងដែរនៃមន្ទីរ ស-២១ ដែលត្រូវ

---

[៧] អ.វ.ត.ក ព័ត៌មានអំពីសំណុំរឿង នៃសំណុំរឿងក្តីលេខ ០០១ អាចរកបាននៅ www.eccc.gov.kh/english/caseInfo001.aspx.

[៨] សក្ខីកម្មរបស់ជនជាប់ចោទ ដូចមានក្នុងរបាយកាណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០៣។ ទោះ យ៉ាងណាក្តី សូមមើលផងដែរនូវឧបសម្ព័ន្ធ "ក" នៃរបាយការណ៍នេះ ដែលលំអិតអំពីការគ្រប់គ្រងដោយផ្ទាល់របស់ជនជាប់ចោទ តែលើផ្នែក មួយ ឈ្មោះថា " ម-១៣" នៃមន្ទីរសន្តិសុខ ។

[៩] សក្ខីកម្មរបស់ជនជាប់ចោទ ដូចមានក្នុងរបាយកាណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០៥។ សូមមើលផងដែរនូវឧបសម្ព័ន្ធ "ក" នៃរបាយការណ៍នេះ ។

[១០] សូមមើលសំណុំរឿងក្តីលេខ ០០១ "ដីកាដំណោះស្រាយចោទប្រកាន់ កាំង ហ្គេចអ៊ាវ ហៅ **ឌុច**" (០៨ សីហា ២០០៨) (ចាប់ពីពេលនេះទៅហៅថា "ដីកាដំណោះស្រាយ") កថាខណ្ឌទី ២៩ ។ យោងទៅលើអង្គហេតុដែលមានការព្រមព្រៀងរបស់តុលាការ ដែលបានអាននៅក្នុងនីតិវិធីសវនាការ អង្គហេតុនេះ មិនត្រូវបានជំទាស់ដោយមេធាវីការពារក្តីទេ ។ សូមមើល របាយកាណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០២ ឧបសម្ព័ន្ធ "ក" តារាងទី ៤ ។

បានប្រើប្រាស់ជាជំរុំកែប្រែ និងអប់រំសារជាថ្មីក្នុងរបបនោះ[១១] ។

**ឌុច** ត្រូវបានឃុំខ្លួនដោយ អ.វ.ត.ក តាមរយៈដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ននៅ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ដែលដំបូង **ឌុច** ជាប់នៅមន្ទីរឃុំឃាំងនៃតុលាការយោធាកម្ពុជា នៅទីក្រុងភ្នំពេញ ចាប់តាំងពីឆ្នាំ ១៩៩៩ ដែលនេះជាករណីធ្វើឱ្យរយៈពេលឃុំខ្លួនបណ្តោះអាសន្នរបស់គាត់ ហួសរយៈពេលកំណត់ ។ **ឌុច** ត្រូវបាន ចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះ ចំពោះការប្រព្រឹត្តបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភដ៏ធ្ងន់ធ្ងរ លើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ព្រមទាំងអំពើមនុស្សឃាត និងទារុណកម្ម យោងតាមក្រមព្រហ្មទណ្ឌ កម្ពុជា ឆ្នាំ១៩៥៦ ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣-៥-៦-២៩ និង ៣៩ នៃច្បាប់ អ.វ.ត.ក ។ យោងតាម ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបញ្ជាក់លម្អិតអំពីការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ ប្រជាពលរដ្ឋ ប្រមាណជាង ១២.៣៨០នាក់ ត្រូវបានសម្លាប់ដោយមិនត្រឹមត្រូវតាមច្បាប់ ឬក៏ការស្លាប់បណ្តាលមកពីលទ្ធផល នៃលក្ខខណ្ឌនៃការរស់នៅអមនុស្សធម៌ នៅមន្ទីរ ស-២១[១២] ។

## ខ. ការបកស្រាយទ្រឹស្តីនៃការទទួលខុសត្រូវ

សវនាការលើអង្គសេចក្តីនៅក្នុងសំណុំរឿងក្តីរបស់ **ឌុច** បានចំណាយពេលវេលារហូតដល់ ៧៣ថ្ងៃ ចន្លោះពី ថ្ងៃទី១៧ ខែកុម្ភៈ រហូត ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩[១៣] ។ ភាពខុសប្លែកអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ផ្សេងទៀត តុលាការកាត់ទោស **ឌុច** គឺអនុម័តយកនូវប្រព័ន្ធពិសេសក្នុងការដំណើរការរឿងក្តី ។ សវនាការកាត់ ទោស **ឌុច** ត្រូវបានប្រព្រឹត្តទៅដោយស្របទៅតាមទម្លាប់ច្បាប់ប្រទេសលោកខាងលិច ដែលជះឥទ្ធិពលយ៉ាងខ្លាំង មកលើប្រទេសទើបតែកាន់របបប្រជាធិបតេយ្យ ដូចជាប្រទេសកម្ពុជា នោះគឺ *ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌប្រទេស បារាំង* ។ ហេតុនេះ តុលាការបានអនុម័តយកនូវវិធីសាស្ត្រការសួរដេញដោលដោយក្រុមប្រឹក្សាជំនុំជម្រះ ហើយ អង្គជំនុំជម្រះជាអ្នកដឹកនាំសវនាការ ដែលអាចសម្រេចកោះហៅសាក្សី និងធ្វើការពិនិត្យភស្តុតាងជាដំបូង ។ ទោះ យ៉ាងណាក៏ដោយ ទាំងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី នៅតែមានសិទ្ធិធ្វើសេចក្តីថ្លែងការណ៍បឋម និង លម្អិត ដើម្បីដាក់បន្ទុក និងដោះបន្ទុកនៃការទទួលខុសត្រូវរបស់ **ឌុច** ។ បន្ថែមលើនេះ ការកំណត់ពីភាពត្រឹមត្រូវ របស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ សហព្រះរាជអាជ្ញា និងមេធាវីការពារក្តី បានដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួន ចំពោះអង្គជំនុំជម្រះ ។

---

[១១] ដីកាដំណោះស្រាយ កឋាខណ្ឌ ៣០ និង របាយកាណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០២ ឧបសម្ព័ន្ធ "ក" តារាងទី ៤ ។

[១២] ដីកាដំណោះស្រាយ កឋាខណ្ឌ ១៣៩ ។

[១៣] រាប់បញ្ចូលទាំងសវនាការបឋម ដែលប្រព្រឹត្តទៅថ្ងៃទី ១៧-១៨ កុម្ភៈ ២០០៩ ។ តាមរយៈរបាយការណ៍នេះ ជាទូទៅយើងយោងទៅ របាយការណ៍ទាំង ២០ សប្តាហ៍នៃសវនាការ នៅពេលដែលយោងទៅលើសំណុំនៃនីតិវិធី និង ២១ សប្តាហ៍ នៅពេលសំដៅទៅលើនីតិវិធី អង្គសេចក្តីទាំងមូល ។

បើទោះជា **ឌុច** បានបង្ហាញពីវិប្បដិសារីរបស់ខ្លួនក៏ដោយ ក៏មិនអាចរួចផុតការចោទប្រកាន់ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ក្នុងពេលដែលគាត់មានអំណាចយ៉ាងឯករាជ្យក្នុងការគ្រប់គ្រងលើដំណើរការប្រព្រឹត្តទៅក្នុងមន្ទីរ ស-២១ បានដែរ[១៤] ។ បន្ទាប់ពី លោកស្រី **ជា លាង** សហព្រះរាជអាជ្ញាជាតិ បានបញ្ជាក់លម្អិតអំពីស្ថានភាពអមនុស្សធម៌ដែលបានប្រព្រឹត្តចំពោះអ្នកទោសនៅមន្ទីរ ស-២១ រួមទាំងរូបភាពនៃអំពើទារុណកម្មមួយចំនួន ដូចជា ការបង្អត់ចំណីអាហារ ការមិនផ្តល់ថ្នាំសង្កូវ សហព្រះរាជអាជ្ញាអន្តរជាតិ លោក **Robert Petit** បានព្យាយាមបង្ហាញអំពី *"ការគ្រប់គ្រងយ៉ាងហ្មត់ចត់"* អនុវត្តដោយជនជាប់ចោទ នៅក្នុងការបំពេញភារកិច្ចជាប្រធានមន្ទីរ ស-២១ ។ ចំណែកឯការលើកឡើងថា **ឌុច** បានអនុវត្តទៅតាមតែការកម្រិតតួនាទី និងភារកិច្ចរបស់ខ្លួនក៏ដោយ ក៏មិនមាន *"ហេតុផល និង ភស្តុតាង"* ក្នុងការគាំទ្រការអះអាងនេះទេ[១៥] ។

ចំពោះការអះអាងរបស់មេធាវីការពារក្តីថា **ឌុច** *"មានការសោកស្តាយ និងអាម៉ាសជាខ្លាំង"* នូវបទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្តនៅក្នុងនាម *"អង្គការ"* ហើយជនជាប់ចោទមានឆន្ទៈក្នុងការសហការជាមួយតុលាការ នៅក្នុងគោលបំណងឱ្យប្រជាពលរដ្ឋកម្ពុជាមានភាពរំលត់កំហឹង និងធូរស្រាលនូវទុក្ខសោករបស់ខ្លួន ។ ទោះបីជា មេធាវីការពារក្តីជាតិរបស់ **ឌុច** មានបំណងស្នើសុំឱ្យកូនក្តីខ្លួនរួចផុតពីការចោទប្រកាន់ ក៏មេធាវីការពារក្តីរបស់ **ឌុច** បានចំណាយពេលជាច្រើននៅក្នុងរឿងក្តីនេះ ដោយធ្វើការអះអាងថា កូនក្តីខ្លួនបានសារភាពទទួលរាល់កំហុស ។ ម្យ៉ាងទៀត **ឌុច** ខ្លួនឯង ក៏បានថ្លែងក្នុងកិច្ចដំណើរការនីតិវិធីដែរថា គាត់មានបំណងទទួលរាល់ការផ្តន្ទាទោសទាំងឡាយដែលអង្គជំនុំជម្រះផ្តល់ចំពោះរូបគាត់ ហើយនឹងមិនធ្វើការប្តឹងឧទ្ធរណ៍ទៅលើសេចក្តីសម្រេចនោះទេ ។ **ឌុច** បានពិពណ៌នាថា គាត់ក៏ជាជនរងគ្រោះម្នាក់ដែរនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលជារបបមានលក្ខណៈឃោរឃៅព្រៃផ្សៃគួរឱ្យភ័យខ្លាច ព្រោះត្រូវគោរព *"ការសម្ងាត់ជាធំ"* ហើយគាត់ក៏ជាមុខសញ្ញាមួយក្នុងការយកទៅ *"កម្ទេច ឬ សម្លាប់"* ផងដែរ[១៦] ។ បន្ថែមលើនេះ ក៏មានអង្គហេតុដែលថា **ឌុច** គឺជាមេគុកម្នាក់ក្នុងចំណោមមេគុកទាំង ១៩៦ ដែលប្រតិបត្តិការទូទាំងប្រទេសកម្ពុជា ការគូសបញ្ជាក់នេះក្នុងគោលដៅដែលថា : គ្មានមេគុកណាក្រៅពី **ឌុច** ត្រូវបានប្រឈមមុខនឹងការជំនុំជម្រះ នាពេលបច្ចុប្បន្ននេះទេ ។ មេធាវីការពារក្តីជាតិរបស់ **ឌុច** បានក្រើនរំលឹកជាច្រើនដងថា កូនក្តីរបស់គាត់ជា *"អ្នកទទួលថ្នាក់"* សម្រាប់អ្នកប្រព្រឹត្តបទល្មើសសំខាន់ៗដទៃទៀត ដែលអ្នកខ្លះក្នុងចំណោមនោះ បានប្រព្រឹត្តបទល្មើសសាហាវយង់ឃ្នងជាងជនជាប់ចោទទៅទៀត[១៧] ។ ហេតុដូច្នេះ មេធាវីការពារក្តីបានលើកឡើងពីបញ្ហាចោទជាក់ស្តែងគឺ *"ថាតើសវនាការនេះ នឹងអនុញ្ញាតិឱ្យមនុស្សម្នាក់ធ្លាប់បានប្រព្រឹត្ត*

---

[១៤] សេចក្តីសន្និដ្ឋានបើកសវនាការរបស់សហព្រះរាជអាជ្ញា (ដូចដែលបានអានដោយសហព្រះរាជអាជ្ញាអន្តរជាតិ លោក Robert Petit ) ដូចដែលមានក្នុង របាយកាណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០២។

[១៥] របាយកាណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០២។

[១៦] សេចក្តីសន្និដ្ឋានបើកសវនាការរបស់មេធាវីការពារក្តី (ដូចដែលបានអានដោយសហមេធាវីក្តីអន្តរជាតិ លោក Francois Roux) ដូចមានក្នុង របាយកាណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០២។

[១៧] សេចក្តីសន្និដ្ឋានបើកសវនាការរបស់មេធាវីការពារក្តី (ដូចដែលបានអានដោយសហមេធាវីក្តីជាតិ លោក ការ សាវុត្ថ) ដូចមានក្នុង របាយកាណ៍ ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០២។

*អំពើអមនុស្សធម៌ជាច្រើន ត្រលប់ទៅរស់នៅក្នុងសង្គមវិញឬទេ"*[១៨] ។ ការលើកឡើងបែបនេះ គេនឹងអាចយល់បានកាន់តែច្បាស់ក្នុងពេលស្តាប់ភស្តុតាង ដែលបានបង្ហាញនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការតែប៉ុណ្ណោះ ។

## គ. សេចក្តីសង្ខេបនៃការបង្ហាញភស្តុតាង

ប្រមាណជាង ២០សប្តាហ៍ អង្គជំនុំជម្រះបានបើកសវនាការ និងចាត់ប្រភេទភស្តុតាងនីមួយៗ ដោយយោងទៅតាមលំដាប់នៃកាលបរិច្ឆេទ ហើយផ្អែកតាមសេចក្តីណែនាំកម្មវិធីជំនុំជម្រះ ដែលបានចេញផ្សាយមុនពេលចាប់ផ្តើមសវនាការ ។ ប្រភេទនៃភស្តុតាង ត្រូវបានបែងចែកទៅតាមលំដាប់សាក្សីត្រូវផ្តល់សក្ខីកម្មរួមមាន : (១)-អង្គហេតុទាក់ទងនឹងមន្ទីរ ម-១៣ (២)-ការបង្កើតមន្ទីរ ស-២១ និងគុកនៅតាខ្មៅ (៣)-ការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា នៅមន្ទីរ ស-២១ (៤)-ជម្លោះប្រដាប់អាវុធ (ឬ អត្ថិភាពនៃជម្លោះប្រដាប់អាវុធរវាងកម្ពុជា និងវៀតណាម) (៥)-ប្រតិបត្តិការរបស់មន្ទីរ ស-២១ រួមទាំងមន្ទីរជើងឯក (៦)-ការបង្កើត និងប្រតិបត្តិការរបស់មន្ទីរ ស-២៤ និង (៧)-បញ្ហាទាក់ទងនឹងអត្តចារិករបស់ជនជាប់ចោទ ។ ម៉្យាងទៀត អង្គជំនុំជម្រះ ក៏បានស្តាប់សក្ខីកម្មពីសាក្សីអ្នកជំនាញស្តីពីសំណង (និងផលប៉ះពាល់ខាងផ្នែកចិត្តសាស្ត្រទៅលើដើមបណ្តឹងរដ្ឋប្បវេណី និងម្ចាស់បណ្តឹងដទៃទៀត) និងទាក់ទងនឹងការផ្តន្ទាទោសផងដែរ [១៩] ។

តារាងទី ១ ផ្តល់នូវសេចក្តីសង្ខេបនៃសក្ខីកម្មដែលបានបង្ហាញ ឬកត់ត្រាក្នុងប្រតិចារិក ដោយចាត់ប្រភេទនៃភស្តុតាង ។ ជាសរុប សាក្សីចំនួន ៦៩រូប មិនរាប់បញ្ចូលជនជាប់ចោទ បានផ្តល់នូវសក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ក្នុងនោះរួមមាន ២២រូប ជាដើមបណ្តឹងរដ្ឋប្បវេណី ៩រូប ជាសាក្សីជំនាញ និង ៣៨រូប ជាសាក្សីបំភ្លឺអង្គហេតុ ។ ក្នុងចំណោមសាក្សីបំភ្លឺអង្គហេតុទាំងអស់ សាក្សីចំនួន ១៤រូប បានផ្តល់ជាសេចក្តីថ្លែងការណ៍ជូនចំពោះអង្គជំនុំជម្រះដោយមានធ្វើសម្បថផងដែរ ហើយសាក្សី ២៤រូបទៀត បានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការដោយផ្ទាល់ ។ សាក្សីផ្តល់សក្ខីកម្មផ្ទាល់មាត់រាប់បញ្ចូលសាក្សី ១២រូប ដែលអះអាងថា ជាអតីតបុគ្គលិកនៅមន្ទីរ ម-១៣ មន្ទីរ ស-២១ មន្ទីរ ស-២៤ និងមន្ទីរព្រៃស ។ ចំណែកសាក្សី ៧រូប ជាសាក្សីផ្តល់សក្ខីកម្ម អំពីអត្តចរិករបស់ជនជាប់ចោទ និងសាក្សី ៥រូប ជាជនរងគ្រោះដោយផ្ទាល់ ។ ពុំមានសាក្សីណាម្នាក់បានផ្តល់សក្ខីកម្មក្នុងសវនាការ

---

[១៨] សេចក្តីសន្និដ្ឋានបើកសវនាការរបស់មេធាវីការពារក្តី (ដូចដែលបានអានដោយសហមេធាវីក្តីអន្តរជាតិ លោក Francois Roux)ដូចមានក្នុង របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០២។

[១៩] សាក្សីជំនាញដែលបានផ្តល់សក្ខីកម្មទាក់ទងទៅនឹងផ្នែកចិត្តសាស្ត្ររបស់ជនរងគ្រោះ និង បញ្ហាសំណង គឺលោក ឈឹម សុធារ៉ា ដែលជាគ្រូពេទ្យផ្នែកចិត្តវិទ្យា បំរើការនៅអង្គការចិត្តសង្គម និងអន្តរវប្បធម៌ កម្ពុជា (TPO) ក្នុងរាជធានីភ្នំពេញ ។ TPO ត្រូវបានចាត់ទុកថាជាទីប្រឹក្សា ដោយអ.វ.ត.ក នៅក្នុងការជួយផ្តល់ការគាំទ្រចំពោះសាក្សីរបស់តុលាការ នៅក្នុងរយៈពេលសវនាការរបស់ **ឌុច** ។ បន្ថែមពីនេះ លោក Justice Richard Goldstone (អតីតព្រះរាជអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិនៅប្រទេស រ៉ូវ៉ាន់ដា និងអតីតប្រទេសយូហ្គោស្លាវី)និងលោក Stephane Hessel បានផ្តល់សក្ខីកម្មទាក់ទងទៅនឹងស្ថានទំងន់ និងស្ថានសម្រាល ដែលគួរតែពិចារណានៅពេលធ្វើការផ្តន្ទាទោស ជាពិសេសទាក់ទងជាមួយនឹងការទទួលវិប្បដិសារីរបស់ជនជាប់ចោទ ។ ក្រុមឃ្លាំមើលតុលាការបានសម្ភាសន៍ជាមួយបុគ្គលិករបស់ TPO នៅថ្ងៃទី ០៨ តុលា ២០០៨ (ចាប់ពីពេលនេះទៅហៅថា"បទសម្ភាសន៍ជាមួយTPO) ។

អសាធារណៈទេ ដែលនេះជាការអនុវត្តដ៏គួរឱ្យកោតសរសើរចំពោះអង្គជំនុំជម្រះ ក្នុងការការពារសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទទទួលបានសវនាការជាសាធារណៈ ។

**តារាងទី ១ : សេចក្ដីសង្ខេបសក្ខីកម្មរបស់សាក្សី**

| ប្រធានបទ | សាក្សីដែលផ្ដល់សក្ខីកម្ម/ ភាគី | ចំនួនសប្ដាហ៍/ រយៈពេលសវនាការ * | ភាគរយនៃសក្ខីកម្មសរុប * |
|---|---|---|---|
| បញ្ហាទាក់ទងនឹងមន្ទីរ ម-១៣ | ជនជាប់ចោទ, François Bizot (ស.អ.ផ), អ៊ុច ស៊ន (ស.អ.ផ), ចាន់ វឿន (ស.អ.ផ), ចាន់ ខន (ស.អ.ផ) | ២ (របាយការណ៍លេខ ៣ និង ៤) | ១០ |
| ការបង្កើតមន្ទីរ ស-២១ និងគុកតាខ្មៅ | ជនជាប់ចោទ | តិចជាង ១ (របាយការណ៍លេខ ៥) | តិចជាង ៥ |
| ការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្ដកម្ពុជានៅមន្ទីរ ស-២១ | Craig Etcheson (ស.ជ), ជនជាប់ចោទ, ម៉ម ណៃ (ស.អ.ផ), Raoul Marc Jennar (ស.ជ) | ២.៥ (របាយការណ៍លេខ ៥, ៦, ៧, ៨, ១៣ និង ១៩) | ១២.៥ |
| ជម្លោះប្រដាប់អាវុធ | Nayan Chanda (ស.ជ), ជនជាប់ចោទ | ១ (របាយការណ៍លេខ ៧ និង ៨) | ៥ |
| ប្រតិបត្តិការរបស់មន្ទីរ ស-២១<br>រាប់បញ្ចូលទាំងមន្ទីរជើងឯក | ជនជាប់ចោទ, វ៉ាន់ ណាត (ស.អ.ផ), ជុំ ម៉ី (ដ), ប៊ូ ម៉េង (ដ), នង ចាន់ផល (ស.អ.ផ), លី/អ៊ា ហ៊ា (ដ), ឡាយ ចាន់ (ដ), ភោគ ខន (ដ), ជិនរ ម៉ែត (ដ), ណាំ ម៉ុន (ដ), ម៉ម ណៃ (ស.អ.ផ), ហ៊ឹម ហ៊ុយ (ស.អ.ផ), ប្រាក់ ខន (ស.អ.ផ), គោក ស្រស់ (ស.អ.ផ), សួស ធី (ស.អ.ផ), មាស ប៉េងគ្រី (ស.អ.ស), គង់ ផៃ (ស.អ.ស), David Chandler(ស.ជ), ឈុន ផល (ស.អ.ផ), សោម ម៉េត (ស.អ.ផ), ម៉ក់ ស៊ីធីម (ស.អ.ស), តយ តេង (ស.អ.ស), សោម សំអុល (ស.អ.ស), ជ័យ សុភារ៉ា (ស.អ.ស), ហ៊ិន អ៊ីម (ស.អ.ស), កាំង ប៉ាន់ (ស.អ.ស) | ៧ (របាយការណ៍លេខ ៩ ដល់ ១៧) | ៣៥ |
| ការបង្កើត និងប្រតិបត្តិការរបស់មន្ទីរ ស-២៤ | ជិនរ ម៉ែត (ដ), តយ តេង (ស.អ.ស), ប៊ូ ថុន (ស.អ.ផ), អ៊ុក ប៊ុនសេង (ស.អ.ស), ថាច់ សៀក | ២ (របាយការណ៍លេខ ១២ និង ១៧) | ១០ |

| | | | |
|---|---|---|---|
| | (ស.អ.ស), កាំង ប៉ាន់ (ស.អ.ស), ជុំ នៅ (ដ), មាស ប៉េងគ្រី (ស.អ.ផ) | | |
| ការខូចខាត និងការឈឺចាប់ពីបទឧក្រិដ្ឋដែលប្រព្រឹត្តដោយជនជាប់ចោទ | Martine Lefèvre (ដ), អ៊ុក នារី (ដ), Robert Hamil (ដ), Antonia Tioulong (ដ), ហាវ សោភា (ដ), សូ សូង (ដ), នេត ផល្លី (ដ), អ៊ឹម សុទ្ធី (ដ), ភីង ហុតស៊ុនថារី (ដ), សៀង វ៉ាន់ឌី (ដ), ជុំ ស៊ីរ៉ាត់ (ដ), ជុំ នៅ (ដ), អ៊ូ សាវរិទ្ធ (ដ), ឈិន ណាវី (ដ), តូច មុនិន្ទ (ដ) | ១ (របាយការណ៍លេខ ១៨ ដល់ ១៩) | ៥ |
| បញ្ហាទាក់ទងនឹងអត្តចរិករបស់ជនជាប់ចោទ | Françoise Silboni-Guibaud (ស.ជ), ការ ស៊ុនប៊ុណ្ណា (ស.ជ), ស៊ូ សាត (ស.អ.ផ), ទេព សែម (ស.អ.ផ), ទេព សុខ (ស.អ.ផ), ជូ វិន (ស.អ.ផ), ហ៊ុន ស្មៀន (ស.អ.ផ), ប៉េង ភ័ណ (ស.អ.ផ), Christopher Lapel (ស.អ.ផ) | ២.៥ (របាយការណ៍លេខ ១៩, ២០ និង ២១) | ១២.៥ |
| ការផ្តន្ទាទោស ស្ថានទម្ងន់ទោស ស្ថានសម្រាលទោស និង សំណង | ឈឹម សុធារ៉ា (ស.ជ), Richard Goldstone (ស.ជ), Stephan Hessel (ស.ជ), | ១.៥ (របាយការណ៍លេខ ១២ និង ២១) | ៧.៥ |

***<u>ពាក្យសំគាល់</u> :***

ស.ជ : សាក្សីជំនាញ

ស.អ.ផ : សាក្សីបំភ្លឺអង្គហេតុ ដែលផ្តល់សក្ខីកម្មផ្ទាល់ក្នុងតុលាការ

ស.អ.ស : សាក្សីបំភ្លឺអង្គហេតុ ដែលសេចក្តីថ្លែងការណ៍ត្រូវបានអាន និងកត់ត្រានៅក្នុងប្រតិចារិក

ដ. : ដើមបណ្តឹងរដ្ឋប្បវេណី (សំគាល់ : រាប់បញ្ចូលទាំងដើមបណឹងរដ្ឋប្បវេណី ដែលបានផ្តល់សក្ខីកម្ម ហើយលក្ខណៈរបស់គេត្រូវបានតតាំងដោយភាគីការពារក្តី)

(*) សំដៅ "រយៈពេលសវនាការ" : ការប្រមាណរយៈពេល ដោយគណនាចំនួនម៉ោងដែលបានចំណាយក្នុងកំឡុង សប្តាហ៍នៃសវនាការផ្តល់សក្ខីកម្ម និងសម្រាប់តែគោលបំណងគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ ។ "សក្ខីកម្មសរុប" ត្រូវបានផ្តល់ក្នុងលក្ខណៈជាអត្រាភាគរយនៃសក្ខីកម្មសរុបទាំងមូល ។

## ឃ. សេចក្តីសង្ខេបភស្តុតាងបង្ហាញតាមអង្គហេតុ

សេចក្តីសង្ខេបខាងក្រោម នឹងរៀបរាប់នូវការសង្ខេបជារួមនៃភស្តុតាងដែលបានបង្ហាញនាពេលសវនាការទៅតាមប្រភេទនៃភស្តុតាង ហើយដែលភ្ជាប់ជាមួយនឹងសេចក្តីសំខាន់ៗនៃភស្តុតាងដែលដាក់បន្ទុកចំពោះជនជាប់ចោទ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ បន្ថែមលើនេះ ក្រុមយើងបានរាប់បញ្ចូលទាំងការសង្ខេបនៃអំណះអំណាងដែលបានលើកឡើង ក្នុងកំឡុងពេលសវនាការបិទការសួរដេញដោល ។ ចំពោះរឿងរ៉ាវលម្អិតនៃភស្តុតាង

ដែលបានបង្ហាញ សូមពិនិត្យមើលរបាយការណ៍របស់ក្រុមឃ្លាំមើលតុលាការខ្មែរក្រហម ពីលេខ ១ ដល់ ២២ ព្រមទាំងឧបសម្ព័ន្ធដែលពាក់ព័ន្ធ ។

### *១. បញ្ហាទាក់ទងនឹងមន្ទីរ ម-១៣*

ទោះបីជា **ឌុច** មិនបានប្រឈមមុខនឹងការចោទប្រកាន់ ចំពោះតួនាទីរបស់គាត់ជាប្រធានមន្ទីរ ម-១៣ ក៏ដោយ ក៏អង្គជំនុំជម្រះបានកំណត់ថា ការយល់ដឹងអំពីតួនាទីដែលគាត់បានបំពេញនៅមន្ទីរសន្តិសុខនេះ គឺមានសារៈសំខាន់ណាស់ក្នុងការប៉ាន់ប្រមាណអំពីកម្រិតនៃសមត្ថភាពរបស់ជនជាប់ចោទ ក្នុងការអភិវឌ្ឍន៍មន្ទីរសន្តិសុខ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យជាទូទៅ និងជាពិសេសនៅមន្ទីរ ស-២១[២០] ។ បញ្ហានេះបានលេចចេញនៅពេលសក្ខីកម្មរបស់ជនជាប់ចោទ ៖ ផ្អែកតាម **ឌុច** មន្ទីរសន្តិសុខ ម-១៣ បានបែងចែកជា ២ សាខា ដែលក្នុងនោះ ខ្លួនគ្រប់គ្រងដោយផ្ទាល់លើសាខា (ម-១៣"ក") ។ បេសកកម្មចម្បងរបស់ **ឌុច** គឺ "ការវាយ ការសួរចម្លើយ និងការកម្ទេចចារកម្ម ដែលគេចាប់បានពីតំបន់ **លង់ ណុល** ។ (កំឡុងកិច្ចដំណើរការនីតិវិធីសវនាការ បានលេចឡើងនូវពាក្យថា *"កម្ទេច"* គឺជាពាក្យប្រើដោយខ្មែរក្រហម ក្នុងន័យថា *"សម្លាប់"*) ។ សេចក្តីថ្លែងដែលបានលើកឡើងក្នុងសកម្មភាពសម្តែងឡើងវិញ **ឌុច** បានធ្វើចំពោះមុខសហចៅក្រមស៊ើបអង្កេត ដោយបានបរិយាយថា អ្នកដែលមានអំណាចធំដាច់ខាតនៅក្នុងការសម្រេចឱ្យកម្ទេច គឺជា *"ថ្នាក់លើ"* របស់ខ្មែរក្រហម ដែលក្នុងចំណោម នោះរួមមាន តា ម៉ុក, វ៉ន វ៉េត និង ជួរ ជេត (ហៅថា បង "គ")[២១] ។ **ឌុច** ហាក់បញ្ជាក់ថា គាត់បានអនុវត្ត សកម្មភាពហិង្សាក្រោមការបញ្ជារបស់ថ្នាក់លើ ហើយដែលជំហរនេះគេឃើញជាបន្តបន្ទាប់នៃថ្ងៃសវនាការ ។

អង្គជំនុំជម្រះ បានកោះហៅសាក្សីចំនួន ៤រូប ចូលផ្តល់សក្ខីកម្មនៅក្នុងផ្នែកនេះ ៖ លោក François Bizot ជាអតីតអ្នកទោសនៅក្នុងជំរុំ ព្រមទាំងលោក អ៊ុច ស៊ន, លោក ចាន់ វឿន និងលោក ចាន់ ខន ដែលអ្នកទាំងនោះបានពោលអះអាងថា ជាអតីតបុគ្គលិកនៅមន្ទីរ ម-១៣ (តែត្រូវបានជនជាប់ចោទបដិសេធន៍)[២២] ។ ការវាយតម្លៃអំពីអត្តចរិករបស់ **ឌុច** ដោយលោក Bizot ហាក់មាននិន្នាការគាំទ្រទ្រឹស្តីរបស់មេធាវីការពារក្តី ដែលថា ជនជាប់ចោទគឺជា *"ឧបករណ៍"* របស់រដ្ឋ បង្កើតឱ្យមានការសម្លាប់រង្គាល និងម៉្យាងទៀត គាត់លើកឡើងថា **ឌុច** គ្រាន់តែជាបុរសវ័យក្មេងម្នាក់ ដែលបានបូជាកម្លាំងកាយចិត្តរបស់ខ្លួន ដើម្បីសម្រេចគោលបំណង ដោយផ្អែកលើគំនិតថា ឧក្រិដ្ឋកម្មមិនមែនជាអំពើខុសច្បាប់ទេ តែគឺជាអ្វីដែលគេត្រូវតែធ្វើ[២៣] ។ សាក្សី ៣រូប ដទៃទៀត បានអះអាងថា លក្ខខណ្ឌ

---

[២០] "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី "នៃអង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក (១៨ កុម្ភៈ ២០០៩) យោបល់ផ្តល់ដោយលោកស្រីចៅក្រម Cartwright ទំព័រ ៤ បន្ទាត់ទី ១-៨ ។ សូមមើលផងដែរ របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០១ (សវនាការបឋម ១៧-១៨ កុម្ភៈ ២០០៩) ។ ទាក់ទងបញ្ហានេះ សក្ខីកម្មអំពី ម-១៣ អាចជាផ្នែកមួយនៅក្នុងការកំនត់ពីកម្រិតនៃពិរុទ្ធភាពប្រព្រឹត្តដោយជនជាប់ ចោទ ចំពោះបទឧក្រិដ្ឋដែលបានរងការចោទប្រកាន់ និងបានប្រព្រឹត្ត នៅក្រោមដីកាដំណោះស្រាយ ។

[២១] សូមមើល របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០៣ ។

[២២] សូមមើល របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០៣ សម្រាប់សក្ខីកម្មរបស់លោក Francois Bizot និង លោក អ៊ុច ស៊ន និង របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០៤ សម្រាប់សក្ខីកម្មរបស់លោក ចាន់ វឿន និង លោក ចាន់ ខន ។

[២៣] របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០៣ ។

សម្រាប់អ្នកទោសនៅមន្ទីរ ម-១៣ មានលក្ខណៈសាហាវឃោរឃៅ និងមានអំពើហិង្សាច្រើនជាងអ្វី ដែលជនជាប់ចោទបានលើកឡើងទៀត ជាពិសេសពាក់ព័ន្ធនឹងចំនួនអ្នកទោសដែលជាប់ក្នុងគុកធំ ក្នុងរណ្ដៅចំហ ដែលស្ថិតក្រោមលក្ខខណ្ឌសួរចម្លើយ និងការឃុំឃាំង ។

## ២. *ការបង្កើតមន្ទីរ ស-២១ និង គុកតាខ្មៅ*

គេបានតាំងសំនួរដល់ជនជាប់ចោទដើម្បីឱ្យគាត់ពន្យល់ពីការបង្កើតមន្ទីរ ស-២១ និងគុកតាខ្មៅ ដោយគ្មានសាក្សីណាម្នាក់ត្រូវបានកោះហៅឱ្យមកផ្ដល់សក្ខីកម្មអំពីអង្គហេតុនេះ ។ ទោះជាយ៉ាងណាក៏ដោយ សាក្សីដទៃទៀតបានផ្ដល់លម្អិត អំពីការបង្កើតមន្ទីរទាំងនេះ តាមរយៈសក្ខីកម្មរបស់ខ្លួន[២៤] ។ ភស្ដុតាងសំខាន់បំផុតដែលផ្ដល់ដោយជនជាប់ចោទកំឡុងសវនាការ គឺពាក់ព័ន្ធនឹងរចនាសម្ព័ន្ធនៃការរាយការណ៍ ដែលត្រូវបានអនុវត្តនៅមន្ទីរ ស-២១ ហើយភស្ដុតាងនេះត្រូវបានអង្គជំនុំជម្រះយកមកពិចារណា នៅពេលធ្វើការប៉ាន់ប្រមាណអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទ ថាជាអ្នកក្ដោបក្ដាប់មុខនាទីជាប្រធានមន្ទីរ ស-២១[២៥] ។ យោងតាម **ឌុច** អ្នកក្រោមបង្គាប់គាត់ទាំងអស់នៅមន្ទីរ ស-២១ ត្រូវរាយការណ៍ផ្ទាល់ទៅគាត់ បន្ទាប់មកគាត់រាយការណ៍បន្តទៅគណៈអចិន្ត្រៃយ៍របស់បក្សកម្ពុជាប្រជាធិបតេយ្យ ដែលជាផ្នែកមួយរបស់គណៈមជ្ឈិមបក្ស ។ គណៈមជ្ឈិមបក្សត្រូវបានស្គាល់ថា *"ជាអង្គភាពខ្ពស់បំផុត និងមានអំណាចសម្រេចគ្រប់បញ្ហាធំៗនៅក្នុងរបបកម្ពុជា ប្រជាធិបតេយ្យ"*[២៦] ។ ជនជាប់ ចោទបានចង្អុលបង្ហាញពីដំណើរនៃការរាយការណ៍ ដោយបានសារភាពមួយចំនួនថា គាត់ធ្លាប់បានធ្វើចំណារ ហើយ ផ្ញើជូនទៅ **សុន សេន** (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ និងសន្តិសុខ ព្រមទាំងជាសមាជិករបស់ គណៈ អចិន្ត្រៃយ៍) ហើយបន្ទាប់មកផ្ញើទៅ **នួន ជា** (ហៅកាត់ថា *"បងទី ២"*) ដោយផ្ដើមថា *"បងជាទីគោរព"* ។ ចំពោះចំណារផ្សេងទៀតលើចម្លើយសារភាពបង្ហាញថា **សុន សេន** បានបញ្ជូនឯកសារទាំងនេះទៅ **ប៉ុល ពត** ឬ ក៏បញ្ជូនទៅសមាជិកគណៈអចិន្ត្រៃយ៍ ប្រសិនបើគាត់យល់ឃើញថាសមស្រប ។ ជនជាប់ចោទក៏បានទាមទារស្នើសុំជួបផ្ទាល់លើ *"ជាញឹកញាប់"* ដើម្បីពិភាក្សាពីសកម្មភាពនៅក្នុងមន្ទីរ ស-២១[២៧] ។

## ៣. *ការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្ដកម្ពុជានៅមន្ទីរ ស-២១*

ភស្ដុតាងនៃការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្ដកម្ពុជា នៅមន្ទីរ ស-២១ គឺមានសារៈសំខាន់ណាស់ដែលនាំឱ្យអង្គជំនុំជម្រះអាចឱ្យកំណត់អំពី : (១) កម្រិតដែលជនជាប់ចោទបានដឹងពីផែនការរួម គោលបំណងរួម ការរៀបចំរួម ដែលបង្កើតបានជាទំរង់នៃសហកម្មឧក្រិដ្ឋកម្មរួម ហើយដោយយោងលើទ្រឹស្ដីនេះ សហព្រះរាជអាជ្ញាបានចោទប្រកាន់ថា ជនជាប់ចោទមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលកើតឡើង (តើទ្រឹស្ដីនេះអាចអនុវត្ត

---

[២៤] សូមមើល សក្ខីកម្មរបស់លោក Craig Etcheson ជាឧទាហរណ៍ ដូចមានក្នុងរបាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ 0៦ និងប្រតិចារិក : សក្ខីកម្មរបស់លោក David Chandler ដូចមានក្នុង របាយកាណ៍ឃ្លាំមើល តុលាការខ្មែរក្រហម លេខ ១៦ ព្រមទាំងប្រតិចារិកពាក់ព័ន្ធ ។

[២៥] ជនជាប់ចោទ ត្រូវបានចោទថាជាមន្ត្រីជាន់ខ្ពស់ នៅផ្នែកទី ៤ នៃដីកាដំណោះស្រាយ ។

[២៦] ដីកាដំណោះស្រាយ កឋា. ៣២ ។

[២៧] សក្ខីកម្មរបស់ជនជាប់ចោទ ដូចមានក្នុងរបាយកាណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ 0៤ និង ឧបសម្ព័ន្ធ "ក" ។

បានឬទេ នៅក្នុងសំណុំរឿងនេះ) (២) ធាតុផ្សំសំខាន់ៗនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជនជាប់ចោទបានរង ការចោទប្រកាន់ (នោះជាវិសាលភាពឧក្រិដ្ឋកម្មដែលបានកើតឡើងនៅមន្ទីរ ស-២១ ជាទម្រង់មួយនៃការវាយ ប្រហារជាទូទៅ ឬការវាយប្រហារជាប្រព័ន្ធប្រឆាំងទៅលើប្រជាជនស៊ីវិលនៅទូទាំងកម្ពុជា ដោយមូលហេតុ ជាតិ ពន្ធ ពូជសាសន៍ សាសនា ឬនយោបាយ[២៨] ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ *"អាដហុក"* បានប្រកាន់ខ្ជាប់ថា ទោះបី ជាគោលនយោបាយ ឬផែនការមិនត្រូវបានតម្រូវឱ្យបញ្ជាក់ពីការវាយប្រហារជាទូទៅ ឬការវាយប្រហារជាប្រព័ន្ធ បានកើតឡើង ក៏ភស្តុតាងនៃគោលនយោបាយ ឬផែនការ អាចត្រូវបានប្រើប្រាស់នៅក្នុងគោលបំណងនេះតែ ប៉ុណ្ណោះ[២៩] ។

អង្គជំនុំជម្រះ ហាក់បង្ហាញពីការជឿជាក់របស់ខ្លួនលើសលុបទៅលើសាក្សីជំនាញ និងជនជាប់ចោទក្នុង ការទទួលបានព័ត៌មានទាក់ទងនឹងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តនៅមន្ទីរ ស-២១ ។ បញ្ហានេះ ប្រហែល ជាដោយសារ អង្គជំនុំជម្រះមានការលំបាកក្នុងការទទួលបានសក្ខីកម្មពីសាក្សីទាក់ទងនឹងបញ្ហានេះ ព្រោះសាក្សីជា ច្រើនដែលនៅពីលើ **ឌុច** ហើយអាចផ្តល់ព័ត៌មានសំខាន់ៗ បច្ចុប្បន្ននេះបានស្លាប់អស់[៣០] ។ ហេតុដូច្នេះហើយ ភាគច្រើននៃការពិចារណារបស់អង្គជំនុំជម្រះចំពោះការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តនៅមន្ទីរ ស-២១ ត្រូវពឹងផ្អែកទាំងស្រុងទៅលើសក្ខីកម្មរបស់សាក្សីជំនាញ លោក Craig Etcheson និង លោក Raoul Marc Jennar ស្តីពីកម្រិតនៃការអនុវត្តការត្រួតត្រារបស់ជនជាប់ចោទ នៅមន្ទីរស-២១ (មន្ទីរស-២១ ជាអង្គភាព ពិសេស) ព្រមទាំងពឹងផ្អែកទៅលើសក្ខីកម្មរបស់ជនជាប់ចោទខ្លួនឯង ។ ទោះបីជាមានចំណុចរួមរវាងអ្នកផ្តល់ សក្ខីកម្មទាំងបី ក៏លោក Etcheson មិនយល់ស្របដាច់ខាតជាមួយលោក Jennar និងជនជាប់ចោទ ទាក់ទងនឹង

---

[២៨] អ្នកអត្ថាធិប្បាយខ្លះ បានកត់សម្គាល់ថា អង្គជំនុំជម្រះនឹងត្រូវធ្វើការប៉ាន់ប្រមាណទៅលើវិសាលភាពដែលនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ ត្រូវបានធ្វើឱ្យភ្លឺច្បាស់ដូចជាផ្នែកមួយនៃទម្លាប់ច្បាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ក៏ដូចជាទៅលើវិសាលភាដែលប្រភេទ នៃច្បាប់នេះ បានអនុវត្តនៅក្នុងប្រទេសកម្ពុជា ។ ជាឧទាហរណ៍ សូមមើល បរិមាអិប្បាយរបស់ Anne Heindel នៅ John Ciorciaria និង និពន្ធ របស់ Anne Heindel : *សវនាការ : ដំណើរការនៃការទទួលខុសត្រូវរបស់ខ្មែរក្រហម (ភ្នំពេញ: មជ្ឈមណ្ឌលឯកសារកម្ពុជា ២០០៩)*

[២៩] សូមមើល សំណុំរឿងក្តី *Prosecutor v Semanza* (Case No. ICTR -97-20-A) សាលក្រមរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ (២០ ឧសភា ២០០៥). សំណុំរឿងក្តី *Prosecutor v Kunarac et al* (Case No. IT- 96-23/1-A) សាលក្រមរបស់អង្គជំនុំជម្រះ សាលាឧទ្ធរណ៍ (១២ មិថុនា ២០០២) កឋា. ៩៨. សំណុំរឿងក្តី *Prosecutor v Brdanin* (Case No. IT- 99-36-T, T.CH II) សាល ក្រមរបស់អង្គជំនុំ ជម្រះសាលាដំបូង (០១ កញ្ញា ២០០៤) កឋា. ១៣៧ ។

[៣០] ជាឧទាហរណ៍សំខាន់ជាងគេនៅក្នុងផ្នែកនេះគឺ លោក **សុន សេន** ជាអតីតឧបនាយករដ្ឋមន្ត្រីខ្មែរក្រហម ទទួលបន្ទុកខាងការពារជាតិ ដែលគួសបញ្ជាក់ជាញឹកញាប់នៅក្នុងសក្ខីកម្មរបស់ជនជាប់ចោទ ។ គាត់ត្រូវបានសម្លាប់នៅឆ្នាំ ១៩៩៧ ក្នុងកំឡុងពេលបែកបាក់ក្រុមបក្ស ក្នុងខ្មែរក្រហម ។ ជាឧទាហរណ៍ សូមមើល របាយកាណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០៩ និង ឧបសម្ព័ន្ធ "ក" ។ បន្ថែមពីនេះ ភស្តុតាងនៅក្នុងការគាំទ្រផ្សេងទៀតក្រៅអំពីរចនាសម្ព័ន្ធដ៏តឹងរឹងនៃខ្សែបណ្តោយពីថ្នាក់លើមកថ្នាក់ក្រោម ដែលមានរវាងជនជាប់ចោទ និង ថ្នាក់លើរបស់គាត់ គឺមានការខ្វះខាត ។ យោងទៅតាមសក្ខីកម្មរបស់សាក្សីជំនាញ លោក Craig Etcheson (ដែលបានធ្វើការ បញ្ជាក់ទៅទស្សនាទានរបស់ជនជាប់ចោទ) ទំនាក់ទំនងខ្សែទទឹង ត្រូវបានអនុញ្ញាតិ លុះត្រាតែមានការ អនុញ្ញាតិពីថ្នាក់លើ ។ សូមមើល សក្ខីកម្មរបស់លោក Craig Etcheson ដូចមានក្នុងរបាយកាណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០៧ ។

ភាពសំខាន់នៃមន្ទីរ ស-២១ និងតំណែងរបស់ **ឌុច** ជាប្រធាន ។ ផ្អែកលើមន្ទីរនេះ គឺជា *"ការិយាល័យសន្តិសុខដែលជាមុំមួយនៃអំណាចរបស់បក្សកម្ពុជាប្រជាធិបតេយ្យ"* លោក Etcheson បានបញ្ជាក់ថា *"មានតែមន្ទីរនេះទេដែលអាចចាប់ខ្លួន និងឃុំខ្លួនមនុស្សទូទាំងប្រទេស"*[៣១] ។ ដោយឡែកលោក Jennar ជឿជាក់ថា វិសាលភាពរបស់មន្ទីរ ស-២១ គឺត្រូវពិចារណាផ្តាច់ចេញពីមន្ទីរសន្តិសុខផ្សេងៗទៀត នៅក្នុងប្រទេសកម្ពុជា ។ ទោះជាយ៉ាងណា សាក្សីជំនាញទាំងពីររូប បានយល់ស្របថា ការបោសសំអាតអ្នកដែលគេចាត់ទុកថាជាសត្រូវនយោបាយ បានក្លាយទៅជាច្បាប់មួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយនេះគឺជាការសន្និដ្ឋានមួយ ដែលទំនងជាគាំទ្រចំពោះការលើកឡើងអំពីការវាយប្រហារជាទូទៅប្រឆាំងនឹងជនស៊ីវិលដោយមូលហេតុនយោបាយ ដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[៣២] ។

### *៤. ជម្លោះប្រដាប់អាវុធ*

ដើម្បីបង្ហាញអំពីការអនុវត្តអនុសញ្ញាទីក្រុងហ្សឺណែវ ក្នុងករណីរបស់ជនជាប់ចោទ (ហេតុនេះការចោទប្រកាន់ ដែលទាក់ទងនឹងការអនុវត្តសន្ធិសញ្ញានេះ គឺមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ) អង្គជំនុំជម្រះនឹងធ្វើការវាយតម្លៃ ថាតើលក្ខខណ្ឌទូទៅ ៤យ៉ាង កើតមានកំឡុងរបបកម្ពុជាប្រជាធិបតេយ្យឬទេ : (១)អត្ថិភាពជម្លោះប្រដាប់អាវុធ (២)ជម្លោះប្រដាប់អាវុធមានលក្ខណៈជាអន្តរជាតិ (៣)អត្ថិភាពនៃការទំនាក់ទំនងរវាងបទឧក្រិដ្ឋ និងជម្លោះប្រដាប់អាវុធ (៤)ជនរងគ្រោះនៃបទឧក្រិដ្ឋនេះ គឺជាបុគ្គលដែលត្រូវបានការពារ យោងតាមបទបញ្ញត្តិនៃអនុសញ្ញាទីក្រុងហ្សឺណែវ ។ អង្គជំនុំជម្រះជាន់ខ្ពស់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) បានបង្កើតលក្ខណៈវិនិច្ឆ័យ ដើម្បីកំណត់ពីការរំលោភបំពានធ្ងន់ធ្ងរបទបញ្ញត្តិនៃអនុសញ្ញានេះ[៣៣] ។

អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មសាក្សីជំនាញលោក Nayan Chanda អំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធរវាងប្រទេសកម្ពុជា និងវៀតណាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[៣៤] ។ លោក Chanda គឺជាអ្នកកាសែតរបស់ទសន្សនាវដ្តី *Far Eastern Economic Review* ហើយរាយការណ៍អំពីប្រទេសវៀតណាម និងកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ថ្វីបើ លោកមិនមែនជាអ្នកជំនាញផ្នែកច្បាប់ លោកបានផ្តល់សក្ខីកម្មថា ប្រទេសជាតិទាំងពីរនេះ មានសង្គ្រាមប្រដាប់អាវុធទៅវិញទៅមកចាប់តាំងពីថ្ងៃដួលរលំរាជធានីភ្នំពេញ ឆ្នាំ១៩៧៥ មកម្ល៉េះ ។ យោងទៅតាមលោក Chanda ប្រទេសវៀតណាម បានប្រកាសសង្គ្រាមជាផ្លូវការជាមួយប្រទេសកម្ពុជា នៅខែធ្នូ

---

[៣១] សូមមើល សក្ខីកម្មរបស់លោក Craig Etcheson ដូចមានក្នុងរបាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០៦។

[៣២] សូមមើល សក្ខីកម្មរបស់លោក Craig Etcheson ដូចមានក្នុងរបាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០៦ និង សក្ខីកម្មរបស់លោក Raoul Marc Jennar ដូចមានក្នុងរបាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ២១។

[៣៣] សំណុំរឿងក្តី *Prosecutor v Brdanin* (Case No. IT- 99-36-T, T.CH II) សាលក្រមរបស់អង្គជំនុំ ជម្រះសាលាដំបូង (០១ កញ្ញា ២០០៤) កថា. ១២១ ។

[៣៤] សូមមើល សក្ខីកម្មរបស់លោក Nayan Chanda ដូចមានក្នុងរបាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០៧ ។

ឆ្នាំ១៩៧៧ ។ លោក Chanda បាននិយាយថា ខ្មែរក្រហមមានការទទួលខុសត្រូវសម្លាប់ជនជាតិវៀតណាមទាំងអ្នកទោសស៊ីវិល និងអ្នកទោសសង្គ្រាម (ឈ្លើយសឹក) ដែលអ្នកទោសប្រភេទនេះត្រូវបានការពារ ដោយអនុសញ្ញាទីក្រុងហ្សឺណែវ ។ លោកក៏បានកត់សម្គាល់ដែរថា ឆន្ទៈប្រឆាំងវៀតណាម ត្រូវបានយកមកប្រើប្រាស់ដោយខ្មែរក្រហម ដើម្បីបង្ហាញសកម្មភាពរបស់ខ្លួនប្រឆាំងនឹងវៀតណាម ។ អត្ថិភាពនៃប្រជាពលរដ្ឋស៊ីវិល និងឈ្លើយសឹកវៀតណាមនៅមន្ទីរ ស-២១ (បញ្ជាក់ដោយជនជាប់ចោទខ្លួនឯង និងសាក្សីមួយចំនួនដែលបានផ្តល់សក្ខីកម្មបន្តបន្ទាប់ អំពីការប្រព្រឹត្តទៅនៃមន្ទីរសន្តិសុខ[៣៥]) ។

## ៥. ប្រតិបត្តិការរបស់មន្ទីរ ស-២១ (រាប់បញ្ចូលទាំងមន្ទីរជើងឯក)

ដូចដែលបានឃើញនៅក្នុងតារាងទី ១ ពេលវេលាមួយភាគធំ អង្គជំនុំជម្រះប្រើសម្រាប់ការស្តាប់សក្ខីកម្មទាក់ទងនឹងប្រតិបត្តិការរបស់មន្ទីរ ស-២១ និង ជើងឯក ។ ភស្តុតាងទាំងនេះ ហាក់មានសារៈសំខាន់ក្នុងការបង្ហាញថា បទឧក្រិដ្ឋដែលជនជាប់ចោទទទួលរងការចោទប្រកាន់ ដូចជា : មនុស្សឃាត ការបំផ្លិចបំផ្លាញ ទារុណកម្ម ការធ្វើទុក្ខបុកម្នេញ អំពើហឹង្សាលើរូបរាងកាយ និងការរំលោភសេពសន្ថវៈ គឺបានប្រព្រឹត្តនៅមន្ទីរ ស-២១ ។ ម៉្យាងទៀត តាមការប៉ាន់ប្រមាណទីតាំងភូមិសាស្ត្រ និងវិសាលភាពនៅមន្ទីរ ស-២១ អាចនិយាយបានថា ជាបណ្តុំនៃប្រជាពលរដ្ឋស៊ីវិល ឬក៏ជាប្រជាពលរដ្ឋ ដែលមកពីតំបន់ភូមិសាស្ត្រផ្សេងៗនៅទូទាំងប្រទេសកម្ពុជា ករណីនេះគឺជាជំនួយដ៏សំខាន់ សម្រាប់អង្គជំនុំជម្រះក្នុងការប៉ាន់ប្រមាណវិសាលភាព ដែលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានប្រព្រឹត្តឡើងនៅមន្ទីរ ស-២១ ។

យោងតាមការគណនាដោយក្រុមឃ្លាំមើលតុលាការ អង្គជំនុំជម្រះបានចំណាយពេលប្រមាណជា ៣៥ភាគរយ នៃរយៈពេលផ្តល់សក្ខីកម្មសរុបដើម្បីស្តាប់ការផ្តល់ភស្តុតាងអំពីអង្គហេតុនេះ ។ នៅក្នុងប្រភេទនៃសាក្សីអង្គហេតុដែលបានផ្តល់សក្ខីកម្ម ភាគច្រើនគឺជាអតីតបុគ្គលិកនៅមន្ទីរ ស-២១ ដែលមានតួនាទីជាអ្នកសួរចម្លើយ ជាឆ្មាំយាមគុក ជាបុគ្គលិកផ្នែករដ្ឋបាល និងពេទ្យ[៣៦] ។ រយៈពេលតិចជាងនេះ ពោលគឺ ១០ភាគរយ

---

[៣៥] សូមមើល សក្ខីកម្មរបស់ជនជាប់ចោទ ដូចមានក្នុងរបាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០៩ និងប្រតិចារិកពាក់ព័ន្ធ : សក្ខីកម្មរបស់លោក ហ៊ឹម ហុយ ដូចមានក្នុងរបាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៤ និងប្រតិចារិក : សក្ខីកម្មរបស់លោក ឡាច មាន លោក ពៀម អេន និង លោក គង់ ផៃ (ទាំងអស់ជា អតីតបុគ្គលិកមន្ទីរ ស-២១) ដូចមានក្នុងរបាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៦ និង ឧបសម្ព័ន្ធ "ក" ព្រមទាំងប្រតិចារិកពាក់ព័ន្ធ ។

[៣៦] អតីតអ្នកសួរចម្លើយ ដែលបានផ្តល់សក្ខីកម្មទាក់ទងនឹងផ្នែកនេះ រួមមាន : លោក ម៉ម ណៃ (របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៣) លោក ហ៊ឹម ហ៊ុយ និង លោក ប្រាក់ ខន (របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៣ និង ១៤។ អតីតឆ្មាំយាមគុក ដែលបានផ្តល់សក្ខីកម្មទាក់ទងនឹងផ្នែកនេះ រួមមាន : លោក គោក ស្រស់ (របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៤ លោក ជៀម សឿ និង លោក ខៀវ យ៉េត (របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៦) ។ អតីតបុគ្គលិករដ្ឋបាលដែលបានផ្តល់សក្ខីកម្ម ទាក់ទងនឹងផ្នែកនេះ រួមមាន : លោក សួស ធី (របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៥) និងលោក ឡាច មាន (របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៦ ) ។ អ្នកស្រី ណាំ ម៉ុន ក៏បានទាមទារថា ជាអតីតបុគ្គលិកពេទ្យនៅមន្ទីរ ស-២១ ដែរ ។ ទោះជាយ៉ាងណាក្តី លក្ខខណ្ឌជាបុគ្គលិកពេទ្យរបស់គាត់ ត្រូវបានជំទាស់ដោយជនជាប់ចោទ ។ សូមមើល របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១២ និង ១៣ ។

ឬស្មើនឹង ២ សប្តាហ៍ នៃរយៈពេលផ្តល់សក្ខីកម្មសរុប ត្រូវបានចំណាយដើម្បីស្តាប់សក្ខីកម្មអំពីការបង្កើត និង ប្រតិបត្តិការរបស់មន្ទីរ ស-២៤ បើទោះបីផ្នែកខ្លះនៃសក្ខីកម្មទាំងនោះជាន់គ្នាជាមួយនឹងអង្គហេតុស្តីពីប្រតិបត្តិការ នៅមន្ទីរ ស-២១។

អង្គជំនុំជម្រះ និងគូភាគី បានផ្តោតសំខាន់លើការសាកសួរសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី អំពីលក្ខខណ្ឌ ស្ថានភាពនៅមន្ទីរ ស-២១ ព្រមទាំងវិធីសាស្ត្រនៃការសួរចម្លើយ និងការធ្វើទារុណកម្មដែលធ្វើដោយអ្នកសួរចម្លើយ នៅទីនោះ ។ សេចក្តីលម្អិតមួយចំនួនត្រូវបាន ជនជាប់ចោទខ្លួនឯង និងសាក្សីមួយចំនួនប្រាប់ឱ្យដឹងថា អ្នកទោស ត្រូវបានសម្លាប់ដោយការបូបឈាមអស់ពីរាងកាយ[៣៧] ។ ចំណែកឯ អ្នកទោសផ្សេងទៀត ត្រូវបានគេធ្វើទារុណកម្ម ដោយវិធីសាស្ត្រដ៏គួរឱ្យខ្ពើមរអើម ដូចជា ការបង្ខំឱ្យស៊ីលាមកមនុស្ស និងផឹកទឹកនោម ឬក៏យកទៅធ្វើការ ពិសោធន៍ផ្នែកវេជ្ជសាស្ត្រ[៣៨] ។ ទារកតូចៗត្រូវបានបោកទំលាក់ពីជាន់លើអគារនៃមន្ទីរ ស-២១[៣៩] និងមាន អ្នកទោសម្នាក់ត្រូវបានដុតទាំងរស់[៤០] ។ បន្ថែមលើនេះ **ឌុច** និងសាក្សីដទៃទៀត រួមមាន លោក **ហ៊ឹម ហ៊ុយ** និង លោក **ប្រាក់ ខន** បានទទួលស្គាល់ថា មានការរំលោភសេពសន្ថវៈលើអ្នកទោសស្រី ទោះបីជា ហេតុការណ៍នេះ មិនបានកើតមានជាទូទៅនៅមន្ទីរ ស-២១ ក៏ដោយ[៤១] ។

សាក្សីមួយចំនួនក៏ត្រូវបានសួរដេញដោលផងដែរ អំពីស្ថានភាពអ្នកទោសនៅមន្ទីរ ស-២១ ។ ជនជាប់ ចោទបានកត់សម្គាល់ថា មានវត្តមាននៃអ្នកទោសចំនួន ៤៨នាក់ មកពី ១១ប្រទេស នៅមន្ទីរ ស-២១[៤២] ។ អតីតអ្នកសួរចម្លើយជាច្រើនរូប បានបញ្ជាក់ថា **ឌុច** ពិតជាមិនមានវត្តមានផ្ទាល់ ឬក៏ចូលរួមនៅក្នុងការសួរ ចម្លើយនៅមន្ទីរ ស-២១ ទេ ។ ទោះជាយ៉ាងណា ពួកគេបានបន្ថែមថា **ឌុច** ជាមេបញ្ជាការរួម នៅក្នុងមន្ទីរ នេះ[៤៣] ។ ម៉្យាងទៀតទាំងសាក្សី ក៏ដូចជាជនជាប់ចោទ បានថ្លែងយ៉ាងលម្អិត អំពីវិសាលភាពនៃការចូលរួមរបស់ ជនជាប់ចោទក្នុងការបណ្តុះបណ្តាលវគ្គសួរចម្លើយ[៤៤] ។ សាក្សីជំនាញលោក David Chadler ក៏បានផ្តល់សក្ខីកម្ម ចំពោះមុខអង្គជំនុំជម្រះថា ជាទូទៅពាក់ព័ន្ធនឹងការពង្រីកទស្សនៈរបស់ខ្លួន ដែលមាននៅក្នុងសៀវភៅរបស់គាត់

---

[៣៧] សក្ខីកម្មរបស់លោក **ប្រាក់ ខន** ដូចមានក្នុងរបាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៤ និង ប្រតិចារិកពាក់ព័ន្ធ (ទោះជាយ៉ាង ណា គួរកត់សម្គាល់ថា ជនជាប់ចោទ បានជំទាស់នឹងវិសាលភាពដែលការអនុវត្តនេះបានប្រព្រឹត្ត) ។

[៣៨] សក្ខីកម្មរបស់ជនជាប់ចោទ ដូចមានក្នុងរបាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០៩ និង ប្រតិចារិកពាក់ព័ន្ធ ។

[៣៩] សក្ខីកម្មរបស់លោក ប្រាក់ ខន ដូចមានក្នុងរបាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៤។

[៤០] សក្ខីកម្មរបស់លោក ជៀម សឿ ដូចមានក្នុងរបាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៦ និង ឧបសម្ព័ន្ធ "ក" ។

[៤១] ចំនុចនេះ ហាក់ដូចជាជំទាស់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលោកស្រី Silke Studzinsky និង លោក គង់ ពិសី ក្នុងកំឡុង ពេលសេចក្តីសន្និដ្ឋានបិទការសួរដេញដោល ។

[៤២] សូមមើល របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០៩។

[៤៣] សក្ខីកកម្មរបស់លោក គោក ស្រស់ ដូចមានក្នុងរបាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៥ និង ឧបសម្ព័ន្ធ "ក" ។

[៤៤] ជាឧទាហរណ៍ សូមមើល របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០៩។

ឈ្មោះថា "*សម្លេងពីមន្ទីរ ស-២១*" : ភាពភ័យខ្លាច និងប្រវត្តិនៅក្នុងគុកដ៏អាថិកំបាំងរបស់ ប៉ុល ពត (សាព័តិមាន របស់សាកលវិទ្យាល័យកាលីហ្វូរនី ឆ្នាំ១៩៩៩)[៤៥] ។

## ៦. ការបង្កើត និងប្រតិបត្តិការរបស់មន្ទីរ ស-២៤ (មន្ទីរព្រៃស)

មន្ទីរ ស-២៤ ត្រូវបានចាត់ទុកជាពិសេសថា *"ជាកន្លែងសម្រាប់រក្សាទុកអ្នកទោស"* ដែលត្រូវគេទុកធ្វើការអប់រំ មុនបញ្ជូនទៅអង្គភាពផ្សេង។ សាក្សីទាំងអស់ផ្តល់សក្ខីកម្មថា ពួកគេជាប់ឃុំនៅមន្ទីរ ស-២៤ ហើយបានបញ្ជាក់ថា អ្នកទោសដែលមិនបាន *"សម្រេចនូវការលត់ដំ"* ត្រូវបញ្ជូនទៅមន្ទីរ ស-២១ ក្នុងគោលបំណងកម្ទេចចោល ។ សាក្សីឈ្មោះ **កាំង ប៉ាន់** ជាអតីតបុគ្គលិកនៅមន្ទីរ ស-២៤ បានសារភាពថា គាត់បានយកអ្នកទោសចេញដោយផ្ទាល់ពីមន្ទីរ ស-២៤ តាមរយៈដាក់ឡានទ្រុងនៅពេលយប់ ។ សាក្សី **ថាច់ សៀក** ជាអតីតបុគ្គលិកផ្សេងទៀតមានតួនាទីជាអ្នកចុះលេខ និងចំនួនអ្នកទោសនៅព្រៃស ប្រមាណជា ២.០០០នាក់ ។ សាក្សីទាំងអស់ ក៏ដូចជាដើមបណ្តឹងរដ្ឋប្បវេណី (រួមទាំងអ្នកស្រី **ជុំ នៅ**) បានដៅបញ្ជាក់ពីភាពសាហាវឃោរឃៅ នៃស្ថានភាពធ្វើការងារនៅជំរុំកសាងកែប្រែ ដោយអ្នកទោសគ្រប់រូបមានភាពស្គមស្គាំង និងបង្ខំឱ្យធ្វើការជាទម្ងន់រហូតដល់ ១៨ ម៉ោងក្នុងមួយថ្ងៃ[៤៦] ។

## ៧. បញ្ហាទាក់ទងនឹងអត្តចរិករបស់ជនជាប់ចោទ

ជាសរុប សាក្សីផ្តល់សក្ខីកម្មលើអត្តចរិករបស់ជនជាប់ចោទមានចំនួន ៧រូប ដែលក្នុងនោះ សាក្សី ៣រូប បានស្គាល់ជនជាប់ចោទ មុនពេលរដ្ឋាភិបាលរបស់សម្តេចសីហនុចាប់ដាក់ពន្ធនាគារនៅ ឆ្នាំ១៩៦៨ ហើយ សាក្សី ៤ រូបទៀត បានស្គាល់ជនជាប់ចោទនៅពាក់កណ្តាល ឆ្នាំ១៩៥០ ដែលពេលនោះគាត់បម្រើការងារជាគ្រូបង្រៀននៅស្រុកស្វាយចេក ។ ជាទូទៅ **ឌុច** ត្រូវបានចាត់ទុកថា ជាមនុស្សមានអត្តចរិកស្លូតបូត សុភាពរាបសារ ជាមនុស្សលះបង់ និងមានចំណេះដឹងខ្ពស់ ។ សាក្សីទាំងនេះ បានបង្ហាញនូវភាពភ្ញាក់ផ្អើល និងតក់ស្លុត នៅពេលដឹងថា មនុស្សដែលខ្លួនស្គាល់នោះ គឺជាប្រធានមន្ទីរសន្តិសុខដ៏ល្បីមួយនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ[៤៧] ។ ពុំមានសាក្សីណាម្នាក់ចង្អុលដូចក្នុងសក្ខីកម្មរបស់លោក François Bizot និងអ្នកជំនាញ David Chandler ឡើយ ដែលក្រោយមកបានកត់សម្គាល់ពីសន្ទុះចិត្តរបស់ជនជាប់ចោទនៅពេលនោះ ក្នុងការអនុវត្តអំណាចនៅមន្ទីរ ស-២១[៤៨] ។ បន្ថែម

---

[៤៥] សក្ខីកម្មរបស់លោក David Chandler ដូចមានក្នុងរបាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៦ និង ប្រតិចារិកពាក់ព័ន្ធ ។

[៤៦] សម្រាប់សក្ខីកម្ម(ជាលិខិត)របស់លោក កាំង ប៉ាន់ និង ថាច់ សៀក សូមមើល របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហមលេខ១៧ និង ប្រតិចារិក ហើយចំពោះសក្ខីកម្មរបស់អ្នកស្រី ជុំ នៅ សូមមើល របាយការណ៍ឃ្លាំមើលតុលាការខ្មែរ ក្រហម លេខ ១៩ និង ប្រតិចារិក។

[៤៧] ចំពោះភស្តុតាងទាក់ទិននឹងលក្ខណៈអត្តចរិករបស់ជនជាប់ចោទ មុនឆ្នាំ ១៩៦៨ សូមមើលសក្ខីកម្មរបស់លោក ស៊ូ សាត លោក ទេព សែម និង ទេព សុក ដូចមានក្នុង របាយការណ៍ឃ្លាំមើលតុលាការខ្មែរ ក្រហម លេខ ២០ និង ប្រតិចារិក។ ចំពោះភស្តុតាងទាក់ទិននឹងលក្ខណៈអត្តចរិករបស់ជនជាប់ចោទ ក្នុងទស្សវត្សន៍ឆ្នាំ ១៩៥០ សូមមើលសក្ខីកម្មរបស់លោក ជូ វិន លោក ហ៊ុន ស្មឿន និង ប៉េង ភ័ណ នៅក្នុងរបាយការណ៍តែមួយ ព្រមទាំងសក្ខីកម្មរបស់លោក Christopher Lapel ដូចមានក្នុងរបាយការណ៍ឃ្លាំមើលតុលាការខ្មែរ ក្រហម លេខ ២១ និង ប្រតិចារិក។

[៤៨] សក្ខីកម្មរបស់លោក David Chandler ដូចមានក្នុងរបាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៦ និង ប្រតិចារិកពាក់ព័ន្ធ ។

លើនេះ អ្នកជំនាញខាងផ្នែកចិត្តសាស្ត្រ លោកស្រី François Siboni-Guilbaud និងលោក **ការ ស៊ុនប៊ុណ្ណា** បានផ្តល់សក្ខីកម្មរួមនៅចំពោះមុខអង្គជំនុំជម្រះ ។ សក្ខីកម្មរបស់អ្នកទាំងពីរបានលើកឡើងយ៉ាងច្បាស់ថា **ឌុច** ពុំមានទទួលរងជំងឺផ្លូវចិត្តណាមួយទេ ។ ពួកគេបានកត់សម្គាល់ថា ជនជាប់ចោទស្ថិតនៅក្នុងដំណើរការនៃការទទួលស្គាល់ពិរុទ្ធភាពរបស់ខ្លួន ដោយសារការស្តាយក្រោយនូវទង្វើដែលបានធ្វើពិតប្រាកដ និងឥតក្លែង ។ ជាពិសេសអាចនិយាយបានថា សវនាការនេះបានផ្តល់ដល់ជនជាប់ចោទនូវលទ្ធភាពស្តារនីតិសម្បទាឡើងវិញ[៤៩] ។

### *៨. ការខូចខាត សំណង និង ការផ្តន្ទាទោស*

ទោះបីជា ពុំទាន់បានកំណត់ពីប្រភេទនៃភស្តុតាង ក៏អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មសាក្សីជំនាញលោក **ឈឹម សុធារ៉ា** អំពីបញ្ហាសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តី ។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនក៏បានផ្តល់សក្ខីកម្មលើផ្នែកនេះដែរ ដោយជួយដល់អង្គជំនុំជម្រះយល់ដឹងចំពោះហេតុការណ៍កើតមាននៅមន្ទីរ ស-២១ ហើយក៏ដើម្បីពង្រឹងទំនាក់ទំនងរវាងការទាមទារ និងព្រឹត្តការណ៍ដែលបានកើតឡើងសម្រាប់ការទាមទារសំណងស្របច្បាប់ ។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនធំបានបង្ហាញពីភាពសោកសៅរបស់ខ្លួន ក្នុងការនឹកឃើញដល់មនុស្សជាទីស្រលាញ់ ដែលបានស្លាប់នៅមន្ទីរ ស-២១ និងការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ ចំពោះគ្រួសារដែលបានដឹងអំពីមរណភាពរបស់សមាជិកខ្លួន[៥០] ។

សាក្សីជំនាញលោក Justice Richard Goldstone និងលោក Stephan Hessel បានផ្តល់សក្ខីកម្មទាក់ទងនឹងស្ថានទម្ងន់ និងសម្រាលទោស ក្នុងការផ្តន្ទាទោសជនជាប់ចោទ ព្រមទាំងមូលហេតុនៃវិប្បដិសារី[៥១] ។

## ខ. សេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោល

កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿងក្តីលេខ ០០១ ត្រូវបានបញ្ចប់ បន្ទាប់ពីភាគីបានបង្ហាញនូវសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោល កាលពីថ្ងៃ២៣ ដល់ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានចាប់ផ្តើមឡើងថ្លែងសេចក្តីសន្និដ្ឋានបញ្ចប់របស់ខ្លួនមុនគេ ដោយផ្តោតសំខាន់ទៅលើតម្រូវការយុត្តិធម៌សង្គម ស្វែងរកការពិត និងផ្តល់សំណងគំរូ ដើម្បីលៃលកឱ្យកូនក្តីខ្លួន និងជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម ។ ម្យ៉ាងទៀត ពួកគេបានបដិសេធការអះអាងរបស់ **ឌុច** ដែលថា មន្ទីរ ស-២១ មិនមានស្វ័យភាព និងបានអះអាងជំនួស **ឌុច** ថា គាត់បានដឹកនាំជំរុំមួយដែលនាំទៅរក *"ការសម្លាប់រង្គាល"* ។ ពួកគេបានពិពណ៌នាអំពីជនជាប់ចោទ

---

[៤៩] សូមមើល របាយការណ៍ឃ្លាំមើលតុលាការខ្មែរ ក្រហម លេខ ២០ និង ប្រតិចារិក។

[៥០] សូមមើល របាយការណ៍ឃ្លាំមើលតុលាការខ្មែរ ក្រហម លេខ ១៨ និង ប្រតិចារិក។

[៥១] ចំពោះសក្ខីកម្មរបស់លោក ឈឹម សុធារ៉ា សូមមើលរបាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៩ និង ចំពោះសក្ខីកម្មរបស់លោក Stephane Hessel និង Justice Richard Goldstone សូមមើល របាយការណ៍ឃ្លាំមើល តុលាការខ្មែរក្រហម លេខ ២១ និងប្រតិចារិក ។

ថា បានធ្វើនូវអ្វីគ្រប់បែបយ៉ាង *"មិនមែនដោយសារគាត់ស្ថិតនៅក្នុងស្ថានភាពបង្ខំនោះទេ ប៉ុន្តែការពិត គឺដោយសារភាពមានជំនឿចិត្តរបស់គាត់ទៅវិញ"*[៥២] ។

ស្របជាមួយនឹងទ្រឹស្តីនៃរឿងក្តី ដើមបណ្តឹងរដ្ឋប្បវេណីបានព្យាយាមបង្ហាញខ្លួននៅសវនាការ សហព្រះរាជអាជ្ញាបានបន្ថែមថា ជនជាប់ចោទគួរតែទទួលខុសត្រូវលើបទល្មើសនីមួយៗ ចំពោះអំពើដ៏សាហាវឃោរឃៅដែលបានប្រព្រឹត្តនៅមន្ទីរ ស-២១ ។ ការច្រានចោលនូវការសម្តែងវិប្បដិសារី និងនិន្នាការរបស់ជនជាប់ចោទ ដែលចាត់ទុកថា ខ្លួនជា *"ស្ពឺនៅក្នុងម៉ាស៊ីននៃការកាប់សម្លាប់របស់ខ្មែរក្រហម"* សហព្រះរាជអាជ្ញាជាតិលោកស្រី **ជា លាង** បានផ្តោតទៅលើមូលហេតុខុសគ្នានៃមន្ទីរស-២១ ថាជាគុកកំពូលនៃមន្ទីរសន្តិសុខក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយនឹងការខិតខំប្រឹងប្រែង ដែលជនជាប់ចោទបានអនុវត្តតួនាទីរបស់គាត់ ។ ម៉្យាងទៀតសហព្រះរាជអាជ្ញាអន្តរជាតិស្តីទីលោក William Smith បានអះអាងភស្តុតាងដែលបង្ហាញថា ប្រសិទ្ធភាពដែលជនជាប់ចោទបានអនុវត្តតួនាទីរបស់គាត់ជាប្រធាននៃមជ្ឈមណ្ឌលធ្វើទារុណកម្មដ៏ល្បីល្បាញនេះ មានន័យថាគាត់បានលើកទឹកចិត្តថ្នាក់លើឱ្យចាប់ខ្លួនឃុំខ្លួន និង *"កម្ទេច"* កម្មាភិបាលនៅមន្ទីរ ស-២១ ។ គាត់បានរៀបរាប់ថាបានភ្លេចភ្លាំង ហើយ *"ឆ្ពោះទៅរកផ្លូវខុស"* ជាមួយនឹងមេរបស់គាត់ **សុន សេន** ដែលអ្នកទាំងពីរមានឆន្ទៈ *"បូជាកំម្លាំងកាយចិត្ត"*[៥៣] ។ សហព្រះរាជអាជ្ញា បានស្នើសុំជាបន្តបន្ទាប់ដល់អង្គជំនុំជម្រះឱ្យផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគាររយៈពេល ៤០ ឆ្នាំ ។ ការស្នើសុំនេះរួមបញ្ចូលទាំងការកាត់បន្ថយរយៈពេល ៥ឆ្នាំ ទៅលើការផ្តន្ទាទោសរបស់ជនជាប់ចោទ ដោយគិតអំពីកត្តាសម្រាលនានា ដូចជាការសហការជាមួយអង្គជំនុំជម្រះជាដើម ។

ងាកមកព្រឹត្តការណ៍ដ៏គួរឱ្យភ្ញាក់ផ្អើល ដែលមេធាវីការពារក្តី បានថ្លែងនូវសេចក្តីសន្និដ្ឋានបញ្ចប់នាសប្តាហ៍នេះ ដោយលើកឡើងថា *"គ្មានពិរុទ្ធភាព"* គ្រប់បទល្មើសដែលចោទប្រកាន់ជនជាប់ចោទ ដែលមានក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ ទោះបីជា មេធាវីការពារក្តីអន្តរជាតិលោក François Roux បានគូសបញ្ជាក់ពីភាពស្របគ្នារវាងសំណុំរឿងក្តីរបស់កូនក្តីខ្លួនជាមួយនឹងរឿងក្តី *Obrenovic* នៅតុលាការ ICTY (ដែលបានទទួលពិរុទ្ធភាព) និងបានលើកឡើងដោយជាក់លាក់ថា កូនក្តីខ្លួនមានវិប្បដិសារីជាខ្លាំង ទាំងជនជាប់ចោទ និងសហមេធាវីការពារក្តីជាតិបានថ្លែងជំនួសថា ស្នើសុំការដោះលែងឱ្យមានសេរីភាពភ្លាម ។ ការលើកឡើងពីសមត្ថកិច្ចរបស់ អ.វ.ត.ក ដែលគួរតែត្រូវលើកឡើងនៅដំណាក់កាលដំបូងនៅក្នុងសវនាការ **ឌុច** ក្នុងនោះមេធាវីជាតិ លោក **ការ សាវុត្ថ** បានផ្តល់អំណះអំណាងផ្សេងៗគ្នាថា : **ឌុច** មិនមែនជាមនុស្សតែម្នាក់ក្នុងចំណោមមេដឹកនាំជាន់ខ្ពស់នោះទេ និងមិនអាច *"ទទួលខុសត្រូវខ្ពស់បំផុត"* ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរ ស-២១ នោះទេ ។ អាជ្ញាយុកាលកាត់ទោស

[៥២] សេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោល របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ លោក Karim Khan ថ្ងៃទី ២៣ វិច្ឆិកា ២០០៩ (កំណត់ត្រាផ្ទាល់របស់អ្នកឃ្លាំមើលតុលាការ អ្នកស្រី Michelle Staggs Kelsall)។ សូមមើល របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ២២។

[៥៣] សេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោល របស់សហព្រះរាជអាជ្ញាអន្តរជាតិ លោក William Smith ថ្ងៃទី ២៤ វិច្ឆិកា ២០០៩ (កំណត់ត្រាផ្ទាល់របស់អ្នកឃ្លាំមើលតុលាការ អ្នកស្រី Michelle Staggs Kelsall)។ សូមមើលផងដែររបាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ២២។

**ឌុច** ចំពោះបទឧក្រិដ្ឋក្នុងស្រុក គឺបានផុតហើយ ហើយថា ការផ្ដន្ទាទោសចំពោះកូនក្ដីខ្លួន គឺផ្ទុយនឹងវដ្ដធម្មនុញ្ញ ។ លោក **ការ សាវុត្ថ** ក៏បានសំអាងទៅលើការការពារ *"បទបញ្ជាថ្នាក់លើ"* ថ្វីបើមេធាវីការពារក្ដីបានព្រមព្រៀងពីមុនថា ករណីនេះមិនការពារពេញលេញនៅក្រោមច្បាប់អន្តរជាតិ[៥៤] ។ នៅពេលអង្គជំនុំជម្រះសួរដេញដោលថា តើនេះមានន័យថា ជនជាប់ចោទបានស្នើសុំលើកលែងការចោទប្រកាន់ មេធាវីការពារក្ដីជាតិលោក **ការ សាវុត្ថ** បានឆ្លើយបញ្ជាក់ថា ជាការប្រាកដណាស់ ។ ទោះបីជា ជនជាប់ចោទ និងមេធាវីការពារក្ដីអន្តរជាតិបានបន្តអះអាងថា **ឌុច** មានការសោកស្ដាយចំពោះបទឧក្រិដ្ឋដែលបានកើតមាននៅមន្ទីរ ស-២១ ព្រមទាំងទទួលខុសត្រូវរាល់សកម្មភាពទាំងអស់របស់អ្នកនៅក្រោមបង្គាប់ក៏ដោយ ក៏ជនជាប់ចោទនៅតែស្នើសុំជាចុងក្រោយឱ្យអង្គជំនុំជម្រះពិចារណាទៅលើអ្វីដែលមេធាវីការពារក្ដីជាតិខ្លួនបានលើកឡើង[៥៥] ។

## ច. បទពិសោធន៍ទទួលបានពីនីតិវិធីបង្ហាញភស្តុតាង

ការស្ដាប់សក្ខីកម្មទៅតាមអង្គហេតុដែលបានកំណត់ គឺជាបែបបទដ៏ល្អមួយ ដែលធ្វើឱ្យគេអាចរៀបចំព័ត៌មានក្នុងសំណុំរឿងក្ដីលេខ ០០១ បានល្អ និងមានលំដាប់លំដោយ ។ អង្គជំនុំជម្រះ និងគូភាគីយល់ថា ការធ្វើបែបនេះជួយសម្រួលដល់ការរៀបចំសំណួរសម្រាប់សាក្សី ។ ប៉ុន្តែបើទោះបីជា មានការខិតខំប្រឹងប្រែងកុំឱ្យមានសំណួរមិនពាក់ព័ន្ធអង្គហេតុក៏ដោយ ក៏អង្គជំនុំជម្រះហាក់ដូចជាមានការលំបាកក្នុងការបញ្ឈប់សំណួររបស់ភាគីចំពោះសាក្សីនីមួយៗ ។ ជារឿយៗ អង្គជំនុំជម្រះបានរកឃើញថា ភាគីបានតាំងសំណួរទៅកាន់សាក្សី ប្រាស់ចាកពីអង្គហេតុដែលបានកំណត់ហើយបានជ្រុលហួសទៅអង្គហេតុផ្សេងទៀត ដែលមិនទាន់បានលើកយកមកសួរដេញដោល ។ ជាក់ស្ដែង សំណួរទាក់ទងនឹងអង្គហេតុស្ដីពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា និងអង្គហេតុស្ដីពីប្រតិបត្តិការរបស់មន្ទីរ ស-២១ និងជើងឯក ក្នុងនោះមានសំណួរជាច្រើនដែលជាន់គ្នា[៥៦] ។ បន្ថែមលើនេះទៀត ក្នុងករណីមួយចំនួន សូម្បីតែចៅក្រមខ្លួនឯង ក៏បានសួរសំណួរច្រំដែលដែរ នៅក្នុងកិច្ចដំណើរការនីតិវិធីដែរ[៥៧] ។

លើសពីនេះ ដោយសារអង្គហេតុនីមួយៗមានទំហំធំ ធ្វើឱ្យដំណើរការនីតិវិធីនៃការសួរដេញដោល ហាក់ផ្ដោតទៅលើព្រឹត្តការណ៍ជាក់លាក់នីមួយៗនៃអង្គហេតុទាំងនោះ ដែលមិននាំទៅរកការវាយតម្លៃពីកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ ។ ជាឧទាហរណ៍ ការសួរបញ្ជាក់ពីការចម្លងយកគំរូមនោគមវិជ្ជាកុម្មុយនីស្តរបស់ខ្មែរក្រហម ហាក់នាំទៅរកការដេញដោលមួយ ដែលទំនងជាមិនជួយដល់ការស្វែងយល់ពីការទទួលខុសត្រូវរបស់

---

[៥៤] សូមមើល វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (វិសោធនកម្មលើកទី ៤) ចុះថ្ងៃទី ១១ កញ្ញា ២០០៩ វិធាន ៨៩-២ ដែលបញ្ជាប្រឈមរបស់អណត្តិតុលាការ គួរតែពិចារណា ។ អាចរកបាននៅក្នុងគេហទំព័រ www.eccc.gov.kh/english/internal_rules.aspx (Last accessed 1 December 2009) ។ ជាប់ពីពេលនេះទៅ រាល់ឯកសារយោងនៅក្នុងផ្នែកនេះ ឬ ផ្នែកផ្សេងនៃវិធានផ្ទៃក្នុងរបស់តុលាការ នឹងត្រូវបានកំណត់ថាជា **"វិធានផ្ទៃក្នុង"** ។

[៥៥] សេចក្ដីសន្និដ្ឋានបញ្ចប់ការសួរដេញដោល របស់សហមេធាវីការពារក្ដី ថ្ងៃទី ២៦-២៧ វិច្ឆិកា ២០០៩ (កំណត់ត្រាផ្ទាល់របស់អ្នកឃ្លាំមើលតុលាការ អ្នកស្រី Michelle Staggs Kelsall) ។

[៥៦] សូមមើល របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ០៥ និង របាយការណ៍ឃ្លាំមើលតុលាការ ខ្មែរក្រហម លេខ ០៨ ។

[៥៧] សូមមើល របាយការណ៍ឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១០ ។

**ខុច** ចំពោះអំពើឧក្រិដ្ឋកម្មនោះទេ ហើយដូចគ្នានេះដែរការតាំងសំណួរទៅលើសេចក្តីលម្អិតនៃលក្ខខណ្ឌនៅមន្ទីរ ស-២១ ក៏ទំនងជាមិនពាក់ព័ន្ធដែរ ព្រោះជនជាប់ចោទបានសារភាពពីការទទួលខុសត្រូវរបស់ខ្លួនរួចទៅហើយ[៥៨] ។

សម្រាប់សំណុំរឿងក្តីលេខ ០០២ ដោយពិចារណា មិនស្តាប់ភស្តុតាងទៅតាមលំដាប់លំដោយនៃអង្គហេតុ អង្គជំនុំជម្រះ មានបំណងធ្វើការអនុម័តយកវិធីសាស្ត្រប្រហាក់ប្រហែលទៅនឹងវិធីសាស្ត្ររបស់តុលាការអន្តរជាតិ ផ្សេងៗទៀត ។ ជាឧទាហរណ៍ តុលាការអន្តរជាតិ ICTY អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់សាក្សី *"អ្នកដែលបានចូលរួមក្នុងអំពើឧក្រិដ្ឋ (insider)"* សំខាន់ៗ ឬអ្នកជំនាញយោធាជាមុន បន្ទាប់មកពិនិត្យលើភស្តុតាងនៅកន្លែងឧក្រិដ្ឋកម្ម (Crime-base evidence) ដែលប្រមូលដោយអាជ្ញាធរក្រុងទៅតាមស្រុកនីមួយៗ ។ ចំពោះរឿងក្តីដែលមានទីកន្លែងឧក្រិដ្ឋកម្មច្រើន ដំបូងត្រូវស្តាប់អង្គហេតុរួមនៃសំណុំរឿងសិន បន្ទាប់មកស្តាប់អង្គហេតុទៅតាមទីកន្លែងនីមួយៗនៃបទឧក្រិដ្ឋ ដែលព្រះរាជអាជ្ញាបានធ្វើការអង្កេត[៥៩] ។ តុលាការពិសេសសម្រាប់ប្រទេស **សៀរ៉ា លេអូន** បានអនុម័តវិធីសាស្ត្រស្រដៀងគ្នានេះដែរ ប៉ុន្តែនៅក្នុងពេលខ្លះ អង្គជំនុំជម្រះស្តាប់សក្ខីកម្មសាក្សីទៅតាមប្រភេទនៃឧក្រិដ្ឋកម្ម ដូចជាជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈ ត្រូវផ្តល់សក្ខីកម្មគ្រប់គ្នា មិនមែនទៅតាមមូលដ្ឋាននៃឧក្រិដ្ឋកម្មនោះទេ (Crime-base *per se*)[60] ។ ការធ្វើបែបនេះ អាចធ្វើឱ្យការតាំងសំណួរ ផ្តោតចំលើប្រធានបទដែលកំពុងដេញដោល ជាពិសេសចំពោះសំណុំរឿង ដែលមានជនជាប់ចោទច្រើននាក់ប្រឈមមុខនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋប្រព្រឹត្តនៅទីតាំងភូមិសាស្ត្រច្រើនកន្លែងផ្សេងគ្នា ។

---

[៥៨] អំណះអំណាងតទល់ទៅនឹងការរាប់បញ្ចូលនៃសំណួរដែលអរូបីច្រើន អាចជាអង្គហេតុដែលថា គំរូនៃប្រព័ន្ធច្បាប់ស៊ីវិល អនុញ្ញាតិឱ្យមានពេលបន្ថែមច្រើន ក្នុងចំនោមចៅក្រម ក្នុងការស្វែងរកការពិតនូវអ្វីដែលបានកើតឡើង និង វិសាលភាពដែលមនោគមវិជ្ជានេះបានដក់ជាប់ក្នុងដួងចិត្តរបស់ជនជាប់ចោទ នាពេលនោះ ។

[៥៩] ការទំនាក់ទំនងតាមអ៊ីម៉ែល ជាមួយនឹងអតីតមេធាវីជាន់ខ្ពស់ពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (១០ វិច្ឆិកា ២០០៩) ។

[៦០] ការសង្កេតផ្ទាល់ខ្លួនរបស់អ្នកនិពន្ធអ្នកស្រី Michelle Staggs Kelsall ពីការឃ្លាំមើលសវនាការតុលាការពិសេស សម្រាប់ប្រទេសសៀរ៉ាលេអូន រវាងខែ កញ្ញា ២០០៤- សីហា ២០០៥ ។

## ផ្នែកទី ៣ : បញ្ហាច្បាប់ និង នីតិវិធី

ដូចនឹងស្ថាប័នយុត្តិធម៌អន្តរជាតិដទៃទៀតដែរ ដែលត្រូវបានបង្កើតឡើងដោយមានយុត្តាធិការកំណត់មួយ ដើម្បីបំរើឱ្យគោលបំណងដែលសម្រេចបានពីការចរចារជាលក្ខណៈនយោបាយ អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា បានព្យាយាមធ្វើយ៉ាងណាដើម្បីអនុវត្តកិច្ចដំណើរការនីតិវិធីឱ្យបានល្អប្រសើរ ដោយប្រកាន់ខ្ជាប់នូវគតិច្បាប់ក្នុងក្របខណ្ឌពេលវេលាដ៏ខ្លី ។ នៅក្នុងករណីនេះសវនាការកាត់ទោស**ឌុច** បានក្លាយទៅជា *"រឿងក្តីគំរូមួយ"*សម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្តវិធានផ្ទៃក្នុង ។ រឿងក្តីលេខ ០០១ នេះ ក៏នឹងឆ្លុះបញ្ចាំងពីកម្រិត ដែលអង្គជំនុំជម្រះយល់ថា ចាំបាច់ក្នុងការគោរពតាមមាត្រដ្ឋានអន្តរជាតិ ដែលបានអនុវត្តនៅតុលាការអន្តរជាតិនានា ដែលភាគច្រើននៃតុលាការទាំងនោះខុសពី អ.វ.ត.ក គឺអនុវត្តតាមប្រពន្ធ័ច្បាប់កុំម៉ុនឡ[៦១] ។

រចនាសម្ព័ន្ធនីតិវិធីជាមូលដ្ឋានរបស់ អ.វ.ត.ក ត្រូវបានប្រើប្រាស់ជាគំរូក្នុងការស៊ើបអង្កេត ដែលក្នុងនោះចៅក្រមដើរតួនាទីយ៉ាងសកម្ម ក្នុងការដឹកនាំកិច្ចដំណើរការនីតិវិធីសវនាការ ។ គេជឿជាក់ថា នីតិវិធីនេះអាចជួយឱ្យសម្រេចបាននូវគោលបំណងនៃ *"ការកំណត់ត្រាប្រវត្តិសាស្ត្រដ៏ត្រឹមត្រូវ"* ដោយសារតែចៅក្រមត្រូវបានចាត់ទុកថា ជាអ្នកស្វែងរកការពិតមួយដ៏សំខាន់ ហើយមានអំណាចក្នុងការសួរដេញដោលអំពីអង្គហេតុពាក់ព័ន្ធ[៦២] ។ ប៉ុន្តែមិនដូចជាតុលាការអន្តរជាតិនានា ដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតប្រទេស **យូហ្គោស្លាវី** និង ប្រទេស **រវ៉ាន់ដា** ដែលអនុវត្តន៏តាមប្រព័ន្ធច្បាប់កុំម៉ុនឡ ក្នុងនោះដំណើរការនីតិវិធីភាគច្រើនដឹកនាំដោយមេធាវី ចៅក្រមនៅ អ.វ.ត.ក ត្រូវបានគេរំពឹងទុកថា នឹងដើរតួនាទីសកម្មក្នុងការកំណត់ព្រំដែននៃរឿងក្តី និងការសួរដេញដោលសាក្សី ។ បន្ថែមពីនេះ ប្រពន្ធ័ច្បាប់ស៊ីវិលដែលបានអនុវត្តនៅប្រទេសកម្ពុជា (យកតាមប្រព័ន្ធច្បាប់ប្រទេសបារាំង) ផ្តល់ឱកាសជាច្រើនដល់ជនជាប់ចោទក្នុងការឆ្លើយតប និងធ្វើសេចក្តីសន្និដ្ឋានចំពោះសក្ខីកម្មសាក្សី ។ ជាលទ្ធផល អង្គជំនុំជម្រះបានចំណាយពេលវេលាជាច្រើនសាកសួរ **ឌុច** អំពីសក្ខីកម្មសាក្សីជាច្រើន ហើយផ្តល់ឱកាសឱ្យជនជាប់ចោទមានមតិចំពោះសេចក្តីថ្លែងរបស់សាក្សីទាំងនោះ ថាតើមានសច្ចភាពឬទេ ។ នីតិវិធីបែបនេះអាចនឹងជួបបញ្ហាជាច្រើន ជាពិសេសចំពោះការគ្រប់គ្រងសវនាការប្រសិនបើសំណុំរឿងនោះ មានជនជាប់ចោទច្រើន ដូចជាសំណុំរឿងក្តីលេខ ០០២ ជាដើម ។

ដូចគ្នានឹងតុលាការដទៃទៀតដែរ ការអនុមត័នីតិវិធីរបស់ អ.វ.ត.ក គឺជាកិច្ចការមួយ ដែលត្រូវធ្វើជាបន្តបន្ទាប់ ដោយសារតែចៅក្រមបានខិតខំខ្នះខ្នែងក្នុងការបង្កើតវិធានថ្មីៗ ដោយរួមបញ្ចូលនូវការអនុវត្តជាក់ស្តែងពី

---

[៦១] **កិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក** បានចែងថា អ.វ.ត.ក អាចស្វែងរក "សេចក្តីណែនាំពីវិធាននីតិវិធី ដែលបានបង្កើតនៅក្នុងកម្រិតអន្តរជាតិ" នៅក្នុងព្រឹត្តការណ៏ដែលច្បាប់កម្ពុជា មិនអាចដោះស្រាយជាមួយបញ្ហាពិសេសបែបនេះ វាមានភាពមិនច្បាស់លាស់ទាក់ទងនឹង ការអនុវត្តវិធានច្បាប់ក្នុងស្រុក ឬ ក៏មានភាពមិនច្បាស់លាស់ទាក់ទងនឹងវិសាលភាពដែលវិធានស្របជាមួយនឹងមាត្រដ្ឋានអន្តរជាតិ ។ សូមមើល **កិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក** មាត្រា ១២-១ ។ ក្នុងករណីនេះ ចៅក្រមអ.វ.ត.ក មិនស្ថិតនៅក្រោមកាតព្វកិច្ចក្នុងការយកគ្រាប់ តាមសេចក្តីណែនាំយុត្តិសាស្រ្តអន្តរជាតិ នៅពេលឈានដល់ការសម្រេចរបស់គេ ។

[៦២] Robert Cryer et al. (2007) *សេចក៏ផ្តើមទៅច្បាប់ និងនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ* (Cambridge : សាកលវិទ្យាល័យសាព័ត៌មាន Cambridge ) (ចាប់ពីពេលនេះហៅថា " **Cryer** ") ទំព័រ ៥០ ។

ច្បាប់ទំនៀមទំលាប់ ដើម្បីឱ្យស្របទៅនឹងគោលបំណងនៃការបង្កើតតុលាការនេះ និងដើម្បីការពារសិទ្ធិរបស់គូភាគីនៅចំពោះមុខតុលាការ ។ មេធាវីការពារក្តីអន្តរជាតិលោក François Roux បានទទួលស្គាល់ថា ច្បាប់ទំនៀមទំលាប់ គឺមាន *គុណសម្បត្តិ* និង *គុណវិបត្តិ* រៀង១ខ្លួន ប៉ុន្តែគាត់ក៏បានបង្ហាញនូវកង្វល់ ចំពោះការរួមបញ្ចូលនៃប្រព័ន្ធទាំងពីរនេះ ។ គាត់បានផ្តល់សង្កេតថា គោលបំណងរបស់តុលាការ គឺជ្រើសរើសយកចំណុចល្អនៃប្រពន្ធ័ច្បាប់ទាំងនេះមកអនុវត្ត ប៉ុន្តែផលលំបាកក៏កើតមានឡើងកំឡុងពេលអនុវត្តន៍កិច្ចដំណើរការនីតិវិធី ជាពិសេសនៅពេលដែលគូភាគីមិនសូវមានការយល់ដឹងពីការអនុវត្តប្រព័ន្ធច្បាប់ស៊ីវិល ហើយបានទទូចសុំឱ្យប្រើប្រាស់ប្រព័ន្ធCommon Law វិញ[63] ។ យោងទៅតាម មេធាវីការពារក្តីអន្តរជាតិ Roux ភាពមិនច្បាស់លាស់នៃប្រព័ន្ធច្បាប់ទាំងពីរកើតឡើង ជាពិសេសចេញពីការិយាល័យសហព្រះរាជអាជ្ញា នៅពេលដែលពួកគេមិនបានពង្រឹងតួនាទីរបស់ខ្លួន ក្នុងដំណាក់កាលស៊ើបអង្កេត ការប្រើសំណួរនាំមុខ និងចេតនារបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសដល់ជនជាប់ចោទ[៦៤] ។ លោកស្រីចៅក្រម Silvia Cartwright បានពន្យល់ថា ករណីនេះគឺជាវិធាការណ៍មួយនាំឆ្ពោះទៅ *"ប្រព័ន្ធចម្រុះ"* (Homogenous System) ក្នុងកម្រិតអន្តរជាតិ ដោយបានកែសម្រួលការយកពីការនុវត្ត ទាំងប្រព័ន្ធច្បាប់កុំម៉ុនឡ និងច្បាប់ស៊ីវិល ដើម្បីឱ្យស្របទៅនឹងភាពជាក់ស្តែង[៦៥] ។ ចំណែកឯ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី លោក William Smith វិញបានលើកឡើងថា បញ្ហារវាងប្រព័ន្ធច្បាប់កុំម៉ុនឡ និងច្បាប់ស៊ីវិល មានលក្ខណៈ *"ស្មុកស្មាញ"* នៅកម្រិតអន្តរជាតិ ឬតុលាការកូនកាត់ ហើយជាបទពិសោធន៍លំបាកនៅក្នុងសំណុំរឿងនេះ គឺដោយសារតែមានភស្តុតាងជាច្រើន ដែលត្រូវបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះមិនមែនដោយសារភាពខុសប្លែកគ្នារវាងប្រពន្ធ័ច្បាប់ទាំងពីរនោះទេ ។[៦៦] ទោះបីជាយ៉ាងនេះក៏ដោយ ការពិភាក្សាអំពីនីតិវិធីការនៃចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី នឹងរៀបរាប់នៅផ្នែកទី ៤ នៃរបាយការណ៍នេះ ។ ផ្នែកនេះផ្តោតសំខាន់លើ **បញ្ហាច្បាប់** ចម្បងបី គឺ *ការឃុំខ្លួនបណ្តោះអាសន្ន ការដាក់ទោសទណ្ឌ* និង *ការអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម* និង **បញ្ហានីតិវិធី** បីធំៗ គឺ *១-ការអនុវត្តគោលការណ៍សមភាពរវាងការការពារក្តី និងការចោទប្រកាន់ ២-ការទទួលយក និងការបង្ហាញភស្តុតាងក្នុងពេលសវនាការ* និង *៣-ការប្រើប្រាស់ចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្ម* ។ ក្រុមឃ្លាំមើលតុលាការបានកត់សម្គាល់បញ្ហាទាំងនេះក្នុងគោលបំណងដើម្បី ១-ពិនិត្យមើលពីផលប៉ះពាល់ជាអវិជ្ជមានចំពោះសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដូចមានចែងក្នុងមាត្រា ១៤ នៃកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដែល

---

[៦៣] បទសម្ភាសន៏ផ្ទាល់ជាមួយលោកមេធាវី Roux François ថ្ងៃទី ១៩ តុលា ២០០៩ (ចាប់ពីពេលនេះហៅថា "បទសម្ភាសន៏ជាមួយសហមេធាវីការពារក្តីអន្តរជាតិ **Roux** ) ។

[៦៤] បទសម្ភាសន៏ជាមួយសហមេធាវីការពារក្តីអន្តរជាតិ **Roux** ។

[៦៥] បទសម្ភាសន៏ជាមួយអ្នកស្រីចៅក្រម Silvia Cartwright (៧ តុលា ២០០៩) (ចាប់ពីពេលនេះទៅហៅថា "បទសម្ភាសន៏ជាមួយអ្នកស្រីចៅក្រម Cartwright) ។

[៦៦] បទសម្ភាសន៏ផ្ទាល់ជាមួយលោកសហព្រះរាជអាជ្ញាអន្តរជាតិ William Smith ថ្ងៃទី ០៧ តុលា ២០០៩ (ចាប់ពីពេលនេះហៅថា "បទសម្ភាសន៏ជាមួយសហព្រះាជអាជ្ញាអន្តរជាតិ William Smith ) ។

ប្រទេសកម្ពុជាបានទទួលស្គាល់ និងមានចែងនៅក្នុងច្បាប់ អ.វ.ត.ក និង ២-ដើម្បីផ្តល់មេរៀនដកពិសោធន៏សម្រាប់សំណុំរឿងដែលកំពុងដំណើរការនៅ អ.វ.ត.ក និងតុលាការថ្នាក់ជាតិ ។

### ក. សិទ្ធិដឹងពីមូលហេតុនៃការចោទប្រកាន់ : *ការអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម* (JCE)

សហកម្មឧក្រិដ្ឋកម្មរួម គឺជាទ្រឹស្តីបង្ហាញពីការទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋ ដែលប្រព្រឹត្តដោយក្រុមមនុស្ស ដើម្បីសម្រេចបាននូវផែនការឧក្រិដ្ឋរួម ។ រហូតមកដល់បច្ចុប្បន្ន ភាពចម្រូងចម្រាស់ចំពោះការអនុវត្តទ្រឹស្តីនេះ នៅតែមានក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតុលាការអន្តរជាតិនានា បើទោះបីជាទ្រឹស្តីនេះត្រូវបានទទួលស្គាល់ដោយសាលក្រមសម្រេចសេចក្តីក្នុងសំណុំរឿង *Tadic* នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីក៏ដោយ ។ ការទទួលស្គាល់ខាងលើ ធ្វើឱ្យទ្រឹស្តីនេះកាន់តែមានភាពច្បាស់លាស់ថែមទៀតថា ជានិយាមទំនៀមទម្លាប់អន្តរជាតិដែលមានតាំងពី ឆ្នាំ១៩៤៥ មកម្ល៉េះ[៦៧] ។

ភាពចម្រូងចម្រាស់ចំពោះការអនុវត្តទ្រឹស្តីនេះ ក្នុងសំណុំរឿងក្តី **ឌុច** បានកើតឡើងតាំងពីដំណាក់កាលដំបូង គឺនៅពេលដែលសហចៅក្រមស៊ើបអង្កេត បានសម្រេចមិនដាក់បញ្ចូលសេចក្តីយោងជាក់លាក់ ស្តីពីទ្រឹស្តសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គហេតុដែលបានរៀបរាប់ក្នុងដីកានោះបង្ហាញថា ការទទួលខុសត្រូវក្នុងទម្រង់សហកម្មឧក្រិដ្ឋកម្មរួម កើតមានចាប់តាំងពីការបង្កើតមន្ទីរ ស-២១ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ រហូតដល់ពេលដួលរលំរបបខ្មែរក្រហម ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ។ សហព្រះរាជអាជ្ញាបានបន្ថែមថា ឧក្រិដ្ឋរួមនៅមន្ទីរ ស-២១ មានលក្ខណៈជាប្រព័ន្ធ ដូចជា ការចាប់ខ្លួន ការឃុំឃាំង ការវាយធ្វើបាប ការសួរចម្លើយ ការធ្វើទារុណកម្ម និងការសម្លាប់បុគ្គលដែលគេចាត់ទុកថាជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា[៦៨] ។ សហព្រះរាជអាជ្ញាបានលើកឡើងថា **ឌុច** ទទួលខុសត្រូវតាមទម្រង់បីប្រភេទនៃទ្រឹស្តីនេះ គឺសហកម្មឧក្រិដ្ឋរួមប្រភេទទី១ ឬ អាចហៅម្យ៉ាងទៀតថា *ទម្រង់មូលដ្ឋាន (basic form)* ។ សហកម្មឧក្រិដ្ឋរួមប្រភេទទី២ ឬអាចហៅថា *ទម្រង់ប្រព័ន្ធ (systematic form)* ដែលក្នុងនេះ **ឌុច** ត្រូវបានចោទប្រកាន់ថា បានធ្វើការគាបសង្កត់មានលក្ខណៈជាប្រព័ន្ធនៅទូទាំងមន្ទីរ ស-២១ ។ ទ្រឹស្តីសហកម្មឧក្រិដ្ឋរួមប្រភេទទី៣ ឬអាចហៅថា

---

[៦៧] សូមមើលសាលក្រមរបស់សាលាឧទ្ធរណ៍ ក្នុងសំណុំរឿងក្តី Dusko Tadic (សំណុំរឿងលេខ IT-94-1-A) ចុះថ្ងៃទី ១៥ កក្កដា ១៩៩៩ កឋាខណ្ឌទី ១៩០-២២០ ។ អ្នកអានអាចរកមើលបន្ថែមបាន អំពី ទស្សនៈទូទៅស្តីពីភាពចម្រូងចម្រាស់ នៃការអនុវត្តទ្រឹស្តីនេះ ក្នុងកម្រិតអន្តរជាតិ ក្នុង California Law Review លេខ ៩៣ ឆ្នាំ២០០៥ ក្នុងអត្ថបទស្តីពី "ការមានទោសជាក្រុមៈ(Guilty Association) សហកម្មឧក្រិដ្ឋកម្មរួម (Joint Criminal Enterprise) ការទទួលខុសត្រូវតាមបញ្ជា (Command Responsibility) និងការវិវត្តន៍ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (Development of International Criminal Law)" ទំព័រ ៧៥-១៦៩ ដោយ Alison Mrston Danner និង Jenny S. Martinez

[៦៨] ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា នៃអ.វ.ត.ក. ក្នុងសំណុំរឿងលេខ ០០១ ស្តីពី " ការផ្តល់ព័ត៌មានសាធារណៈ ដោយសហព្រះរាជអាជ្ញា ស្របតាមវិធាន ៩៤ ដែលទាក់ទងនឹងដីកាសន្និដ្ឋានស្ថាពរក្នុងវិធាន ៦៦ ក្នុងសំណុំរឿង **ឌុច** "(ថ្ងៃទី១៨ កក្កដា ២០០៨) ។

*ទម្រង់ទូលាយ (extened form)* ក្នុងនេះ **ឌុច** ត្រូវបានគេដាក់ឱ្យទទួលខុសត្រូវដោយហេតុថា ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្រៅកន្លែងឧក្រិដ្ឋកម្មរួម ឬមន្ទីរ ស-២១ ក៏ចាត់ទុកថា ជាលទ្ធផលចេញពីការបង្កើតប្រពន្ធ័ឧក្រិដ្ឋកម្មដែលអាចដាក់ឱ្យ **ឌុច** ទទួលខុសត្រូវផងដែរ[៦៩] ។

អង្គបុរេជំនុំជម្រះបានច្រានចោលបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាដោយសំអាងលើមូលហេតុនីតិវិធី ។ អង្គបុរេជំនុំជម្រះ បានលើកហេតុផលថា ក្នុងកំឡុងពេលមុនសហព្រះរាជអាជ្ញាចេញសេចក្តីសន្និដ្ឋានស្ថាពរ អំពីការស៊ើបអង្កេត ជនជាប់ចោទមិនត្រូវបានផ្តល់ព័តិមានឱ្យបានគ្រប់គ្រាន់អំពីការចោទប្រកាន់ចំពោះការចូលរួមរបស់គាត់ក្នុងសហកម្មឧក្រិដ្ឋកម្មរួមនៅមន្ទីរ ស-២១ ទេ ។ ដោយមិនពេញចិត្ត សហព្រះរាជអាជ្ញាបានដាក់សំណើសុំជាបន្តជូនអង្គជំនុំជម្រះសាលាដំបូង នៅពេលចាប់ផ្តើមសវនាការកាត់ទោស **ឌុច** ដោយស្នើសុំឱ្យកែប្រែការកំណត់បទចោទប្រកាន់ ដែលមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ យោងតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣)[៧០] ។ សហព្រះរាជអាជ្ញាបានពន្យល់ថា ការកែប្រែបទចោទប្រកាន់ចំពោះ **ឌុច** នឹងមិនប៉ះពាល់ដល់សិទ្ធិរបស់គាត់ក្នុងការទទួលបានការជូនដំណឹងអំពីមូលហេតុនៃការចោទប្រកាន់ទេ ព្រោះអង្គហេតុកំណត់ពីអំពើសហកម្មឧក្រិដ្ឋកម្មរួមត្រូវបានទទួលស្គាល់ និងមានលក្ខណៈគ្រប់គ្រាន់ ។ បន្ទាប់ពីទទួលបានសេចក្តីសន្និដ្ឋាន អំពីសហកម្មឧក្រិដ្ឋកម្មរួមពីភាគី អង្គជំនុំជម្រះបានកំណត់ថា នឹងចេញសេចក្តីសម្រេចអំពីបញ្ហានេះ នៅពេលបញ្ចប់សំណុំរឿង ។

សិទ្ធិអំណាចរបស់អង្គជំនុំជម្រះក្នុងការផ្លាស់ប្តូរអង្គហេតុ ដែលមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះគឺមានប្រភពមកពីគោលការណ៍ប្រព័ន្ធច្បាប់ស៊ីវិល *តុលាការដឹង ឬចេះច្បាប់ iura novit curia (the court knows the law*[៧១] *។* ក្រៅពីតុលាការខ្មែរក្រហម មានតែតុលាការព្រហ្មទណ្ឌអន្តរជាតិ *(International Criminal Court [ICC])* ទេ ដែលបានចែងអំពីគោលការណ៍នេះ ហើយអនុញ្ញាតិឱ្យមានការផ្លាស់ប្តូរអង្គហេតុដែលបានធ្វើឡើងដើម្បីចោទប្រកាន់ *"...ដោយមិនឱ្យហួសពីអង្គហេតុដែលមាននិងហួសពីការកែប្រែបទចោទ"*។[៧២] នៅក្នុងសំណុំរឿង *Lubanga Dyilo* អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ បានបញ្ជាក់ថា ភាគីអាចស្នើសុំឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញពីការកំណត់អង្គហេតុដែលគេលើឡើងដើម្បីចោទប្រកាន់ជនជាប់ចោទ[៧៣] ។

---

[៦៩] សូមមើលដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា នៃអ.វ.ត.ក. កឋាខណ្ឌ ២៥១ ។

[៧០] វិធាន ៩៨(២) ចែងថា អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទប្រកាន់ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលធាតុផ្សំបទល្មើសថ្មីនៃបទចោទបានឡើយ ។

[៧១] សូមមើល cryer ទំព័រ ៣៧៦ ។

[៧២] សូមមើលបទបញ្ជា (Regulation) របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ លេខ ៥៥ ។

[៧៣] សូមមើលសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទី១នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងរឿងក្តី *Lubanga Dyilo* (សំណុំរឿងលេខ ICC-01/04-01/06) ស្តីពី "សំណើសុំរបស់រដ្ឋអជ្ញា និង មេធាវីការពារក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចស្តីពីការបញ្ជាក់ឡើងវិញស្តីពីការចោទប្រកាន់ (The Prosecution and Defense Application for Leave to Appeal the Decision on the Confirmation of Charges)" ចុះថ្ងៃទី ២៥ ឧសភា ឆ្នាំ ២០០៧ ។

ប៉ុន្តែនៅក្នុងរឿងក្តី *Kupreskic, et al* តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មានការប្រយត្ន័ប្រយែងក្នុងការប្រើប្រាស់គោលការណ៍ *តុលាការចេះ ឬដឹងច្បាប់* នេះ ព្រោះថាគោលការណ៍នេះរំលោភមាត្រា ២១(៤)ក នៃលក្ខន្តិកៈរបស់ខ្លួន ដែលក្នុងនោះបានធានាពីសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានព័ត៌មានពេញលេញអំពីមូលហេតុនៃការចោទប្រកាន់[៧៤] ។

ដំណោះស្រាយចំពោះការអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿងលេខ ០០១ នេះ គឺជាមូលដ្ឋានដ៏សំខាន់ សម្រាប់សំណុំរឿងក្រោយៗទៀតរបស់ អ.វ.ត.ក ។ ការកំណត់យកទម្រង់ទាំងបីនៃទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង **ឌុច** ធ្វើឱ្យកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យកាន់តែធំជាងមុន ។ ជាងនេះទៅទៀត ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង អាចកំណត់ពីអង្គហេតុដែលបានទទួលស្គាល់បន្ថែមលើទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅពេលបិទបញ្ចប់នីតិវិធីជំនុំជម្រះដោយមិនរាប់បញ្ចូលនូវអ្វីដែលបានទទួលស្គាល់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ ។ បើគេពិនិត្យមើលពីបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរ ដែលជនជាប់ចោទបានកំពុងរងការចោទប្រកាន់ អង្គជំនុំជម្រះសាលាដំបូងមានការប្រុងប្រយ័ត្នក្នុងការកំណត់ថា តើគួរប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនដូចម្តេច ចំពោះការកំណត់អង្គច្បាប់ និងអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ បន្ថែមលើនេះ ទាំងសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ត្រូវធានាថាដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿងលេខ ០០២ និងសំណុំរឿងក្រោយៗ នឹងមិនមានបញ្ហាដូចដែលអង្គបុរេជំនុំជម្រះបានរកឃើញក្នុងសំណុំរឿងក្តីលេខ ០០១ នោះទេ ។

## ខ. សិទ្ធិទទួលបានការជំនុំជម្រះក្នុងរយៈពេលសមរម្យ

### ១. ការឃុំខ្លួនបណ្តោះអាសន្ន

**ឌុច** បានជាប់ឃុំបណ្តោះអាសន្នក្នុងតុលាការយោធាអស់រយៈពេលជាង ០៨ឆ្នាំ មុនបញ្ជូនមក អ.វ.ត.ក នៅថ្ងៃទី៣០ ខែកក្កដា ២០០៧ ។[៧៥] ការិយាល័យសហព្រះរាជអាជ្ញា និងអង្គបុរេជំនុំជម្រះ បានលើកហេតុផលថា ការឃុំខ្លួន **ឌុច** បណ្តោះអាសន្ននៅតុលាការយោធា មិនមែនជាការទទួលខុសត្រូវរបស់ អ.វ.ត.ក ទេ ចំណែកឯការបន្តឃុំខ្លួនបណ្តោះអាសន្ននៅ អ.វ.ត.ក គឺចាំបាច់ដើម្បីធានាសុវត្ថិភាពរបស់ជនត្រូវចោទ ។[៧៦] ភាគីមេធាវីការពារក្តី បានលើកបញ្ហានេះចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា ការបន្តឃុំខ្លួន **ឌុច** ដោយគ្មានការជំនុំជម្រះ គឺ

---

[៧៤] សូមមើលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ក្នុងសំណុំរឿងក្តី *Kupreskic, et al.* (IT-95-16) ចុះថ្ងៃទី ១៤ មករា ២០០០ កថាខ័ណ្ឌ ៧៤០ ។

[៧៥] សូមមើលសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនៃអ.វ.ត.ក. សំណុំរឿងក្តីលេខ ០០១ ស្តីពី "សំណើសុំដោះលែងឱ្យនៅក្រៅឃុំ" ថ្ងៃ ១៥ មិថុនា ២០០៩ ។

[៧៦] សូមមើល "ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ **កាំង ហ្គេចអ៊ាវ** ហៅ **ឌុច** របស់" ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក. ក្នុងសំណុំរឿងក្តីលេខ ០០១ ថ្ងៃទី ៣១ កក្កដា ២០០៧ ។

ជាការរំលោភលើច្បាប់ជាតិ និងអន្តរជាតិ ។[៧៧] ក្រុមមេធាវីការពារក្តី បានស្នើសុំឱ្យដោះលែងជនជាប់ចោទជាបន្ទាន់ ព្រមទាំងរកដំណោះស្រាយចំពោះការឃុំបណ្តោះអាសន្នហួសរយៈពេល នៅពេលចេញសាលក្រម ។[៧៨] ប្រសិនបើការឃុំខ្លួនបណ្តោះអាសន្ន **ឌុច** ដោយតុលាការយោធា ត្រូវបូកបញ្ចូលនឹងការឃុំខ្លួនបណ្តោះអាសន្ននៅ អ.វ.ត.ក នោះមានន័យថា រយៈពេលឃុំខ្លួនបណ្តោះអាសន្ននេះ លើសរយៈពេលដែលក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានកំណត់ ៣ឆ្នាំ និងបទដ្ឋាននានាដែលទទួលស្គាល់ទូទៅចំពោះការឃុំខ្លួនបណ្តោះអាសន្នក្នុងរយៈពេលកិច្ចដំណើរការនីតិវិធីធម្មតា ។[៧៩]

នៅក្នុងសេចក្តីសម្រេច ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា តុលាការយោធាបានរំលោភសិទ្ធិជនជាប់ចោទ ។ ហេតុដូចនេះ អង្គជំនុំជម្រះបានប្រកាសថា ប្រសិនបើខ្លួនចេញសាលក្រមសម្រេចសេចក្តីថា ជនជាប់ចោទគ្មានទោសនោះ **ឌុច** មានសិទ្ធិទាមទារឱ្យមានដំណោះស្រាយចំពោះការឃុំខ្លួនដោយខុសច្បាប់នៅតុលាការយោធា ព្រមទាំងដំណោះស្រាយចំពោះការរំលោភសិទ្ធិរបស់គាត់ ។[៨០] ផ្ទុយទៅវិញ យោងតាមមាត្រា ៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ប្រសិនបើសាលក្រមសម្រេចថា មានទោស នោះ **ឌុច** មានសិទ្ធិទាមទារឱ្យតុលាការបូកបញ្ចូលរយៈពេលជាប់ឃុំក្រោមសមត្ថកិច្ចរបស់តុលាការយោធា ចាប់ពីថ្ងៃទី ១០ ខែឧសភា ឆ្នាំ១៩៩៩ ដល់ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ រួមជាមួយនឹងរយៈពេលជាប់ឃុំនៅក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក រាប់ចាប់ពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ តទៅ ។ ក្នុងករណីនេះ ទោសរបស់ **ឌុច** នឹងត្រូវកាត់បន្ថយរយៈពេលប្រហែល ០៨ឆ្នាំ ។[៨១]

ទោះបីជា ច្បាប់រដ្ឋធម្មនុញ្ញ និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងពីការការពារនូវការរំលោភសិទ្ធិរបស់ជនជាប់ចោទ មិនឱ្យមានការឃុំខ្លួនបណ្តោះអាសន្នលើសពីរយៈពេលកំណត់ក៏ដោយ ក៏ក្នុង

---

[៧៧] សូមមើលរបាយការណ៍ឃ្លាំមើលសាលាក្តីខ្មែរក្រហមលេខ ០១ ក្នុងសវនាការបឋមថ្ងៃទី១៧-១៨ កុម្ភៈ ២០០៩។

[៧៨] មេធាវីការពារក្តីយោងមាត្រា ៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលថា ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវគិតបញ្ចូលទាំងស្រុងក្នុងចិរវេលានៃទោស ដែលបានប្រកាស ឬជាយថាហេតុនៃចិរវេលាសរុបនៃទោសដែលបានទទួលរង បន្ទាប់ពីការស្រូបទោសបញ្ចូលគ្នា ។ សូមមើលមាត្រា ៧៧-២ នៃលក្ខនិកៈក្រុងរ៉ូម ។ សូមមើលវិធាននៃនីតិវិធី និង ភស្តុតាង មាត្រា ១០១-ខ-៥ និង ១០១.គ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ សូមមើលវិធាននៃនីតិវិធី និងភស្តុតាង មាត្រា ១០១-ខ-៤ និង ១០១-គនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសរ៉ូវ៉ាន់ដា ។ សូមមើលវិធាននៃនីតិវិធី និងភស្តុតាង មាត្រា ១០១.ខ-៣ និងមាត្រា ១០១. ឃ នៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលេអូន ។

[៧៩] សូមមើលមាត្រា ២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ។

[៨០] សូមមើលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿងក្តីលេខ ០០១ នៃ អ.វ.ត.ក. ស្តីពីសំណើសុំដោះលែងក្រៅឃុំ ។

[៨១] ក្នុងករណីនេះយើងសន្មតថា រយៈពេលជាប់ឃុំ ៣ ឆ្នាំដំបូងរបស់គាត់ស្របច្បាប់ ដោយយោងតាមច្បាប់កម្ពុជា។ សូមមើលបន្ថែមសេចក្តីសម្រេចស្តីពីសំណើសុំដោះលែងឱ្យនៅក្រៅឃុំ ។

ការអនុវត្តជាក់ស្តែង សិទ្ធិនេះនៅតែត្រូវបានរំលោភបំពានដដែល ។[៨២] ប្រសិនបើពិនិត្យមើលពីហេតុផល ដែលសហព្រះរាជអាជ្ញា និងតុលាការប្រើអំណាចខ្លួន ដើម្បីពន្យារយៈពេលឃុំខ្លួនបណ្តោះអាសន្ន ដូចបានកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ហាក់ដូចជាមិនមានភាពច្បាស់លាស់ ។[៨៣] ជាងនេះទៅទៀត បញ្ហាជាច្រើននៅក្នុងការអនុវត្តជាក់ស្តែង ដូចជា ការលំបាកក្នុងការបញ្ចប់ការស៊ើបសួរ ធ្វើឱ្យជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្នជាច្រើនខែ/ឆ្នាំ ដោយហួសអាជ្ញាយុកាលកំណត់ ។ ការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះ អំពីការឃុំខ្លួន **ឌុច** ដោយខុសច្បាប់នៅតុលាការយោធា គឺជាយុត្តិសាស្ត្រដ៏ល្អ ដែលមេធាវីជាតិអាចយកជាគំរូ និងធ្វើការតស៊ូមតិ ដើម្បីឱ្យមានដំណោះស្រាយសមស្របចំពោះករណីឃុំខ្លួនបណ្តោះអាសន្នមកលើកូនក្តីខ្លួន ។ ការសម្រេចបែបនេះ ក៏ជួយធ្វើឱ្យមានការយកចិត្តទុកដាក់ជាខ្លាំង ចំពោះសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្នុងរយៈពេលសមស្រប និងទទួលបានដំណោះស្រាយសមរម្យ ប្រសិនបើមានការរំលោភលើសិទ្ធិនេះ ។

## ២. ការបង្ហាញពីវិប្បដិសារី

នៅក្នុងកិច្ចស៊ើបសួរ និងក្នុងពេលសវនាការជំនុំជម្រះនៅ អ.វ.ត.ក **ឌុច** បានទទួលស្គាល់មួយភាគធំនូវតួនាទីរបស់គាត់ក្នុងរបបខ្មែរក្រហម ព្រមទាំងឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅមន្ទីរ ស-២១ ។ ក្នុងឱកាសដែលអង្គជំនុំជម្រះផ្តល់ពេលឱ្យឆ្លើយតបចំពោះសេចក្តីថ្លែងរបស់សហព្រះរាជអាជ្ញានៅថ្ងៃសវនាការទី២ **ឌុច** បានឆ្លៀតឱកាសសុំខមាលទោសចំពោះជនរងគ្រោះ ហើយសុំឱ្យពួកគេអភ័យទោសដល់រូបគាត់ ។[៨៤] **ឌុច** ព្រមធ្វើការសហការជាមួយតុលាការ និងភាគីនានា ដើម្បីជួយបន្ធូបន្ថយការឈឺចាប់របស់ប្រជាជនកម្ពុជា។[៨៥] ចំពោះនីតិវិធីក្នុងប្រពន្ធ័ច្បាប់ Common Law និងតុលាការអន្តរជាតិនានា ការទទួលស្គាល់ការទទួលខុសត្រូវរបស់ **ឌុច** គឺជាការទទួលកំហុសចំពោះបទចោទប្រកាន់ជាច្រើនមកលើរូបគាត់ ។ ទោះបីជា មានការសារភាពបែបនេះក៏ដោយតាមច្បាប់នីតិវិធីកម្ពុជា និងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក មិនបានកំណត់ឱ្យពន្លឿនដំណើរការនីតិវិធីជំនុំជម្រះទេដែលផ្ទុយពីតុលាការអន្តរជាតិផ្សេងៗ ។[៨៦] ចំណែកឯវិធានផ្ទៃក្នុងរបស់ អ.វ.ត.កបានកំណត់លក្ខខណ្ឌចំនួនពីរមុននឹងសម្រេចទោសលើជនជាប់ចោទ ។ ទី១-សហព្រះរាជអាជ្ញាត្រូវបង្ហាញពិរុទ្ធភាពរបស់ជនជាប់ចោទ និង ទី២-ការបង្ហាញ

---

[៨២] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១៨៣ ដល់ ១៨៤ ។ សូមមើលរបាយការណ៍របស់អ្នកតំណាងពិសេសរបស់អគ្គលេខាអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ស្តីពី "ជំនួយបច្ចេកទេសនិងការពង្រឹងសមត្ថភាព" ដោយលោក Yash Ghai ((A/HRC/7/42) ថ្ងៃទី ២៩ កុម្ភៈ ២០០៨ ។

[៨៣] សូមមើលរបាយការណ៍ របស់ Gai .

[៨៤] សូមមើលរបាយការណ៍ឃ្លាំមើលសាលាក្តីខ្មែរក្រហម លេខ ០២ ( ថ្ងៃទី៣០ មិនា ដល់១ មេសា ២០០៩) ។

[៨៥] សូមមើលប្រតិចារឹកសវនាការថ្ងៃទី ៣១ មិនា ២០០៩ ក្នុងសំណុំរឿងក្តីលេខ ០០១ របស់អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក និងរបាយការណ៍ឃ្លាំមើលសាលាក្តីខ្មែរក្រហម លេខ ០២ ( ថ្ងៃទី៣០ មិនា ដល់១ មេសា ២០០៩) ។

[៨៦] សូមមើល ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ។ លក្ខន្តិកៈក្រុងរ៉ូមមាត្រា ៦៥ ។ វិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី វិធាន ៦២ ស្ទួន និង វិធាន ១០០។ វិធានរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលេអូន វិធាន ៦១(៥) និង វិធាន ៦២ ។

នោះត្រូវធ្វើឱ្យហួសពីវិមតិសង្ស័យ ។[៨៧] ហេតុនេះហើយបានជាសវនាការលើអង្គសេចក្តីត្រូវបានប្រព្រឹត្តឡើង ទោះ-បីជា ជនជាប់ចោទបានឆ្លើយសារភាពពីទោសកំហុសរបស់ខ្លួនក៏ដោយ ។

ថ្វីត្បិតតែជនជាប់ចោទបានផ្លាស់ប្តូរជំហររបស់ខ្លួននាថ្ងៃសវនាការចុងក្រោយ ការរៀបចំការជំនុំជម្រះដ៏ពេញលេញក្នុងសំណុំរឿង **ឌុច** គឺ *អាច* ជាការរំលោភលើសិទ្ធិជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្នុងរយៈពេលសមរម្យ ។ កិច្ចដំណើរការនីតិវិធីអង្គសេចក្តីបានចំណាយពេលរហូត ២២ សប្តាហ៍ ហើយមិនទាន់ដឹងច្បាស់នៅឡើយថា តើអង្គជំនុំជម្រះនឹងប្រើរយៈពេលប៉ុន្មាន ដើម្បីចេញសាលក្រមក្នុងសំណុំរឿងក្តីនេះ ។[៨៨] បើយើងពិចារណាអំពីការទទួលស្គាល់ការទទួលខុសត្រូវភាគច្រើនរបស់ **ឌុច** ចំពោះបទចោទមកលើរូបគាត់តាំងពីដំណាក់កាលស៊ើបអង្កេតមកនោះ គេអាចនិយាយបានថា សវនាកា **ឌុច** គួតែចប់មុនរយៈពេលនេះ ។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី រយៈពេលជាមធ្យមគិតចាប់ពីការទទួលស្គាល់បទចោទប្រកាន់របស់ជនជាប់ចោទរហូតដល់ពេលចេញសាលាក្រម គឺមានរយៈពេល ២២សប្តាហ៍ ។[៨៩] រយៈពេលជំនុំជម្រះយូបំផុត គឺ ៣៥សប្តាហ៍ រីឯខ្លីបំបផុត គឺ ០៧សប្តាហ៍ ។[៩០] ប៉ុន្តែបើយើងពិនិត្យឱ្យបានម៉ត់ចត់ទៅលើសវនាការ **ឌុច** គឺខុសពីសវនាការនៅតុលាការអន្តរជាតិនានាព្រោះវាបានកើតឡើង ៣០ឆ្នាំក្រោយអំពើឧក្រិដ្ឋកម្ម ហើយមានការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណីទៀត ដូចនេះសវនាការជម្រះក្តី **ឌុច** គឺមិនអូសបន្លាយពេលយូដូចដែលគេយល់ឃើញនោះទេ ។

គេអាចនឹងយល់ថា ប្រសិនបើផ្នែកមួយនៃតួនាទីស្វែងរកយុត្តិធម៌របស់ អ.វ.ត.ក គឺស្វែងរកការពិតនៃអំពើឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងកំឡុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ សវនាការនេះមានភាពយុត្តិធម៌នៅក្នុងកម្រិតមួយ ។[៩១] ជាក់ស្តែង ភស្តុតាងដែលបង្ហាញក្នុងកិច្ចដំណើរការនីតិវិធី បានបំភ្លឺកាន់តែច្បាស់នូវប្រវត្តិ

---

[៨៧] សូមមើលវិធាន ៣ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. និងវិធាន ៨៧-១។ សូមមើល របាយការណ៍ឃ្លាំមើលសាលាក្តីខ្មែរក្រហម លេខ ២១ ឧបសម្ព័ន្ធ ខ ។

[៨៨] រយៈពេលសវនាការចាប់ពីថ្ងៃដំបូង គឺ ១៧-១៨ កុម្ភៈ ២០០៩ និងថ្ងៃទី ២០ មិនា ២០០៩ ដល់ ២០ កញ្ញា ២០០៩ ដោយមិនរាប់ការសម្រាប់របស់តុលាការនៅថ្ងៃបុណ្យ គឺមានរយៈពេល ២៥ សប្តាហ៍។ ប៉ុន្តែប្រសិនបើគិតពីថ្ងៃសវនាការទាំងមូលវិញ រាប់តាំងពីសវនាការបឋមពីថ្ងៃទី ១៧-១៨ កុម្ភៈ ២០០៩ ដល់ ២០ កញ្ញា ២០០៩ គឺមានរយៈពេល ៣០ សប្តាហ៍ ។

[៨៩] សូមមើលរឿងក្តីនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូយ្គោស្លាវី ដូចជារឿងក្តី Babic (IT-0273) រឿងក្តី Banovic (II-02-65/1) រឿងក្តី Bralo (IT-95-17) រឿងក្តី Cesic (IT-95-10/1) រឿងក្តី Deronjic (IT-02-61) រឿងក្តី Dosen, et al (IT-98-8) រឿងក្តី Erdmovic (IT-96-22) រឿងក្តី Jokic (IT-01-42/1) រឿងក្តី Kolundzija,et al (IT-95-8) រឿងក្តី Mrda (IT-02-59) រឿងក្តី Nikolic (IT-94-2) រឿងក្តី Nikolic (IT-02-60/1) រឿងក្តី Obrenovic (IT-02-60/2) រឿងក្តី Plavsic (IT-00-39 &40/1) រឿងក្តី Rajic (IT-95-12) រឿងក្តី Sikirica, et al (IT-95-8) រឿងក្តី Simic (IT-95-9/2) រឿងក្តី Todorovic (IT-95-9/1) ព័ត៌មានស្តីពីសំណុំរឿងនេះអាចរកបាននៅ www.icty.org ។

[៩០] សូមមើលរឿងក្តី Mrda (IT-2-59) និង Sikirica, et al (IT-95-8 ICTY) នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ ព័ត៌មាននៃសំណុំរឿងនេះអាចរកបាននៅ www.icty.org ។

[៩១] សូមមើលប្រតិចារឹកសវនាការអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. សំណុំរឿងលេខ ០០១ ថ្ងៃទី ៣១ មិនា ២០០៩។

សាស្ត្រ ដ៏ខ្មៅងងឹតរបស់ប្រទេសកម្ពុជាក្នុងសម័យនោះ ។[៩២] ដូចនេះ ការពិតនៃអំពើឧក្រិដ្ឋ ដែលបានមកដោយការជជែកដេញដោលក្នុងសវនាការ គេពិបាកនឹងនិយាយថា មានការរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប ។

### គ. គោលការណ៍សមភាពរវាងការការពារ និងការចោទប្រកាន់ *(Equality of Arms)*

គោលការណ៍នេះ ជាផ្នែកមួយដ៏សំខាន់នៃដំណើរការជំនុំជម្រះក្តីដោយយុត្តិធម៌ក្នុងប្រពន្ធ័ច្បាប់ស៊ីវិល និងសំដៅលើសមភាពរវាងធនធានដែលមាន និងសិទ្ធិនានាក្នុងកិច្ចដំណើរការនីតិវិធីរវាងព្រះរាជអាជ្ញា និង មេធាវីការពារក្តី ។[៩៣] គោលការណ៍នេះ ត្រូវតែគោរពជាចាំបាច់ ជាពិសេសក្នុងករណីជំនុំជម្រះលើករណីសម្លាប់រង្គាលព្រោះការចោទប្រកាន់ទៅលើជនជាប់ចោទពីភាគីព្រះរាជអាជ្ញា គឺក្នុងបំណងឱ្យមានការដាក់ទោសធ្ងន់ ហើយមាននិន្នាការបន្ថយតួនាទីរបស់ក្រុមការពារក្តី ។ នៅ អ.វ.ត.ក ការអនុវត្តគោលការណ៍នេះកាន់តែមានភាពស្មុគ្រស្មាញឡើង ដោយសារមានការចូលរួមពីភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលនាំឱ្យភាគីនៅសវនាកាឡើងដល់ទៅបី ។ នៅក្នុងស្ថានភាពនេះ ដើម្បីអនុវត្តគោលការណ៍នេះឱ្យមានប្រសិទ្ធិភាព អង្គជំនុំជម្រះត្រូវធានាឱ្យមានតុល្យភាពរវាងភាគីទាំងបី ។[៩៤]

វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក បានកំណត់ថា គោលបំណងនៃសកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺដើម្បីធានាពីការចូលរួមរបស់ជនរងគ្រោះក្នុងកិច្ចដំណើរការនីតិវិធី ដោយ *"ជួយគាំទ្រដល់ការចោទប្រកាន់"*[៩៥] ប៉ុន្តែក្នុងកិច្ចដំណើរការជំនុំជម្រះក្តី **ឌុច** គេចាំបាច់ត្រូវបកស្រាយចំណុចនេះឱ្យបានច្បាស់លាស់ព្រោះមេធាវីការពារក្តីតែងតែជំទាស់នឹងកម្រិតនៃការប្រើប្រាស់សិទ្ធិរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។[៩៦] ជាញឹកញាប់ មេធាវីការពារក្តី បានលើកឡើងថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើរតួជា *"ព្រះរាជអាជ្ញាទី២"* មិនមែនជួយគាំទ្រដល់ការចោទប្រកាន់នោះទេ ។[៩៧] នៅក្នុងបទសម្ភាសន៍ជាមួយមេធាវីការពារក្តីអន្តរជាតិលោក Roux បានពន្យល់

---

[៩២] នៅក្នុងសំណុំរឿងរវាងសហព្រះរាជអាជ្ញា និង Erdemovic អង្គជំនុំជម្រះបានពន្យល់ថា តួនាទីរបស់សាលាក្តីអន្តរជាតិ ក្រៅពីស៊ើបអង្កេត ចោទប្រកាន់ និងដាក់ទោសចំពោះទង្វើរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ គឺជួយចូលរួមចំណែកដល់ការផ្សះផ្សារ ការស្វែងរកការពិត នៅពីក្រោយអំពើឃោឃៅដែលប្រព្រឹត្តនៅអតីតប្រទេសយូហ្គោស្លាវី ។ សូមមើលបន្ថែមសាលក្រមសំណុំរឿងនេះ ថ្ងៃទី ៥ មិនា ១៩៩៨ ។

[៩៣] សូមមើលសំណុំរឿងរវាងព្រះរាជអាជ្ញា និង Delalic (IT-96-21) ថ្ងៃទី ៤ កុម្ភៈ ១៩៩៨ កឋាខណ្ឌ ៤៧ នៃអង្គជំនុំជម្រះសាលាដំបូង ICTY

[៩៤] សូមមើលបណ្តឹងឧទ្ធរណ៍នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ក្នុងសំណុំរឿង Kordic ថ្ងៃទី ១១ កញ្ញា ២00១ (IT-94-96-21) ។

[៩៥] វិធាន ២៣-១-ក នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. ។

[៩៦] សូមមើលរបាយការណ៍ឃ្លាំមើលសាលាក្តីខ្មែរក្រហមលេខ ៧, ៩, និង លេខ ២១ ។

[៩៧] សូមមើលរបាយការណ៍ឃ្លាំមើលសាលាក្តីខ្មែរក្រហមលេខ ៧, ៩, ២១។ លើសពីនេះក្រុមធាវីការពារក្តី បានលើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើហួសពីតួនាទីរបស់ខ្លួនក្នុងការ "គាំទ្រការចោទប្រកាន់" ដោយព្យាយាមដាក់ឯកសារទាំងឡាយណា ដែលមិនជាប់ទាក់ទងនឹងកូនក្តីរបស់ខ្លួន។ ទាក់ទងចំនុចនេះ សូមមើលបន្ថែមក្នុងរបាយការណ៍ឃ្លាំមើលសាលាក្តីខ្មែរក្រហមលេខ ៩, និង ២១ ។

ថា ការដែលឱ្យដើមបណ្ដឹងរដ្ឋប្បវេណីចូលធ្វើអន្តរាគមន៍ក្នុងកិច្ចដំណើរការនីតិវិធីនេះ គឺដើម្បីទាមទារសំណង ហើយករណីនេះអាចធ្វើទៅបាន នៅពេលជនជាប់ចោទបដិសេធមិនទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ។[៩៨]

នៅក្នុងសេចក្ដីសម្រេច កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការជំនុំជម្រះប្រកបដោយយុត្តិធម៌ក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ រួមទាំងសិទ្ធិក្នុងការតតាំងជាមួយសហព្រះរាជអាជ្ញា ។ នៅពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមជួយ និងគាំទ្រការចោទប្រកាន់ក្នុងដំណើរការនីតិវិធី តួនាទីរបស់ពួកគេមិនមែនជាព្រះរាជអាជ្ញាទេ ។[៩៩] ទោះបីជាយ៉ាងណា សេចក្ដីសម្រេចនេះមិនបានឱ្យនិយមន័យ ឬបកស្រាយឱ្យបានច្បាស់លាស់ពីតួនាទីនៃការចូលរួមរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទេ ។ អង្គជំនុំជម្រះគ្រាន់តែប្រកាសថា ភាគីនីមួយៗមានតួនាទីខុសៗគ្នា ក្នុងការរក្សាការពារប្រយោជន៍ និងការទទួលខុសត្រូវរបស់ខ្លួនក្នុងកិច្ចដំណើរការនីតិវិធី ។[១០០] បញ្ហានេះក៏អាចនឹងកើតឡើងជាថ្មី នៅក្នុងសំណុំរឿងក្ដីលេខ ០០២ ដែលគេរំពឹងថា នឹងមានដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនចូលរួម ។

## ឃ. ការអនុវត្ត និងការបកស្រាយវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក

### ១. អំពីការអនុវត្តនៃការដាក់ភស្តុតាងចំពោះមុខអង្គជំនុំជម្រះ

អង្គជំនុំជម្រះ ត្រូវធ្វើការសម្រេចចិត្តដោយផ្អែកតែទៅលើភស្តុតាង ដែលភាគីបានដាក់ដេញដោលនៅចំពោះមុខខ្លួនប៉ុណ្ណោះ ។ តាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក បានចែងថា ឯកសារត្រូវចាត់ទុកថា ជាភស្តុតាង លុះត្រាតែ ខ្លឹមសារនៃឯកសារនោះត្រូវបានសង្ខេប ឬអាននៅក្នុងសវនាការ ។[១០១] ប៉ុន្តែឆ្លងតាមការអនុវត្តវិធាននេះក្នុងសំណុំរឿងក្ដីលេខ ០០១ បង្ហាញពីបញ្ហាលំបាក និងត្រូវចំណាយពេលយ៉ាងច្រើន ព្រោះមានឯកសាររាប់សិបទំព័រដែលភាគីត្រូវដាក់ដេញដោលចំពោះមុខអង្គជំនុំជម្រះ ។[១០២]

កិច្ចប្រជុំរៀបចំសវនាការ កាលថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ត្រូវបានរៀបចំឡើង ដើម្បីដោះស្រាយបញ្ហានេះ ។[១០៣] ជាលទ្ធផល ការណែនាំមួយត្រូវបានសម្រេចឡើង ដោយអនុញ្ញាតឱ្យគូភាគី ដែលមានបំណងដាក់ឯកសារជាភស្តុតាងចំពោះមុខអង្គជំនុំជម្រះ ត្រូវតែបង្ហាញពីអត្តសញ្ញាណនៃឯកសារ និងលេខយោងរបស់វា ។ សហព្រះរាជអាជ្ញា បានសម្ដែងនូវការស្ញើចសរសើរនូវការឆ្លើយតបដ៏ទាន់ពេលវេលាចំពោះបញ្ហាការដាក់ភស្តុតាង

[៩៨] បទសម្ភាសន៍ជាមួយមេធាវីការពាក្ដីអន្តរជាតិ លោក Francois Roux ថ្ងៃទី ១៩ តុលា ២០០៩ ។

[៩៩] សូមមើលសេចក្ដីសម្រេចក្នុងសំណុំរឿងលេខ ០០១ របស់អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក. ស្ដីពី " សំណើរួមរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះជំហររបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការដាក់សារណាស្ដីពីការដាក់ទោស និង សេចក្ដីណែនាំអំពីការតាំងសំនួរទៅជនជាប់ចោទ អ្នកជំនាញ សាក្សី ស្ដីពីអត្តចារីករបស់ **ឌុច** " ថ្ងៃទី ៩ តុលា ឆ្នាំ ២០០៩ វាក្យខណ្ឌទី ២៦ ។

[១០០] សូមមើលសេចក្ដីសម្រេចថ្ងៃទី ០៩ តុលា ២០០៩ វាក្យខណ្ឌ័ទី ២៧ ។

[១០១] វិធាន ៨៧-១ និង ៨៧-៣ នៃវិធានផ្ទៃក្នុង ។

[១០២] សូមមើលរបាយការណ៍ឃ្លាំមើលសាលាក្ដីខ្មែរក្រហម លេខ ៦,៩,១៦, និង លេខ ២១ ។

[១០៣] សូមមើលរបាយការណ៍ឃ្លាំមើលសាលាក្ដីខ្មែរក្រហម លេខ ៩ ។

ចំពោះមុខអង្គជំនុំជម្រះ ហើយបានកត់សម្គាល់ថា ការអនុវត្តន៍បែបនេះឆ្លុះបញ្ចាំងពីការអនុវត្តន៍នៅសាលាក្តីអន្តរជាតិនានា ដែលកាត់ទោសចំពោះឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ ស្មុគ្រស្មាញ និងបង្កឱ្យបាត់បង់អាយុជីវិតមនុស្សរាប់ពាន់នាក់ ។[១០៤] ដោយកត់សម្គាល់ឃើញថា ការធ្វើបែបនេះអាចជួយបង្កើនល្បឿនដល់កិច្ចដំណើរការនីតិវិធី គេបានធ្វើវិសោធនកម្មវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងជាបន្តបន្ទាប់ ដោយកំណត់ឱ្យបង្ហាញអត្តសញ្ញាណភស្តុតាងឯកសារមុខអង្គជំនុំជម្រះ និងភាគីជំនួសវិញ ។[១០៥] ដំណោះស្រាយបែបនេះ គឺអាចជួយឱ្យអង្គជំនុំជម្រះចំណេញពេលវេលាក្នុងសវនាការសំណុំរឿងក្តីលេខ ០០២ ដែលពេលនោះនឹងមានភស្តុតាងឯកសារជាច្រើនលើសលុបត្រូវដាក់បង្ហាញ ។

## ២. ការទទួលយកភស្តុតាង

បញ្ហានៃការទទួលយកភស្តុតាងនៅក្នុងសំណុំរឿងក្តីលេខ ០០១ គឺទាក់ទងនឹងកម្រិតនៃការទទួលយកបទសម្ភាសន៍ទុកជាភស្តុតាង ហើយដែលបទសម្ភាសន៍នោះមិនបានធ្វើឡើងតាមនីតិវិធីតុលាការទេ ។ ភាពជាប់គាំងដែលបណ្តាលមកពីបញ្ហានេះនាំឱ្យអូសបន្លាយពេលវេលាសវនាការ ជាពិសេស នៅពេលដែលមេធាវីការពារក្តីជំទាស់នឹងការដាក់បញ្ចូលបទសម្ភាសន៍របស់មនុស្សដែលបានស្លាប់បាត់ទៅហើយ (ឯកសារនេះធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា) ។[១០៦] មេធាវីការពារក្តី បានលើកឡើងថា កំណត់ហេតុបទសម្ភាន៍នោះមិនបានធ្វើសម្បថជាមុនទេ ហើយក៏មិនមានការជជែកសាកសួរតទល់គ្នាមុនមានការជំនុំជម្រះដែរ ដូចនេះមិនគួរទទួលយកជាភស្តុតាង។[១០៧] ទោះបីជា សហព្រះរាជអាជ្ញាបានលើកមតិជំទាស់នឹងអំណះអំណាងខាងលើ ក៏អង្គជំនុំជម្រះសាលាដំបូងបានសម្រេចគាំទ្រអំណះអំណាងរបស់មេធាវីការពារក្តី ហើយប្រកាសថា កំណត់ហេតុនៃបទសម្ភាសន៍ទាំងនោះមិនអាចទទួលយកជាភស្តុងបានទេ ។[១០៨] ដោយលើកហេតុផលថា ប្រភព និងខ្លឹមសារនៃកិច្ចសម្ភាសន៍ ព្រមទាំងស្ថានភាព ដែលជនជាប់ចោទមិនមានលទ្ធភាពតទល់នឹងសេចក្តីពិតនៃកំណត់ហេតុ បានធ្វើឱ្យឯកសារទាំងនោះមិនមានលក្ខណៈសមស្របក្នុងការទទួលយកជាភស្តុតាង អនុលោមតាមវិធាន ៨៧(៣) ។[១០៩]

---

[១០៤] បទសម្ភាសន៍ជាមួយលោក William Smith សហព្រះរាជអាជ្ញាអន្តរជាតិ ។

[១០៥] វិសោធនកម្មនេះត្រូវបានគេគិតគូ ហើយអនុមត័ដោយកិច្ចប្រជុំពេញអង្គទីលើកទី ៦ របស់អ.វ.ត.ក. ដែលធ្វើនៅថ្ងៃទី ៧-១១ កញ្ញា ២០០៩។ សម្រាប់ព័តិមានបន្ថែម សូមមើលសេចក្តីប្រកាសព័តិមានថ្ងៃទី ៣ ខែកញ្ញា ២០០៩ និង ១១ ខែកញ្ញា ២០០៩ ដែលអាចរកបានតាម www.ecc.gov.kh ។

[១០៦] មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាអង្គការមិនមែនរដ្ឋាភិបាល ដែលបង្កើតឡើងនៅឆ្នាំ ១៩៩៥ ដោយសកលវិទ្យាល័យYale ស្តីពីកម្មវិធីប្រល័យពូជសាសន៍ ។ ស្ថាប័ននេះ គឺជាមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ ដែលផ្ទុកឯកសាររាប់សិប ដែលគេយកទៅប្រើសម្រាប់បង្ហាញក្នុងសំណុំរឿងក្តី **ឌុច**។

[១០៧] សូមមើលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការទទួលយកភស្តុតាងឯកសារក្នុងសំណុំរឿងលេខ ០០១ ថ្ងៃទី ២៦ ខែឧសភា ២០០៩ វាក្យខណ្ឌ ២។ សូមមើល របាយការណ៍ឃ្លាំមើលសាលាក្តីខ្មែរក្រហមលេខ ៣, ៤, ៦, ១២, និង ១៦ ។

[១០៨] សូមមើល សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង អំពីភាពទទួលយកបានភស្តុតាងឯកសារក្នុងសំណុំរឿង វាក្យខណ្ឌទី ១៦ ។

[១០៩] សូមមើល សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក. អំពីភាពទទួលយកបានឯកសារក្នុងសំណុំរឿងជាភស្តុតាង កឋាខណ្ឌ័១ ៦ ។ ដើម្បីឈានដល់ការសន្និដ្ឋានស្តីពីបញ្ហានេះ អង្គជំនុំជម្រះ បាននិយាយយោងទៅដល់កត្តាមួយចំនួន ដូចខាងក្រោម ដែល

បញ្ហាស្រដៀងគ្នានេះដែរ ការទទួលយកភស្តុតាង ដែលជាកំណត់ហេតុបទសម្ភាសន៍ធ្វើឡើងរវាងជនជាប់ចោទជាមួយលោក Christope Peschoux ក្នុងទសវត្សន៍ឆ្នាំ១៩៩០ ដែលបច្ចុប្បន្ន លោកគឺជាតំណាងឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ត្រូវបានដេញដោលយ៉ាងស្វិតស្វាញរវាងសហព្រះរាជ-អាជ្ញា និងមេធាវីការពារក្តី ។ នៅពេលលោកចៅក្រម Jean-Mac Lavergne ចោទសួរអំពីកាលៈទេសៈធ្វើកំណត់សម្ភាសន៍នោះ **ឌុច** បានលើកឡើងថា គាត់ត្រូវបានស្នើឱ្យផ្តល់បទសម្ភាសន៍ដោយមានការបំភាន់ភ្នែក និងមិនបានដឹងថា សេចក្តីថ្លែងនេះនឹងត្រូវយកមកប្រើប្រាស់ដើម្បីជាភស្តុតាងប្រឆាំងនឹងរូបលោកនាពេលសវនាការនេះទេ[១១០] ។ សហព្រះរាជអាជ្ញាបានឱ្យដឹងថា គេមិនបានលើកឡើងបញ្ហានេះមុនដំណាក់កាលជំនុំជម្រះនោះទេ ពោលគឺនៅពេលដែល ភស្តុតាងត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង ។ បន្ថែមលើនេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី Silke Studzinsky បានកត់សម្គាល់ថា ករណីនេះច្បាស់ណាស់ថា ផលប្រយោជន៍របស់ជនជាប់ចោទក្នុងការបដិសេធន៍កំណត់ហេតុបទសម្ភាសន៍នោះ ព្រោះខ្លាចលាតត្រដាងពីឧក្រិដ្ឋកម្មដទៃទៀតក្នុងពេលដែលខ្លួនមានតួនាទីជាប្រធានមន្ទីរ ស-២១ ។[១១១]

អង្គជំនុំជម្រះសាលាដំបូង បានច្រានចោលកំណត់ហេតុបទសម្ភាសន៍នេះ ដោយឈរលើវិធាន ៨៧(៣)ខ និង គ ដែលកំណត់ពីការបដិសេធន៍ភស្តុតាង នៅពេលភស្តុតាងទាំងនោះមិនត្រូវបានដាក់ក្នុងរយៈពេលសមស្រប ឬមានភាពច្រំដែល ។ គួរកត់សម្គាល់ដែរថា ដំណើរការអូសបន្លាយនៃកិច្ចស៊ើបសួរលើការចោទប្រកាន់ **ឌុច** និងការពិនិត្យពីភាពត្រឹមត្រូវនៃកំណត់ហេតុសម្ភាសន៍នោះធ្វើឱ្យចំណាយពេលជាច្រើន ហើយឯកសារនោះគ្រាន់តែជាព័ត៌មានបំពេញបន្ថែមតែប៉ុណ្ណោះ ។[១១២]

អង្គជំនុំជម្រះបានប្រកាន់យកនូវដំណោះស្រាយជាក់ស្តែង ចំពោះភាពអាចទទួលយកបានភស្តុតាងនេះ ហើយស្របពេលនោះក៏ធានាពីការគោរពសិទ្ធិជនជាប់ចោទផងដែរ ។ អង្គជំនុំជម្រះចាំបាច់ត្រូវគិតគូរអំពីវិធានការដ៏ប្រុងប្រយត្ន័ក្នុងការទទួលយកភស្តុតាងជាឯកសារបន្ថែមដែលមានស្រាប់ ហើយគួរពិចារណាពីអង្គហេតុនានា ដែល

---

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និង តុលាការពិសេសម្រាប់ប្រទេសសេរ៉ាលេអូន បានពិចារណាដើម្បីកំណត់ពីភាពអាចទទួលយកបាន នូវសេចក្តីថ្លែងដោយសាក្សី ដែលបានបាត់បង់ជីវិត ឬដែលមិនអាចកោះអញ្ជើញមកបំភ្លឺបាន គឺៈ ក).ក្នុងកាលៈទេសៈដែលសេចក្តីថ្លែងនោះត្រូវបានធ្វើ ឬថត ខ).ថាតើសេចក្តីថ្លែងនោះត្រូវបានពិនិត្យដោយភាគី ដែលភស្តុតាងនោះ នឹងត្រូវគេយកមកប្រឆាំងដែរឬទេ គ).ថាតើសេចក្តីថ្លែងនោះកើនឡើង តាមសារជាតិរបស់វាដែរឬទេ ។ អង្គជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី យោងលើ វិធាន ៩២ ស្ទួន និង តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលេអូន យោងលើវិធាន ៩២ និងសេចក្តីសម្រេចដោយអង្គជំនុំ ជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ក្នុងសំណុំរឿង Popvic និង Milutinovic ព្រមទាំងសេចក្តីសម្រេចដោយតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលេអូន ក្នុងសំណុំរឿង Taylor ។ សូមមើលបន្ថែម សេចក្តីសម្រេចស្តីពីការទទួលយកឯកសារក្នុងសំណុំរឿងធ្វើជាភស្តុតាង កថាខណ្ឌទី ១៥ ។

[១១០] សូមមើល សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង អំពីភាពទទួលយកបានភស្តុតាងឯកសារក្នុងសំណុំរឿង វាក្យខណ្ឌទី ១៦ ។

[១១១] សេចក្តីឆ្លើយឆ្លងតាមសំបុត្រអេឡិចត្រូនិច ជាមួយលោកស្រី Silke Studzinsky នៅថ្ងៃទី ១៩ វិច្ឆិកា ២០០៩ ។

[១១២] សេចក្តីសម្រេចស្តីពី "ការទទួលយកឯកសារជាភស្តុតាងក្នុងសំណុំរឿង" កថាខណ្ឌ ២០ ។

ជនជាប់ចោទបានទទួលស្គាល់ភាគច្រើននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ បញ្ហាទទួលយកភស្តុតាងទំនងជានឹងលេចឡើងនៅក្នុងសំណុំរឿងក្តីលេខ ០០២ទៀត បើពិនិត្យមើលពីទំហំសំណុំរឿងដែលកំពុងរៀបចំជំនុំជម្រះនេះ ហើយទំនងជាជនត្រូវចោទទាំងបួនជំទាស់នឹងខ្លឹមសារនៃឯកសារដែលដាក់បង្ហាញ ។ ការប្រកាន់យកវិធានការទៅតាមស្ថានភាពជាក់ស្តែងនៅក្នុងដំណាក់កាលនេះ អាចនឹងជួយដល់អង្គជំនុំជម្រះដោះស្រាយបញ្ហាទាំងនោះ នៅពេលដែលមានបញ្ហាស្មុគស្មាញច្រើនជាងនេះកើតឡើង ។

### ៣. ការទទួលយកភស្តុតាងបានពីការធ្វើទារុណកម្ម

ឯកសារមួយចំនួនក្នុងសំណុំរឿងក្តី **ឌុច** មានចម្លើយសារភាពដែលទទួលបានពីការធ្វើទារុណកម្មលើអ្នកទោសនៅមន្ទីរ ស-២១ ។ នៅពេលដែលភាគីព្យាយាមស្វះស្វែងរកការបំភ្លឺអំពីលក្ខខណ្ឌរបស់ អ.វ.ត.ក ក្នុងការទទួលយកចម្លើយសារភាពពីការធ្វើទារុណកម្មយកមកធ្វើជាភស្តុតាង អង្គជំនុំជម្រះសាលាដំបូងបានណែនាំដល់ភាគីឱ្យបញ្ជាក់ពីស្ថានភាពនៃឯកសារដែលទទួលបាន ។[១១៣] ដោយពិចារណាពី មាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីការប្រឆាំងការធ្វើទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយ ដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស អង្គជំនុំជម្រះបានកំណត់ថា ភាគីអាចយកខ្លឹមសារនៃចម្លើយសារភាពនោះយកមកប្រើបាន ប្រសិនបើមិនបានបំពានលើមាត្រានៃអនុសញ្ញានេះទេ ឬក៏ភស្តុតាងដែលបង្ហាញនោះគ្រាន់តែធ្វើឡើង ដើម្បីបញ្ជាក់ថា មានការទាញយកចម្លើយសារភាពក្រោមរូបភាពទារុណកម្ម ។[១១៤] អង្គជំនុំជម្រះ បានបញ្ជាក់ការណែនាំដោយផ្ទាល់មាត់ និងជាលាយលក្ខអក្សរដោយលើកឡើងថា "ភាពជាប់ពាក់ពន្ធ័នៃឯកសារនេះ គឺកម្រិតត្រឹមអង្គហេតុដែលចម្លើយសារភាពនោះពិតជាបានធ្វើឡើងមែន ហើយភស្តុតាងនោះធ្វើឡើងក្រោមរូបភាពទារុណកម្មដែលមិនបង្ហាញពីភាពពិតនៃខ្លឹមសារចម្លើយសារភាពនោះទេ" ។[១១៥]

ដោយអាចប្រឈមមុខទៅនឹងបញ្ហានេះនៅក្នុងសំណុំរឿងក្តីលេខ ០០២ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានកំណត់ថា មាត្រា១៥ នៃអនុសញ្ញានេះហាមឃាត់ការប្រើប្រាស់ចម្លើយសារភាព ដែលទទួលបានក្រោមរូបភាពទារុណកម្មយកមកធ្វើជាភស្តុតាងប្រឆាំងជនរងគ្រោះ ប៉ុន្តែមិនមែនប្រឆាំងទាំងស្រុងនឹងជនដែលជាប់ពាក់

---

[១១៣] សូមមើល របាយការណ៍ឃ្លាំមើលសាលាក្តីខ្មែរក្រហមលេខ ៧ ។ ប្រទេសកម្ពុជាបានផ្តល់សច្ចាបន័លើកតិកាសញ្ញាអន្តរជាតិ ស្តីពីការប្រឆាំងការធ្វើទារុណកម្ម នៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ១៩៩២ ។ មាត្រា ១៥ នៃកតិកាសញ្ញានេះចែងថា "រដ្ឋជាភាគីនីមួយៗ ត្រូវធានាថា រាល់ចម្លើយសារភាព ដែលបានមកដោយសារការធ្វើទារុណកម្ម មិនត្រូវប្រើធ្វើជាភស្តុតាងទេ ក្នុងដំណើរការនីតិវិធី លើកលែងតែភស្តុតាងនោះ ត្រូវគេប្រើដើម្បីប្រឆាំងជនជាប់ចោទនៃអំពើទារុណកម្មនោះ"។ ខ្លឹមសារ នៃមាត្រានេះត្រូវបានចែងផងដែរ នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨ និង វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. ក្នុងវិធាន ២១(៣) ។

[១១៤] សូមមើល របាយការណ៍ឃ្លាំមើលសាលាក្តីខ្មែរក្រហមលេខ ៧ ។

[១១៥] សូមមើល សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក. ក្នុងសំណុំរឿងក្តីលេខ ០០១ ស្តីពី " សំណើសុំរបស់ភាគី ក្នុងការដាក់បង្ហាញឯកសារមួយចំនួន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង យោងតាមវិធាន ៨៧(២)" វាក្យខណ្ឌទី ៨ ចុះថ្ងៃទី ៣១ ឧសភា ២០០៩ ។

ព័ន្ធនឹងទារុណកម្មនោះទេ ។[១១៦] ដូចនេះ ព័ត៌មាននៅក្នុងចម្លើយសារភាពនេះ អាចត្រូវបានប្រើប្រាស់ជាតម្រុយក្នុងការស៊ើបអង្កេតរកប្រភពព័ត៌មានផ្សេងៗទៀត ប្រសិនបើព័ត៌មានទាំងនោះមិនបានបង្ហាញពីការពិត ក៏គេអាចយកបង្ហាញថា "បក្សកុម្មុយនីស្តកម្ពុជាបានសំអាងលើខ្លឹមសារនៃចម្លើយសារភាពទាំងនេះ ដើម្បីប្រព្រឹត្តអំពើឧក្រិដ្ឋដែលមានលក្ខណៈជាប្រព័ន្ធ ដូច្នេះក៏ឋិតក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក ដែរ" ។[១១៧]

គួរកត់សម្គាល់ផងដែរថា វិធាននីតិវិធីនិងភស្តុតាងនៃតុលាការ *អាដហុក* អនុញ្ញាតឱ្យមានការបដិសេធភស្តុតាងទទួលបានតាមវិធីដែលសង្ស័យថា មិនអាចជឿជាក់បាន ឬប្រសិនបើការទទួលយកភស្តុតាងនោះ បង្កឱ្យមានការប៉ះពាល់ដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ។[១១៨] ចំណែកឯវិធាននីតិវិធី និងភស្តុតាងរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន អនុញ្ញាតឱ្យច្រានចោលភស្តុតាងដែលមិនអាចជួយដល់ការស្វែងរកយុត្តិធម៌បាន ។[១១៩] អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿងក្តីលេខ ០០១ និងការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿងក្តីលេខ ០០២ មានវិធានការដូចគ្នាក្នុងការដោះស្រាយបញ្ហានៃការទទួលយកភស្តុតាងជាចម្លើយសារភាព ដែលទទួលបានពីជនរងគ្រោះក្រោមរូបភាពទារុណកម្ម ។ អង្គភាពទាំងពីររបស់សាលាក្តីខ្មែរក្រហម បានបញ្ជាក់ថា ខ្លឹមសារ និងចំណារលើចម្លើយសារភាព នឹងមិនយកមកធ្វើជាមូលដ្ឋានការពិតទេ ពោល គឺគ្រាន់តែយកធ្វើជាភស្តុតាងថា ពិតជាមានការធ្វើទារុណកម្ម ឬក៏គ្រាន់តែធ្វើជាតម្រុយស៊ើបអង្កេតប៉ុណ្ណោះ ។ ទោះបីជាយ៉ាងនេះក៏ដោយ អ.វ.ត.ក កំពុងឋិតនៅក្នុងជំហរមួយមិនរឹងប៉ឹង នៅពេលដែលពុំទាន់មានសេចក្តីណែនាំច្បាស់លាស់រីឯវិធាន ៣២(១) ដែលចែងពីការហាមមិនឱ្យប្រើកំណត់ហេតុ ឬភស្តុតាងដែលបានមកដោយវិធីមិនស្របច្បាប់ គឺអនុវត្តតែចំពោះភស្តុតាង ឬកំណត់ហេតុធ្វើឡើងដោយអង្គភាពរបស់ អ.វ.ត.ក ប៉ុណ្ណោះ មិនមែនធ្វើឡើងដោយបក្សកុម្មុយនីស្តកម្ពុជានោះទេ ។[១២០] ដូចនេះ អ.វ.ត.ក អាចពឹងផ្អែកលើបទពិសោធន៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានា មកធ្វើជាសេចក្តីណែនាំ នៅពេលជួបបញ្ហានៃការទទួលយកភស្តុតាងឯកសារ ដែលបានដោយអំពើទារុណកម្ម ។

---

[១១៦] សូមមើល ដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអ.វ.ត.ក. ក្នុងសំណុំរឿងក្តីលេខ ០០២ ស្តីពី " ស្តីពីការប្រើប្រាស់ចម្លើយសារភាព ឬកំណត់ហេតុដែលបានពីការធ្វើទារុណកម្ម" វាក្យខណ្ឌទី ២៧ ចុះថ្ងៃទី ២៨ ខែកក្កដា ២០០៩ ។

[១១៧] សូមមើល ដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអ.វ.ត.ក. ក្នុងសំណុំរឿងក្តីលេខ ០០២ ស្តីពី " ស្តីពីការប្រើប្រាស់ចម្លើយសារភាព ឬកំណត់ហេតុដែលបានពីការធ្វើទារុណកម្ម" វាក្យខណ្ឌទី ២១-២២ ចុះថ្ងៃទី ២៨ ខែកក្កដា ២០០៩ ។

[១១៨] សូមមើល វិធាន ៩៥ នៃ វិធាននីតិវិធី និងភស្តុតាង របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និង វិធាន ៩៥នៃវិធាននីតិវិធី និង ភស្តុតាង របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដា ។

[១១៩] សូមមើលវិធាន ៩៥នៃវិធាននីតិវិធី និងភស្តុតាង របស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលេអូន ។

[១២០] វិធាន ២១-៣ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. ចែងថា " គ្មានទម្រង់ណាមួយនៃការជំរុញលើកទឹកចិត្ត ការបង្ខំរូបរាងកាយ ឬការបំភិតបំភ័យ ត្រូវបានយកទៅអនុវត្តក្នុងពេលសម្ភាសន៍ ចំពោះអ្នកដែលត្រូវបានគេសួរយកចម្លើយ ឬអ្នកដទៃទៀតឡើយ ។ ប្រសិនបើទម្រង់ណាមួយនៃស្ថានភាពទាំងនេះត្រូវបានប្រើប្រាស់នោះ ចម្លើយ ឬកំណត់ហេតុ មិនត្រូវបានចាត់ទុកជាភស្តុតាងនៅមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយអ្នកទទួលខុសត្រូវចំពោះទង្វើនេះ ត្រូវដាក់ពិន័យសមស្របនឹងកំហុស ដោយអនុលោមតាមវិធាន ៣៥ និង ៣៨ ។

វាជាការចាំបាច់ដែលត្រូវយកចិត្តទុកដាក់ និងធ្វើការពិភាក្សានៅពេលអង្គភាពរបស់ អ.វ.ត.ក ប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនចំពោះបញ្ហានេះ ព្រោះថាការប្រើទារុណកម្ម ការផ្តន្ទាទោស អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើដែលធ្វើឱ្យបាត់បង់តម្លៃជាមនុស្ស គឺជាកង្វល់ដ៏ធំនៅកម្ពុជា ។[១២១] លើសពីនេះទៅទៀត បើពិនិត្យមើលអំពីទម្ងន់ដែលមានទៅលើចម្លើយសារភាពក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ និងអំពីរបៀបដែលមន្ត្រីនគរបាល និងមន្ត្រីតុលាការយកចម្លើយសារភាពដើម្បីសម្រេចទោសនោះ គេមិនត្រូវគួសបញ្ជាក់ឱ្យហួសហេតុនោះទេ អំពីភាពចាំបាច់ក្នុងការធានាមិនឱ្យមានការយល់ខុស ឬរំលោភបំពានលើដំហដ៏ច្បាស់លាស់របស់ អ.វ.ត.ក ស្តីពីការយកចម្លើយសារភាពធ្វើជាភស្តុតាង ។

## ខ. ការផ្តន្ទាទោស

នៅក្នុងកិច្ចដំណើរការនីតិវិធី មេធាវីការពារក្តីបានព្យាយាមសម្រាលការទទួលខុសត្រូវរបស់ **ឌុច** ដោយលើកឡើងអំពីភាពភ័យខ្លាច និងការសម្ងាត់ដែលមានលក្ខណៈជាប្រព័ន្ធនៅក្នុងរបបខ្មែរក្រហម ។[១២២] នៅក្នុងបរិបទនេះ មេធាវីការពារក្តីរបស់ **ឌុច** ព្យាយាមបង្ហាញពីមូលហេតុ ដើម្បីឱ្យអង្គជំនុំជម្រះអាចនឹងយកមកពិចារណាក្នុងការសម្រាលទោសដល់ជនជាប់ចោទ ដូចជា ការសារភាព ការសម្តែងនូវវិប្បដិសារី ការសហការជាមួយអង្គជំនុំជម្រះ និងគូភាគីជាដើម ។ ការទទួលសារភាពកំហុស ដូចបានអនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិនានា គឺត្រូវបានសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលនេះជាវិធានមួយជួយលើកទឹកចិត្តដល់បុគ្គលផ្សេងទៀតឱ្យសារភាព ទោះបីជា មិនទាន់បានចោទប្រកាន់ ឬស្គាល់អត្តសញ្ញាណជនល្មើស ឬក៏ជាសាក្សីក៏ដោយ ។[១២៣] ការធ្វើបែបនេះជួយឱ្យតុលាការចំណេញពេលវេលា និងជួយដល់ការស្វែងរកការពិតទៀតផង ។[១២៤] ទោះបីជានៅថ្ងៃចុងក្រោយ **ឌុច** បានស្នើសុំឱ្យមានការដោះលែងរូបគាត់ក៏ដោយ ក៏គាត់បានទទួលស្គាល់អង្គហេតុភាគច្រើន ដែល

---

[១២១] សូមមើល របាយការណ៍របស់គណៈកម្មាធិការអង្គការសហប្រជាជាតិប្រឆាំងការធ្វើទារុណកម្ម ក្នុងសម័យប្រជុំលើកទី ៣១ ស្តីពី "សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់គណៈកម្មាធិការអង្គការសហប្រជាជាតិប្រឆាំងការធ្វើទារុណកម្ម ចំពោះករណីប្រទេសកម្ពុជា" (CAT/C/ CR/31/7) ចុះថ្ងៃទី ១០ សីហា ២០០៤។

[១២២] សូមមើល របាយការណ៍ឃ្លាំមើលសាលាក្តីខ្មែរក្រហម លេខ ១៦ ។

[១២៣] សូមមើល សាលក្រមកាត់ទោសរបស់អង្គជំនុំជម្រះសាលាដំបូង នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ក្នុងរឿងក្តី Erdemovic (IT-96-22-T*bis*) ចុះថ្ងៃទី ៥ ឧសភា ១៩៩៨ ។

[១២៤] ទាក់ទនឹងការសារភាពទោសកំហុស សូមមើលសាលក្រមរបស់ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដា ដូចជាៈ សាលក្រមកាត់ទោសរបស់អង្គជំនុំជម្រះ ក្នុងរឿងក្តី Kambanda (ICTR-97-23-S) ថ្ងៃទី ៤ ខែកញ្ញា ១៩៩៨ ។ សាលក្រមកាត់ទោសរបស់អង្គជំនុំជម្រះថ្នាក់ទី ១ ក្នុងរឿងក្តី Serushago (ICTR-98-39-S) ថ្ងៃទី ៥ ខែកុម្ភៈ ១៩៩៩ ។ សាលក្រមកាត់ទោសរបស់អង្គជំនុំជម្រះថ្នាក់ទី ១ ក្នុងរឿងក្តី Ruggiu (ICTR-97-32-I) ថ្ងៃទី ១ ខែមិថុនា ២០០០។ សាលក្រមកាត់ទោសរបស់អង្គជំនុំជម្រះថ្នាក់ទី ៤ ក្នុងរឿង Rutanagira (ICTR-95-1C-T) ថ្ងៃទី ១៤ ខែមិនា ២០០៥ ។ សាលក្រមកាត់ទោសរបស់អង្គជំនុំជម្រះថ្នាក់ទី ១ ក្នុងរឿង Bisengimana (ICTR-00-60-T) ថ្ងៃទី ១៣ ខែមេសា ២០០៦ ។ សូមមើលផងដែរ សាលក្រមកាត់ទោសរបស់អង្គជំនុំជម្រះ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ក្នុងរឿង Todorovic (ICTR-95-9/1-S) ថ្ងៃទី ៣១ ខែកក្កដា កឋាខណ្ឌទី ៨១ ។

មានក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ នៅពេលមានលើកឡើងអំពីការសុំខមាលទោស ដើម្បីព្យាយាមបង្ហាញឱ្យចៅក្រមជឿថា ជាការពិត និងផុសចេញពីដួងចិត្តពិតប្រាកដនោះ ការអត់អោនទោសពីសំណាក់ជនរងគ្រោះ ក៏ជារឿងមួយដែលគេត្រូវតែគិតគូរផងដែរ ។ សក្ខីកម្មរបស់លោក Justice Richard Goldstone ពន្យល់ថា ការទទួលស្គាល់ពីការទទួលខុសត្រូវ និងការបង្ហាញវិប្បដិសារីរបស់ជនជាប់ចោទ គឺជាផ្នែកមួយជួយដល់ដំណើរការផ្សះផ្សាជាតិ ទោះបីជាជនរងគ្រោះព្រមទទួលយក ឬក៏មិនយល់ព្រមក៏ដោយ ។[១២៥] ជាចុងក្រោយ ការសហការដ៏ស្និតរមួតជាមួយសហព្រះរាជអាជ្ញា ក៏ជាស្ថានសម្រាលមួយដែរ ដែលមានចែងក្នុងវិធាន ១០១ នៃវិធាននីតិវិធី និងភស្តុតាងរបស់ តុលាការ *អាដហុក* នានា ។

បន្ថែមលើការលើកឡើងពីស្ថានសម្រាល ដែលអង្គជំនុំជម្រះនឹងពិចារណានៅពេលកំណត់ទោស មេធាវីការពារក្តី បានបង្ហាញពីស្ថានសម្រាលផ្សេងៗទៀតជាច្រើន ដែលអាចជួយដល់អង្គជំនុំជម្រះក្នុងការកំណត់ពិរុទ្ធភាពជនជាប់ចោទ ។ ជាពិសេស មេធាវីការពារក្តីបានលើកឡើងថា កូនក្តីខ្លួនធ្វើតាមការបញ្ជារបស់ថ្នាក់លើ និងដោយមានការបង្ខំ គ្មានជម្រើសអ្វីក្រៅពីធ្វើតាមតែបញ្ជារបស់អង្គការទេ ដោយស្ថិតក្នុងភាពភ័យខ្លាចជាប្រចាំចំពោះសុវត្ថិភាពរបស់ខ្លួន និងក្រុមគ្រួសារ ។ ទោះបីជាយ៉ាងនេះក៏ដោយ ការកំណត់ថា ការគោរពបទបញ្ជារបស់ថ្នាក់លើមិនមែនជាស្ថានសម្រាលទោសទេ ហើយបញ្ហានេះមេធាវីការពារក្តី **ឌុច** ក៏បានដឹងដែរ ។[១២៦] ជាក់ស្តែងក្នុងរឿងក្តី *Erdemovic* អង្គជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានទទួលស្គាល់ថា នៅពេលដែលជនជាប់ចោទពិតជាគ្មានជម្រើសអ្វីផ្សេងក្រៅពីការសម្លាប់អ្នកដទៃ ឬក៏ត្រូវឱ្យគេសម្លាប់វិញនោះ "ស្ថានភាពស្ថិតនៅក្រោមការបង្ខំបែបនេះ មិនមានមូលដ្ឋានការពារគ្រប់គ្រាន់ចំពោះទាហានដែលគេត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋសង្គ្រាម ដែលជាប់ពាក់ពន្ធ័នឹងការសម្លាប់ជនស្លូតត្រង់នោះទេ" ។[១២៧] ប៉ុន្តែមិនមែនគ្រប់ភាគីចាត់ទុកការសុំទោសរបស់ **ឌុច** ដូចគ្នានឹងការទទួលស្គាល់កំហុសរបស់ខ្លួនទេ ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលោកស្រី Silke Studizsky បានលើកឡើងថា ការទទួលស្គាល់អង្គហេតុរបស់ **ឌុច** មានតែ ៦៨% ប៉ុណ្ណោះ នៃអង្គហេតុដែលមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលនេះមិនគួរយល់ថា ជាការសារភាពទាំងស្រុងបានទេ ។[១២៨]

---

១២៥ សូមមើល របាយការណ៍ឃ្លាំមើលសាលាក្តីខ្មែរក្រហម លេខ ២១ ឧបសម្ព័ន្ធ ក ។

១២៦ មាត្រា ៧ នៃ លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ មាត្រា ៧ នៃលក្ខន្តិកៈរបស់ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដា ។ មាត្រា ៣៣ នៃលក្ខន្តិកៈក្រុងរ៉ូម ។ និងសូមមើលប្រតិចារឹក នៃសវនការសំណុំរឿងលេខ 00១ ថ្ងៃទី ៣១ មិនា ២00៩ ។

១២៧ សូមមើល សាលក្រមកាត់ទោសរបស់អង្គជំនុំជម្រះនៃ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ក្នុងរឿងក្តី Erdmovic (IT-96-22-T*bis*) ថ្ងៃទី ៥ មិនា ១៩៩៨ ។

១២៨ ព័ត៌មានទទួលបានតាមរយៈការទាក់ទងតាមសំបុត្រអេឡិចត្រូនិច ជាមួយលោកស្រីមេធាវី Silke Studzinsky ថ្ងៃទី ១៨ ខែវិច្ឆិកា ២00៩ ។

ចំណុចផ្សេងទៀត ដែលចៅក្រមអាចនឹងពិចារណានៅពេលសម្រេចសេចក្ដីអំពីទោស គឺស្ថានភាពផ្ទាល់របស់ **ឌុច** ដូចជា អាយុ ភាពជាគ្រូបង្រៀនដែលមានអត្តចរិតស្លូតបូត និងចិត្តល្អ មុនពេលដែលចូលក្នុងជួរបក្សកុម្មុយនិស្តកម្ពុជា និងក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ព្រមទាំងចេតនារបស់គាត់ក្នុងការស្ដារនិតិសម្បទាឡើងវិញ ដើម្បីចូលរួមរស់ក្នុងសង្គម ។[១២៩] ទន្ទឹមនឹងនោះ អង្គជំនុំជម្រះអាចនឹងពិចារណាលើស្ថានទំងន់មួយចំនួន ដូចជា ឋានៈជាអនុប្រធាន និងក្រោយមកជាលេខានៅមន្ទីរ ស-២១ ព្រមទាំងការប្រព្រឹត្តអំពើឃោរឃៅចំពោះជនស្លូតត្រង់ ដែលជាមនុស្សចាស់ ស្ត្រី និងកុមារ ដើម្បីកំណត់ពីកម្រិតនៃការទទួលខុសត្រូវពិតប្រាកដរបស់គាត់ ។[១៣០] ក្រៅពីនេះក៏គួរពិចារណាផងដែរ អំពីតថភាពមួយចំនួនមុននឹងសម្រេចទោស ដូចជា ទំហំឧក្រិដ្ឋកម្ម រួមមាន មធ្យោបាយនិងវិធីសាស្ត្រដ៏ឃោរឃៅ ការបំភិតបំភ័យ ដែលគេប្រើដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្ម ។[១៣១] លើសពីនេះទៅទៀតបញ្ហាទុក្ខវេទនាទាំងផ្លូវកាយ ផ្លូវចិត្តរបស់ជនរងគ្រោះ និងផលប៉ះពាល់ដ៏យូរអង្វែងពីអំពើឧក្រិដ្ឋចំពោះអ្នករួចរស់ជីវិតពីការសម្លាប់ សមាជិកគ្រួសាររបស់ជនរងគ្រោះ ព្រមទាំងប្រជាជនកម្ពុជាទាំងមូល ក៏ជះឥទ្ធិពលចំពោះទំហំនៃការទទួលខុសត្រូវរបស់ជនជាប់ចោទផងដែរ ប៉ុន្តែការពិចារណាចំណុចណាមួយនោះ គឺអាស្រ័យលើអង្គជំនុំជម្រះជាអ្នកកំណត់ ។

គេអាចមើលឃើញថា អង្គជំនុំជម្រះនឹងពិចារណាលើកត្តាជាច្រើនក្នុងចំណោមកត្តាដែលរៀបរាប់ខាងលើ ហើយតើកត្តាទាំងនេះមានទម្ងន់ប៉ុណ្ណាទៅលើការសម្រេចទោស **ឌុច** ។ ក្រៅពីនោះ ការស្នើសុំឱ្យរួចផុតពីការចោទប្រកាន់របស់ **ឌុច** នាថ្ងៃសវនាការចុងក្រោយ ក៏ជះឥទ្ធិពលដល់លទ្ធផលនៃការសម្រេចទោសផងដែរ ។ បញ្ហានេះអង្គជំនុំជម្រះចាំបាច់ត្រូវកំណត់ថា តើអាចជួយដល់ការពិចារណាលើភាពពិតប្រាកដនៃវិប្បដិសារី **ឌុច** ដែរឬទេ ។ គេរំពឹងទុកថា អង្គជំនុំជម្រះនឹងពិនិត្យមើលយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានា ព្រោះច្បាប់របស់ អ.វ.ត.ក និងវិធានផ្ទៃក្នុង មិនបានបញ្ជាក់អំពីបញ្ហានេះ ដែលអាចយកមកធ្វើជាមូលដ្ឋានពិចារណាអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌបាន ។ ទោះបីជាយ៉ាងនេះក៏ដោយគេសង្ឃឹមថា សិទ្ធិដ៏ធំទូលាយ ដែលចៅក្រមមានក្នុងការ

---

[១២៩] សូមមើល របាយការណ៍ឃ្លាំមើលសាលាក្ដីខ្មែរក្រហមលេខ ២០ ទាក់ទងនឹង "អត្តចរិកល្អ និងឆន្ទៈរបស់ **ឌុច** ក្នុងការស្ដានីតិសម្បទា និងចូលរួមរស់ក្នុងសង្គម ។ របាយការណ៍ឃ្លាំមើលសាលាក្ដីខ្មែរក្រហមលេខ ២១ ទាក់ទងនឹងសេចក្ដីសង្ខេបនៃសក្ខីភាពរបស់គ្រូគង្វាលលោក Christopher Lapel ស្ដីពីចូលសាសនាគ្រីស្តរបស់ **ឌុច** ។ ចំពោះបញ្ហាស្ថានភាពផ្ទាល់ខ្លួន ដែលអាចធ្វើជាស្ថានសម្រាល សូមមើល សេចក្ដីសម្រេចកាត់ទោសរបស់អង្គជំនុំជម្រះនៃ តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី ក្នុងរឿងក្ដី Erdmovic (IT-96-22-T*bis*) ថ្ងៃទី ៥ មិនា ១៩៩៨ ដែលក្នុងនោះចៅក្រមបានពិចារណាអំពី *Inter alia* គឺអាយុ អត្តចារិករបស់ជនជាប់ចោទ ។

[១៣០] សូមមើល "ការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិ" ដោយ Jones. John RWD and Powels, Steven ២០០៣ បោះពុម្ពលើកទី៣ ដោយ Oxford University Press ទំព័រ ៧៨៣ ។ សូមមើល របាយការណ៍ឃ្លាំមើលសាលាក្ដីខ្មែរក្រហមលេខ ១៦ និង វិធាន ១៤៥-២ខ-៣ នៃ វិធាននីតិវិធីនៃភស្តុតាង របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

[១៣១] សូមមើល សាលក្រមរបស់អង្គជំនុំជម្រះនៃ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ក្នុងរឿងក្ដី Krstic (IT-98-33-T) ថ្ងៃទី២ សីហា ២០០១ ។

បំពេញភារកិច្ចរបស់ខ្លួន នឹងជួយឱ្យអង្គភាពនេះអាចស្វែងយល់កាន់តែច្បាស់ពីការទទួលស្គាល់វិប្បដិសារី និងអាចកំណត់បាននូវកម្រិតការទទួលខុសត្រូវពិតប្រាដករបស់ **ឌុច** ។

## ច. បទពិសោធន៍ទទួលបានពីបញ្ហាច្បាប់ និងនីតិវិធី

ជារួម អង្គជំនុំជម្រះបានបំពេញការងាររបស់ខ្លួនបានយ៉ាងល្អ ក្នុងការកំណត់បញ្ហាច្បាប់ និងនីតិវិធីដែលកើតឡើងក្នុងសវនាការកាត់ទោស **ឌុច** ដែលជាការគួរឱ្យកោតសរសើរ ។ ជាពិសេស ដំណោះស្រាយដ៏ល្អ ដែលអង្គជំនុំជម្រះប្រកាន់យកក្នុងការដោះស្រាយបញ្ហាឃុំខ្លួន **ឌុច** លើសនីតិវិធីកំណត់ និងសេចក្តីណែនាំស្តីពីការប្រើប្រាស់ភស្តុតាងដែលទទួលបានមកពីការធ្វើទារុណកម្មនៅមន្ទីរ ស-២១ ដែលចាត់ទុកថា ជាយុត្តិសាស្ត្រសម្រាប់សំណុំរឿងក្រោយៗរបស់ អ.វ.ត.ក ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះមុនៗ ក៏មានសារៈសំខាន់ផងដែរ ដែលអាចយកមកប្រើប្រាស់នៅតុលាការថ្នាក់ជាតិ ។ មេធាវីកម្ពុជាអាចប្រើប្រាស់យុត្តិសាស្ត្រនេះ ក្នុងការការពារសិទ្ធិកូនក្តីខ្លួន ដើម្បីទទួលបានការបន្ថយទោស ករណីឃុំខ្លួនបណ្តោះអាសន្នលើសពីរយៈពេលកំណត់ ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។ ខណៈដែលក្រុមឃ្លាំមើលតុលាការ មានមន្ទិលមួយចំនួនទាក់ទងនឹងការអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង **ឌុច** និងផលប៉ះពាល់នៃការអនុវត្តទ្រឹស្តីនេះចំពោះសិទ្ធិជនជាប់ចោទក្នុងការទទួលបានការជូនដំណឹងពីបទចោទប្រកាន់មុនពេលបើកការជំនុំជម្រះ ការវាយតម្លៃទុកជាមុនអំពីបញ្ហានេះមុនពេលចេញសាលក្រមគឺជាការប្រញាប់ប្រញាល់ពេក ។ ស្រដៀងគ្នានេះ គេមិនគួរលើកឡើងពីផលប៉ះពាល់នៃការសម្រេចអំពីទោសរបស់អង្គជនុំជម្រះមុនពេលដែលសាលក្រមចេញនោះទេ ។

អង្គជំនុំជម្រះអាចប្រឈមនឹងការដាក់សេចក្តីសន្និដ្ឋានផ្សេងទៀត ទាក់ទងនឹងតុល្យភាពរវាងសិទ្ធិជនជាប់ចោទ និងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅពេលសំណុំរឿងក្តីលេខ ០០២ ចាប់ផ្តើមដំណើរការសវនាការ ។ ដូចបានពិភាក្សានៅផ្នែកបន្ទាប់ ទោះបីជាចៅក្រមរបស់ អ.វ.ត.ក កំពុងតែគិតគូរពិចារណាអំពីការផ្លាស់ប្តូរបែបបទនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការ បញ្ហាសំខាន់ ដូចជាអត្ថន័យនៃពាក្យ *គាំទ្រការចោទប្រកាន់* ដែលចែងក្នុងវិធាន ២៣ នៅតែមិនទាន់បានបកស្រាយឱ្យបានច្បាស់លាស់នៅឡើយ ។ បញ្ហានេះ ចាំបាច់ត្រូវលើកយកមកពិចារណា មុនពេលដែលសំណុំរឿងក្តីលេខ ០០២ ចាប់ផ្តើម ដើម្បីធានាថាដំណើរការនីតិវិធីអាចប្រព្រឹត្តទៅដោយរលូន ។

## ផ្នែកទី៤ ៖ ការចូលរួម និងការគាំពារ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី

ការអនុញ្ញាតឱ្យមានការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធី គឺជាបែបបទមួយថ្មីដែល អ.វ.ត.ក បានអនុវត្ត និងបានទាក់ទាញការចាប់អារម្មណ៍ពីមជ្ឈដ្ឋានអន្តរជាតិយ៉ាងខ្លាំង ។[១៣២] អ.វ.ត.ក បានដើរមួយជំហានមុនតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ដោយកាលពី ឆ្នាំ២០០៧ ចៅក្រមបានសម្រេចបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងវិធាននៃផ្ទៃក្នុង (តាមប្រពន្ធ័ច្បាប់ស៊ីវិលប្រទេសបារាំង) នៅក្នុងកិច្ចប្រជុំពេញអង្គរបស់ខ្លួន ដើម្បីឱ្យមានការយកចិត្តទុកដាក់ថែមមួយកម្រិតទៀតចំពោះសិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលបានការពិត និងយុត្តិធម៌ ។ ករណីនេះក៏ជាលើកដំបូងចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលជនរងគ្រោះនៃអំពើសម្លាប់រង្គាលត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងឋានៈជាភាគី មិនត្រឹមតែជាសាក្សីធម្មតាប៉ុណ្ណោះទេ ដែលនេះជាការវិវត្តន៍ជាប្រវត្តិសាស្ត្រចំពោះសិទ្ធិរបស់ជនរងគ្រោះក្នុងឧក្រិដ្ឋកម្មអន្តរជាតិ ។

សេចក្តីសម្រេចរបស់ចៅក្រម អ.វ.ត.ក ក្នុងការបញ្ចូលជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធី គឺជាជំហាមួយដ៏ក្លាហាន បើពិនិត្យមើលច្បាប់របស់តុលាការ គឺមិនឃើញមានចែងអំពីបញ្ហាដែលអាចឱ្យចៅក្រមយកធ្វើជាមូលដ្ឋានក្នុងការសម្រេចទេ ។ ទោះបីជា មាត្រា១២ នៃកិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក ចង្អុរបង្ហាញឱ្យតុលាការបង្កើតនីតិវិធីដោយអនុលោមទៅតាមច្បាប់កម្ពុជា ដែលទទួលស្គាល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិធីព្រហ្មទណ្ឌក៏ដោយ ក៏កិច្ចព្រមព្រៀងនេះមិនមានចែងពីកំណត់យោងឱ្យបានច្បាស់លាស់ អំពីរបៀបនៃការចូលរួមរបស់ជនរងគ្រោះនោះទេ ។[១៣៣] បន្ថែមលើនេះ នៅពេលដែលចៅក្រមធ្វើសេចក្តីសម្រេចលើបញ្ហានេះ តុលាការពុំមានខ្ទង់ថវិការសម្រាប់ការចំណាយលើដំណើរការចូលរួមរបស់ជនរងគ្រោះទេ ។ ហើយប្រសិនបើសិទ្ធិរបស់ជនរងគ្រោះ (ដូចជា សិទ្ធិដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សិទ្ធិទទួលបានអ្នកតំណាងស្រប

---

[១៣២] មានអត្ថបទព័ត៌មានអន្តរជាតិរាប់រយដែលបានសរសេរអំពីដំណើរការចូលរួមរបស់ជនរងគ្រោះក្នុងសាលាក្តីខ្មែរក្រហម ដូចជា៖ "ជនរងគ្រោះក្នុងរបបខ្មែរក្រហម ចូលរួមក្នុងព្រឹត្តការណ៍ជាប្រវិត្តិសាស្ត្រ" ចុះថ្ងៃទី ៥ កុម្ភៈ ២០០៨ ដោយសារព័ត៌ *Scoop News* របស់ប្រទេស New Zealand ព័ត៌មាននេះអាចរកបានក្នុងគេហទំព័រ http://www.scoop.co.nz/stories/WO0802/S00053.htm ។ "ជនរងគ្រោះក្នុងរបបខ្មែរក្រហមផ្តល់សក្ខីកម្មក្នុងសវនាការនៅកម្ពុជា" ចុះថ្ងៃទី ១៦ មិថុនា ២០០៩ ដោយសារព័ត៌មាន *New York Time* ។ "ប្រទេសកម្ពុជា៖ យុត្តិធម៌ នៅនឹងមុខសម្រាប់ជនរងគ្រោះរបបខ្មែរក្រហម" ចុះថ្ងៃទី ១៣ កុម្ភៈ ២០០៩ ដោយសារព័ត៌ *IPS Bangkok* អាចរកបានក្នុងគេហទំព័រ http://www.ipsnews.net/news.asp?idnews=45755 ។ "ប្រជាជនកម្ពុជាស្វែងរកយុត្តិធម៌" ចុះថ្ងៃទី ២៣ មិនា ២០០៩ ដោយ *Contra Costa Times (California)* អាចរកបានក្នុងគេហទំព័រ http://www.contracostatimes.com/california/ci_11981705 ។ "សំណងគឺជាផ្នែកមួយដ៏សំខាន់ក្នុងកាទទួលបាននូវយុត្តិធិមសម្រាប់អតីតជនរងគ្រោះក្នុងរបបខ្មែរក្រហម" ចុះថ្ងៃទី ៣ កក្កដា ២០០៩ ដោយសារព័ត៌មាន *Christian Science Monitor* ។

[១៣៣] ទោះបីជាបែបនេះក៏ដោយ វាហាក់ដូជាមានការភាន់ច្រឡំ ដោយមាត្រា ៣៥ នៃច្បាប់ស្តីពីការបង្កើតសាលាក្តីខ្មែរក្រហមមិនបានកំណត់ឱ្យសិទ្ធិជនរងគ្រោះ ក្នុងការប្តឹងឧទ្ធរណ៍នឹងសាលក្រមចេញដោយអង្គជំនុំជម្រះ ដែលនេះហាក់ដូចជាមានន័យថា គេបានគិតគូរអំពីការបញ្ចូលជនរងគ្រោះ ក្នុងកិច្ចដំណើរការរបស់តុលាការ នៅពេលដែលគេរៀបចំធ្វើច្បាប់នេះទេ ។ នេះអាច ជាមូលដ្ឋានមួយដ៏ល្អសម្រាប់ចៅក្រម កំណត់ថា តើគួរតែបញ្ចូលជនរងគ្រោះក្នុងកិច្ចដំណើរការជំនុំជម្រះឬទេ ។

ច្បាប់ និងសិទ្ធិទទួលបានសំណងរួម ឬជំងឺចិត្ត) ត្រូវបានគោរពយ៉ាងពេញលេញ នោះកិច្ចដំណើរការនេះមិនអាចចៀសផុតពីការចំណាយថវិកាដ៏ច្រើនសន្ធឹកសន្ធាប់ទេ ។[១៣៤]

សវនាការជំនុំជម្រះក្តី **ឌុច** បានផ្តល់នូវការសាកល្បងជាលើកដំបូងដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ជនរងគ្រោះសរុបចំនួន ៩០នាក់ បានក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ ពួកគេត្រូវបានបែងចែកជាបួនក្រុម ដោយមិនគិតទៅតាមប្រភេទព្យសនកម្មទេ គឺគិតទៅតាមប្រភពដាក់ពាក្យបណ្តឹងទៅតុលាការ ដែលជំនួយពីអង្គការមិនមែនរដ្ឋាភិបាលចំនួនបួនជួយសម្របសម្រួលសកម្មភាពចូលរួមទាំងនោះ ។ នៅក្នុងក្រុមនីមួយៗតំណាងដោយមេធាវីជាតិ និងអន្តរជាតិ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការដាក់សេចក្តីសន្និដ្ឋាននានា ។ នេះមានន័យថា នៅក្នុងដំណើរការជំនុំជម្រះក្តី បន្ថែមលើសហព្រះរាជអាជ្ញា ២រូប និងសហមេធាវីការពារក្តី ២រូប ក៏មានវត្តមានមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីរហូតដល់ ៨រូបទៀត ធ្វើការសួរដេញដោលសាក្សី ឬជនជាប់ចោទ។

ទាំងអង្គជំនុំជម្រះសាលាដំបូង និងដើមបណ្តឹងរដ្ឋប្បវេណី ទំនងជាប្រឈមមុខនឹងបញ្ហាដ៏លំបាកជាច្រើនក្នុងការសម្របសម្រួល អំពីយន្តការថ្មីដែលមិនធ្លាប់មាននេះ ។ បើយើងពិនិត្យមើលទៅលើការងាររបស់អង្គជំនុំជម្រះ ក្នុងការធ្វើឱ្យមានតុល្យភាពរវាងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសិទ្ធិរបស់ជនជាប់ចោទ យើងអាចយល់បានថា នេះគឺជាភារកិច្ចដ៏ស្មុគស្មាញមួយ ។ ទោះបីជា អង្គជំនុំជម្រះបានកំណត់រយៈពេលដ៏តឹងរ៉ឹងដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏សវនាការនៅតំណាក់កាលដំបូង ត្រូវបានប្រព្រឹត្តទៅដោយសំណួរ និងការដាក់សារណាជាច្រើន ។ បើយើងពិនិត្យលើបញ្ហារបស់ដើមបណ្តឹងរដ្ឋប្បវេណីវិញ កង្វះនៃសេចក្តីណែនាំច្បាស់លាស់អំពីតួនាទីរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងការកម្រិតនូវផែនការផ្តល់សំណងសមស្រប ធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីអស់ជំនឿចិត្តលើកិច្ចដំណើរការ ហើយថែមទាំងមិនសប្បាយចិត្តចំពោះការសម្រេចហាក់គ្មានហេតុផលច្បាស់លាស់ក្នុងការកម្រិតសិទ្ធិមេធាវីរបស់ពួកគេ ។ ម្យ៉ាងទៀត បញ្ហាជាច្រើនដែលកើតមានឡើងក្នុងកំឡុងពេលសវនាការ គឺការមិនរៀបចំដើមបណ្តឹងរដ្ឋប្បវេណីជាមុនក្នុងការធ្វើសេចក្តីថ្លែងការណ៍ខ្លួន និងដោយនេះជានីតិវិធីថ្មីបញ្ហាមួយចំនួនអាចនឹងកើតមាននៅពេលសវនាការ ហេតុដូចនេះ ការរៀបចំឱ្យមានការសម្របសម្រួលបន្ថែម

---

[១៣៤] សូមមើលតារាង S.2.e: Resource Requirments by Object of Expenditure និង តារាង S.2.f: Post Requirement for Defense Support Section and Victim Unit កឋាខណ្ឌ ៨២-៨៩ នៃគម្រោងចំណាយ ដែលរៀបចំដោយអ.វ.ត.ក. ។ ព័ត៌មាននេះអាចរកបានតាមរយៈ http://www.unakrt-online.org/04_documents.htm#Budget> ។ ក្នុងតារាងនោះបង្ហាញថាគម្រោងចំណាយដំបូងរបស់តុលាការ មិនមានខ្ទង់សម្រាប់ការចូលរួមរបស់ជនរងគ្រោះទេ ។ ជំនួយថវិការដែលគេស្វះស្វែងរកពេលដំបូងនោះ គឺតិចតួចណាស់ ក្នុង នាះតុលាការបានស្នើសុំជំនួយថវិការសម្រាប់ប្រធានអង្គភាពជនរងគ្រោះជាតិ និងអនុប្រធានអន្តរជាតិ ព្រមទាំង សម្រាប់អ្នកពិនិត្យពាក្យបណ្តឹងចំនួន ៦នាក់ ទៀត ដោយផ្អែកលើមូលដ្ឋានថា ពួកគេម្នាក់ៗអាចពិនិត្យបាន ៤ ពាក្យបណ្តឹងក្នុង១ថ្ងៃ ។ បើពិនិត្យមើលពីទំហំពាក្យបណ្តឹងដែលអង្គភាពនេះទទួលបានជាង ៤០០០ មកដល់បច្ចុប្បន្ន ពីអ្នកដាក់ពាក្យបណ្តឹងនោះគម្រោងចំណាយនេះហាក់ដូចជាមិនមានលក្ខណៈជាក់ស្តែងទេ ។

រវាងផ្នែករដ្ឋបាលរបស់តុលាការ ក្រុមចៅក្រម និងអង្គការនានា ត្រូវផ្ដល់ព័ត៌មានដល់ដើមបណ្ដឹងរដ្ឋប្បវេណីឱ្យបានជិតដល់ អំពីដំណើរការជំនុំជម្រះ ។

ការជួបបញ្ហាប្រឈមជាច្រើននៅក្នុងសំណុំរឿងក្ដីលេខ ០០១ ទាក់ទងនឹងការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយសំណុំរឿងបន្ទាប់នឹងមានទំហំធំជាងសំណុំរឿងក្ដី **ឌុច** នោះ ចៅក្រមកំពុងតែរិះរកវិធី ដើម្បីកែលម្អដំណើរការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឱ្យកាន់តែប្រសើរឡើង ។ នៅពេលដែលមិនទាន់ដឹងច្បាស់អំពីបែបបទនៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿងក្រោយៗ គេរំពឹងទុកថា ការរៀបចំឱ្យមានការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទំនងជានឹងអាចកម្រិតតួនាទីមេធាវីរបស់ពួកគេ ដោយរៀបចំឱ្យមានមេធាវីតែមួយក្រុមជំនួសវិញ ។ ក្រៅពីពិនិត្យលើផែនការរៀបចំនេះ ក៏គួរក្រលេកមើលឱ្យកាន់តែលម្អិតទៅលើដំណើរការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿងក្ដីលេខ ០០១ ព្រមទាំងស្វែងរកដំណោះស្រាយឱ្យកាន់តែមានប្រសិទ្ធិភាព ព្រោះអង្គជំនុំជម្រះអាចនឹងជួបប្រទះក្នុងសំណុំរឿងក្ដីលេខ ០០២ និងសំណុំរឿងបន្តបន្ទាប់ ។ នៅក្នុងចំណុចដំបូងនៃផ្នែកនេះ យើងនឹងពិភាក្សាលើលក្ខខណ្ឌនានា ដើម្បីក្លាយជាដើមបណ្ដឹងរដ្ឋប្បវេណី បន្ទាប់យើងនឹងលើកឡើងអំពីសិទ្ធិសំខាន់ៗរបស់ពួកគេក្នុងកិច្ចដំណើរការជំនុំជម្រះក្ដី ។ ការបំពេញតួនាទីរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក៏ត្រូវបានយកមកពិភាក្សានៅក្នុងផ្នែកនេះផងដែរ ។ រីឯចំណុចចុងក្រោយនៃផ្នែកនេះ យើងក៏ពិភាក្សាដោយសង្ខេបផងដែរអំពីការជួយគាំពារសាក្សី និងជនរងគ្រោះនៅ អ.វ.ត.ក ។

## ក. ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

បញ្ហាគន្លឹះមួយក្នុងចំណោមបញ្ហាជាច្រើន ដែល អ.វ.ត.ក បានជួបប្រទះក្នុងការសម្រួលដំណើរការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការជំនុំជម្រះក្ដីនោះ គឺការកំណត់និយមន័យពាក្យថា "*ជនរងគ្រោះ*" ដើម្បីអាចចូលរួមបាន ។ វិធានផ្ទៃក្នុងរបស់តុលាការបានកំណត់និយមន័យពាក្យ "*ជនរងគ្រោះ*" ថា ជាអ្នកដែលទទួលរងព្យសនកម្ម (ការខូចខាត) ផ្លូវកាយ ផ្លូវចិត្ត ឬសម្ភារៈ ហើយដែលព្យសនកម្មនោះកើតឡើងផ្ទាល់ ដោយសារអំពើល្មើស និងមានបន្តរហូតមកដល់បច្ចុប្បន្ន ។[១៣៥] យោងតាមវិធាន ២៣ នៃវិធានផ្ទៃក្នុង ជនរងគ្រោះអាចចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីជាដើមបណ្ដឹងរដ្ឋវប្បវេណី នៅពេលដែលសហចៅក្រមស៊ើបអង្កេតសម្រេចទទួលស្គាល់នៅដំណាក់កាលស៊ើបអង្កេត ឬក៏ត្រូវបានអង្គជំនុំជម្រះទទួលស្គាល់ មុនពេលចាប់ផ្ដើមសវនាការលើអង្គសេចក្ដី ។ ទោះបីជាយ៉ាងណា វិសាលភាពដែលមេធាវីការពារក្ដីអាចចោទសួរពីលក្ខណៈសម្បត្តិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមិនបានកំណត់ច្បាស់លាស់នៅក្នុងវិធាននេះទេ ខណៈដែលវិធាន ២៣(៤) ផ្ដល់អំណាចឱ្យអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការកំណត់ពីលក្ខណៈសម្បត្តិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅដំណាក់កាលជំនុំជម្រះ ។ ចំណែកឯ វិធាន ១០០(១) បានកំណត់ឱ្យមានការពន្យាការវាយតម្លៃលើសេចក្ដីថ្លែងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រឆាំងនឹងជនជាប់ចោទរហូតដល់ការចេញសាលក្រម ។ ចំណុចនេះបង្ហាញថា ប្រសិនបើអង្គជំនុំជម្រះយល់ថាសមស្របនោះ ខ្លួន

---

[១៣៥] វិធាន២៣(២) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣) ។

អាចបង្គាប់ឱ្យមេធាវីការពារក្តីដាក់សេចក្តីសន្និដ្ឋាន អំពីលក្ខណៈសម្បត្តិរបស់ដើមបណ្តឹងរដ្ឋប្បវេណីបាននៅគ្រប់ដំណាក់កាលមុនបិទការជំនុំជម្រះ ។

នេះជានីតិវិធីដែលអង្គជំនុំជម្រះបានអនុវត្តក្នុងសំណុំរឿងក្តីលេខ ០០១ ។ ជាលទ្ធផល គឺរយៈពេលត្រឹមតែ ៣សប្តាហ៍ មុនការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ មេធាវីការពារក្តី បានលើកឡើងនូវការជំទាស់របស់ខ្លួន ចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺប្រហែលជាមួយភាគបួន (១/៤) នៃដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ។[១៣៦] ពុំមែនជាការភ្ញាក់ផ្អើលនោះទេ ដែលការជំទាស់នេះញ៉ាំងឱ្យមានប្រតិកម្មតបពីសំណាក់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយបានលើកឡើងថា វិធាន ២៣(៤) រួមជាមួយវិធាន ៨៣(១) ចែងថា ការជំទាស់ណាមួយចំពោះភាពអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ គួរតែធ្វើឡើងនៅក្នុងដំណាក់កាលសវនាការបឋម ដែលរៀបចំឡើងមុនការជំនុំជម្រះលើអង្គសេចក្តី ។[១៣៧] ប៉ុន្តែ មេធាវីការពារក្តីបានឆ្លើយតបថា ពួកគេធ្វើទៅតាមសំណើរបស់អង្គជំនុំជម្រះ ក្នុងការដាក់សេចក្តីសន្និដ្ឋានជំទាស់ ដែលអង្គជំនុំជម្រះក៏បានយល់ព្រមផងដែរ ។

## ១. ឯកសារសំខាន់ៗ ដើម្បីគាំទ្រពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ការជំទាស់របស់មេធាវីការពារក្តីចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ផ្អែកលើហេតុផលថា ពាក្យសុំទាំងនោះគ្មានភស្តុតាងបង្ហាញថាខ្លួនជាជនរងគ្រោះនៅមន្ទីរ ស-២១ ឬមានទំនាក់ទំនងជាមួយអ្នកស្លាប់នៅទីនោះ។[១៣៨] ដូច្នេះ ភាពស្មុគស្មាញបានកើតឡើង ជុំវិញបញ្ហាឯកសារអត្តសញ្ញាណបង្ហាញពីទំនាក់ទំនង និងបញ្ហាចំណងសាច់ញាតិ ដែលដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើង ។

ឆ្លើយតបនឹងការចោទប្រកាន់របស់មេធាវីការពារក្តីដែលថា ឯកសារគាំទ្រពាក្យបណ្តឹងមិនគ្រប់គ្រាន់នោះ មេធាវីដើមបណ្តឹងរដ្ឋបវេណី បានពន្យល់អំពីការលំបាកក្នុងការប្រមូលឯកសារអត្តសញ្ញាណសម្រាប់គាំទ្រពាក្យបណ្តឹង ។ ពួកគេបានលើកឡើងថា បណ្ណសាររបស់មន្ទីរ ស-២១ មិនមានឯកសារទុកនៅពេញលេញ ហើយ ឯកសារជាច្រើនផ្សេងទៀតក៏ត្រូវបានបំផ្លាញចោលក្នុងរបបខ្មែរក្រហម ធ្វើឱ្យកូនក្តីខ្លួនមិនអាចរកឯកសារយកមកធ្វើជាឯកសារភស្តុតាងបញ្ជាក់ពីបញ្ហានេះបានឡើយ ។[១៣៩] ពួកគេក៏បានបន្ថែមទៀតថា អង្គជំនុំជម្រះអាចពិចារណា អំពីភាព

---

[១៣៦] ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ ត្រូវបានគេទទួលស្គាល់ជាភាគីក្នុងកិច្ចដំណើរការនីតិវិធីជាបណ្តោះអាសន្ន ។ នៅថ្ងៃទី ២៦ ខែសីហា ២០០៩ ក្រុមមេធាវីការពារក្តីបានដកការជំទាស់របស់ខ្លួនចំពោះដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២ គឺ D25/20 និង E2/57 ។ សូមមើលរបាយការណ៍ឃ្លាំមើលសាលាក្តីខ្មែរក្រហមលេខ ១៩ ។

[១៣៧] សូមមើល របាយការណ៍ឃ្លាំមើលសាលាក្តីខ្មែរក្រហមលេខ ១៩ ។ សូមមើលផងដែរ ប្រតិចារឹកសវនាការអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿងក្តីលេខ ០០១ថ្ងៃទី ២៥ សីហា ២០០៩ ។

[១៣៨] សូមមើល របាយការណ៍ឃ្លាំមើលសាលាក្តីខ្មែរក្រហមលេខ ១៨ ។

[១៣៩] ជាឧទាហរណ៍ គេលើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណី D25/15បានបំផ្លាញចោលឯកសារអត្តសញ្ញាណរបស់គាត់ ដើម្បីកុំឱ្យគេស៊ើបការណ៍បាន ។ សូមមើលបន្ថែម ប្រតិចារឹកសវនាការអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០១ ថ្ងៃទី២៦ សីហា ២០០៩ ទំព័រ ២៧ ។

អាចទទួលយកបាននូវពាក្យបណ្តឹងរបស់កូនក្តីខ្លួន ដោយវិភាគទៅលើឯកសារបញ្ជាក់ ឬឯកសារដទៃទៀត ដែលបានភ្ជាប់ជាមួយពាក្យបណ្តឹង ក្នុងករណីពុំមានភស្តុតាងជាឯកសារនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យទេ ។[១៤០] ការអះអាងបែបនេះ ទំនងជាការស្នើថា អង្គជំនុំជម្រះគួរតែប្រកាន់យកនូវបទដ្ឋាននៃការពិនិត្យភស្តុតាងប្រហាក់ប្រហែលនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងសំណុំរឿងក្តីរបស់ *Bemba* ដែលក្នុងនោះ អង្គជំនុំជម្រះបានលើកឡើងថា *"ការវាយតម្លៃលើពាក្យសុំនីមួយៗត្រូវធ្វើឡើង ដោយផ្អែកលើអង្គហេតុពាក់ព័ន្ធ"* ជាជាងផ្អែកទៅលើទម្រង់ឯកសារដ៏ជាក់លាក់មួយ ។[១៤១] នៅក្នុងករណីនេះ អង្គបុរេជំនុំជម្រះថ្នាក់ទី ៣ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានកត់សម្គាល់ថា កាលៈទេសៈផ្ទាល់ខ្លួនរបស់អ្នកដាក់ពាក្យបណ្តឹង ព្រមទាំងការលំបាកដែលជួបប្រទះក្នុងការស្វែងរកឯកសារផ្លូវការបញ្ជាក់អំពីអត្តសញ្ញាណនោះ ក៏គួរតែយកមកពិចារណានៅពេលដែលពិនិត្យពីភាពអាចទទួលយកបានពាក្យបណ្តឹងរបស់ពួកគេ ។[១៤២] ក្នុងករណីរឿងក្តីនោះ ឯកសារចំនួន ២២ប្រភេទ ត្រូវបានទទួលយក ជាភស្តុតាងបញ្ជាក់អំពីអត្តសញ្ញាណ ។[១៤៣] មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលោក Alain Werner បានថ្លែងថា ប្រសិនបើពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបដិសេធដោយសារកង្វះឯកសារគាំទ្រនោះ និងមានពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននៅក្នុងរឿងក្តីលេខ ០០២ ដែលនឹងត្រូវគេធ្វើការបដិសេធ ។[១៤៤]

### ២. ភស្តុតាងបង្ហាញពីទំនាក់ទំនងសាច់ញាតិ

លើសពីនេះទៅទៀត មេធាវីការពារក្តីបានជំទាស់នឹងពាក្យសុំតាំខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយឈរលើមូលដ្ឋានថា ក្នុងពាក្យបណ្តឹងទាំងនោះមិនបានបង្ហាញពីទំនាក់ទំនងសាច់ញាតិជាមួយអ្នកដែលបានជាប់នៅក្នុងមន្ទីរ ស-២១ ទេ ។ តួយ៉ាង ដើមបណ្តឹងរដ្ឋប្បវេណី E2/37 ត្រូវបានជំទាស់ ព្រោះក្នុងពាក្យបណ្តឹងនោះគ្រាន់តែអះអាងថា អ្នកដែលស្លាប់នៅទីនោះ គឺជាមិត្តភ័ក្ររបស់ខ្លួន ។ ទោះបីជា វិធានផ្ទៃក្នុងមិនបានបញ្ជាក់ពីលក្ខខណ្ឌច្បាស់លាស់នៃទំនាក់ទំនងសាច់ញាតិ ដើម្បីដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏មេធាវី

---

[១៤០] អំណះអំណាងរបស់លោកស្រីមេធាវី Fabienne Trusse-Napouse ដែលទទួលបានការគាំទ្រពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ និង ពីព្រះរាជអាជ្ញាអន្តរជាតិ ។ សូមមើល ប្រតិចារឹកសវនាការអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿងលេខ ០០១ ថ្ងៃទី២៦ សីហា ២០០៩ ទំព័រ ៦ ។

[១៤១] ក្នុងសំណុំរឿង Jean-Pierre Bemba (ICC-01/05/01/08-320) អង្គបុរេជំនុំជម្រះថ្នាក់ទី ៣ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិចេញសេចក្តីសម្រេចលើកទី ៤ ស្តីពី "ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី" ថ្ងៃទី ១២ ធ្នូ ២០០៨ កថាខ័ណ្ឌ ៣១ ។ ក្នុងករណីសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ ដំបូងអង្គបុរេជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ពិនិត្យការរៀបរាប់ក្នុងទំរង់បែបបទរបស់អ្នកដាក់ពាក្យ បន្ទាប់មកផ្ទៀងផ្ទាត់ជាមួយរបាយការណ៍ផ្លូវការ ជាពិសេសជាមួយរបាយការណ៍របស់អង្គការសហប្រជាជាតិ ដើម្បីធ្វើការវាយតម្លៃ ។ សូមមើលបន្ថែម *ស្ថានភាពក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ* ក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះថ្នាក់ទី១ អំពី " ទំរង់បែបបទសម្រាប់ការចូលរួមក្នុងដំណើរការនីតិវិធី ចំពោះ VPRS1, VPRS2, VPRS3, VPRS4, VPRS5, និង VPRS6 ថ្ងៃទី ១៧ មករា ២០០៦ ក្នុងសំណុំរឿងលេខ ICC-01/04-101-tEN-Corr កថាខ័ណ្ឌ ១០១ ។

[១៤២] សេចក្តីសម្រេចលើកទី៤ ស្តីពីការចូលរួមរបស់ជនរងគ្រោះ ក្នុងសំណុំរឿងរបស់ Bemba កថាខ័ណ្ឌ ៣៥ ។

[១៤៣] សេចក្តីសម្រេចលើកទី៤ ស្តីពីការចូលរួមរបស់ជនរងគ្រោះ ក្នុងសំណុំរឿងរបស់ Bemba កថាខ័ណ្ឌ ៣៦ ។

[១៤៤] បទសម្ភាសន៍ជាមួយលោក Alain Werner មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ថ្ងៃទី ១៣ តុលា ២០០៩ ។

ការពារក្តី បានលើកឡើងថា នេះគឺជាទម្លាប់នៅក្នុងប្រពន្ធ័ច្បាប់ស៊ីវិល ដែលតម្រូវឱ្យជាប់សាច់ញាតិជិតដិត ឬក៏ជាសមាជិកគ្រួសារ រវាងដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្ទាល់ ។[១៤៥] អំណះអំណាងគាំទ្រការបកស្រាយនេះនៅក្នុងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលចែងថា *សមាជិកគ្រួសារជិតដិត និងអ្នកនៅក្រោមបន្ទុកអាចអះអាងថា ខ្លួនទទួលរងឈឺចាប់ផ្លូវចិត្ត* ។[១៤៦] ជាងនេះទៅទៀតគោលការណ៍ទី ៨ នៃគោលការណ៍គ្រឹះ និងសេចក្តីណែនាំស្តីពីសិទ្ធិក្នុងការទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះ នៃអំពើរំលោភលើសិទ្ធិមនុស្សអន្តរជាតិ និងសេចក្តីណែនាំជាមូលដ្ឋានអំពីសិទ្ធិចំពោះការព្យាបាល និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ ចែងថា ជនរងគ្រោះគួរតែត្រូវបានកម្រិតត្រឹមតែជាសមាជិកគ្រួសារជិតដិតបំផុត និងជនរងគ្រោះផ្ទាល់ប៉ុណ្ណោះ ។[១៤៧]

អង្គជំនុំជម្រះបានកំណត់ថា ខ្លួននឹងចេញសេចក្តីសម្រេច អំពីការជំទាស់របស់មេធាវីការពារក្តី ចំពោះពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលចេញសាលក្រម ។ ដូច្នេះ គឺនៅតំណាក់កាលនេះហើយ ដែលជោគវាសនារបស់ដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវបានសម្រេច ។ ភាពមិនច្បាស់លាស់ដែលថា នឹងអាចមានដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ត្រូវបានគេបដិសេធនោះ ធ្វើឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំង លោកស្រី Silke Studzinsky បានបង្ហាញនូវការបារម្ភចំពោះស្ថានភាពមិនប្រាកដប្រជាដែលកូនក្តីខ្លួនកំពុងប្រឈមមុខ ។[១៤៨]

នៅក្នុងកិច្ចប្រជុំពេញអង្គរបស់តុលាការ បានសម្រេចជាគោលការណ៍ថា ក្នុងសំណុំរឿងក្តីលេខ 00២ រាល់ការជំទាស់ណាមួយ ចំពោះពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី គួតែធ្វើមុនសវនាការលើអង្គសេចក្តី ។ ដើម្បីកុំឱ្យមានភាពស្មុគ្រស្មាញ ដែលអាចកើតមាននៅក្នុងការជំនុំជម្រះបន្តបន្ទាប់នាពេលខាងមុខ កិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះ គួរតែចេញសេចក្តីណែនាំអំពីលក្ខខណ្ឌ និងកម្រិតនៃទំនាក់ទំនងសាច់ញាតិ ដែលអង្គជំនុំជម្រះអាចយកមកពិចារណា នៅពេលសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ ការធ្វើបែបនេះ គឺអាចជួយដល់ការពិចារណាផ្អែកលើនិយាមសិទ្ធិមនុស្ស ដែលទទួលស្គាល់ជាអន្តរជាតិ ព្រមទាំងបរិបទរបស់ប្រទេសកម្ពុជា

---

[១៤៥] បទសម្ភាសន៏ជាមួយមេធាវីការពារក្តីអន្តរជាតិលោក Roux ។ ក្រុមការពារក្តីយល់ថា "ទំនាក់ទទនងសាច់ញាតិ" រួមមានតែ ប្តី ប្រពន្ធ កូនប្រុស-ស្រី ម្តាយឪពុក របស់ជនរងគ្រោះ ។ សូមមើល ប្រតិចារឹកនៃសវនាការសំណុំរឿង 00១ ថ្ងៃទី ២៦ សីហា ២00៩ ទំព័រ ១២ ។ សូមមើលបន្ថែម ផ្នែក ៣៩៥-២(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសអាល្លឺម៉ង់ ដែលបានផ្តល់សិទ្ធិ "ចូលរួមធ្វើជារដ្ឋអាជ្ញាឯកជនដ៏សំខាន់ (private accessory prosecutor)" សិទ្ធិនេះត្រូវតែផ្តល់ទៅឱ្យឪពុក-ម្តាយ កូន និងសហពទ្ធ័ របស់អ្នកដែលបានសម្លាប់ដោយអំពើខុសច្បាប់ ។

[១៤៦] សេចក្តីសម្រេចលើកទី៤ ស្តីពីការចូលរួមរបស់ជនរងគ្រោះ ក្នុងសំណុំរឿរបស់ Bemba កឋាខ័ណ្ឌ ៧២ ។

[១៤៧] ដោយត្រូវបានអនុមត័ និងបញ្ជាក់ដោយសេចក្តីសម្រេចលេខ ៦0/១៤៧ ចុះថ្ងៃទី១៦ ធ្នូ ២00៥ ក្នុងនោះ គោលការណ៏ទី ៨ ចែងថា " ពាក្យថា *ជនរងគ្រោះ* សំដៅរួមទាំងសមាជិកគ្រួសារដែលជិតស្និត រឺកូនចៅរបស់ជនរងគ្រោះផ្ទាល់ " ។

[១៤៨] ទំនាក់ទំនងតាមសំបុត្រអេឡិចត្រូនិចជាមួយលោកស្រី Silke Studzinsky ថ្ងៃទី ១៩ ខែវិច្ឆិកា ២00៩ ។

*"ទស្សនៈអំពីគ្រួសារមានលក្ខណៈទូលំទូលាយ"* ហើយហួសពីគ្រួសារដែលសមាជិកមានតែកូន និងឪពុកម្តាយ ។ [១៤៩]

## ខ. ការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ៖ វត្តមានចូលរួម

សិទ្ធរបស់ជនរងគ្រោះនៅពេលជំនុំជម្រះ គឺជាការឆ្លុះបញ្ចាំងនូវសិទ្ធិទទួលបានការពិត ហើយក្រោយមកត្រូវបានទទួលស្គាល់កាន់តែច្រើនឡើងៗថា ជាបទដ្ឋានទំនៀមទំលាប់ និងជាគោលការណ៏ច្បាប់ ដែលកំពុងតែទទួលបាននូវការយកចិត្តទុកដាក់ ។[១៥០] បើយើងក្រឡេកមើលពីទិដ្ឋភាពចិត្តសាស្ត្រសង្គម វត្តមានរបស់ជនរងគ្រោះនៅពេលជំនុំជម្រះ ទាំងនៅក្នុងបន្ទប់សវនាការ ឬសាលសម្រាប់សាធារណៈជន គឺមានសារៈសំខាន់ណាស់ ក្នុងការធានាថា ប្រទេសកម្ពុជាបានយល់ពីដំណើរការផ្សះផ្សាកាន់តែទូលំទូលាយឡើង ។ តាមការកត់សម្គាល់ដោយអ្នកចិត្តសាស្ត្រមកពីអង្គការផ្នែកសុខភាពផ្លូវចិត្ត ហៅកាត់ថា TPO បានលើឡើងថា ប្រសិនបើជនរងគ្រោះកាន់តែច្រើនអាចប្រឈម និងការស្វែងយល់អំពីមូលហេតុនៃការកើតឡើងនូវអំពើឧក្រិដ្ឋទាំងនោះ ពួកគេអាចនឹងដោះស្រាយបានជាមួយនឹងកេរ្តិ៍ដំណែលដែលបន្សល់ពីរបបខ្មែរក្រហម ។[១៥១] ដូចគ្នានេះ ដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី **ជុំ នៅ** បានទទួលស្គាល់ថា ការចូលរួមនៅក្នុងកិច្ចដំណើរការជំនុំជម្រះ ជួយឱ្យគាត់ធូរស្រាលក្នុងអារម្មណ៏បានខ្លះ ហើយលែងមានគំនិតសងសឹក ឬក៏គុំគួនបន្តទៀត ។[១៥២]

ផ្ទុយពីជនរងគ្រោះទូទៅ ដើមបណ្តឹងរដ្ឋប្បវេណី គឺជាអ្នកដែលចូលរួមនៅក្នុងសវនាការកាន់តែសកម្ម និងមានសារៈសំខាន់ តាមដែលលោកមេធាវី Alain Werner បានកត់សម្គាល់អំពីអត្ថន័យនៃការចូលរួមរបស់កូនក្តីខ្លួន ។[១៥៣] ស្រដៀងគ្នានេះដែរ ដើមបណ្តឹងរដ្ឋប្បវេណី លោក **ជុំ ម៉ី** បានប្រាប់ថា គាត់មាន *"កាតព្វកិច្ច"* តាមដានសវនាការជារៀងរាល់ថ្ងៃ ព្រោះគាត់មានបំណងចង់ចូលរួមយ៉ាងសកម្ម ដើម្បីឱ្យដឹងថា តើដំណើរការនីតិវិធីនេះមានយុត្តិធម៌ដែរឬទេ ។[១៥៤] គាត់ក៏បានកត់សម្គាល់បន្ថែមទៀតថា គាត់មានអារម្មណ៏គាប់ចិត្តគ្រប់ពេល ដែលតុលាការបានឆ្លើយតបនឹងការសង្កេត ឬបណ្តឹងតវ៉ារបស់គាត់ ។[១៥៥]

---

[១៤៩] បទសម្ភាសន៍ជាមួយលោកជំទាវបណ្ឌិត Helen Jarvis ។ លោកជំទាវបានកត់សម្គាល់បន្ថែមទៀតថា " មនុស្សយើង អាចចាត់ទុកគ្នាថាជាបងប្អូនប្រុសស្រី ដោយមិនចាំបាច់មានទំនាក់ទំនងសាច់ញាតិទេ" ។ នៅកម្ពុជា " និយមន័យអំពី គ្រួសារ គឺមាន លក្ខណៈធំធេងជាងទំនាក់ទំនងពិតប្រាកដ" ។

[១៥០] សូមមើល សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងសំណុំរឿង Katanga និង Mathieu Ngudjolo Chui (ICC-01-04-01/07-474) ស្តីពី "សិទ្ធិមួយចំនួនក្នុងកិច្ចដំណើរការនីតិវិធី ដែលជនរងគ្រោះមាន មុនពេលដំណាក់កាលជំនុំជម្រះ" ថ្ងៃទី ១៣ ឧសភា ២០០៨ ។ កំណត់សម្គាល់ចុងទំព័រលេខ ៣៩ ។

[១៥១] បទសម្ភាសន៍ជាមួយបុគ្គលិក អង្គការ TPO ។

[១៥២] បទសម្ភាសន៍ជាមួយដើមណ្តឹងរដ្ឋប្បវេណីលោកស្រី **ជុំ នៅ** ថ្ងៃទី ៨ ខែ តុលា ២០០៩ ។

[១៥៣] បទសម្ភាសន៍ជាមួយលោក Alain Werner មេធាវីដើមបណ្តឹរដ្ឋប្បវេណីក្រុម១ ថ្ងៃទី ១៣ តុលា ២០០៩ ។

[១៥៤] បទសម្ភាសន៍ជាមួយលោក **ជុំ ម៉ី** ថ្ងៃទី ៦ ខែ តុលា ២០០៩ ។

[១៥៥] បទសម្ភាសន៍ជាមួយលោក **ជុំ ម៉ី** ថ្ងៃទី ៦ ខែ តុលា ២០០៩ ។

បើទោះជាមើលឃើញថា វាមានសារៈសំខាន់បែបនេះក៏ដោយ ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនយល់ឃើញថា ការចូលរួមក្នុងកិច្ចដំណើរការសវនាការ ត្រូវចំណាយប្រាក់អស់ច្រើន ហើយមានការលំបាក ។ ជាលទ្ធផលនៅក្នុងកំឡុងពេល បីខែដំបូងនៃសវនាការ មានតែដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូបប៉ុណ្ណោះ ដែលបានចូលរួមតាមដានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ(សាលាក្តីបានរៀបចំកន្លែងអង្គុយរហូតដល់ ១០កៅអី) ។[១៥៦] គេបានប្រាប់ក្រុមឃ្លាំមើលតុលាការថា ការដែលមិនសូវមានវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមនោះមិនមែនដោយសារពួកគេមិនចាប់អារម្មណ៍ពីកិច្ចដំណើរការជំនុំជម្រះនេះទេ ប៉ុន្តែពួកគេមិនអាចមានលទ្ធភាពចូលរួម ហើយទាក់ទងនឹងបញ្ហានេះដែរ ក្រុមអង្គការមិនមែនរដ្ឋាភិបាលបានកត់សម្គាល់ថា មានដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានខកចិត្ត ដោយសារពួកគេមិនអាចចូលរួមតាមដានសវនាការដោយផ្ទាល់[១៥៧] ដោយសារតែពួកគេភាគច្រើនរស់នៅតាមបណ្តាខេត្តនានា ដូចនេះការមកចូលរួមក្នុងកិច្ចដំណើរការសវនាការ គឺមិនអាចធ្វើទៅបានទេ ព្រោះត្រូវចំណាយថវិការច្រើនទៅលើការស្នាក់នៅ និងម្ហូបអាហារប្រចាំថ្ងៃ ។[១៥៨] ទោះបីជា វត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានការកើនឡើងក្នុងសវនាការជំនុំជំម្រះក្តី **ឌុច** ចាប់ពីពាក់កណ្តាលខែមិថុនាក៏ដោយ គេអាចមើលឃើញថា នឹងអាចមានការលំបាកសម្រាប់តុលាការនេះ ក្នុងការរក្សាកំណើនវត្តមានចូលរួមនេះក្នុងសំណុំរឿងក្តីលេខ ០០២ ដែលនឹងមានជនរងគ្រោះជាច្រើន ត្រូវគេទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនោះ ។[១៥៩]

ច្បាប់ស្តីពីការបង្កើតសាលាក្តីខ្មែរក្រហម និងវិធានផ្ទៃក្នុង មិនបានចែងថា តុលាការមានកាតព្វកិច្ចផ្តល់ជំនួយហិរញ្ញវត្ថុដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ ។[១៦០] ទោះបីជាយ៉ាងណាក៏ដោយ បើយើងគិតអំពីសារៈសំខាន់នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី យើងអាចនិយាយបានថា តុលាការគួរតែមានការទទួលខុសត្រូវខ្លះនៅក្នុងការងារនេះ ។ ការទទួលស្គាល់កាតព្វកិច្ចនេះ តុលាការបានចាត់វិធានការមួយចំនួន ដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមបានកាន់តែច្រើន ។ អង្គភាពជនរងគ្រោះនៃសាលាក្តីខ្មែរក្រហម បានបង្ហាញពីចេតនារបស់ខ្លួន ក្នុងការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីចូលរួមស្តាប់ពេលគេធ្វើសេចក្តីថ្លែងការណ៍បើកការជំនុំជម្រះ និងសេចក្តីសន្និដ្ឋានបញ្ចប់ ឬយ៉ាងហោចណាស់ក្នុងពេលណាមួយនៃថ្ងៃសវនាការ[១៦១] នេះជាឆន្ទៈដ៏គួរឱ្យកោតសរសើរ ។ បន្ថែមលើនេះ ប្រសិនបើអង្គភាពជនរងគ្រោះមិនមានថវិការគ្រប់គ្រាន់ក្នុងការសម្របសម្រួលឱ្យមានការចូលរួម

---

[១៥៦] នៅពីរថ្ងៃដំបូងនៃថ្ងៃសវនាការ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៣ ក្នុងចំណោម ៩៣ នាក់ បានចូលរួមក្នុងកិច្ចដំណើរការសវនាការ ដោយខ្លះបានអង្គុយក្នុងបន្ទប់សវនាការ ខ្លះអង្គុយក្នុងសាលសាធារណៈជន ។ សូមមើល របាយការណ៍ឃ្លាំមើលសាលាក្តីខ្មែរក្រហមលេខ ២ ។

[១៥៧] សូមមើល របាយការណ៍ឃ្លាំមើលសាលាក្តី ខ្មែរក្រហម លេខ ៧ ។

[១៥៨] បទសម្ភាសន៍ជាមួយលោកស្រី Slike Studzinsky ថ្ងៃទី ២១ តុលា ២០០៩ ។ លោកស្រីមេធាវី បានរៀបរាប់ថា "មានដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនចង់ចូលរួម ប៉ុន្តែដោយសារបញ្ហាថវិការ ទើបពួកគេមិនអាចមកបាន" ។

[១៥៩] សូមមើលរបាយការណ៍ឃ្លាំមើលសាលាក្តី ខ្មែរក្រហម លេខ៨, ៩, ១០, ១១, ១៤, ១៥, ១៦, ១៨, ១៩, ២១ ។

[១៦០] ច្បាប់ស្តីពីការបង្កើតសាលាក្តីខ្មែរក្រហម ។

[១៦១] បទសម្ភាសន៍ជាមួយលោកជំទាវបណ្ឌិត Helen Jarvis ។

ពីដើមបណ្តឹងរដ្ឋប្បវេណីទេ គេគួរតែស្វះស្វែងរកកិច្ចសហការជាមួយក្រុមអង្គការសង្គមស៊ីវិល ឬក៏អង្គភាពផ្សេងទៀតនៃសាលាក្តីខ្មែរក្រហម ដូចជា ផ្នែកកិច្ចការសាធារណៈជាដើម ដើម្បីសម្រេចបាននូវគោលបំណងនេះ ។

## គ. ការចូលរួមនៅក្នុងដំណើរការនីតិវិធី : ការគាំទ្រការចោទប្រកាន់ និងការទាមទារសំណង

### ១.សិទ្ធិទូទៅក្នុងដំណាក់កាលជំនុំជម្រះ

ដូចដែលបានលើកឡើងនៅក្នុងផ្នែកទី ៣ នៃរបាយការណ៍នេះ វិធានផ្ទៃក្នុងរបស់តុលាការ ចែងយ៉ាងទូលាយទៅលើសេចក្តីណែនាំអំពីកម្រិតដែលដើមបណ្តឹងរដ្ឋប្បវេណី អាចចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីបាន ។ យោងទៅតាមវិធាន ២៣(១) នៃវិធានផ្ទៃក្នុង ចែងថា ជនរងគ្រោះអាចចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីដោយគាំទ្រការចោទប្រកាន់ ប៉ុន្តែតាមរយៈនេះ កម្រិតដែលពួកគេអាចតាំងសំណួរទៅសាក្សីប្រភេទណាមួយ ឬទៅជនជាប់ចោទ មិនមានកំណត់ច្បាស់នៅឡើយទេ ។ ដូចនេះ អង្គជំនុំជម្រះត្រូវប្រើអំណាចឆន្ទានុសិទ្ធិដ៏ទូលាយរបស់ខ្លួន ដើម្បីកំណត់លើកម្រិតដែលដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមបានក្នុងន័យនេះ ។

ក្នុងសំណុំរឿងក្តីលេខ ០០១ អង្គជំនុំជម្រះបានចាត់វិធានការកាន់តែតឹងតែងចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីសុំការអនុញ្ញាតដាក់សេចក្តីសន្និដ្ឋានឆ្លើយតបនឹងការស្នើសុំឱ្យដោះលែងជនជាប់ចោទពីការឃុំខ្លួនបណ្តោះអាសន្ននោះ ព្រមទាំងការសុំឆ្លើយតបទៅនឹងសេចក្តីថ្លែងរបស់សហព្រះរាជអាជ្ញា នៅពេលបើកការជំនុំជម្រះ ត្រូវបានបដិសេធ ។[១៦២] បន្ថែមលើនេះ ទោះបីជា ដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសិទ្ធិចូលរួមនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏ពួកគេពុំមានសិទ្ធិធ្វើសេចក្តីថ្លែង នៅពេលបើកការជំនុំជម្រះដែរ ។

ម្យ៉ាងទៀត ទោះបីជាពេលដំបូង ក្រុមមេធាវីតំណាងដើមណ្តឹងរដ្ឋប្បវេណីទទួលបាននូវសិទ្ធិដ៏ទូលាយក្នុងការតាំងសំណួរទៅសាក្សីក៏ដោយ ក៏ក្រោយមកអង្គជំនុំជម្រះបានដាក់កម្រិតពេលវេលាចំពោះមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងភាគីផ្សេងទៀតផងដែរ ។ វិធានការបែបនេះទំនងជាសមហេតុផល ព្រោះថាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានតាំងសំណួរច្រំដែលជាច្រើន ។

បញ្ហាចម្រូងចម្រាសទាក់ទិននឹងការចូលរួមរបស់ដើបណ្តឹងរដ្ឋប្បវេណី បានកើតឡើងនៅចុងបញ្ចប់នៃសវនាការ នៅពេលដែលអង្គជំនុំជម្រះបានសម្រេចមិនអនុញ្ញាតឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីតាំងសំណួរទៅជនជាប់ចោទ និងសាក្សី ក្នុងការដេញដោលអំពីអត្តចរិករបស់ជនជាប់ចោទ ព្រមទាំងមិនអនុញ្ញាតឱ្យដាក់សេចក្តីសន្និដ្ឋានទៅលើការដាក់ទោសទណ្ឌ ។ ការសម្រេចអំពីបញ្ហានេះ ពុំមានជំហរច្បាស់លាស់ ដោយសារតែអង្គជំនុំជម្រះធ្វើសេចក្តីសម្រេចផ្ទាល់មាត់ មិនបានចេញលាយលក្ខអក្សរភ្លាមៗ ដូចនេះមេធាវីតំណាងដើមបណ្តឹងរដ្ឋប្ប

[១៦២] វិធាន ៨២(៣) វិធាន ៨៩ ស្ទួន(២) នៃវិធានផ្ទៃក្នុង វិសោធនកម្មលើកទី៣ ។

វេណី គ្មានជម្រើសក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចនោះទេ មុនពេលបិទការជំនុំជម្រះ ។ ចំពោះការសម្រេចបែបនេះ បានធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើពហិការមិនចូលរួមក្នុងសវនាការ ដើម្បីបង្ហាញពីទស្សនៈមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ។[១៦៣]

នៅក្នុងសេចក្តីសម្រេចចេញ នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩ អង្គជំនុំជម្រះបានកត់សម្គាល់ថា តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធី មិនមែនមានន័យថា ពួកគេមានសិទ្ធិទូទៅក្នុងការចូលរួមដូចជាសហព្រះរាជអាជ្ញានោះទេ ។[១៦៤] ដោយហេតុថា តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងកិច្ចដំណើរការនីតិវិធីមិនដូចនឹងសហព្រះរាជអាជ្ញា ដូច្នោះការកំណត់ទោសគួរតែជាសិទ្ធិរបស់សហព្រះរាជអាជ្ញាតែម្នាក់ប៉ុណ្ណោះ ។[១៦៥] សិទ្ធិនេះ រួមទាំងសិទ្ធិក្នុងការតាំងសំណួរទៅសាក្សីបំភ្លឺ អំពីអត្តចរឹតរបស់ជនជាប់ចោទ ដែលសក្ខីកម្មរបស់ពួកគេគាំទ្រដល់ការអះអាងរបស់ជនជាប់ចោទ ដើម្បីទទួលបានស្ថានសម្រាលទោស ។[១៦៦] ទោះបីជាយ៉ាងណា នៅក្នុងមតិជំទាស់របស់លោកចៅក្រម Lavergne បានកត់សម្គាល់ថា ការតាំងសំណួរអំពីបុគ្គលិកលក្ខណៈអាចមានទំនាក់ទំនងជាមួយនឹងពិរុទ្ធភាព ។[១៦៧] គាត់ក៏បានបន្ថែមទៀតថា មុនពេលសួរដេញដោលអំពីអត្តចរឹករបស់ជនជាប់ចោទដើមបណ្តឹងរដ្ឋប្បវេណីតែងតែត្រូវបានអនុញ្ញាតឱ្យតាំងសំណួរទៅសាក្សី និងជនជាប់ចោទ ស្តីពីបញ្ហាជាច្រើនដែលជាប់ទាក់ទងដល់អត្តចរឹករបស់ជនជាប់ចោទផងដែរ បើទោះបីជាការតាំងសំណួរទាំងនោះ បានធ្វើឡើងក្រោមប្រធានបទខុសៗគ្នាក៏ដោយ ។[១៦៨] ផ្ទុយពីមតិភាគច្រើន លោកចៅក្រម Lavergne បានពិចារណាបន្ថែមទៀត អំពីគោលបំណងដ៏ចំបងមួយរបស់តុលាការនេះ គឺ ***ការផ្សះផ្សា*** ។[១៦៩] លោកចៅក្រមក៏បានកត់សម្គាល់បន្ថែម ទៀតថា វានឹងមានការពិបាកដើម្បីសម្រេចគោលដៅចុងក្រោយនេះ ប្រសិនបើគេមិនអនុញ្ញាតឱ្យជនរងគ្រោះ សួរសំណួរថាហេតុអ្វីបានជាមានអំពើឧក្រិដ្ឋកម្មកើតឡើងចំពោះរូបគេ ។[១៧០] មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បាន

---

[១៦៣] សូមមើល "លិខិតរបស់ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿងលេខ ០០១ ផ្ញើជូនប្រធានអង្គជំនុំជម្រះ" ។ បទសម្ភាសន៍ ជាមួយដើមបណ្តឹងរដ្ឋប្បវេណី លោក **ជុំ ម៉ី** និង លោកស្រី **ជុំ នៅ** ។

[១៦៤] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក. ក្នុងសំណុំរឿងលេខ០០១ ថ្ងៃទី ០៩ តុលា ២០០៩ កថាខ័ណ្ឌ ២៥ ។

[១៦៥] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក. ក្នុងសំណុំរឿងលេខ ០០១ ថ្ងៃទី ០៩ តុលា ២០០៩ កថាខ័ណ្ឌ ៤២ ។

[១៦៦] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក. ក្នុងសំណុំរឿងលេខ ០០១ ថ្ងៃទី ០៩ តុលា ២០០៩ កថាខ័ណ្ឌ ៤៦ ។

[១៦៧] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក. ក្នុងសំណុំរឿងលេខ ០០១ ថ្ងៃទី ០៩ តុលា ២០០៩ ។ មតិជំទាស់ របស់លោកចៅក្រម Jean Marc Lavergne កថាខ័ណ្ឌ ២៧ ។ បទសម្ភាសន៍ជាមួយបុគ្គលិកការិយាល័យសហព្រះរាជអាជ្ញា ថ្ងៃទី ១៣ តុលា ២០០៩ ។

[១៦៨] មតិជំទាស់របស់លោកចៅក្រម Jean Marc Lavergne កថាខ័ណ្ឌ ៣៥ និងបទសម្ភាសន៍ជាមួយបុគ្គលិកការិយាល័យសហព្រះរាជអាជ្ញា ថ្ងៃទី ១៣ តុលា ២០០៩ ។

[១៦៩] មតិជំទាស់របស់លោកចៅក្រម Jean Marc Lavergne កថាខ័ណ្ឌ ៣១ ។

[១៧០] មតិជំទាស់ របស់លោកចៅក្រម Jean Marc Lavergne កថាខ័ណ្ឌ៣១ ។ សូមមើល សក្ខីភាពរបស់បណ្ឌិត **ឈឹម សុធារ៉ា** ក្នុងប្រតិចារឹកសវនាការសំណុំរឿងលេខ ០០១ ថ្ងៃទី ២៥ សីហា ២០០៩ ទំព័រ ២០ ។ លោកបណ្ឌិត **សុធារ៉ា** បានបញ្ជាក់ថា ជនរងគ្រោះមានការលំបាកក្នុងការធ្វើឱ្យធូស្បើយដំបៅផ្លូវចិត្តរបស់ពួកគេប្រសិនបើមិនអាចរើកមុខ "អ្នកដែលនៅពីក្រោយឧក្រិដ្ឋកម្មនោះ" ។

សម្ដែងការមិនពេញចិត្តនឹងសេចក្ដីសម្រេចនេះ ។

## ២. ការអនុវត្តតួនាទីរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

វិធាន ២៣(៧) នៃវិធានផ្ទៃក្នុង បានធានាសិទ្ធិដើមបណ្ដឹងរដ្ឋប្បវេណីឱ្យមានអ្នកតំណាងផ្លូវច្បាប់ ។ ទោះបីជាមានការកំណត់បែបនេះក៏ដោយ តុលាការមិនបានផ្ដល់ជំនួយហិរញ្ញវត្ថុឱ្យមេធាវីជនរងគ្រោះក្នុងសំណុំរឿងក្ដីលេខ ០០១ ទេ ។ ផ្ទុយទៅវិញ បែរជាអង្គការម្ចាស់ជំនួយ និងសង្គមស៊ីវិល ដើរតួរជាអ្នកសម្របសម្រួល និងផ្ដល់ការឧបថម្ភចំពោះដំណើរការចូលរួមរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធី ។ ជាលទ្ធផល មេធាវីបួនក្រុម ត្រូវបានទទួលជំនួយពីស្ថាប័នដោយឡែកពីគ្នា ហើយពួកគេហាក់ដូចជាមានជំហរខុសៗគ្នាក្នុងដំណើរការនីតិវិធី ។

ក្រៅពីនេះ ទោះបីជាអង្គភាពជនរងគ្រោះរបស់តុលាការពេលខ្លះ បានជួយសម្របសម្រួលដល់ទំនាក់ទំនងការងាររវាងក្រុមមេធាវី និងតុលាការ ក៏នៅក្នុងសំណុំរឿងក្ដីលេខ ០០១ មិនមានជំនួយ ឬធនធានគ្រប់គ្រាន់ក្នុងការរៀបចំយុទ្ធសាស្ត្រដោះស្រាយបញ្ហានេះទេ ។ លើសពីនេះទៅទៀត អង្គភាពនោះក៏ពុំមានសិទ្ធិអំណាចក្នុងការដោះស្រាយបញ្ហានេះដែរ ។ បើពិនិត្យពីការរៀបចំដំណើរការនៅដំណាក់កាលដំបូង អង្គភាពជនរងគ្រោះមានតួនាទីគ្រាន់តែត្រួតពិនិត្យលើពាក្យបណ្ដឹងរបស់ជនរងគ្រោះប៉ុណ្ណោះ ពោលគឺមិនបានធានាឱ្យមានកិច្ចសហការរវាងមេធាវីតំណាងរដ្ឋប្បវេណី ដើម្បីការពារប្រយោជន៍រួមរបស់ជនរងគ្រោះនោះទេ ហើយក៏មិនមានសេចក្ដីណែនាំអនុវត្តន៍ស្ដីការសម្របសម្រួលទំនាក់ទំនងការងាររបស់មេធាវីដែរ ។

បន្ថែមលើនេះ អង្គភាពជនរងគ្រោះមិនមានមូលនិធិគ្រប់គ្រាន់ ដើម្បីសម្របសម្រួលទំនាក់ទំនងការងាររវាងមេធាវី និងកូនក្ដីខ្លួន និងដើម្បីរៀបចំសំណុំរឿង ។[១៧១] បទសម្ភាសន៍មួយចំនួនជាមួយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញថា ពួកគេមិនសប្បាយចិត្ត ដោយសារតែគ្មានធនធានគ្រប់គ្រាន់ ដើម្បីឱ្យពួកគេអាចជួបប្រាស័យទាក់ទងផ្ទាល់ជាមួយកូនក្ដីខ្លួន ឬផ្ដល់ជំនួយឱ្យបានគ្រប់គ្រាន់សម្រាប់ក្រុមការងារ ។[១៧២] ម្យ៉ាងទៀត ប្រឈមមុខនឹងបញ្ហាទាំងនេះ ផ្អែកតាមដើមបណ្ដឹងរដ្ឋប្បវេណីលោកស្រី **ជុំ នៅ** លើកឡើងថា អវត្តមានជាប្រចាំរបស់មេធាវីអន្តរជាតិ កាន់តែធ្វើឱ្យមេធាវីជាតិមានការលំបាកក្នុងការបំពេញការងារខ្លួន ។[១៧៣] ប្រធានអង្គភាពជនរងគ្រោះបច្ចុប្បន្ន លោកជំទាវ **Helen Jarvis** បានទទួលស្គាល់ពីភាពចាំបាច់ក្នុងការជួយសម្របសម្រួលបន្ថែមទៀត ដល់ទំនាក់ទំនងការងាររវាងមេធាវីដើមបណ្ដឹង និងកូនក្ដី ។ ចំពោះបញ្ហានេះ លោកជំទាវក៏បានបង្ហាញ

---

[១៧១] បទសម្ភាសន៍ជាមួយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ លោក Werner និង កញ្ញាទី ស្រីណា នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០០៩ ។ សូមមើលបន្ថែម របាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ១២ ចំនុចដែលលោកស្រីមេធាវី Studzinsky ថាគាត់បានជួបជាមួយលោកស្រី ណាំ ម៉ុន តែបីលើកប៉ុណ្ណោះ មុនពេលឡើងសវនាការ ដែលជាការឆ្លើយទៅនឹងសំណួររបស់លោកស្រីចៅក្រម Cartwright ថា ហេតុអ្វីបានជាព័តិមានបន្ថែមរបស់ លោកស្រី ណាំ មុន ទើបតែរកឃើញ។

[១៧២] បទសម្ភាសន៍ជាមួយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ លោក Werner ។ បទសម្ភាសន៍ជាមួយមេធាវី ទី ស្រីណា ។ បទសម្ភាសន៍ជាមួយមេធាវី ហុង គីមសួន នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៩ ។

[១៧៣] បទសម្ភាសន៍ជាមួយដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រី ជុំ នៅ

ការប្តេជ្ញាចិត្តក្នុងការជួយឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសបន្ថែមទៀត ដើម្បីប្រស័យទាក់ទងជាមួយកូនក្តីខ្លួនក្នុងសំណុំរឿងក្តីលេខ ០០២ ។[១៧៤]

បញ្ហាកង្វះធនធាន និងកង្វះការសម្របសម្រួលរួម បង្ហាញឱ្យឃើញពីមិនមានភាពស៊ីសង្វាក់គ្នាក្នុងការអនុវត្តតួនាទីរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការនីតិវិធីសំណុំរឿងលេខ ០០១។ ក្នុងនោះមេធាវីមួយចំនួនយល់ថា តួនាទីចម្បងរបស់ពួកគេនៅក្នុងតុលាការ គឺគាំទ្រការការចោទប្រកាន់ រីឯមេធាវីខ្លះទៀតបានលើកថា តួនាទីរបស់ពួកគេគឺតំណាងឱ្យសម្លេង និងក្តីកង្វល់របស់ជនរងគ្រោះ ។ ពេលខ្លះ បញ្ហានេះធ្វើឱ្យមេធាវីតាំងសំណួរដោយផ្អែកតែទៅលើអង្គហេតុផ្ទាល់ខ្លួនរបស់កូនក្តីម្នាក់ៗ ទោះបីជាសំណួរទាំងនោះមិនជាប់ពាក់ព័ន្ធនឹងសំណុំរឿង ។[១៧៥] ផ្ទុយទៅវិញ មេធាវីដែលខិតខំប្រឹងប្រែងគាំទ្រសហព្រះរាជអាជ្ញា ពេលខ្លះហាក់ដូចជាដើរតួជាសហព្រះរាជអាជ្ញាទី២ ជាជាងគាំទ្រការចោទប្រកាន់ ។

បញ្ហាធំមួយបានកើតឡើងទាក់ទងនឹងការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅតុលាការ ។ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវឡើងផ្តល់សក្ខីកម្ម ចាំបាច់ណាស់ត្រូវមានការទំនាក់ទំនងនឹងការពិភាក្សាឱ្យបានគ្រប់គ្រាន់ជាមួយមេធាវីរបស់ខ្លួនមុននឹងឡើងសវនាការ កង្វះការរៀបចំជាមុនអាចនាំឱ្យជនរងគ្រោះមានបទពិសោធន៍មិនល្អនៅក្នុងតុលាការ ។ បញ្ហានេះបានបង្ហាញឱ្យឃើញកាន់តែច្បាស់កំឡុងពេលផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី លោក **លី ហ៊័រ** ដែលអះអាងថា ខ្លួនជាអ្នករួចរស់ជីវិតពីមន្ទីរ ស-២១ ប៉ុន្តែជនជាប់ចោទតវ៉ាពីអត្តសញ្ញាណរបស់គាត់ ព្រោះសាក្សីមិនបានបង្ហាញពីភាពស៊ីសង្វាក់គ្នានៅក្នុងសក្ខីកម្មខ្លួន ។[១៧៦] ភាពមិនស៊ីសង្វាក់នេះក៏កើតមានបន្តបន្ទាប់ ករណីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋវេណីនៅចំពោះមុខអង្គជំនុំជម្រះ ផ្ទុយពីនឹងព័តមាននៅក្នុងពាក្យសុំរបស់ខ្លួន ហើយក៏បង្កើនធ្វើឱ្យមេធាវីការពារក្តីសួរដេញដោលលម្អិតអំពីបញ្ហានេះ ។[១៧៧] ជាលទ្ធផល ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនត្រូវបញ្ឈប់សក្ខីកម្មកំឡុងពេលនោះ ដែលបន្សល់នូវបន្ទិលអំពីអត្តសញ្ញាណរបស់ពួកគេ ។ ករណីនេះអាចនាំឱ្យមានលទ្ធផលអវិជ្ជមានចំពោះការចូលរួមរបស់ពួកគេ ហើយអាចបណ្តាលឱ្យមានជំងឺផ្លូវចិត្តឡើងវិញ ។[១៧៨] តាមបទសម្ភាសន៍ជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយរូប បានលើកឡើងថា មុនដំណាក់កាលសវនាការ គាត់មិនបានស្វែងរកភស្តុតាងលម្អិតជុំវិញកូនក្តីខ្លួនទេ ព្រោះគាត់មិនបានរំពឹងទុកថា កូនក្តីខ្លួននឹង

---

[១៧៤] បទសម្ភាសន៍ជាមួយលោកជំទាវបណ្ឌិត Helen Jarvis

[១៧៥] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ១០, ១៣, ១៤, ១៥

[១៧៦] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ១២

[១៧៧] ឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ លោក ភោគ ខន ត្រូវបានសួរតទល់នឹងឯកសារពាក្យសុំ និងព័តិមានផ្តល់ដល់អង្គជំនុំជម្រះ ។ សូមមើលបន្ថែម របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហមលេខ ១២ ។

[១៧៨] ឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណី លី ហ៊័រ បានបង្ហាញនូវការមិនមិនសប្បាយចិត្តរបស់ក្នុងដំណើរការសវនាការ។ យោងតាមមេធាវីអន្តរជាតិលោក Werner លោក លី ហ៊័រ ត្រូវបានដាក់ឱ្យស្ថិតក្នុង "ស្ថានភាពលំបាកខ្លាំង ដោយគាត់មានអារម្មណ៍ថាប្រជាពលរដ្ឋចោទគាត់ថានិយាយកុហក" ។

ត្រូវគេសួរដេញដោលដូចជាសាក្សីទូទៅនោះទេ ។[១៧៩] បើពិនិត្យមើលលើវិធានផ្ទៃក្នុងរបស់តុលាការ បានឱ្យដឹងថា ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវចាត់ទុកដូចជាសាក្សីធម្មតាឡើយ ។

បញ្ហាមួយទៀតពាក់ព័ន្ធនឹងការតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺជារបៀបនៃគ្រប់គ្រងពេលវេលារបស់មេធាវី ព្រោះថាមេធាវីតំណាងដើមបណ្តឹងបានសួរដេញដោលសំណួរច្រំដែលជាញឹកញាប់ ។[១៨០] ដើម្បីដោះស្រាយបញ្ហានេះ នៅក្នុងសប្តាហ៍ទី៩នៃដំណើរការសវនាការ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ពេលវេលាឱ្យភាគីសួរសំណួរទៅកាន់សាក្សី ឬជនជាប់ចោទ ប៉ុន្តែបញ្ហានៅតែបន្តកើតមានដដែល ។[១៨១] សំណួរច្រំដែលដូចជាមានការកាត់បន្ថយជាបន្តបន្ទាប់គួរឱ្យកត់សម្គាល់ បន្ទាប់ពីមេធាវីតំណាងដើមបណ្តឹងរកវិធីសាស្ត្រដើម្បីអនុវត្តតាមការណែនាំរបស់អង្គជំនុំជម្រះ គឺនៅសប្តាហ៍ទី១៥ ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បានចាត់តាំងមេធាវីម្នាក់ ឬពីរនាក់ ធ្វើជាតំណាងសួរដេញដោលសាក្សី និងជនជាប់ចោទ ។[១៨២]

ដើម្បីចៀសវាងបញ្ហាដូចដែលបានរៀបរាប់ខាងលើនេះ អង្គប្រជុំពេញអង្គលើកទី៦របស់តុលាការបានព្រមព្រៀងកំណត់ឱ្យមានសហមេធាវីនាំមុខ ២រូប តំណាងឱ្យក្រុមមេធាវីទាំងអស់ដែលទទួលបន្ទុកសំណុំរឿងទាំងមូល ។[១៨៣] គេមើលឃើញថា នៅក្នុងសំណុំរឿងក្តីលេខ ០០២ ក្រុមដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវបែងចែកដោយផ្អែកលើផលប្រយោជន៍ក្រុមផ្សេងគ្នា ដូចជា តាមរយៈព្យសនកម្ម ឬជនជាតិ ឬយេនឌ័រ ឬសាសនា ។ ក្រុមនីមួយៗនឹងត្រូវតំណាងដោយមេធាវីជំនាញលើវិស័យទាំងនោះ ប៉ុន្តែ ពួកត្រូវធ្វើការក្រោមការដឹកនាំរបស់សហមេធាវីនាំមុខ[១៨៤] ។ ទោះបីជាយ៉ាងណាក៏ដោយ គេនៅតែមានក្តីកង្វល់ចំពោះការអនុវត្តវិធានការថ្មីនេះ ក្នុងនោះមានដូចជា ថាតើអ្នកណាទទួលខុសត្រូវជ្រើសរើសសហមេធាវនាំមុខ ហើយតើគួរមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ? លើសពីនេះទៀត តើសហមេធាវីនាំមុខមានតួនាទីកម្រិតណាក្នុងការសម្របសម្រួលការងារមេធាវីក្នុងក្រុមនីមួយៗ ឬក៏គ្រាន់តែប្រាប់ឱ្យពួកគេចាត់ចែងការងារក្នុងក្រុមរៀងៗខ្លួន? មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោក Alain Werner បានលើកឡើងថា ដើម្បីឱ្យប្រព័ន្ធការងារថ្មីនេះដំណើរការ សហមេធាវីនាំមុខពីររូបនោះ ចាំបាច់ត្រូវតែជាអ្នកមានចំណេះដឹងខ្ពស់ និងបទពិសោធន៍យូរអង្វែងលើវិស័យព្រហ្មទណ្ឌអន្តរជាតិ និងមានសមត្ថភាពក្នុងការសម្របសម្រួលការងារក្នុងចំណោមមេធាវីដែលមកពីប្រព័ន្ធច្បាប់ផ្សេងគ្នា ។[១៨៥] សេចក្តីបារម្ភមួយទៀតថា តើដើមបណ្តឹងរដ្ឋប្បវេណី មានបំណងចង់បានមេធាវីតំណាងតាមក្រុមនីមួយៗដូចដែលរៀបរាប់ខាងលើដែរឬទេ? ហើយ

---

[១៧៩] បទសម្ភាសន៍ជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ លោក Werner

[១៨០] បទសម្ភាសន៍ជាមួយលោកស្រីចៅក្រម Cartwright និងរបាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ៧, ៨ និង ៤ ។

[១៨១] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ៩, ១១, និង ៤ ។

[១៨២] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហមលេខ ១៥ ។

[១៨៣] សូមមើលព័ត៌មានរបស់ អ.វ.ត.ក "កិច្ចពេញអង្គលើកទី៦របស់អ.វ.ត.ក" អាចរកបានតាមរយៈ http://www.eccc.gov.kh/english/news.view.aspx?doc_id=311>

[១៨៤] បទសម្ភាសន៍ជាមួយលោកស្រីបណ្ឌិត Jarvis

[១៨៥] បទសម្ភាសន៍ជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ លោក Werner

ក្នុងនោះពួកគេមួយចំនួនប្រហែលជាចង់ចូលរួមធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីធម្មតាជាជាងនៅក្នុងក្រុម ពិសេសណាមួយ ដែលនេះជាបញ្ហាចាំបាច់គួរតែត្រូវដោះស្រាយ មុនសវនាការសំណុំរឿងក្តីលេខ០០២ចាប់ផ្តើម ។

### ៣. សំណង

វិធាន ២៣(១១) បានលើកឡើងយ៉ាងច្បាស់ថា អង្គជំនុំជម្រះអាចសម្រេចផ្តល់ឱ្យជាសំណងសមូហភាព និងសំណងផ្លូវចិត្ត ទៅដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ហើយការផ្តល់សំណងនេះត្រូវធ្វើឡើងប្រឆាំងនឹងទណ្ឌិត និងជាបន្ទុករបស់ទណ្ឌិត ។[១៨៦] យោងតាមសំណើរួមរបស់ដើមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំតែ *"សំណងមានលក្ខណៈជាសមូហភាព និងសំណងជំងឺចិត្ត"* ប៉ុណ្ណោះ រួមមាន ការចុះធ្វើសកម្មភាពនៅតាមជនបទឆ្ងាយៗ ការផ្សព្វផ្សាយព័ត៌មាន ការផ្តល់ការថែទាំសុខភាព ការរៀបចំឱ្យមានកម្មវិធីអប់រំ និងការរំលឹកដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហមនៅប្រទេសកម្ពុជា ។[១៨៧] រូបភាពនៃសំណងទាំងនេះ គឺជាកេរ្តិ៍តំណែលនៃតុលាការ ដែលអាចជួយដល់ដំណើរការផ្សះផ្សាជាតិ ។ ទោះបីជាយ៉ាងនេះក៏ដោយ ក្នុងសំណើនោះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី មិនបានបែងចែករវាងជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីទេ ពោលគឺលើកឡើងនូវសំណើសុំទូទៅ ។ កំឡុងពេលធ្វើបទសម្ភាសន៍ជាមួយក្រុមឃ្លាំមើលតុលាការ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនបានលើកឡើងថា ពួកគេមិនសប្បាយចិត្តនឹងសំណង ដែលមិនផ្តល់ដល់បុគ្គលម្នាក់ៗ ។[១៨៨] ដូច្នេះ វាជាការចាំបាច់ណាស់ក្នុងការសម្រេចទុកជាមុននូវរូបភាពនៃសំណងជាក់លាក់ណាមួយ នៅក្នុងវិធានផ្ទៃក្នុង ដែលអាចបែងចែកដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះមិនមែនដើមបណ្តឹងរដ្ឋប្បវេណី ។ ដូចនេះ អ.វ.ត.ក និងអង្គការក្រៅរដ្ឋាភិបាល ត្រូវផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវអំពីបញ្ហាសំណងទៅជនរងគ្រោះ និងគួររកដំណោះស្រាយទៅតាមសំណងដែលពួកគេទាមទារ ។[១៨៩]

បញ្ហាសំខាន់ផ្សេងទៀត ដែលនៅតែមិនទាន់បានដោះស្រាយនៅឡើយ គឺការអនុវត្តសំណង ។ វិធានផ្ទៃក្នុង កំណត់ថា ជនជាប់ចោទជាអ្នកទទួលបន្ទុកចេញសំណង ប្រសិនបើរកឃើញថា មានពិរុទ្ធពីបទឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់ ។[១៩០] ជនជាប់ចោទបានប្រកាសថា ខ្លួនមានជីវភាពក្រីក្រ និងពុំមានថវិការចំណាយលើសំណងដូចដែលបានស្នើសុំនោះទេ ។ ដូច្នេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំឱ្យមានការចូលរួមពីរាជរដ្ឋាភិបាល

---

[១៨៦] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣) វិធាន ២៣(១១) ។

[១៨៧] ដើមបណ្តឹងរដ្ឋប្បវេណីមានការប្រុងប្រយ័ត្នដោយគូសបញ្ជាក់ថា សំណើអំពីសំណងទាំងនេះគឺមានកម្រិតតិចតួចបំផុត ដូចនេះអង្គជំនុំជម្រះអាចប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការសម្រេចអំពីសំណងសមស្របតាមការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសូមមើល "សេចក្តីថ្លែងការណ៍រួមរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណង កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩" កឋាខណ្ឌ ៤៦ នៅក្នុងសំណុំរឿង ក្តីលេខ ០០១ ។

[១៨៨] បទសម្ភាសន៍ជាមួយដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី និង ជុំ នៅ

[១៨៩] បទសម្ភាសន៍ជាមួយបុគ្គលិកអង្គការសុខភាពផ្លូវចិត្ត TPO និងជាមួយលោក រាជ សម្បត្តិ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩

[១៩០] វិធានផ្ទៃក្នុង វិសោធនកម្មលើកទី៣ វិធាន ២៣(១១)

និងឱ្យបង្កើតមូលនិធិសច្ចគ្រូចិត្ត ប៉ុន្តែដើម្បីអនុវត្តន៍តាមសំណើទាំងពីរនេះបាន ចាំបាច់ត្រូវធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ។ ទោះបីជា សំណើសុំឱ្យមានបង្កើតមូលនិធិសច្ចគ្រូចិត្តហាក់ដូចជានៅឆ្ងាយក៏ដោយ តែការអំពាវនាវឱ្យមានការចូលរួមពីរាជរដ្ឋាភិបាលកម្ពុជា គឺជាមូលដ្ឋានដ៏រឹងមាំ ដែលមាននៅក្នុងច្បាប់អន្តរជាតិ ។ សន្ធិសញ្ញាច្បាប់ទំនៀមទំលាប់អន្តរជាតិ ព្រមទាំងទម្លាប់អនុវត្តរបស់រដ្ឋ បានឆ្លុះបញ្ចាំងពីគោលការណ៍ដែលថា រដ្ឋត្រូវមានភារកិច្ចជួយផ្តល់ដំណោះស្រាយដល់ជនរងគ្រោះនៃអំពើរំលោភធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានប្រព្រឹត្តក្នុងទឹកដីប្រទេសនោះ ។[១៩១] ទោះបីជាយ៉ាងនេះក៏ដោយ ការលំបាកក្នុងការអនុវត្តធ្វើឱ្យចៅក្រមយល់ថាសំណើបែបនេះមិនអាចធ្វើទៅបាន ។

ដូច្នេះ ចាំបាច់ត្រូវឱ្យមានការពិភាក្សាបន្ថែមទៀតស្តីពី *"សំណងសមូហភាព និងសំណងផ្លូវចិត្ត"* ហើយថាតើគួរត្រូវបានអនុវត្តដូចម្តេចក្នុងបរិបទប្រទេសកម្ពុជា ។ គេសង្ឃឹមថា អង្គជំនុំជម្រះសាលាដំបូងនឹងដាក់ចេញនូវយុត្តិសាស្ត្រជាវិជ្ជមាននៅក្នុងសំណុំរឿងក្តីលេខ ០០១ ដែលអាចឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះអាចទទួលយកបាន ដើម្បីកាត់បន្ថយនូវការឈឺចាប់របស់ពួកគេ ទោះបីជាសំណងនិមិត្តរូបក៏ដោយ ។

## ឃ. ការចូលរួម ការការពារ និងការគាំពារសាក្សី

ជាទូទៅ ការចូលរួមរបស់សាក្សីនៅក្នុងដំណើរការសវនាការ **ឌុច** បានប្រព្រឹត្តទៅយ៉ាងរលូន និងគ្មានបញ្ហាអសន្តិសុខណាមួយកើតឡើងទេ ។ ប៉ុន្តែចំពោះការចាក់ផ្សាយអំពីដំណើរការនីតិវិធីសវនាការជាសាធារណៈ តាមប្រព័ន្ធទូរទស្សន៍ អាចបង្កឱ្យមានបញ្ហាដល់ការរៀបចំសាក្សីនៅក្នុងសវនាការ ។

### ១. ការពិនិត្យភស្តុតាង និងចូលរួមនីតិវិធីជាសាធារណៈ

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះដើម្បីរៀបចំការពិនិត្យភស្តុតាង ដូចជា សក្ខីកម្មសាក្សី និងអ្នកជំនាញបានញ៉ាំងឱ្យមានការជជែកដេញដោល ថាតើមានជាប់ពាក់ពន្ធ័ទៅនឹងអង្គហេតុដែលបានកំណត់ទុកដែរឬទេ ។[១៩២] បញ្ហានេះបានប៉ះពាល់ដល់ការតាំងសំណួរចំពោះសាក្សីជំនាញ ដែលត្រូវបានសួរដេញដោលហួសពីប្រធានបទដូចបានកំណត់ ។[១៩៣] បន្ថែមលើនេះ តាមប្រព័ន្ធច្បាប់ស៊ីវិល សាក្សីចូលផ្តល់សក្ខីកម្ម ត្រូវចាត់ទុកជាសាក្សីរបស់តុលាការដូចនេះភាគីពុំមានសិទ្ធិរៀបចំសាក្សី ដើម្បីឱ្យផ្តល់សក្ខីកម្មគាំទ្រពួកគេទេ ។ កត្តានេះ គឺកុំឱ្យភាគីមានឥទ្ធិពលខ្លាំង

---

[១៩១] អត្ថបទច្បាប់សិទ្ធិមនុស្ស លេខ២០៩ ទំព័រ ២១១-២២៣ របស់ Bassiouni, M. Cherif (2006) ស្តីពី "ការទទួលស្គាល់ជាអន្តរជាតិនូវសិទ្ធិជន រងគ្រោះ" ។

[១៩២] សូមមើលឧទាហរណ៍ របាយការណ៍ស្តីពីសក្ខីកម្មរបស់លោក Craig Etcheson, របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ៦ ។

[១៩៣] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ១៣ ។ ក្នុងពេលផ្តល់សក្ខីកម្ម លោក ម៉ម ណៃ បានផ្តល់ព័ត៌មានផ្ទុយទៅអ្វី ដែលគាត់បានរាយការណ៍ទៅសហចៅក្រមស៊ើបអង្កេត ។ លោក ហ៊ឹម ហុយ មិនអាចបញ្ជាក់ឡើងវិញអំពីព័ត៌មាន ដែលបានផ្តល់ទៅឱ្យសហចៅក្រមស៊ើបអង្កេតទេ ។

ទៅលើសាក្សី ប៉ុន្តែសាក្សីបែជាពុំត្រៀមលក្ខណៈបានល្អ ព្រោះគ្មានមានការរៀបចំជាមុន ។ ពេលខ្លះសក្ខីកម្មសាក្សីហាក់ដូចជាមិនស៊ីសង្វាក់ទៅនឹងអ្វីដែលពួកបានឆ្លើយចំពោះមុខការិយាល័យសហចៅក្រមស៊ើប ដែលបញ្ហានេះអាចបណ្តាលមកពីគម្លាតពេលឆ្ងាយពេកនៃការផ្តល់ចម្លើយចំពោះមុខសហចៅក្រមស៊ើប និងការឆ្លើយមុខអង្គជំនុំជម្រះ ឬក៏អាចមកពីពួកគេមិនយល់ ឬសំណួរមានលក្ខណៈស្មុគស្មាញ ។[១៩៤] សាក្សីមួយចំនួនមិនអាចផ្តល់អំណះអំណាងគាំទ្រការលើកឡើងរបស់ពួកគេ ហើយខ្លះដូចជាមានអារម្មណ៍ភ័យខ្លាច ដោយសារបរិយាកាសក្នុងបន្ទប់សវនាការ ។[១៩៥]

សាក្សីមួយចំនួនត្រូវបានដឹងថា តាមដានកិច្ចដំណើរការសវនាការតាមរយៈកញ្ចក់ទូរទស្សន៍[១៩៦] និងខ្លះទៀត បានចូលទស្សនាសវនាការដោយផ្ទាល់មុនពេលពួកគេផ្តល់សក្ខីកម្ម ។[១៩៧] លោកស្រីចៅក្រម Cartwright បានកត់សម្គាល់ថា នៅក្នុងកិច្ចដំណើរការនីតិវិធីដែលបានផ្សាយជារៀងរាល់ថ្ងៃតាមកញ្ចក់ទូរទស្សន៍ ហើយមានអ្នកទស្សនាជាង ៥០០នាក់ ចាំបាច់ត្រូវមាននីតិវិធានការជាក់ស្តែង ដើម្បីដោះស្រាយកុំឱ្យប៉ះពាល់ដល់សក្ខីកម្មរបស់សាក្សី ។[១៩៨] លោកស្រីចៅក្រមក៏យល់ផងដែរ ពីការលំបាករបស់សាក្សីក្នុងការចងចាំរឿងហេតុ ដែលកន្លងហួសមកយូរហើយ ។ លោកស្រីបានបន្តធ្វើអត្ថាធិប្បាយថា រយៈពេលកន្លងហួសធ្វើឱ្យការចងចាំព្រឹត្តការណ៍មានភាពស្រពិចស្រពិល ។[១៩៩] ខណៈដែលអត្តសញ្ញាណសាក្សីត្រូវបានបង្ហាញហើយ ប៉ុន្តែក្រោយមកសក្ខីកម្មខ្លួនត្រូវបានលើកពេលវិញ ករណីនេះគួរជៀសវាងជាដាច់ខាត យោងតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ត្រូវបានចែងថា អ្នកជំនាញ និងសាក្សី ហាមឃាត់មិនឱ្យចូលរួម និងទស្សនាសវនាការទេ មុនពេលផ្តល់សក្ខីកម្ម ។[២០០] ប្រធានអង្គភាពគាំពារសាក្សី និងអ្នកជំនាញ លោកស្រី Wendy Lobwein បានកត់សម្គាល់ថា តុលាការបាននឹងកំពុងអនុវត្តស្រដៀងគ្នាទៅនឹងវិធានការដែលតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានធ្វើ ។[២០១] លោកស្រីបានបន្តថា នៅពេលសវនាការធ្វើជាសាធារណៈត្រូវបានចាក់ផ្សាយ គឺពុំមានលទ្ធភាពណាមួយហាមឃាត់សាក្សីមិនឱ្យតាមដានបានទេ ។ ផ្ទុយទៅវិញ សាក្សីត្រូវតែឆ្លើយដោយស្មោះត្រង់ ប្រសិនបើអង្គជំនុំជម្រះសួរដេញដោលអំពីអ្វី

---

[១៩៤]

[១៩៥] ជាក់ស្តែងសាក្សីជំនាញលោក Nayan Chanda ត្រូវបានសួរដេញដោលពីប្រភពព័ត៌មានដែលគាត់ទទួលបានដើម្បីសរសេរសៀវភៅរបស់គាត់ ។ គាត់បានបញ្ជាក់ថា គាត់មិនបានចាំច្បាស់ទេ ហើយវាហាក់ដូចជាច្បាស់ថា គាត់មិនដែលបានមកប្រទេសកម្ពុជាទេ ព្រោះគាត់បានបង្ហាញពីការប្រើប្រាស់ប្រភពព័ត៌មានមិនផ្ទាល់ពីប្រទេសកម្ពុជា ។ សូមមើលរបាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោស ខ្មែរក្រហម សប្តាហ៍ទី៧ និងសូមមើលប្រតិចារឹករបស់តុលាការ ថ្ងៃទី ២៥ និង ២៦ ខែឧសភា ឆ្នាំ២០០៩ ។

[១៩៦] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ១៤ ។

[១៩៧] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ១៥ ។

[១៩៨] បទសម្ភាសន៍ជាមួយលោកស្រីចៅក្រម Cartwright

[១៩៩] បទសម្ភាសន៍ជាមួយលោកស្រីចៅក្រម Cartwright

[២០០] វិធាន ៨៨(២) នៃវិធានផ្ទៃក្នុងវិធានវិសោធនកម្មលើកទី៣ ។

[២០១] ឧទាហរណ៍: អង្គភាពគាំពារសាក្សី និងអ្នកជំនាញនៃតុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ICTY បានរៀបចំកូនសៀវភៅព័ត៌មាន សម្រាប់សាក្សីដែលអាចរកបានតាមរយៈ http://www.icty.org/x/file/About/Registry/Witnesses/witnesses_booklet_en.pdf.

ដែលខ្លួនបានឃើញ បានដឹង បានឮ ពីសក្ខីកម្មរបស់សាក្សីមុនៗ ។ ស្រដៀងនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី សាក្សីត្រូវមានការទទួលខុសត្រូវខ្លួនឯង មិនត្រូវពិភាក្សា និងផ្តល់ព័ត៌មានជាមួយអ្នកដទៃ ជាពិសេស ប្រសិនបើពួកគេបានដឹង ឬនឹងដឹងព័ត៌មានពីសាក្សីដទៃ ដែលត្រូវផ្តល់សក្ខីកម្មដែរ ពួកគេមានករណីកិច្ចតែមួយគត់ គឺត្រូវឆ្លើយដោយស្មោះត្រង់ ។[២០២]

## ២. សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង និងកាតព្វកិច្ចនិយាយការពិត

នៅគ្រប់ដំណាក់កាលនីតិវិធី វិធាន ២៨(១) នៃវិធានផ្ទៃក្នុង បានធានាសិទ្ធិសាក្សីឱ្យធ្វើការបដិសេធមិនធ្វើសេចក្តីថ្លែងណាមួយដែលអាចឱ្យខ្លួនឯងជាប់ពិរុទ្ធ ។ ការការពារមិនឱ្យធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង ត្រូវបានលើកឡើងនៅក្នុងដំណាក់កាលជំនុំជម្រះសំណុំរឿងក្តីលេខ ០០១ នៅពេលអតីតបុគ្គលិកមន្ទីរ ស-២១ ឡើងផ្តល់សក្ខីកម្ម ។ មេធាវីការពារក្តីអន្តរជាតិ លោក Roux បានលើកឡើងនូវ *"ការព្រួយបារម្ភនេះ"* ដើម្បីឆ្លើយតបទៅនឹងការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់ឱ្យ **ឌុច** ទទួលខុសត្រូវតាមទ្រឹស្តី *"សហកម្មឧក្រិដ្ឋកម្មរួម (JCE)"* ។ លោក Roux បានពន្យល់ថា ប្រសិនបើ **ឌុច** ត្រូវបានដាក់ឱ្យទទួលខុសត្រូវតាមទ្រឹស្តីនេះមែន អតីតបុគ្គលិកក្រោមបង្គាប់គាត់ទាំងអស់នឹងត្រូវចាប់ខ្លួន ហើយប្រឈមមុខនឹងការចោទប្រកាន់ ។[២០៣] មេធាវី Roux បានរំលឹកទៀតថា ទោះបីជាតុលាការ អ.វ.ត.ក បានធានាថា នឹងមិនយកសាក្សីទាំងនោះមកកាត់ទោសក៏ដោយ ក៏ពួកគេអាចប្រឈមមុខ នឹងការចោទប្រកាន់ពីតុលាការជាតិដែរ ។[២០៤]

បើទោះបីជា អង្គជំនុំជម្រះមិនបានរំលឹកសាក្សីឱ្យបានច្បាស់លាស់អំពីបញ្ហា *"សហកម្មឧក្រិដ្ឋកម្មរួម (JCE)"* ក៏តុលាការបានជូនដំណឹងប្រាប់សាក្សីអំពីសិទ្ធិមិនផ្តល់សក្ខីភាពប្រឆាំងនឹងខ្លួនឯង ព្រមទាំងកាតព្វកិច្ចនិយាយតែការពិតដែលមានចែងក្នុងវិធាន ៣៦(១) ។ បន្ថែមលើនេះ មេធាវីប្រឹក្សាយោបល់ដល់សាក្សីក៏ត្រូវបានចាត់តាំងឡើងផងដែរដើម្បីជំនួយដល់សាក្សី ។[២០៥] មេធាវីរូបនេះមានវត្តមានក្នុងដំណើរការសវនាការនៅពេលសាក្សី ដែលជាអតីតបុគ្គលិកមន្ទីរ ស-២១ មកផ្តល់សក្ខីកម្ម ។[២០៦]

---

[202] អ៊ីម៉ែលឆ្លើយតបនឹងប្រធានអង្គភាពគាំទ្រជនរងគ្រោះ និងសាក្សីជំនាញ លោក Ms Lobwein, Wendy នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ (បន្ទាប់ហៅថា "អ៊ីម៉ែលឆ្លើយពី **Lobwein**)

[២០៣] សូមមើលប្រតិចារឹករបស់តុលាការ ថ្ងៃទី ២៥ និង២៦ ខែឧសភា ឆ្នាំ២០០៩ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ ។

[២០៤] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ១៣ ។

[២០៥] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ១៣, ១៤ និង១៥ ។

[២០៦] លោកមេធាវី **គង់ សំអុន** ដែលអង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងអង្គភាពផ្សេងទៀតបានជ្រើសរើសឱ្យប្រឹក្សាយោបល់ដល់សាក្សីបានធ្វើតំណាងឱ្យសាក្សីទាំងអស់ ដែលជាអតីតៈបុគ្គលិករបស់មន្ទីរស-២១ ។ គាត់ធ្វើការប្រឹក្សាយោបល់ដល់លោក **ម៉ម ណៃ, ហ៊ឹម ហ៊ុយ, ប្រាក់ ខន, គោក ស្រស់, សេក ធន, ជៀម សឿ, ឡាច មាន, ឈុន ផល** និង **សោម ម៉េត** ។ សូមមើល របាយការណ៍អ្នកឃ្លាំមើលមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ១៣, ១៤, ១៦ និង១៧ ។

## ៣. ការការពារ និងការផ្ដល់ការគាំទ្រផ្នែកផ្លូវចិត្តដល់សាក្សី

សវនាការកាត់ក្ដី **ឌុច** ពុំមានបញ្ហាទាក់ទងទៅនឹងការការពារសាក្សីទេ ។ ទោះបីជាយ៉ាងនេះក៏ដោយ ពេលខ្លះនៅក្នុងដំណើរការជំនុំជម្រះ សាក្សីហាក់មានអារម្មណ៍ភ័យខ្លាចជនជាប់ចោទ បញ្ហានេះទំនងជាមកពីដោយសារជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋានលើសក្ខីកម្មរបស់ពួកគេ ។ សាក្សីមួយចំនួនបានឱនមុខចុះ ហើយខ្លះទៀតស្រក់ទឹកភ្នែក នៅពេលដែលមេធាវីការពារក្ដីសួរដេញដោល ។[២០៧] បន្ថែមលើនេះ ចំពោះអតីតបុគ្គលិកក្រោមបង្គាប់ **ឌុច** មួយចំនួន ហាក់មានអារម្មណ៍មិនល្អ នៅពេលជនជាប់ចោទឆ្លើយតបទៅនឹងសក្ខកម្មរបស់ខ្លួន ។[២០៨] ស្រដៀងគ្នានេះដែរ នៅពេល **ឌុច** ថ្លែងទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់ ពួកគេដូចហាក់មានការតក់ស្លុត និងរំជួលចិត្តជាខ្លាំង ។[២០៩] បើទោះបីជាយ៉ាងនេះក៏ដោយ នៅពេលដែលហេតុការណ៍នេះកើតឡើង អង្គជំនុំជម្រះបានណែនាំភ្លាមៗទៅ មេធាវីប្រឹក្សាយោបល់ឱ្យជួយសម្រួលដល់កូនក្ដីរបស់ខ្លួន។[២១០]

ជាសំណាងតុលាការនេះមានការចូលរួមពីអង្គការជាតិ ផ្នែកសុខភាពផ្លូវចិត្ត ‘TPO’ ដែលដើរតួផ្ដល់ប្រឹក្សាយោបល់ផ្លូវចិត្ត ព្រមទាំងមានបុគ្គលិកចាំជួយសម្រួល និងផ្ដល់សេវានេះយ៉ាងទាន់ពេលវេលា ដោយសហការជាមួយអង្គភាពគាំពារសាក្សី និងអង្គភាពជនរងគ្រោះ ទោះបីជា តុលាការមិនបានផ្ដល់មូលនិធិសម្រាប់បុគ្គលិករបស់អង្គការនេះក៏ដោយ ។ សេវាកម្មផ្នែកសុខភាពផ្លូវចិត្តរបស់អង្គការនេះ គឺចាំបាច់ណាស់ ព្រោះមិនមានអ្នកជំនាញផ្នែកសុខភាពផ្លូវចិត្តច្រើនទេ នៅក្នុងប្រទេសដើម្បីជួយបញ្ហានេះ ។ បុគ្គលិក ‘TPO’ បានកត់សម្គាល់ថា ពួកគេបានផ្ដល់ការជំនួយខាងផ្នែកផ្លូវចិត្ត មិនត្រឹមតែកំឡុងពេលផ្ដល់សក្ខីកម្មទេ ថែមទាំងមុន និងក្រោយពេលផ្ដល់សក្ខីកម្មទៀតផង ។[២១១] ទោះបីជាបែបនេះក៏ដោយ ទំហំនៃការផ្ដល់សេវានេះ នៅមានកម្រិតនៅឡើយ ព្រោះតុលាការ

---

[២០៧] បទសម្ភាសន៍ជាមួយបុគ្គលិកអង្គការសុខភាពផ្លូវចិត្ត TPO និងរបាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ១៣ ។

[២០៨] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហមលេខ១៤ ចំណុចដែលជនជាប់ចោទបដិសេធនឹងសេចក្ដីថ្លែងរបស់សាក្សី ប្រាក់ ខន ។

[២០៩] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ១៧ ។

[២១០] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ១៣ នៅពេលមេធាវីការពារក្ដីជាតិលោក **ការ សាវុត្ថ** មានកាយវិការមិនសមរម្យចំពោះដើមបណ្ដឹងរដ្ឋប្បវេណី ណាំ ម៉ុន បន្ទាប់មកអង្គជំនុំជម្រះបានធ្វើការដាស់តឿនលោក ឱ្យនិយាយសមរម្យទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណីដែលពេលនោះកំពុងតែមានអារម្មណ៍ភ័យខ្លាច ។ សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម សប្ដាហ៍ទី ១៧ :បន្ទាប់ពីនិយាយទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី **ប៊ូ ថុន** ពេលនោះអង្គជំនុំជម្រះបានដាស់តឿន **ឌុច** ម្ដងទៀតឱ្យបញ្ឈប់ កាយវិការនេះម្ដងទៀត ព្រោះធ្វើឱ្យសាក្សីមានការឈឺចាប់ខ្លាំង ។

[២១១] បទសម្ភាសន៍ជាមួយលោកស្រីបណ្ឌិត Jarvis និង បុគ្គលិកអង្គការសុខភាពផ្លូវចិត្ត TPO។ បុគ្គលិកកត់សម្គាល់ថា ទំនាក់ទំនងរបស់ពួកគេជាមួយដើមបណ្ដឹងរដ្ឋប្បវេណី គឺជិតស្និតជាងជនរងគ្រោះដែលជាសាក្សី តាមសកម្មភាពទំនាក់ទំនងនៅឆ្នាំ២០០៨ ។ ពួកគេបន្ថែមថា តាមធម្មតា ពួកគេត្រូវជួបជាមួយសាក្សីជាមុន មុននឹងឡើងឱ្យផ្ដល់សក្ខីកម្ម ដោយអមដំណើរពួកគាត់ពីកន្លែងស្នាក់នៅភ្នំពេញ ហើយពេលខ្លះ ពីភូមិឃុំដែលគាត់ស្នាក់នៅ ទៅតុលាការ ។ ផ្អែកតាមការវាយតម្លៃនេះ មានការបារម្ភអំពីសុវត្ថិភាពរបស់សាក្សីនៅភូមិឃុំ ហើយដែលបានគូសបញ្ជាក់ដោយប្រធានអង្គភាពជនរងគ្រោះ Jarvis ។

មិនបានផ្តល់ជំនួយ ។[២១២] បញ្ហានេះអាចប៉ះពាល់ដល់ដំណើរការជំនុំជម្រះសំណុំរឿងលេខ ០០២ នៅពេលដែលសាក្សីជាច្រើនមានការភ័យខ្លាច និងព្រួយបារម្ភ ។ ប្រធានអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ លោកស្រី Lobwein បានលើកឡើងថា អង្គភាពលោកស្រីកំពុងតែពិនិត្យមើលបទពិសោធន៍នៅក្នុងប្រតិបត្តិការរបស់ខ្លួនក្នុងសំណុំរឿងក្តីលេខ ០០១ ។ ទោះបីជាយ៉ាងនេះក៏ដោយ លោកស្រីបានបន្ថែមទៀតថា អង្គភាពនេះបានបំពេញការងាររបស់ខ្លួនមុនពេលសាក្សីផ្តល់សក្ខីកម្ម និងដោះស្រាយបញ្ហានានាដែលកើតមានផងដែរ នៅកំឡុង និងក្រោយដំណាក់កាលជំនុំជម្រះ ។[២១៣]

## ខ. បទពិសោធន៍ទទួលបានពីការចូលរួម និង ការគាំពារដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី

សវនាការជំនុំជម្រះក្តី **ឌុច** គឺជាសំណុំរឿងដើម្បីសាកល្បងចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ។ នៅក្នុងសវនាការសំណុំរឿងក្តីលេខ ០០១ តុលាការបានព្យាយាមរកដំណោះស្រាយចំពោះបញ្ហាសំខាន់ៗជាច្រើន ទាក់ទងនឹងការអនុវត្តយន្តការថ្មីនេះ ដូចជា ត្រូវកំណត់ពីតួនាទីរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបន្ទប់សវនាការ និងការពារផលប្រយោជន៍ជនរងគ្រោះ ។ អង្គជំនុំជម្រះ បានសម្រេចកំណត់ពីតួនាទីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើកម្រិតនៃការចូលរួមរបស់ពួកគេ ជាជាងទៅលើគុណភាពនៃការចូលរួម ។ ដូចនេះហើយ អង្គជំនុំជម្រះគ្រាន់តែបានសម្រេចកំណត់រយៈពេលតាំងសំណួរសម្រាប់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយណែនាំឱ្យចៀសវាងនូវសំណួរច្រំដែល ដោយចៅក្រមមិនបានចង្អុលបង្ហាញអំពីថាតើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គួរមានតួនាទីដូចម្តេចនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ឬយុត្តិសាស្ត្រច្បាប់អន្តរជាតិដែលពាក់ព័ន្ធបញ្ហានេះ ។ ការសម្រេចបែបនេះ គឺប្រហែលជាមកពីអង្គជំនុំជម្រះត្រូវប្រឈមមុខនឹងបញ្ហាជាច្រើន ដូចជា ពេលវេលាក្នុងដំណើរការសវនាការ និងបញ្ហាជាច្រើន ដែលចៅក្រមជួបប្រទះ ហើយត្រូវដោះស្រាយរាល់ថ្ងៃ ។

ខណៈពេលដែលចៅក្រមនៃអង្គជំនុំជម្រះសង្ឃឹមយ៉ាងមុតមាំថា នឹងមានការកែទម្រង់រចនាសម្ព័ន្ធនៃការចូលរួមពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្តីលេខ ០០២ ដោយកំណត់ជាក់លាក់ពីតួនាទីរបស់មេធាវី និងកាត់បន្ថយចំនួនមេធាវីសកម្មក្នុងពេលសវនាការនោះ ដំណោះស្រាយប្រកបដោយប្រសិទ្ធិភាពចំពោះបញ្ហាសំខាន់ៗជាច្រើនទៀតដែលមាននៅក្នុងសំណុំរឿងក្តីលេខ ០០១ គួរតែត្រូវយកមកពិចារណាផងដែរ ។ ប្រសិន

---

[២១២] បទសម្ភាសន៍ជាមួយបុគ្គលិកអង្គការសុខភាពផ្លូវចិត្ត TPO ថា តុលាការមិនបានផ្តល់ជំនួយថវិការដល់ការងាររបស់ពួកគេទេ ព្រមទាំងសូម្បីតែការដឹកជញ្ជូន ។ បន្ថែមលើនេះ តាមការអង្កេតតាមទូរទស្សន៍ក្នុងបន្ទប់រងចាំរបស់បុគ្គលិកអង្គការសុខភាពផ្លូវចិត្ត មិនមានដំណើរការ ដូចនេះពួកគេត្រូវធ្វើដំណើទៅមកៗ ដើម្បីឱ្យដឹងថា តើសាក្សីដែលកំពុងផ្តល់សក្ខីកម្មនោះចប់ហើយឬនៅ។ បញ្ហាបច្ចេក-ទេស នេះ បានជះឥទ្ធិពលដល់ការងាររបស់ TPO ក្នុងការរៀបចំសាក្សីឱ្យឡើងសវនាការ ។

[២១៣] លោកស្រីបានបន្តកត់សម្គាល់ថា បច្ចុប្បន្នអង្គភាពគាំពារសាក្សី និងអ្នកជំនាញ មមាញឹកកំឡុងពេលស៊ើបអង្កេតនៃសំណុំរឿងក្តីលេខ ០០២ ហើយការរៀបចំសម្រាប់រឿងក្តីលេខ ០០២ បានចាប់ផ្តើមធ្វើជាយូរមកហើយ ។ បន្ថែមលើនេះអង្គភាពនេះបានរៀបចំបុគ្គលិកបន្ថែមប្រសិនបើចាំបាច់ ដំណើរការសវនាការសំណុំរឿងក្តីលេខ ០០២ ( អ៊ីម៉ែលឆ្លើយតបពី លោកស្រី Lobwein) ។

បើមានសេចក្តីណែនាំអនុវត្តចំពោះពាក្យថា *"ការគាំទ្រការចោទប្រកាន់"* ដូចមានចែងនៅវិធាន ២៣(១) និង កម្រិតដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចតាំងសំណួរទៅសាក្សី នោះវានឹងអាចធ្វើឱ្យធ្វើឱ្យដំណើរការនីតិវិធីប្រព្រឹត្តទៅយ៉ាងរលូនដែលជាប្រយោជន៍ដល់ភាគីទាំងអស់ ។ បន្ថែមលើនេះ ការផ្តល់សិទ្ធិឱ្យអង្គភាពជនរងគ្រោះ ផ្តល់ព័ត៌មានដល់ជនរងគ្រោះអំពីអ្វីដែលពួកគេចង់ដឹងពីតុលាការនេះ ព្រមទាំងអនុវត្តវិធានការផ្សេងៗទៀត ដើម្បីជួយគាំទ្រដល់ជនរងគ្រោះទូទៅ នឹងអាចជួយដល់ពួកគេឱ្យយល់កាន់តែច្បាស់ពីដំណើរការនីតិវិធីរបស់តុលាការ និងមានបទពិសោធន៍កាន់តែច្រើន ។

ចំពោះការការពារ និងគាំពារសាក្សី បានប្រព្រឹត្តទៅយ៉ាងល្អនៅក្នុងសវនាការកាត់ក្តី **ឌុច** ។ ប៉ុន្តែ បើគេពិនិត្យមើលពីទំហំសំណុំរឿង និងចំនួនជនជាប់ចោទក្នុងរឿងក្តីលេខ ០០២ ចាំបាច់ត្រូវរៀបចំឱ្យមានជំនួយផ្នែកផ្លូវចិត្តបន្ថែមទៀត ។

## ផ្នែកទី៥ ៖ ការគ្រប់គ្រងសវនាការ

២២សប្ដាហ៍ នៃសវនាការកាត់ទោស **ឌុច** អង្គជំនុំជម្រះបានបង្ហាញពីការយកចិត្តទុកយ៉ាងខ្លាំង ចំពោះការដឹកនាំនីតិវិធី ។[២១៤] ដំបូងឡើយ អង្គជំនុំជម្រះហាក់មានការប្រុងប្រយ័ត្នចំពោះការដឹកនាំនីតិវិធីអនុវត្តរបស់ខ្លួន ព្រោះសវនាការមានលក្ខណៈមាត្រដ្ឋានអន្តរជាតិបែបនេះ ទើបតែមានលើកទីមួយនៅប្រទេសកម្ពុជា ។ កំឡុងពេលនោះដែរ អង្គជំនុំជម្រះបានណែនាំភាគីឱ្យរៀបចំសំណួរឱ្យបានពេញលេញ និងមានន័យគ្រប់គ្រាន់ដល់សាក្សី និង ស្របទៅនឹងនីតិវិធីដែលបានកំណត់ ។[២១៥] នៅសប្ដាហ៍ទី៨ ទោះបីជា នីតិវិធីប្រព្រឹត្តទៅយឺតជាងកាលកំណត់ ក៏អង្គជំនុំជម្រះបានធ្វើការវាយតម្លៃថា សវនាការនឹងបញ្ចប់នៅក្នុង ខែធ្នូ ឆ្នាំ២០០៩ ។[២១៦] ករណីនេះនាំឱ្យមានកិច្ចប្រជុំរៀបចំសវនាការ ដែលគ្រប់ភាគីបានព្រមព្រៀងថា ពួកគេត្រូវពន្លឿននីតិវិធីសវនាការ ។[២១៧]

អង្គជំនុំជម្រះ បានចាត់វិធានការជាបន្តបន្ទាប់ ដើម្បីពន្លឿនដំណើរការនីតិវិធី ដូចជា កំណត់ពេលវេលាសម្រាប់ភាគីតាំងសំណួរទៅសាក្សី ព្រមទាំងបានបែងចែកពេលវេលាប្រជុំ ដើម្បីដោះស្រាយនូវបញ្ហានានា ដែលកើតឡើងក្នុងពេលសវនាការ ។[២១៨] ប្រធានអង្គជំនុំជម្រះលោកចៅក្រម **និល ណុន** កាន់តែមានទំនុកចិត្តក្នុងការចេញសេចក្ដីណែនាំយ៉ាងសកម្ម ដើម្បីធានាសវនាការប្រព្រឹត្តទៅបានយ៉ាងរលូន ដោយបោះបង់ចោលឥរិយាបទឆាប់មានប្រតិកម្ម នៅពេលព្យាយាមរក្សាសណ្ដាប់ធ្នាប់ក្នុងបន្ទប់សវនាការនាដើមសប្ដាហ៍ដំបូង ។ ទោះបីជា បានអនុវត្តវិធានការទាំងនេះក៏ដោយ ក៏នៅតែមានបញ្ហាចោទទៅលើការគ្រប់គ្រងពេលវេលាដដែល ដោយពេលខ្លះនៅក្នុងដំណើរការនីតិវិធី ទាំងចៅក្រមជំនុំជម្រះ និងភាគី នៅតែបន្តតាំងសំណួរមិនពាក់ព័ន្ធអង្គហេតុ ឬសួរសំណួរច្រំដែល ។ ស្រដៀងនឹងបញ្ហានេះ ចៅក្រមជំនុំជម្រះនៅតែបន្តឱ្យសាក្សី និងជនជាប់ចោទ ឆ្លើយនៅសំណួរទាំងនោះ ។[២១៩] បន្ថែមលើនេះ បញ្ហាបច្ចេកទេសនៅក្នុងបន្ទប់សវនាការ ក៏ជាហេតុនាំឱ្យមានការពន្យាដំណើរការនីតិវិធីផងដែរ ប៉ុន្តែបញ្ហានេះ ក៏ត្រូវបានដោះស្រាយភ្លាមៗដែរ ។

---

[២១៤] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្នុងសវនាការបឋម ក្នុងសំណុំរឿងក្ដីលេខ 001 នៅខែកុម្ភៈ ឆ្នាំ២០០៩ មុនសវនាការអង្គសេចក្ដី ដែលធ្វើនៅ ថ្ងៃទី៣0 មិនា ២០០៩ ដែលសរុបទាំងសវនាការសន្និដ្ឋានបញ្ចប់មានចំនួន ២២ សប្ដាហ៍ ។ **<u>ចំណាំ ៖</u>** ការវាយតម្លៃក្នុងរបាយការណ៍នេះភាគច្រើន ធ្វើតែក្នុងសវនាការ ចាប់ពី ថ្ងៃ៣0 មិនា ដល់ ១៧ កញ្ញា ២០០៩ ប៉ុណ្ណោះ ។

[២១៥] មកដល់សប្ដាហ៍ទី៨ អង្គជំនុំជម្រះបានទទួលស្គាល់ថា ការពិភាក្សាទៅលើអង្គហេតុពីរដំបូង ដែលមានក្នុងដីកាសេចក្ដីសន្និដ្ឋានបញ្ជូនរឿងជំនុំជម្រះ បានចំណាយពេលយូរជាងកាលកំណត់ ។ សូមមើលបន្ថែម ក្នុងរបាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ៨ ។

[២១៦] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ៨ ។

[២១៧] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ៨ ។

[២១៨] អង្គជំនុំជម្រះ បានកំណត់ថា នៅថ្ងៃព្រហស្បតិ៍ សប្ដាហ៍ទី ៣ នៃខែនីមួយៗ ត្រូវបានរក្សាទុកសម្រាប់ដោះស្រាយបញ្ហា ដែលមិនទាន់សម្រេច ដូចជា បញ្ហានៃការកំណត់រយៈពេលសួរដេញដោលសាក្សី និងសូមមើលរបាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ៩ ។

[២១៩] ឧទាហរណ៍ របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ៤, ៩, ១១, ១៣, ១៤, និង១៩ ។

ក្រៅពីបញ្ហាទាំងនេះ អង្គជំនុំជម្រះក៏ជួបប្រទះនឹងបញ្ហាមួយចំនួន នៅពេលព្យាយាមចេញសេចក្តីសម្រេច និងសេចក្តីណែនាំឱ្យទាន់ពេលវេលា ។ ទោះបីជា ចៅក្រមចង់ឱ្យសេចក្តីសម្រេចទាំងនោះឱ្យមានប្រសិទ្ធិភាពខ្ពស់ក៏ដោយ ពេលខ្លះសេចក្តីណែនាំរបស់អង្គជំនុំជម្រះមិនមានមូលដ្ឋានច្បាស់លាស់ ហើយការចេញសេចក្តីសម្រេចលើបញ្ហាសំខាន់ៗមួយចំនួនមានការយឺតយ៉ាវ ។ ការយឺតយ៉ាងនេះត្រូវបានពន្យល់ថា ដោយសារតែបញ្ហានោះមានភាពស្មុគស្មាញ មានការយឺតយ៉ាងក្នុងការបកប្រែ ឬក៏ថា អង្គជំនុំជម្រះកំពុងស្វែងរកការឆ្លើយតបពីអង្គការនានា ដែលអាចផ្តល់ព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងបញ្ហាដែលត្រូវចេញសេចក្តីសម្រេច ។[២២០] ទោះបីជា មានបញ្ហាបែបនេះក៏ដោយ បើប្រៀបធៀបនឹងអង្គជំនុំជម្រះសាលាដំបូងនៃតុលាការអន្តរជាតិដទៃទៀត ដូចជាតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលេអូន គេអាចនិយាយបានថា អង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក រៀបចំ និងគ្រប់គ្រងសវនាការជម្រះក្តី **ឌុច** យ៉ាងល្អប្រសើរ និងស្របតាមមាត្រដ្ឋានអន្តរជាតិ ។

នៅក្នុងជំពូកនេះ មានបែងចែកជា ៤ផ្នែក តូចៗ ក) ការគ្រប់គ្រងរបស់តុលាការ ខ) ការគ្រប់គ្រងលើបញ្ហាទូទៅ គ) ការចូលរួមពីសាធារណជន ឃ) វត្តមាន និងសកម្មភាពរបស់ភាគី ។ ផ្នែក"ក" បង្ហាញពីការវិភាគពាក់ព័ន្ធនឹងការចេញសេចក្តីណែនាំ និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដែលរួមមានកាលវិភាគសម្រាប់ជំនុំជម្រះ ព្រមទាំងវិធានការដើម្បីធានាការពន្លឿនសវនាការ ។ ក្នុងផ្នែកនេះក៏មាននិយាយដោយសង្ខេបអំពីកង្វះខាតមួយចំនួន ដែលកើតក្នុងសវនាការរយៈពេល ២២សប្តាហ៍ និងវិធានការដើម្បីកែលម្អ ។ ផ្នែក"ខ" នឹងពិភាក្សាទៅលើវត្តមានចូលរួមរបស់ភាគី និងការគ្រប់គ្រងក្នុងសវនាការ ។ ក្រៅពីនេះ មានលើកឡើងពីបញ្ហាបកប្រែភាសា និងបញ្ហាបច្ចេកទេសផងដែរ ។ ក្នុងផ្នែក"គ" ពាក់ព័ន្ធនឹងវត្តមានសាធារណជន ដែលមិនមែនគ្រប់គ្រងផ្ទាល់ដោយអង្គជំនុំជម្រះទេ ។ ប៉ុន្តែ ចាំបាច់ត្រូវតែលើកបញ្ហានេះមកពិភាក្សា ព្រោះថាសវនាការនេះមិនអាចសម្រេចនូវគោលដៅរបស់ខ្លួន បើគ្មានការយល់ដឹង និងការចូលរួមពីសាធារណជនទេនោះ ។ នៅផ្នែកចុងក្រោយនឹងបង្ហាញពីវត្តមានភាគី ឬមេធាវីរបស់ពួកគេ និងការវាយតម្លៃជាទូទៅចំពោះការបំពេញតួនាទីរបស់ពួកគេក្នុងពេលសវនាការ ។

## ក. ការគ្រប់គ្រងរបស់តុលាការ

### ១. ការគ្រប់គ្រងទូទៅ

នៅពី/បីសប្តាហ៍ដំបូងនៃសវនាការកាត់ទោស **ឌុច** កិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅយ៉ាងយឺតៗ ។ នៅសប្តាហ៍ទី៨ អង្គជំនុំជម្រះបានប្រកាសថា ប្រសិនបើកិច្ចនីតិវិធីប្រព្រឹត្តទៅតាមល្បឿនសព្វថ្ងៃ នោះសំណុំរឿងក្តីលេខ ០០១ នឹងត្រូវបញ្ចប់នៅ ខែធ្នូ ឆ្នាំ២០០៩ ។[២២១] ពេលខ្លះ គេចាំបាច់ត្រូវពន្យាពេល ដើម្បីដោះស្រាយបញ្ហានីតិវិធី និងបញ្ហាបច្ចេកទេស ។ ទោះបីបែបនេះក៏ដោយ ក្រុមឃ្លាំមើលតុលាការយល់ថា ដំណើរការនីតិវិធីមានការយឺតយ៉ាវ ដោយសារសំណួរច្រំដែល សំណួរមិនពាក់ព័ន្ធ និងការធ្វើសេចក្តីថ្លែងការណ៍វែងអន្លាយរបស់ជន

---

[២២០] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ៥, ៤, ២០, និង ២១ ។

[២២១] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ៨ ។

ជាប់ចោទ សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ទៅលើបញ្ហាដែលមិនពាក់ព័ន្ធអង្គហេតុ ។[២២២]

ជាច្រើនសប្ដាហ៍កន្លងផុតទៅ អង្គជំនុំជម្រះបានបង្កើនវិធានការខ្លួន ដើម្បីជំរុញល្បឿនសវនាការនេះ ។ ក្នុងនោះមានដូចជា ការចាប់ផ្ដើមសវនាការយ៉ាងទៀងទាត់ពេលវេលា ចៀសវាងក្នុងការឈប់សម្រាកយូរ ឬការបញ្ឈប់សវនាការមុនម៉ោងកំណត់ ។ ដូចធ្លាប់បានអនុវត្តនៅតុលាការអន្តរជាតិផ្សេងៗជាច្រើន អង្គជំនុំជម្រះនៃ អ.វ.ត.ក បានសម្រេចដកចេញសាក្សីមួយចំនួនពីបញ្ជីឈ្មោះសាក្សី ដោយអានកំណត់ហេតុយកចម្លើយជំនួសវិញ ។[២២៣] ចំពោះសាក្សីដែលអង្គជំនុំជម្រះរក្សាទុក សុទ្ធតែជាអ្នកដែលខ្លួនយល់ថា សក្ខីកម្មរបស់ពួកគេពាក់ព័ន្ធនឹងអង្គហេតុ ។[២២៤] មេធាវីការពារក្ដីអន្តរជាតិលោក François Roux បានកោតសសើរចំពោះវិធានការនេះ ប៉ុន្តែកត់សម្គាល់ថា ការជំនុំជម្រះនៅតែមានភាពយឺតយ៉ាវ បើទោះបីជា ជនជាប់ចោទបានសារភាពពីការទទួលខុសត្រូវរបស់ខ្លួនរួចហើយក្ដី ។[២២៥]

អង្គជំនុំជម្រះ ក៏បានកំណត់នូវវិធានការមួយផ្សេងទៀត ដើម្បីកុំឱ្យភាគីសួរសំណួរដែលមិនពាក់ព័ន្ធ ហើយធ្វើយ៉ាងណាធានាថា សំណួរត្រូវតែស្របនឹងអង្គហេតុដែលលើកមកពិភាក្សា ។ ការអនុវត្តនូវវិធានការនេះ នៅមិនទាន់រលូនពីដំបូងទេ ព្រោះអង្គជំនុំជម្រះមិនបានចេញសេចក្ដីណែនាំឱ្យបានជាក់លាក់ ដែលជាហេតុនាំឱ្យមានការជំទាស់ពីភាគី ។[២២៦] ពេលខ្លះគឺជនជាប់ចោទខ្លួនឯងជាអ្នកកំណត់ថា តើសំណួរនោះច្រំដែលឬទេ ព្រោះអង្គជំនុំជម្រះបានណែនាំកុំឱ្យជនជាប់ចោទឆ្លើយសំណួរណាដែលខ្លួនយល់ថាបានសួររួចហើយ ។[២២៧] បញ្ហានេះត្រូវបានកែលម្អដោយអង្គជំនុំជម្រះ បានព្រមានយ៉ាងម៉ឺងម៉ាត់ទៅភាគីកុំឱ្យលើកឡើងបញ្ហាដដែលៗមកសួរដេញដោល ។ ទោះបីជាបានចាត់វិធានការបែបនេះចំពោះភាគីក៏ដោយ អង្គជំនុំជម្រះខ្លួនឯងមិនបានព្យាយាមអនុវត្តវិធានការនេះ ចំពោះចៅក្រមណាដែលសួរសំណួរច្រំដែល ឬមិនពាក់ពន្ធ័នឹងអង្គហេតុដែរ ។[២២៨]

អង្គជំនុំជម្រះហាក់ដូចជាមានការស្ទាក់ស្ទើរ ក្នុងការបង្អាក់ចម្លើយដែលមិនចំទៅនឹងសំណួរ ។[២២៩] បញ្ហានេះកើតឡើងនៅពេលដែលជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណីឡើងសវនាការ ។ នៅពេលខ្លះសេចក្ដីថ្លែងការណ៍

---

[២២២] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ៤, ៩, ១១, ១៣, ១៤, និង១៩

[២២៣] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ១០, និង ១១

[២២៤] បទសម្ភាសន៍ជាមួយលោកស្រីចៅក្រម Cartwright ។ សូមមើលរបាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ១១ ។

[២២៥] បទសម្ភាសន៍ជាមួយមេធាវីការពារក្ដីលោក Roux

[២២៦] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ៤ និងលេខ ៥ ។

[២២៧] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ៥ និង លេខ ៨ ។

[២២៨] ឧទាហរណ៍ នៅសប្ដាហ៍ទី៨ លោកចៅក្រម **យ៉ា សាខន** បានសួរដេញដោលលម្អិតទៅលើអង្គហេតុនៅជើងឯក ដែលត្រូវបានសួររួចហើយ ហើយចៅក្រម **ធូ មណី** ក៏ធ្វើការដេញដោលច្រំដែលលើអង្គហេតុគុកព្រៃសរ នៅសប្ដាហ៍ទី ១០ ។ សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ៨, ១០ និង ១១ ។

[២២៩] របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ១៩ ។

របស់ពួកគេ ហួសពីប្រធានបទដែលកំពុងជជែកដេញដោល ឬក៏ហួសពីអង្គហេតុដែលមានក្នុងសំណុំរឿង ។[២៣០] ការដោះស្រាយបញ្ហានេះ គឺជាការប្រឈមមួយសម្រាប់អង្គជំនុំជម្រះ ។[២៣១]

មកដល់សប្តាហ៍ទី៩ នៃសវនាការកាត់ទោស **ឌុច** អង្គជំនុំជម្រះបានសម្រេចបែងចែកពេលវេលាឱ្យភាគីសួរសំណួរទៅសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ។[២៣២] វិធានការនេះ ត្រូវបានអនុវត្តយ៉ាងម៉ឺងម៉ាត់ ដោយសំណើសុំពេលវេលាបន្ថែមរបស់ភាគី ត្រូវបានបដិសេធជាញឹកញាប់ ។[២៣៣] ប៉ុន្តែអង្គជំនុំជម្រះក៏អនុញ្ញាតិផងដែរ នៅក្នុងករណីមួយចំនួន[២៣៤] ជាពិសេស ចំពោះក្រុមមេធាវីការពារក្តី ដែលបានជំទាស់ទៅនឹងរយៈពេលដែលអង្គជំនុំជម្រះបានបែងចែកឱ្យខ្លួនចំនួន ៤០នាទី ស្មើនឹងពេលរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ មេធាវីការពារក្តីបានលើកឡើងថា យោងតាមគោលការណ៍ *"សមភាពរវាងការការពារ និងការចោទប្រកាន់"* មេធាវីការពារក្តីគួរតែត្រូវបានផ្តល់ ពេលឱ្យស្មើនឹងរយៈពេលរបស់សហព្រះរាជអាជ្ញា រួមជាមួយនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺ

---

[២៣០] ឧទាហរណ៍ របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ៧ : រៀបរាប់ពីរបៀបដែលជនជាប់ចោទឆ្លើយហួសពីសំណួរដែលសួរមកលើខ្លួន ។ សូមមើល របាយកាណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១២: រៀបរាប់ពីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី **ជិន ម៉េត** ហួសពីសមត្ថកិច្ចរយៈពេលរបស់ អ.វ.ត.ក ។របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហមលេខ១៥ ។

[២៣១] សក្ខីកម្មរបស់ **ឌុច** ពាក់ព័ន្ធនឹងអត្តចរិករបស់ខ្លួនត្រូវបានផ្អាកដោយសារកាលវិភាគតម្រូវឱ្យសាក្សីជំនាញពីររូបផ្តល់សក្ខីកម្មពេលនោះ ។ លើសពីនេះ សេចក្តីថ្លែងរបស់ដើមបណ្តឹងរដ្ឋប្បវេណី **ជុំ នៅ** ក៏ត្រូវបានផ្អាក ដោយសារកាលវិភាគត្រូវធ្វើសក្ខីកម្មតាមរយៈប្រព័ន្ធ video-conference ពីសំណាក់សាក្សីនៅក្រៅប្រទេស។ សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ២០ និង ២១

[២៣២] នៅពេលសួរដេញដោលសាក្សី សហព្រះរាជអាជ្ញាមានរយៈពេល ៣០នាទី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេល ៤០នាទី និងមេធាវីការពារក្តីមានរយៈ ពេល ៤០នាទី ។ ចំពោះការដាក់ឯកសារ ភាគីមានរយៈពេល ៥នាទី សម្រាប់ការសួរសំណួរ និងការជំទាស់ព្រមទាំង ៥នាទី សម្រាប់ការឆ្លើយតប ។ អង្គជំនុំជម្រះ ក៏បានណែនាំដល់ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឱ្យជ្រើសរើសមេធាវីតំណាងជាតិម្នាក់ និងអន្តរជាតិម្នាក់ សម្រាប់សួរដេញដោល ។ សម្រាប់ការសួរដេញដោលជនជាប់ចោទ សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីទទួលបានរយៈពេល ៣ម៉ោង និងមេធាវីការពារក្តីទទួលបាន ៤ម៉ោង ។

[២៣៣] គួឱ្យឆ្ងល់ដែរ ភាគច្រើនអង្គជំនុំជម្រះ បានបដិសេធការស្នើរសុំពេលវេលាបន្ថែមរបស់មេធាវីដើមតំណាងបណ្តឹងរដ្ឋប្បវេណី ដូចជាសំណើរបស់លោកស្រីមេធាវី Silke Studzinsky និងលោកស្រីមេធាវី Matine Jacquin នៅថ្ងៃទី២៩ ខែមិថុនា និងថ្ងៃទី១ ខែកក្កដា ត្រូវបានបដិសេធ។ សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ១១ ។

[២៣៤] ឧទាហរណ៍សំណើរបស់កញ្ញាមេធាវី **ទី ស្រ៊ីណា** សុំបន្ថែមពេលវេលាសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី **ជុំ ម៉ី** ត្រូវបានអង្គជំនុំជម្រះអនុញ្ញាត ។ សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ១១ ។ នៅពេលសួរដេញដោលសាក្សី **សេក ឌន** អង្គជំនុំជម្រះក៏បន្ថែមពេល ១០នាទី ឱ្យមេធាវីការពារក្តី ផងដែរ ។ សូមមើលរបាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៦។ កំឡុងពេលសួរដេញដោលសាក្សីជំនាញលោក David Chandler សហព្រះរាជអាជ្ញាស្នើសុំពេលបន្ថែម១៥នាទី ដើម្បីបញ្ចប់សំណួររបស់ខ្លួនក៏ត្រូវបានអនុញ្ញាតផងដែរ ។ ហើយក៏អនុញ្ញាតផ្តល់រយៈពេលដូចគ្នានេះតាមសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ១៦ ។

៧០នាទី ។ អង្គជំនុំជម្រះបានទទួលស្គាល់ការលើកឡើងរបស់មេធាវីការពារក្តី ប៉ុន្តែមិនបានយល់ស្របចំពោះការស្នើសុំនេះទេ ដោយថា ខ្លួននឹងផ្តល់ពេលបន្ថែមឱ្យមេធាវីការពារក្តី **ឌុច** ទៅតាមស្ថានភាពជាក់ស្តែង ។[២៣៥]

## ២. សេចក្តីសម្រេចដែលពុំមានអំណះអំណាងច្បាស់លាស់ និងការពន្យាពេលសម្រេចសេចក្តី

ទោះបីជា មានករណីលើកលែងច្រើនជាងការចេញសេចក្តីសម្រេច អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចជាច្រើនលើក ដោយមិនបានពន្យល់ពីមូលហេតុនៃការសម្រេចនោះទេ ។ ករណីនេះកើតមានជាពិសេស នៅពេលអង្គជំនុំជម្រះព្យាយាមធ្វើយ៉ាងណាឱ្យភាគីគោរពតាមរយៈពេលដែលបានកំណត់ក្នុងការសួរសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ។ ការសម្រេចបែបនេះធ្វើឱ្យអង្គជំនុំជម្រះ អាចត្រូវបានរិះគន់ដោយហេតុថា សេចក្តីសម្រេចទាំងនោះមិនស្របគ្នា និងគ្មានមូលដ្ឋានច្បាស់លាស់ ។[២៣៦] ដើម្បីធ្វើជាគំរូសម្រាប់តុលាការជាតិ គេចាំបាច់ត្រូវតែប្រឹងប្រែងដើម្បីចៀសវាងកាធ្វើសេចក្តីសម្រេច ឬសេចក្តីណែនាំណាដែលមិនមានមូលដ្ឋាន និងហេតុផលច្បាស់លាស់ ។

ទោះបីជាអង្គជំនុំជម្រះ បានចេញសេចក្តីសម្រេចដោយគ្មានមូលដ្ឋានច្បាស់លាស់ក៏ដោយ ក៏សេចក្តីសម្រេចអំពីបញ្ហាសំខាន់ៗមួយចំនួន ហាក់ដូចជាមានការយឺតយ៉ាវ ។ យោងតាមការសន្និដ្ឋានផ្ទាល់របស់ក្រុមឃ្លាំមើលតុលាការអង្គជំនុំជម្រះ បានចំណាយរយៈពេលជាមធ្យម ៥៦ថ្ងៃ ដើម្បីឆ្លើយតបទៅនឹងការដាក់ឯកសារពីភាគី ។[២៣៧] នៅពេលដែលភាគីចោទសួរ អំពីបញ្ហាយឺតយ៉ាវនេះ អង្គជំនុំជម្រះតែងតែលើកហេតុផលពីភាពស្មុគស្មាញនៃ

---

[២៣៥] សូមមើលរបាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម លេខ ១៥ ។ អង្គជំនុំជម្រះកត់សម្គាល់ថា ទៅតាមភាពជាក់ស្តែង មេធាវីការពារក្តី មិនដែលស្នើសុំបន្ថែមពេលនោះទេ ហើយក៏មិនដែលលើកឡើងបញ្ហាការសន្និដ្ឋានពីសក្ខីកម្មរបស់សាក្សីដែរ ។ ដោយយោង លើបញ្ហានេះ អង្គជំនុំជម្រះសម្រេចរក្សាទុកពេលដែលចែកឱ្យភាគីនៅដដែល ប៉ុន្តែបានអះអាងថា មេធាវីការពារក្តីមានមានសិទ្ធិ "ក្នុងការស្នើសុំពេលសួរដេញដោលបន្ថែម សម្រាប់សួរសំណួរសំខាន់ៗ " ទៅតាមករណីនីមួយៗ" ។

[២៣៦] ឧទាហរណ៍ នៅសប្តាហ៍ទី៣ អង្គជំនុំជម្រះបានកំណត់ពេលសួរដេញដោលដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ផ្តល់ឱ្យតែ ៣០នាទី ដោយមិនផ្តល់មូលហេតុ ពីការសម្រេចបែបនោះ ។ ចាប់ពីសប្តាហ៍ទី៤ ពុំមានការពន្យល់ជាសាធារណៈ ថាហេតុអ្វីបានជាគេឈប់ប្រើរហស្សនាម សម្ងាត់សម្រាប់សាក្សី ។ នៅសប្តាហ៍ទី១១ អង្គជំនុំជម្រះបានអនុញ្ញាតចំពោះសំណើសុំពេលបន្ថែមរបស់មេធាវីតំណាងដើមបណ្តឹង រដ្ឋប្បវេណីជាតិក្រុមទី១ កញ្ញា **ទី ស្រីណា** ដើម្បីតាំងសំណួរទៅលោក **ជុំ ម៉ី** ដោះពុំបានពន្យល់ហេតុផលនៃការសម្រេចបែបនេះ រីឯ សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិក្រុម ២ ត្រូវបានបដិសេធហើយក៏មិនមានពន្យល់ពីហេតុផលដែរ ។ នៅ សប្តាហ៍ទី១៤ សហព្រះរាជអាជ្ញារងអន្តរជាតិលោក William Smith បានសុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីសួរបញ្ជាក់ពីជំលោះរវាង ជនជាប់ចោទ និង **ហ៊ីរ** នៅពេល **ឌុច** ធ្វើការឆ្លើយតបទៅនឹងសក្ខីកម្មរបស់ **ហ៊ឹម ហុយ** ។ អង្គជំនុំជម្រះក៏បានបដិសេធសំណើនេះ ដោយ គ្មានការពន្យល់ពីមូលហេតុ ។ បញ្ហាសំខាន់ដែលត្រូវបានសម្រេច ដោយមិនពន្យល់ហេតុផលសមហេតុផលឱ្យទាន់ពេលវេលានោះការសម្រេចមិនអនុញ្ញាតឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សួរដេញដោលអំពីសាក្សីអំពីអត្តចរិកជនជាប់ចោទ ។ សេចក្តីសម្រេចនេះត្រូវបានប្រកាសឱ្យដឹង នៅថ្ងៃទី ២០ ខែសីហា ឆ្នាំ២០០៩ និង សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរថ្ងៃទី ៩ ខែតុលា ឆ្នាំ២០០៩ ។ សូម មើល របាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ៣, ៤, ១០, ១១, ១៣, ១៩, និង ២០ ។

[២៣៧] ការគណនានេះផ្អែកលើរយៈពេលរវាងការដាក់សំណើពីដំបូង និងការចេញសម្រេច ក្រៅពីនេះ រួមបញ្ចូលទាំងពេលវេលាសម្រាប់ភាគីឆ្លើយតប ។ រយៈពេលខ្លីបំផុត ដែលអង្គជំនុំជម្រះបានឆ្លើយទៅតាមការដាក់សំណើរបស់ភាគី គឺរយៈពេល ៤ថ្ងៃ ។ (សូមមើលសេចក្តី សម្រេចរបស់អង្គជំនុំជម្រះក្នុងសំណុំរឿងក្តីលេខ ០០១ ស្តីពី "សំណើសុំពិចារណាឡើងវិញ លើសេចក្តីសម្រេចអំពីកស្តុតាង

បញ្ហាដែលត្រូវសម្រេច[២៣៨] កង្វះព័ត៌មាន[២៣៩] និងការចំណាយពេលបកប្រែភាសានៃសេចក្ដីសម្រេចទាំងនោះ[២៤០] ។ ទោះបីជាយ៉ាងណា គេអាចមើលឃើញថា ភាគីមិនសប្បាយចិត្តនឹងការពន្យាពេលនេះទេ ជាពិសេស ចំពោះសេចក្ដីសម្រេចលើបញ្ហាសំខាន់ៗ ។

### ៣. ឥរិយាបថនៅក្នុងបន្ទប់សវនាការ

ជាទូទៅ ទាំងអង្គជំនុំជម្រះ និងភាគី តែងប្រកាន់ភ្ជាប់នូវវិជ្ជាជីវៈខ្លួនក្នុងពេលសវនាការ ។ ប៉ុន្តែ ក្រុមឃ្លាំមើលតុលាការ កត់សម្គាល់ឃើញថា មានភាគី ឬចៅក្រមងោកងុយម្ដងម្កាលកំឡុងពេលសវនាការ ។[២៤១] បន្ថែមលើនេះទៀត នៅពេលភាគីធ្វើការតវ៉ា ឬលើកអំណះអំណាង ឬសួរដេញដោលសវនាការ ហាក់ដូចពុំមានរបៀបរៀបរយ ដោយភាគីមិនបានគោរពតាមការណែនាំរបស់អង្គជំនុំជម្រះ ។[២៤២] ដើម្បីគ្រប់គ្រងបញ្ហានេះ ប្រធានអង្គជំនុំជម្រះ បានដាស់តឿនដោយពាក្យសំដីធ្ងន់ៗជាច្រើនលើក ។

---

បញ្ជាក់ពី អត្តសញ្ញាណរបស់ដើមបណ្ដឹងរដ្ឋប្បវេណី E2/36 "ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩) ។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់ សំណើនេះកាលពីថ្ងៃទី ៦ ខែសីហា ឆ្នាំ២០០៩ ។ រយៈពេលយូបំផុត គឺ ១២៨ថ្ងៃ (សូមមើលសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះក្នុងសំណុំរឿងក្ដីលេខ ០០១ ស្ដីពី "ឯកសារភាពយន្តវៀតណាមស្ដីពីសាក្សី CP3/3/2 និង CP3/3/3 ដែលចងក្រងដោយការិយាល័យ សហព្រះរាជអាជ្ញា " នៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០០៩ ។ មេធាវីការពារក្ដីបានដាក់សំណើជាច្រើននៅថ្ងៃទី ២៤ ខែមិនា ឆ្នាំ២០០៩ ។

[២៣៨] នៅសប្ដាហ៍ទី៥ ប្រធានអង្គជំនុំជម្រះបានពន្យល់ថា ចំពោះកង្វះនៃការណែនាំឱ្យបានច្បាស់លាស់ស្ដីពី ភាពទទួលយកបាននៃឯកសារមួយចំនួនក្នុងសំណុំរឿងដែលគេមិនបានពិនិត្យនោះ គឺបណ្ដាលមកពីភាពស្មុគស្មាញនៃឯកសារទាំងនោះ ។ សូមមើលរបាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ៥ ។

[២៣៩] បញ្ហានេះ ត្រូវបានគេលើឡើងធ្វើជាមូលហេតុនៃការយឺតយាវ ក្នុងការចេញសេចក្ដីសម្រេចស្ដីពី ការឃុំបណ្ដោះអាសន្នរបស់ជនជាប់ចោទ ។ អង្គជំនុំជម្រះបានលើកហេតុផលថា តុលាការយោធាមិនបានផ្ដល់ឯកសារដែលខ្លួនត្រូវការ ។ សូមមើលរបាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហមសប្ដាហ៍ទី ៤ ។

[២៤០] ជាពិសេស បញ្ហានេះត្រូវបានគេដកស្រង់ដោយយោងទៅលើ សេចក្ដីសម្រេចអំពី "សំណើរួមរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់សេចក្ដីសម្រេច អំពីតួនាទីរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងកាធ្វើសំណើអំពីការដាក់ទោស និង អំពីសេចក្ដីណែនាំសម្រាប់ការតាំងសំណួរទៅជនជាប់ចោទ សាក្សី និងអ្នកជំនាញ អំពីអត្តចរិករបស់ជនជាប់ចោទ" ដែលបានចេញនៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ បន្ទាប់ពីរយៈពេល ៤ខែ ដែលមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់សំណើនេះ។ សូមមើលរបាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ២០ និង ២១ ។

[២៤១] សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ៣, ៩, និង២១ ។

[២៤២] នៅសប្ដាហ៍ទី៤ លោកស្រីមេធាវី Studzinsky ទំនងជាមិនអើពើនឹងការណែនាំរបស់អង្គជំនុំជម្រះក្នុងការយកឯកសារណាមួយ មកធ្វើជាមូលដ្ឋាននៃការសួរដេញដោល ហើយដូចគ្នានេះដែរ នៅសប្ដាហ៍ទី១០ លោកស្រី មិនយកចិត្តទុកដាក់នឹងការដាស់តឿនរបស់អង្គជំនុំជម្រះដែលមិនឱ្យសួរសំណួរមិនពាក់ព័ន្ធ ។ នៅសប្ដាហ៍ទី១៦ អង្គជំនុំជម្រះបានព្រមានភាគីនៅពេលដែលពួកគេក្រោកឈរឡើងឆ្លើយតបទៅភាគីផ្សេងទៀតដោយគ្មានការស្នើសុំជាមុនពីអង្គជំនុំជម្រះជាមុន ។ សូមមើលរបាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ៤, ៩, និង ១៦ ។

អង្គជំនុំជម្រះណែនាំឱ្យ ជនជាប់ចោទមានអកប្បកិរិយាល្អត្រឹមត្រូវនៅក្នុងសវនាការ ។ ប៉ុន្តែ ពេលខ្លះជនជាប់ចោទថ្លែងដោយផ្ទាល់ទៅកាន់សាក្សី នៅពេលឆ្លើយតបទៅនឹងសក្ខីកម្មរបស់សាក្សី ។ ដោយយល់ឃើញឥរិយាបទបែបនេះមិនសមរម្យ ហើយអាចធ្វើឱ្យសាក្សីមានការភិតភ័យ អង្គជំនុំជម្រះបានធ្វើការណែនាំភ្លាមៗឱ្យជនជាប់ចោទធ្វើការឆ្លើយតបទៅនឹងសក្ខីកម្មរបស់សាក្សី ដោយលើកទៅចំពោះមុខអង្គជំនុំជម្រះវិញ ។[២៤៣] នៅពេលដែលដាស់តឿនជនជាប់ចោទកុំឱ្យប្រើអាកប្បកិរិយាមិនសមរម្យចំពោះសាក្សីជំនាញ និងមេធាវី[២៤៤] អង្គជំនុំជម្រះក៏មានការប្រយ័ត្នប្រយែងក្នុងការការពារសេចក្តីថ្លៃថ្នូរបស់ជនជាប់ចោទផងដែរ ។[២៤៥]

## ខ. ការគ្រប់គ្រងលើបញ្ហានានា

### ១. ការរៀបចំកន្លែងអង្គុយនៅក្នុងបន្ទប់សវនាការ

បើទោះបីជា បន្ទប់សវនាការមានទំហំធំល្មមក៏ដោយ ក៏ការចូលរួមជាច្រើនពីភាគីក្នុងសវនាការកាត់ក្តី **ឌុច** ធ្វើឱ្យការរៀបចំកន្លែងអង្គុយមានការលំបាក ។[២៤៦] ជាក់ស្តែង នៅសប្តាហ៍ទី១៣ ទាំងមេធាវីការពារក្តី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ បានជំទាស់នឹងការរៀបចំកន្លែងអង្គុយសម្រាប់មេធាវីប្រឹក្សាយោបល់សាក្សីដែលគេបានរៀបចំឱ្យអង្គុយនៅខាងផ្នែកមេធាវីការពារក្តី ។ ពួកគេបានលើកឡើងថា ការធ្វើបែបនេះអាចប៉ះពាល់ដល់អារម្មណ៍របស់សាក្សី ដែលឡើងមកធ្វើសក្ខីកម្ម ព្រោះថាការដែលឱ្យមេធាវីប្រឹក្សាយោបល់សាក្សីអង្គុយនៅខាងមេធាវីការពារក្តី គេអាចវិនិច្ឆ័យជាមុនថា សាក្សីនោះគាំទ្រខាងជនជាប់ចោទ ។ អង្គជំនុំជម្រះ បានពន្យល់ពីការសម្រេចរបស់ខ្លួនចំពោះបញ្ហានេះថា ខ្លួនត្រូវតែសម្រេចបែបនេះ ដោយសារតែបន្ទប់សវនាការមានទំហំតូច ចំណែកកន្លែងអង្គុយរបស់មេធាវីប្រឹក្សាយោបល់សាក្សី គឺមានទីតាំងខុសពីកន្លែងរបស់មេធាវីការពារក្តី ។[២៤៧]

ក្រៅពីការរៀបចំកៅអីអង្គុយដល់ភាគី អង្គជំនុំជម្រះបានខិតខំប្រឹងប្រែងក្នុងការធានាថា គ្រប់ភាគី និងបុគ្គលពាក់ព័ន្ធ មានកន្លែងសមរម្យនៅក្នុងបន្ទប់សវនាការ ។[២៤៨] ជាក់ស្តែង កន្លែងអង្គុយសម្រាប់បុគ្គលិកជំនួយផ្លូវចិត្ត ត្រូវបានរៀបចំបន្ថែមឱ្យអង្គុយក្បែរដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីជួយសម្របសម្រួល និងផ្តល់ប្រឹក្សាយោបល់ផ្នែកផ្លូវចិត្តដល់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ។[២៤៩] ម្យ៉ាងទៀត ការផ្តល់ឱកាសឱ្យដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនចូលរួមស្តាប់នៅក្នុងសវនាការ ហាក់មិនមានកន្លែងអង្គុយគ្រប់គ្រាន់សម្រាប់ពួកគេទាំងអស់ទេ ។

---

[២៤៣] សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៤ និង ១៧ ។

[២៤៤] នៅសប្តាហ៍ទី៩ ជនជាប់ចោទបានហៅសាក្សីជំនាញ Etcheson ថា "ជាអ្នកនិពន្ធឆ្កួតលីលា" ហើយបានឆ្លើយតបទៅនឹងសំនួររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិក្រុម២ ដោយចំអក ។ សូមមើលរបាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហមលេខ៩ ។

[២៤៥] ជាក់ស្តែងអង្គជំនុំជម្រះ បានរំលឹកដល់ដើមបណ្តឹងរដ្ឋប្បវេណី **ជុំ ម៉ី** កុំឱ្យមានការនិយាយគម្រាមទៅកាន់ជនជាប់ចោទ ។ សូមមើលរបាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១១ ។

[២៤៦] បទសម្ភាសន៍ជាមួយលោកស្រីចៅក្រម Cartwright ។

[២៤៧] សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១៣ ។

[២៤៨] បទសម្ភាសន៍ជាមួយលោកស្រីចៅក្រម Cartwright ។

[២៤៩] បទសម្ភាសន៍ជាមួយលោកស្រីបណ្ឌិត Jarvis ។

មានកន្លែង អង្គុយតែ ១០កៅអី ប៉ុណ្ណោះ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ៩០នាក់ ។[២៥០] ការរៀបចំកន្លែងអង្គុយក្នុងបន្ទប់សវនាការអាចជាបញ្ហាប្រឈមក្នុងសំណុំរឿងក្តីលេខ ០០២ ដែលមានជនជាប់ចោទរហូតដល់ទៅ៤រូប និងដើមបណ្តឹងរដ្ឋប្បវេណីប្រហែលជាជាង ១០០០នាក់ ។ ដូចនេះហើយគេអាចរំពឹងទុកជាមុនបានថា នឹងមិនមានដើមបណ្តឹងរដ្ឋប្បវេណីដែលអាចចូលរួមស្តាប់ក្នុងបន្ទប់សវនាការទេ ។ វិធានការច្បាស់លាស់ក្នុងការរៀបចំ បញ្ហានេះ នៅមិនទាន់ត្រូវបានកំណត់នៅឡើយ ។ នៅក្នុងបទសម្ភាសន៍លោកស្រីចៅក្រម Cartwright បានលើក ឡើងថា អង្គជំនុំជម្រះទទួលស្គាល់ពីបញ្ហានេះ ហើយនឹងដោះស្រាយនៅពេលដែលសំណុំរឿងក្តីលេខ ០០២ មកដល់ដំណាក់ កាលសវនាការពេលណានោះ ។[២៥១]

## ២. បញ្ហាបកប្រែភាសា

ក្នុងសវនាការដែលប្រើភាសាផ្លូវការច្រើន ចាំបាច់ត្រូវធានាឱ្យការបកប្រែមានគុណភាពល្អ ទាំងការបកប្រែផ្ទាល់មាត់ និងការបកប្រែឯកសារ ។ ចំពោះការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌអន្តរជាតិ បញ្ហានេះកាន់តែមានសារៈសំខាន់ ដោយសារតែរឿងក្តីនោះជាទូទៅមានទំហំធំ ហើយជនជាប់ចោទក៏ត្រូវប្រឈមមុខនឹងការចោទប្រកាន់ពីបទល្មើសជាច្រើន ។ កំហុសនៃការបកប្រែឯកសារតុលាការ ធ្វើឱ្យជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរទៅលើការថ្លឹងថ្លែង និងការវាយតម្លៃភស្តុតាងទាំងនោះ ដែលអាចនាំឱ្យប៉ះពាល់ទៅលើគោលការណ៍ *"សន្មត់ទុកជាមុនថាគ្មានទោស"* ។ ម្យ៉ាងវិញទៀត ភាពមិនត្រឹមត្រូវនៃការបកប្រែផ្ទាល់មាត់ លើសក្ខីកម្ម និងអំណះអំណាងដែលភាគីលើកឡើងក្នុងសវនាការ នាំឱ្យមានការយឺតយ៉ាវដល់ដំណើរការនីតិវិធីជំនុំជម្រះ ហើយអាចនឹងប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ។

បញ្ហានៃបកប្រែផ្ទាល់មាត់ និងការបកប្រែឯកសារ គឺជាកង្វល់មួយនៅក្នុងសវនាការជំនុំជម្រះក្តី **ឌុច** ។ ស្ថិតក្រោមវិធានផ្ទៃក្នុង ភាសាជាផ្លូវការនៅក្នុងសវនាការជំនុំជម្រះក្តី **ឌុច** មានបីភាសា គឺ ភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ។[២៥២] គេអាចមើលឃើញថា មានការលំបាកក្នុងការធានាឱ្យមានប្រសិទ្ធិភាព និងភាពត្រឹមត្រូវ ក្នុងកម្រិតខ្ពស់នៃការបកប្រែផ្ទាល់មាត់ និងការបកប្រែឯកសារ ។ នៅពេលខ្លះ កិច្ចដំណើរនីតិវិធី ហាក់មានការបកប្រែត្រឹមត្រូវតិចតួចបំផុត ។

ភាពមិនត្រឹមត្រូវនៃការបកប្រែឯកសារបណ្តាលឱ្យមានមន្ទិលសង្ស័យ ថាតើឯកសារទាំងនោះគួរតែយកមកប្រើជាភស្តុតាងឬទេ ។[២៥៣] នៅសប្តាហ៍ទី១០ អង្គជំនុំជម្រះបានសម្រេចថា ចំពោះបញ្ហាការទទួលយក

---

[២៥០] កន្លែងអង្គុយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបន្ទប់សវនាការមានតែ ១០កៅអី ប៉ុណ្ណោះ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីសរុបមានរហូតដល់ ៩០នាក់ នៅក្នុងសំណុំរឿងក្តីលេខ ០០១ ។ បទសម្ភាសន៍ជាមួយដើមបណ្តឹងរដ្ឋប្បវេណី **ជុំ ម៉ី** ។

[២៥១] បទសម្ភាសន៍ជាមួយលោកស្រីចៅក្រម Cartwright ។

[២៥២] ច្បាប់បង្កើតអ.វ.ត.ក មាត្រា៤៥ ចែងថា ភាសាផ្លូវការរបស់ អ.វ.ត.ក គឺភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ។

[២៥៣] មេធាវីការពារក្តីអន្តរជាតិលោក François Roux បានជំទាស់ទៅនឹងកំណត់ហេតុសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយលើកហេតុផលថា ការបកប្រែជាភាសាខ្មែរ និងបារាំងមានភាពផ្ទុយគ្នា នាំឱ្យគេសង្ស័យថា តើឯកសារនោះគឺជាឯកសារតែមួយឬទេ ។

ភស្តុតាងជាឯកសារ ភស្តុតាងដែលមានការបកប្រែមិនត្រឹមត្រូវ ត្រូវដោះស្រាយ *"មួយករណីម្តងៗ"* ។ ប៉ុន្តែដោយសារឯកសារជាច្រើន ជាឯកសារដាក់បន្ទុកលើជនជាប់ចោទ ការពិនិត្យមើលពីភាពត្រឹមត្រូវនៃការបកប្រែឯកសារទាំងនោះ ត្រូវធ្លាក់ទៅលើជនជាប់ចោទ ។[២៥៤] អង្គជំនុំជម្រះក៏បានស្នើឱ្យភាគីជួយកែតម្រូវកំហុសនៃការបកប្រែផ្ទាល់មាត់ និងឯកសារ កំឡុងពេលនីតិវិធីសវនាការ ។ វិធានការនេះមានប្រសិទ្ធិភាពក្នុងកម្រិតមួយ ប៉ុន្តែពេលខ្លះក្រុមឃ្លាំមើលតុលាការ បានកត់សម្គាល់ថា ការធ្វើបែបនេះត្រូវចំណាយពេលច្រើន ហើយនាំឱ្យកិច្ចនីតិវិធីកាន់តែអូសបន្លាយថែមទៀត ។[២៥៥] បន្ថែមលើនេះ គេក៏បារម្ភផងដែរពីកម្រិតដែលចៅក្រម និងភាគីអាចយល់នូវអ្វីត្រូវបានលើកឡើងនៅក្នុងសវនាការ ។ នៅពេលខ្លះ អង្គជំនុំជម្រះ សហព្រះរាជអាជ្ញា មេធាវីការពារក្តី និង មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនយល់នូវការបកប្រែក្នុងសវនាការ[២៥៦] ដែលនាំឱ្យមានការឆ្លើយតបមិនចំបញ្ហាក្នុងកំឡុងសួរដេញដោល និងសក្ខីកម្មរបស់សាក្សី ។[២៥៧]

បញ្ហាផ្សេងទៀតពាក់ព័ន្ធនឹងការបកប្រែ គឺមិនមានការបកប្រែ ដោយផ្ទាល់ពីភាសាខ្មែរទៅភាសាបារាំង និងពីភាសាបារាំងទៅភាសាខ្មែរទេ ។ ដូចនេះ រាល់ព័ត៌មានជាភាសាខ្មែរទាំងអស់ក្នុងសវនាការ ត្រូវបកទៅជាភាសាអង់គ្លេស បន្ទាប់បកប្រែទៅជាភាសាបារាំង ផ្ទុយទៅវិញ បើជាភាសាបារាំងក៏ត្រូវបកប្រែដូចគ្នានេះដែរ ទៅជាភាសាអង់គ្លេស រួចបន្តទៅជាភាសារខ្មែរ ។ ប្រព័ន្ធនៃការបកប្រែបែបនេះ ប្រឈមមុខនឹងការយល់ច្រលំជាច្រើន អំពីសក្ខីកម្មជាភាសាខ្មែរ និងភាសាបារាំង ដោយសារតែភាពខុសប្លែកគ្នានៃការប្រើប្រាស់ភាសាទាំងពីរ ។ អង្គភាពបកប្រែភាសារបស់តុលាការ បានឱ្យដឹងថា ដំបូងឡើយអង្គភាពនេះបានព្យាយាមរៀបចំឱ្យមានការបកប្រែជាភាសាដោយផ្ទាល់ពីភាសាខ្មែរទៅភាសាបារាំង និងពីភាសាបារាំងទៅភាសាខ្មែរ ប៉ុន្តែ គុណភាពនៃការបកប្រែមិនអាចទទួលយកបាន ។[២៥៨] អាស្រ័យហេតុនេះ ទើបប្រព័ន្ធបកប្រែភាសាបែបនេះ ត្រូវបានយកមកប្រើប្រាស់ ហើយអង្គភាពនេះក៏បានបញ្ជាក់ផងដែរថា ប្រពន្ធ័បែបនេះត្រូវបានប្រើជាទូទៅនៅក្នុងកម្រិតអន្តរជាតិ ដូចជានៅសាលាជម្រះក្តីអន្តរជាតិជាដើម ។[២៥៩]

---

មេធាវី Roux បានលើកឡើងថា ឯកសារនេះ មិនសមស្របយកមកប្រើប្រាស់ក្នុងសវនាការនោះទេ ។ សូមមើលរបាយការណ៍ អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ៤ ។

[២៥៤] សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១០ ។

[២៥៥] សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ៥ ។

[២៥៦] សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហមលេខ ៣ ។

[២៥៧] សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ៤ ។ ក្រុមឃ្លាំមើលកម្ពុជា បានកត់សម្គាល់ថា ភាពមិនស្របគ្នានៅក្នុងការបកប្រែពីភាសាអង់គ្លេស ឬបារាំងទៅជាភាសាខ្មែរដែលផ្នែកខ្លះពិបាកយល់និងមិនត្រឹមត្រូវ ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤ បានលើកឡើងនូវបញ្ហានេះថា គាត់មិនអាចយល់នូវការអះអាងលើកឡើងរបស់ភាគីដទៃទៀត ។ សូមមើលរបាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ៧ ។

[២៥៨] អ៊ីម៉ែលឆ្លើយឆ្លងកាលពីថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០០៩ ជាមួយអង្គភាពបកប្រែ ។

[២៥៩] អ៊ីម៉ែលឆ្លើយឆ្លងកាលពីថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០០៩ ជាមួយអង្គភាពផ្នែកបកប្រែ "យើងបានបញ្ជាក់ពីបញ្ហានេះ ។ ប្រព័ន្ធនៃការបកប្រែបែបនេះ ត្រូវបានប្រើនៅ តុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (សម្រាប់ភាសាដែលប្រើនៅអតីតប្រទេស

ភាគីបានលើកបញ្ហាបកប្រែភាសា និងស្នើសុំឱ្យអង្គជំនុំជម្រះ បញ្ជូនទៅអង្គភាពបកប្រែភាសារបស់តុលាការដោះស្រាយបញ្ហានេះ ។[២៦០] ក្រៅពីសំណើទាំងនេះ អង្គជំនុំជម្រះក៏បានយកចិត្តទុកដាក់បន្ថែមទៀត ដោយណែនាំដល់ភាគី និងសាក្សី ឱ្យនិយាយយឺតៗ ខ្លីៗ និងច្បាស់ៗ ដើម្បីធានាពីភាពត្រឹមត្រូវនៃការបកប្រែ ។ នៅសប្តាហ៍ទី ១២ អង្គជំនុំជម្រះបានចាត់វិធានការផ្នែកបច្ចេកទេស ដើម្បីគ្រប់គ្រងល្បឿននៃការផ្តល់សក្ខីកម្ម និងសេចក្តីថ្លែងរបស់ភាគី និងសាក្សី តាមរយៈការបើកមីក្រូហ្វូនឱ្យភាគីអាចនិយាយបាន តែនៅពេលដែលចប់ការបកប្រែប៉ុណ្ណោះ ។[២៦១] ប៉ុន្តែបញ្ហាការបកប្រែដោយផ្ទាល់មាត់ ក្នុងសវនាការនៅតែមាន ទោះបីជាមិនមានច្រើនដូចកាលពីដំបូងក៏ដោយ ។[២៦២] អង្គភាពបកប្រែភាសារបស់តុលាការបានទទួលស្គាល់ថា ការកែលម្អការបកប្រែភាសាឱ្យប្រសើរឡើង គឺជាការងារដែលត្រូវធ្វើជាដំណាក់កាល ហើយបានឱ្យដឹងដែរថា អង្គភាពនេះ មានផែនការបញ្ជូនអ្នកបកប្រែឱ្យទៅរៀនវគ្គបំប៉នកម្រិតមូលដ្ឋាន និងកម្រិតមធ្យមរយៈពេល ៦ខែ សម្រាប់ការងារនៅឆ្នាំ ២០១០-២០១១ ។[២៦៣]

### ៣. បញ្ហាបច្ចេកទេស

មានបញ្ហាបច្ចេកទេសខ្លះទាក់ទងនឹងប្រព័ន្ធសម្លេង និងរូបភាពនៅក្នុងសវនាការ ដែលបណ្តាលឱ្យរំខានដល់កិច្ចដំណើរការនីតិវិធីទាំងមូល ។[២៦៤] ចំណែកឯប្រដាប់ស្តាប់ការបកប្រែភាសាខូចជាញឹកញាប់ ធ្វើឱ្យអ្នកទស្សនាត្រូវផ្លាស់ប្តូរប្រដាប់ស្តាប់កំឡុងពេលសវនាការ ។[២៦៥] ចំពោះការផ្តល់សក្ខីកម្មពីចំងាយ (video-conference) ក៏មានបញ្ហារអាក់រអួលផងដែរ ។[២៦៦] ប៉ុន្តែបញ្ហាទាំងនោះត្រូវបានដោះស្រាយជាបន្ទាន់ ដែលនេះជាកិច្ចខិតខំប្រឹងប្រែង ដ៏គួរឱ្យកោតសរសើររបស់អង្គភាពផ្នែកសម្លេង និងរូបភាព (Audio-Visual Unit) ។

---

យូហ្គោស្លាវី) ។ តុលាការអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដា (*Kinyarwanda*) និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ICC (*Kiswahili and Lingala*) ។ ប្រព័ន្ធនេះ ក៏ប្រើនៅសហរដ្ឋអាមេរិកសម្រាប់ជនជាតិចិន និងអារ៉ាប់ ហើយនៅ គណៈកម្មាធិការសហព័ន្ធអឺរ៉ុប គេក៏ប្រើ សម្រាប់ "ភាសាផ្សេងក្រៅពីភាសាផ្លូវការ" ដូចជា ភាសាហ្វាំងឡង់ ភាសាអេស្តូនី ភាសាហុងហ្គារី និងកន្លែងផ្សេងទៀត ដែលប្រើភាសា ទាំងនោះ ត្រូវគេប្រើច្រើន ដូចជាអង្គប្រជុំមួយជាដើម ។"

[២៦០] មេធាវីការពារក្តីអន្តរជាតិលោក François Roux បានលើកអំពីបញ្ហានៃការបកប្រែ ហើយបានទទួលការគាំទ្រពីភាគី ។ សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ៤ ។

[២៦១] សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១២ ។

[២៦២] ដូចដែលមានរៀបរាប់នៅក្នុងរបាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ២ រហូត លេខ ២១ អំពីបញ្ហាពាក់ព័ន្ធនឹងការបកប្រែ ហើយនៅរបាយការណ៍ លេខ ២០ និង ២១ ការរៀបរាប់របស់សាក្សី មានការលំបាកពិបាកយល់ ឬដោយសារការបកប្រែសក្ខីកម្មទាំងនោះ មិនត្រឹមត្រូវ ។

[២៦៣] អ៊ីម៉ែលឆ្លើយឆ្លងកាលពីថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០០៩ អង្គភាពបកប្រែ ។

[២៦៤] ជាឧទាហរណ៍ សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ២, ៣, ៩, ១០, ១១, និង ១២ ។

[២៦៥] សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហមលេខ ៧ ។

[២៦៦] ការពន្យាពេលការធ្វើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី **អ៊ូ សាវិទ្ធិ** នៅសប្តាហ៍ទី១៨ និង ភាពរអាក់រអួលនៃប្រព័ន្ធបច្ចេកទេសកំឡុងពេលសក្ខីកម្មរបស់ លោក Justice Goldstone និង Stephane Hessel នៅសប្តាហ៍ទី ២១។ សូមមើល របាយការណ៍អ្នកឃ្លាំ មើលតុលាការខ្មែរក្រហម សប្តាហ៍ទី ១៨ និង ២១ ។

## គ. ការចូលរួមពីសាធារណៈជន

### ១. វត្តមានរបស់សាធារណៈជន

អង្គភាពកិច្ចការសារធារណៈរបស់តុលាការបានឱ្យដឹងថា ប្រជាជនប្រមាណជា ២៧,០០០នាក់ និង អ្នកកាសែតជាង ៣,០០០នាក់ បានចូលរួមដំណើរការសវនាការនៅក្នុងសំណុំរឿងក្តីលេខ ០០១ ។ ទាំងអង្គភាពកិច្ចការសាធារណៈ និងអង្គការសង្គមស៊ីវិលបានជួយសម្របសម្រួលប្រជាពលរដ្ឋពីបណ្តាស្រុក/ខេត្តផ្សេងៗ ឱ្យចូលរួមសវនាការនេះ តាមរយៈរៀបចំការដឹកជញ្ជូន ។ អង្គភាពកិច្ចការសាធារណៈ បានធ្វើការណែនាំពន្យល់ប្រជាពលរដ្ឋជាមុនខ្លះៗ អំពីរបៀបបែបបទនៅក្នុងសាលសវនាការ និងព័ត៌មានមួយចំនួននៃសំណុំរឿងក្តី ។[២៦៧] បន្ថែមជាងនេះ អង្គភាពកិច្ចការសាធារណៈ ក៏បានយកចិត្តទុកដាក់អញ្ជើញប្រជាពលរដ្ឋពីតំបន់ដាច់ស្រយាល ឱ្យចូលរួមសវនាការនេះផងដែរ ។[២៦៨]

### ២. បរិក្ខាផ្សេងៗសម្រាប់សាធារណៈជន (Public Facilities)

បរិក្ខាផ្សេងៗសម្រាប់សាធារណៈជន មិនមានចំនួនគ្រប់គ្រាន់ឆ្លើយតបទៅនឹងការកើនឡើងយ៉ាងខ្លាំងនៃអ្នកចូលរួមតាមដានទស្សនាសវនាការទេ ។ លោក **រាជ សម្បត្តិ** ប្រធានអង្គភាពកិច្ចការសាធារណៈ បានទទួលស្គាល់បញ្ហានេះ ហើយដើម្បីដោះស្រាយបញ្ហានេះ តុលាការបានខិតខំពង្រីកអាហារដ្ឋានធំជាងមុន ៣ដង ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃអ្នកចូលរួម ។[២៦៩] លោកបានបន្ថែមថា ការតំឡើងទូរទស្សន៍បន្ថែមនៅអាហារដ្ឋាន ដើម្បីឱ្យអ្នកចូលរួម ដែលមិនអាចរកកន្លែងអង្គុយនៅក្នុងបន្ទប់សវនាការ ក៏អាចតាមដានការជំនុំជម្រះបាន ទោះបីជា ការរៀបចំនេះធ្វើឡើងនៅពេលជិតបញ្ចប់សវនាការសំណុំរឿងក្តីលេខ ០០១ ក៏ដោយ ។[២៧០] ច្រកចេញ-ចូលតែមួយ និងការឆែកឆេរត្រួតពិនិត្យពីអ្នកចូលរួមសវនាការសារធារណៈ បណ្តាលឱ្យមានការកកស្ទះ ជាពិសេសកំឡុងពេល សម្រាកពេលព្រឹក និងពេលរសៀល ។ ចំណែកឯ បន្ទប់ទឹកក៏មានចំនួនមិនគ្រប់គ្រាន់ផងដែរ ។[២៧១] ចំពោះបញ្ហានេះ លោក **រាជ សម្បត្តិ** បានឱ្យដឹងថា តុលាការមានផែនការដោះស្រាយ ប៉ុន្តែត្រូវចាំមើលលើថវិការដែលផ្នែករដ្ឋបាលនឹងចាត់ចែងមកឱ្យសិន ។[២៧២]

## ឃ. វត្តមាន និង សកម្មភាពរបស់ភាគី

ជាទូទៅ ភាគីទាំងអស់មានវត្តមានជាប់ជានិច្ចនៅក្នុងសវនាការ ។ ទោះបីជា មេធាវីការពារក្តីអន្តរជាតិលោក François Roux អវត្តមានជាច្រើនលើក ដែលដំបូងឡើយ អវត្តមានរបស់លោកបានជះឥទ្ធិពលមិនល្អ

---

[២៦៧] បទសម្ភាសន៍ជាមួយប្រធានអង្គភាពកិច្ចការសាធារណៈលោក **រាជ សម្បត្តិ** ។

[២៦៨] បទសម្ភាសន៍ជាមួយប្រធានអង្គភាពកិច្ចការសាធារណៈលោក **រាជ សម្បត្តិ** ។

[២៦៩] បទសម្ភាសន៍ជាមួយប្រធានអង្គភាពកិច្ចការសាធារណៈលោក **រាជ សម្បត្តិ** ។

[២៧០] បទសម្ភាសន៍ជាមួយប្រធានអង្គភាពកិច្ចការសាធារណៈលោក **រាជ សម្បត្តិ ។**

[២៧១] បន្ទប់ទឹកសាធារណៈ មានចំនួនតែ៥ប៉ុណ្ណោះ សម្រាប់បុរស និងស្ត្រី ។

[២៧២] បទសម្ភាសន៍ជាមួយប្រធានអង្គភាពកិច្ចការសាធារណៈលោក **រាជ សម្បត្តិ** ។

ចំពោះការការពារសិទ្ធិជនជាប់ចោទ ។[២៧៣] នៅសប្ដាហ៍ទី៥ កំឡុងពេលមេធាវី Roux អវត្តមាន **ឌុច** ហាក់ដូចជាដើរតួជាមេធាវីការពារខ្លួនឯង ដោយសារតែមេធាវីការពារក្ដីជាតិពុំមានធ្វើសកម្មភាពណាមួយឡើយ ។[២៧៤] ប៉ុន្តែពេលក្រោយមកមេធាវីការពារក្ដីជាតិ ហាក់ដូចជាសកម្មជាងមុន នៅពេលដែលមេធាវី Roux អវត្តមាន ។

ការិយាល័យសហព្រះរាជអាជ្ញា បានធ្វើការប្ដូរវេនអ្នកតំណាងនៅក្នុងសវនាការជាញឹកញាប់ ព្រោះទទួលភារកិច្ចផ្សេងៗគ្នាក្នុងសំណុំរឿង ។ សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទីលោក William Smith បានកត់សម្គាល់ថា ការផ្លាស់ប្ដូរវេននេះ គឺទៅតាមការបែងចែកការងារក្នុងសំណុំរឿងរបស់តំណាងសហព្រះរាជអាជ្ញាម្នាក់ៗ ហើយក៏ជាការអនុវត្តទូទៅក្នុងរឿងក្ដីឧក្រិដ្ឋធំៗផងដែរ ។[២៧៥] ការិយាល័យសហព្រះរាជអាជ្ញា អាជ្ញានៅតុលាការអន្តរជាតិជាច្រើនតែងតែចាត់តាំងតំណាង ដែលមានបទពិសោធន៍ខ្ពស់យ៉ាងហោចណាស់ ១រូប ចូលរួមជាប្រចាំក្នុងកិច្ចដំណើរការសវនាការ ដើម្បីគ្រប់គ្រងសំណុំរឿងឱ្យបានមត់ចត់ និងមានប្រសិទ្ធិភាព ។ ប៉ុន្តែគេមិនឃើញមានការរៀបចំបែបនេះទេនៅការិយាល័យសហព្រះរាជអាជ្ញាក្នុងដំណើរការជំនុំជម្រះក្ដី **ឌុច** ទេ ។ ហេតុដូច្នេះហើយ បានជាគេកត់សម្គាល់ថា ក្នុងការិយាល័យនេះ ហាក់ដូចខ្វះការសម្របសម្រួលរវាងតំណាងសហព្រះរាជអាជ្ញាដែលទទួលភារៈកិច្ចផ្សេងៗគ្នាក្នុងសំណុំរឿង នៅពេលដែលពួកគេផ្លាស់វេនចូលរួមសវនាការ ។ ជាក់ស្ដែង នៅសប្ដាហ៍ទី២០ តំណាងសហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងសំណើដែលបានគិតថា មេធាវីការពារក្ដីបានស្នើកាលពីថ្ងៃមុន ប៉ុន្តែតាមការពិតសំណើនោះមេធាវីការពារក្ដីមិនបានលើកឡើងនោះទេ ។[២៧៦] លោក Smith បានទទួលស្គាល់ថា ពិតជាមានបញ្ហានេះមែន ប៉ុន្តែមិនមែនដោយសារប្រព័ន្ធនៃការប្ដូរវេនគ្នាទេ ។ លោកបានលើកឡើងពីការលាលែងតំណែងរបស់តំណាងសហព្រះរាជអាជ្ញាចំនួន ៤រូប ក្នុងនោះរួមទាំងលោក Robert Petit ផងដែរ កំឡុងពេលសវនាការថា ជាបញ្ហាដែលនាំឱ្យមានការលំបាកក្នុងការអនុវត្តប្រពន្ធ័នេះ ។[២៧៧]

## ខ. បទពិសោធន៍ទទួលបានពីការគ្រប់គ្រងសវនាការ

ជារួម គេគួរតែកោតសរសើរក្រុមប្រឹក្សានៃអង្គជំនុំជម្រះ ចំពោះការខិតខំប្រឹងប្រែងនៅក្នុងសំណុំរឿងក្ដីលេខ 00១ ។ សវនាការបានដំណើរការដោយប្រសិទ្ធិភាពខ្ពស់ ហើយអង្គជំនុំជម្រះបានបំពេញការងារដោយរលូន និងមានសហប្រតិបត្តិការពីភាគីក្នុងសំណុំរឿងក្ដីលេខ 00១ ។ ទោះជាយ៉ាងណាក៏ដោយ បើពិនិត្យមើលពីភាពស្មុគ

---

[២៧៣] សូមមើលចំណុចទី ១៣ នៃ http://www.eccc.gov.kh/english/court_doc.list.aspx?courtDocCat=tc_docs ដែលចង្អុលបង្ហាញពីកាលវិភាគសវនាការ ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២00៩ ។ សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម សប្ដាហ៍ទី ៥ ។

[២៧៤] សូមមើលរបាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ៥, និង៨ ។ ជនជាប់ចោទបានធ្វើការជំទាស់ដោយផ្ទាល់ទៅនឹងសំណួរដោយមិនឆ្លើយដោយសំអាងថា សំណួរទាំងនោះជាសំណួរមិនពាក់ព័ន្ធ និងច្រំដែល ហើយស្នើសុំឯកសារបន្ថែមនៅពេលសួរដោយភាគី ។

[២៧៥] បទសម្ភាសន៍ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ លោក William Smith

[២៧៦] សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ២0 ។

[២៧៧] បទសម្ភាសន៍ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ William Smith

ស្ទាញនៃសំណុំរឿងនេះ អង្គជំនុំជម្រះគួរដកបទពិសោធន៍អំពីការគ្រប់គ្រងសវនាការនេះ ។ ក្នុងសវនាការដែលមានជនជាប់ចោទច្រើន ពួកគេអាចនឹងធ្វើការតវ៉ាពីការចោទប្រកាន់មកលើខ្លួន ដែលក្នុងស្ថានភាពនេះអង្គជំនុំជម្រះត្រូវគ្រប់គ្រងសវនាការដោយម៉ឺងម៉ាត់ និងប្រកបដោយយុត្តិធម៌ ។ ក្នុងនោះត្រូវមានភាពស្របគ្នារវាងសេចក្ដីណែនាំ ហើយត្រូវចេញសេចក្ដីសម្រេចដោយមានសំអាងហេតុច្បាស់លាស់ ។ ក្នុងសំណុំរឿងក្ដីលេខ ០០១ អង្គជំនុំជម្រះបានប្រឹងប្រែងគោរពតាមគោលការណ៍នេះ ។ ដំណើរការសវនាការសំណុំរឿងក្ដីលេខ ០០២ នឹងប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធិភាព ហើយតុលាការនេះអាចនឹងក្លាយទៅជាគំរូដ៏ល្អសម្រាប់តុលាការកម្ពុជា ប្រសិនបើគេអនុវត្តគោលការណ៍នេះបានខ្ជាប់ខ្ជួន ។ បន្ថែមលើនេះ ការបង្អាក់សំណួរ និងសក្ខីកម្មមិនពាក់ព័ន្ធ ឬច្រំដែល និងជួយបង្កើនល្បឿន ព្រមទាំងប្រសិទ្ធិភាពដំណើរការនីតិវិធីសវនាការផងដែរ ។

ក្រុមឃ្លាំមើលតុលាការ បានស្នើសុំឱ្យតុលាការខិតខំប្រឹងប្រែងន្ថែមទៀត ដើម្បីធានាឱ្យមានធនធានហិរញ្ញវត្ថុផ្ដល់ដល់អង្គភាពកិច្ចការសាធារណៈ ក្នុងការរៀបចំឱ្យប្រជាពលរដ្ឋខ្មែរអាចចូលរួមតាមដានទស្សនាសវនាការ ។ ទោះបីជាយ៉ាងណា ការអញ្ជើញប្រជាពលរដ្ឋឱ្យចូលរួម គួរតែឱ្យស្របទៅនឹងស្ថានភាពជាក់ស្ដែងរបស់តុលាការ ព្រោះកន្លងមកធ្លាប់មានការអញ្ជើញប្រជាពលរដ្ឋឱ្យចូលរួមមានចំនួនច្រើនជាងកន្លែងអង្គុយក្នុងសាលសវនាការ ដែលគេមើលឃើញថាហាក់ដូចជាមិនសូវសមរម្យ ។

បើពិនិត្យមើលពីតួនាទីដ៏សំខាន់នៃការធានាឱ្យមានភាពយុត្តិធម៌ គួរតែខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធានាឱ្យគុណភាពនៃការបកប្រែឯកសារ និងការបកប្រែផ្ទាល់មាត់ក្នុងសវនាការឱ្យកាន់តែប្រសើរឡើង ។ ដោយសារឯកសារភស្តុតាង និងអង្គហេតុដែលបានធ្វើការដេញដោលនៅក្នុងសវនាការ គឺជាមូលដ្ឋានតែមួយគត់ ដែលអង្គជំនុំជម្រះនឹងយកមកធ្វើការវិនិច្ឆ័យក្ដី ជាការចាំបាច់ណាស់ក្នុងធានាឱ្យមានភាពត្រឹមត្រូវនៃការបកប្រែ ។ កិច្ចខិតខំប្រឹងប្រែងដ៏គួរឱ្យកោតសរសើរ ដែលអង្គភាពបកប្រែមានគម្រោងពង្រឹងសមត្ថភាពបុគ្គលិករបស់ខ្លួន ។ ប៉ុន្តែចាំបាច់ត្រូវយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីធានាថាកំហុសនៃការបកប្រែឈានដល់កម្រិតតិចបំផុត ។

ជាទីបញ្ចប់ ការិយាល័យសហព្រះរាជអាជ្ញា ចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងនូវរបៀបគ្រប់គ្រងរឿងក្ដីរបស់ខ្លួន ។ ហើយត្រូវមានកិច្ចខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធានាឱ្យមានការសម្របសម្រួលរវាងតំណាងសហព្រះរាជអាជ្ញា និងកាត់បន្ថយការចាកចេញរបស់បុគ្គលិក ។ វិធានការទាំងនេះមានសារៈសំខាន់ណាស់ ជាពិសេស នៅក្នុងសវនាការដែលមានភាពស្មុគស្មាញជាងសំណុំរឿងក្ដីលេខ ០០១ ដែលមានជនជាប់ចោទតែម្នាក់ ហើយបានទទួលសារភាពអំពីការទទួលខុសត្រូវរបស់ខ្លួនជាច្រើនក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ។

# សេចក្តីសន្និដ្ឋាន

សវនាការសំណុំរឿងក្តីលេខ ០០១ មានដំណើរការទៅយ៉ាងរលូន និងប្រកបដោយប្រសិទ្ធិភាព ។ ក្នុងនោះ ទាំងអង្គជំនុំជម្រះ និងភាគីបានបំពេញតួនាទីរបស់ខ្លួនយ៉ាងគួរឱ្យកោតសរសើរ ។ ចំពោះការលំបាកជាច្រើន ដូចជាភាពស្មុគស្មាញ និងទំហំនៃរឿងក្តី ព្រមទាំងស្ថានភាពរបស់តុលាការ ចៅក្រមចាំបាច់ត្រូវអនុវត្តគោលការណ៍ទៅតាមស្ថានភាពជាក់ស្តែងដែលធ្លាប់បានធ្វើកន្លងមក ដើម្បីធានាថា សវនាការជំនុំជម្រះក្តី **ឌុច** បានប្រព្រឹត្តទៅដោយយុត្តិធម៌ និងមានប្រសិទ្ធិភាព ។ បន្ថែមលើនេះ ក្នុងស្ថានភាព និងនីតិវិធីថ្មី ដែលភាគីកំពុងអនុវត្តគួរត្រូវធ្វើយ៉ាងណាឱ្យមានការសហការ និងការសម្របសម្រួលរវាងភាគីទាំងអស់ ដើម្បីធ្វើឱ្យសវនាការដំណើរការប្រកបទៅដោយភាពជោគជ័យ ។ កិច្ចខំប្រឹងប្រែងរបស់អង្គភាពបកប្រែ អង្គភាពគ្រប់គ្រងកិច្ចការទូទៅ អង្គភាពកិច្ចការសាធារណៈ និងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ត្រូវបានទទួលស្គាល់ថា បានចូលរួមចំណែកធ្វើឱ្យការជំនុំជម្រះក្តីនេះគោរពតាមមាត្រដ្ឋានយុត្តិធម៌អន្តរជាតិ ។

ដូចដែលមានរៀបរាប់នៅក្នុងរបាយការណ៍នេះ បើទោះបីជា ការជំនុំជម្រះបានទទួលជោគជ័យក្នុងកម្រិតមួយក៏ដោយ គេឃើញមានបញ្ហាសំខាន់ៗមួយចំនួន គួរធ្វើការកែលម្អនៅក្នុងនីតិវិធីតុលាការនេះ ។ ជាពិសេសបែបបទក្នុងការរៀបចំធ្វើសក្ខីកម្មចំពោះមុខតុលាការ សម្រាប់សំណុំរឿងក្រោយៗគួរតែត្រួតពិនិត្យឡើងវិញ ដើម្បីកាត់បន្ថយសំណួរច្រំដែល និងសំណួរមិនពាក់ព័ន្ធអង្គហេតុ ឱ្យស្ថិតនៅកម្រិតតិចបំផុត ។ បន្ថែមលើនេះ ចៅក្រមនៃអង្គជំនុំជម្រះ ត្រូវខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីជៀសវាងការចេញសេចក្តីសម្រេចដែលគ្មានមូលដ្ឋានច្បាស់លាស់ និងដើម្បីធានាឱ្យមានប្រសិទ្ធិភាពជាងមុនក្នុងការបញ្ឈប់សំណួរដែលមិនពាក់ពន្ធ័ ឬច្រំដែល ពីភាគី និងចៅក្រម ។ ចំពោះការិយាល័យសហព្រះរាជអាជ្ញា ចាំបាច់ត្រូវមានការសម្របសម្រួលបន្ថែមទៀត ដើម្បីឱ្យការប្តូរវេនរបស់តំណាងសហព្រះរាជអាជ្ញាមានប្រសិទ្ធិភាព ហើយជួយពង្រឹងតួនាទីសហព្រះរាជអាជ្ញាក្នុងសវនាការ ។ ចំណែកភាគីការពារក្តី បើពិនិត្យមើលពីព្រឹត្តិការណ៍ដ៏គួរឱ្យភ្ញាក់ផ្អើលចំពោះការផ្លាស់ប្តូរគោលជំហរ **ឌុច** នៅពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់នោះ ការកំណត់ឱ្យជនជាប់ចោទតែងតាំងមេធាវីនាំមុខម្នាក់ក្នុងចំណោមសហមេធាវីការពារក្តីទាំងពីររូប គឺចាំបាច់ដើម្បីធានាឱ្យមានភាពស្របគ្នានៃយុត្តិសាស្ត្រការពារក្តី ។ លើសពីនេះ ត្រូវឱ្យមានការសម្របសម្រួលបន្ថែមទៀតរវាងសហមេធាវីការពារក្តី ។ ក្នុងចំណោមអង្គភាពផ្សេងៗ របស់តុលាការដែលជួយដល់ដំណើរការជំនុំជម្រះ មូលនិធិសម្រាប់ការផ្តល់ជំនួយផ្លូវចិត្ត គួរតែជាអទិភាព ហើយដូចគ្នានេះដែរគួរតែមានការខិតខំបន្ថែមទៀត ដើម្បីឱ្យការបកប្រែប្រព្រឹត្តទៅដោយឆាប់រហ័ស និងមានគុណភាព អាចទទួលយកបាន ហើយបញ្ហាដ៏សំខាន់បំផុតក្នុងតុលាការនេះ ទំនងជាការកំណត់ឱ្យបានច្បាស់លាស់ជាងនេះ ពីតួនាទីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងការការពារផលប្រយោជន៍របស់ជនរងគ្រោះឱ្យបានច្រើនជាងមុន ។ អង្គជំនុំជម្រះបានបង្ហាញយ៉ាងច្បាស់ថា ពួកគេចាត់ទុកបញ្ហានេះ គឺជាបញ្ហាអាទិភាព ហើយអង្គជំនុំជម្រះនឹងធ្វើវិសោធនកម្មវិធានផ្ទៃក្នុងរបស់តុលាការក្នុងចំណុចនេះ ។ *"មេរៀនដកពិសោធន៍"* ដ៏សំខាន់ពីសំណុំរឿងក្តីលេខ ០០១ ប្រហែលជាថា

ប្រសិនបើមានការកែប្រែណាមួយនោះ គេគួរតែពិភាក្សាឱ្យបានជិតស្និតជាមួយមេធាវីតំណាងដើមណ្តឹងរដ្ឋប្បវេណី និងអង្គការអន្តរការី ដើម្បីធានាឱ្យមានការសម្របសម្រួលច្រើនជាងមុន ចំពោះការចូលរួម និងការការពារផលប្រយោជន៍កូនក្តីខ្លួន ។ បន្ថែមលើនេះ ការសម្របសម្រួលការទំនាក់ទំនងរវាងមេធាវី និងកូនក្តីបន្ថែមទៀត និងការធានាថា ការធ្វើវិសោធនកម្មវិធានផ្ទៃក្នុងបានពិចារណាអំពីតម្រូវការរបស់មេធាវីក្នុងការជួបប្រជុំជាមួយកូនក្តីទំនងជាអាចជួយសម្រួលដល់ដំណើរការនីតិវិធីក្នុងសំណុំរឿងក្រោយ ។ ក្រៅពីនេះ ចាំបាច់ត្រូវគិតគូរបន្ថែមទៀតក្នុងការកំណត់ឱ្យបានច្បាស់លាស់អំពីសំណងសមូហភាព និងសំណងផ្លូវចិត្ត ហើយរិះរកវិធីសាស្ត្រ ដើម្បីអនុវត្តសំណងទាំងនេះឱ្យមានប្រសិទ្ធិភាពនៅ អ.វ.ត.ក ។

ជាងនេះទៀត គេគួរតែខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការចាត់វិធានការណាមួយកំណត់អំពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការ និងការធ្វើឱ្យប្រសើរឡើងនូវនីតិវិធីនៃការចូលរួមរបស់ពួកគេ ដើម្បីធានាឱ្យជនរងគ្រោះទទួលបានព័ត៌មានបន្ថែមទៀតពីតុលាការ និងដំណើរការស្វែងរកយុត្តិធម៌ដែលពួកគេអាចនឹងទទួលបាន ។ អង្គភាពជនរងគ្រោះ គួរត្រូវប្រកាន់យកតួនាទីច្រើនជាងនេះ ដើម្បីធានាឱ្យមានវិធានការបន្ថែមទៀត ក្នុងការសម្រួលឱ្យគេទទួលបានព័ត៌មានអំពីដំណើរការតុលាការ និងការស្វែងរកយុត្តិធម៌កាន់តែច្រើន ។ ប៉ុន្តែទន្ទឹមពេលនេះដែរ គេគួរតែគិតគូរយកចិត្តទុកដាក់នូវអ្វីដែលជនរងគ្រោះចង់បានអំពីដំណើរការនេះ ។ ការធ្វើឱ្យមានតុល្យភាពរវាងបញ្ហាទាំងពីរនេះទំនងជាកិច្ចការដ៏លំបាក ប៉ុន្តែវាជាបញ្ហាសំខាន់ ប្រសិនបើតុលាការចង់ធ្វើជាផ្នែកមួយនៃដំណើរការផ្សះផ្សាជាមួយអតីតកាលដ៏ជូចត់នៅក្នុងប្រទេសកម្ពុជា តុលាការចាំបាច់ត្រូវការធានាឱ្យប្រជា-ពលរដ្ឋអាចយល់ដឹងឱ្យបានច្រើនពីដំណើរការរបស់ខ្លួន ។

ការប្រឈមមុខនឹងអ្វីដែលប្រជាពលរដ្ឋចង់បានពី អ.វ.ត.ក មិនមែនជារឿងងាយស្រួលនោះទេ ។ គោលដៅពីរក្នុងការធានាថា តុលាការនេះនឹងគោរពតាមមាត្រដ្ឋានយុត្តិធម៌អន្តរជាតិ អាចនឹងក្លាយជានិមិត្តរូបដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់ៗរូប គឺជាភារកិច្ចដ៏លំបាកក្នុងការសម្រេចឱ្យបាននៅក្នុងបរិបទដែលខ្លួនកំពុងតែអនុវត្ត ។ ប៉ុន្តែ អតីតអ្នកទោសនៅមន្ទីរ ស-២១ លោក **វ៉ាន់ ណាត់** ដែលបានផ្តល់សក្ខីកម្មក្នុងសវនាការជម្រះក្តី **ឌុច** បានលើក ឡើងថា *"អ្វីដែលខ្ញុំចង់បាននោះ គឺរបស់ដែលមើលមិនឃើញ ហើយនោះគឺជាយុត្តិធម៌... ខ្ញុំសង្ឃឹមថា យុត្តិធម៌ នឹងមានរូបរាងពិតប្រាកដ ហើយមនុស្សគ្រប់រូបអាចមើលឃើញ"* ។[២៧៨] ការដោះស្រាយឱ្យមានយុត្តិធម៌ដែលគេ អាចមើលឃើញ និងយុត្តិធម៌ផ្លូវចិត្តដែលប្រជាជនកម្ពុជារង់ចាំជាយូរមកហើយនោះ នៅតែបន្តជាបញ្ហាប្រឈមសម្រាប់តុលាការ ។ ប៉ុន្តែ ប្រសិនបើ អ.វ.ត.ក ចង់បន្សល់ទុកនូវកេរ្តិ៍តំណែល ដែលអាចឱ្យប្រជាជនកម្ពុជា *"អាចឈានឆ្ពោះទៅមុខ"* បញ្ហានេះប្រហែលជាអទិភាពសំខាន់បំផុត ។

[២៧៨] សូមមើល របាយការណ៍អ្នកឃ្លាំមើលតុលាការខ្មែរក្រហម លេខ ១១ ។

## ក្របខាងក្រោយ

**គម្រោងផ្ដួចផ្ដើមយុត្តិធម៌អន្តរជាតិអាស៊ី** (Asian International Justice Initiative [AIJI]) **គឺជាគម្រោងមួយដែលកើតឡើងដោយកិច្ចសហការរវាង** East West Center, Honolulu and University of California, Berkeley War Crimes Studies Center ។ **កម្មវិធីឃ្លាំមើលដំណើរការសាលាក្ដីខ្មែរក្រហមរបស់គម្រោងនេះត្រូវបានបង្កើតឡើងក្នុង ឆ្នាំ២០០៨ ដើម្បីជួយសម្រួលដល់ការវិភាគ និងការជជែកពិភាក្សាក្នុងតំបន់ស្ដីពីកិច្ចដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ របាយការណ៍នេះ បង្ហាញលម្អិតអំពីដំណើរការសវនាការជម្រះក្ដីជនជាប់ចោទ** ***កាំង ហ្គេចអ៊ាវ*** **ហៅ ឌុច ដែលជាស្នាដៃរយៈពេល ១០ខែរបស់ក្រុមឃ្លាំមើលតុលាការខ្មែរក្រហមក្នុងកម្មវិធីនេះ ។**

រូបភាពក្របមុខនៃរបាយការណ៍នេះគឺ ជាស្នាដៃច្នៃប្រឌិតរបស់ជាងគំនូរដ៏ល្បីនៅប្រទេសកម្ពុជា លោក **វ៉ាន់ ណាត** ដែលជាអ្នករស់រានមានជីវិតពីមន្ទីរ ស-២១ ហើយក៏ជាសាក្សីម្នាក់ក្នុងដំណើរការសវនាការជំនុំជម្រះក្ដី **ឌុច** ផងដែរ ។ នៅផ្នែកពណ៌ "ខ្មៅ" នៃរូបភាពនេះតំណាងឱ្យទុក្ខលំបាកវេទនា និងការឈឺចាប់ ដែលប្រជាជនកម្ពុជាបានទទួលរងក្នុងរបបខ្មែរក្រហម ។ ចំណែកឯផ្នែកពណ៌ "ស" តំណាងឱ្យសុខសន្តិភាព និងការផ្សះផ្សាជាតិ ។ រូបភាព *"មនុស្សលើកដៃសំពះ"* បង្ហាញពីការអំពាវនាវចង់បានយុត្តិធម៌ ដែលប្រជាជនកម្ពុជាទន្ទឹងរង់ចាំអស់រយៈកាលជាង ៣០ឆ្នាំ មកហើយ ។